ខុមហ្វ្រែល COMFREL

# គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

# របាយការណ៍ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ឆ្នាំ២០១៣









ធ្នូ ២០១៣

# មាតិកា

១. សង្ខេបការរកឃើញ ....4

១.១ មុនការបោះឆ្នោត....4

១.២ អំឡុងពេលបោះឆ្នោត....6

១.៣ ក្រោយពេលបោះឆ្នោត ....8

២. ការវាយតម្លៃទៅលើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ឆ្នាំ២០១៣ ....11

៣. ក្របខណ្ឌច្បាប់....13

៣.១. ការដោះស្រាយវិវាទ....14

៣.២.ប្រព័ន្ធបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ....14

៣.៣. បទបញ្ញា និងនីតិវិធីរបស់ គ.ជ.ប....15

៤. ការជ្រើសរើសសមាជិកគណកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត(PEC) និងការគណកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត(CEC)....18

៥. ការរៀបចំការបោះឆ្នោត....20

៥.១ ការចុះឈ្មោះ និងសម្អាតបញ្ជីឈ្មោះបោះឆ្នោត....20

៥.២ ការចុះឈ្មោះបេក្ខជនគណបក្សនយោបាយ....22

៥.៣ ការបែងចែកប័ណ្ណព័ត៌មានបោះឆ្នោត ....22

៥.៤ លិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត ....24

៥.៥ ការឃោសនារបស់គណបក្សនយោបាយ ....25

៥.៦ ថ្ងៃបោះ និងរាប់សន្លឹកឆ្នោត....27

៥.៧ ការរាប់សន្លឹកឆ្នោត និងលទ្ធផលបោះឆ្នោត ....32

៦. ប្រព័ន្ធផ្សព្វផ្សាយ....33

៦.១ ការរំលោភក្រមសីលធម៌ និងបទបញ្ញារបស់គ.ជ.ប....33

៦.២ ការទទួលបានការផ្សព្វផ្សាយជាពិសេសទូរទស្សន៍ និងវិទ្យុ....36

៦.៣ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងហ្វេសបុក.....42
៧. ការទិញទឹកចិត្ត និងការចំណាយរបស់គណបក្សនយោបាយ.....44
៧.១ ការទិញទឹកចិត្ត.....44
៧.២ ការចំណាយរបស់គណបក្សនយោបាយ.....44
៨. ការប្រើប្រាស់ធនធានរដ្ឋ.....44
៩. ការទទួល និងដោះស្រាយបណ្តឹង.....49
៩.១ ដំណើរការដោះស្រាយបណ្តឹង.....50
៩.២ បណ្តឹងកំឡុងពេលឃោសនាបោះឆ្នោត.....51
៩.៣ បណ្តឹងអំឡុងពេលបោះ និងរាប់សន្លឹកឆ្នោត.....52
៩.៤ បណ្តឹងទាក់ទងទៅនឹងលទ្ធផលបណ្តោះអាសន្ន.....53
៩.៥ ការដោះស្រាយបណ្តឹងតវ៉ាទាក់ទងទៅនឹងលទ្ធផលបណ្តោះអាសន្នដោយគ.ជ.ប.....54
៩.៦ បណ្តឹង និងការដោះស្រាយជំលោះលទ្ធផលបោះឆ្នោតដោយក្រុមប្រឹក្សាធម្មនុញ្ញ.....57
១០. លទ្ធផលបោះឆ្នោត ការផ្ទៀងផ្ទាត់ និងការវិភាគ.....62
១០.១ ការផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោត.....62
១០.២ ការពិព័ណ៌នាលទ្ធផលបោះឆ្នោត.....66
១០.៣ បេក្ខជនស្ត្រីជាប់ឆ្នោត.....68
១០.៤ យុវជនជាប់ឆ្នោត.....68
១១. ការចូលរួមរបស់ប្រជាពលរដ្ឋ និងការបាត់បង់សិទ្ធិបោះឆ្នោត.....69
១១.១ ការចូលរួមរបស់ស្ត្រី និងការបាត់បង់សិទ្ធិ.....69
១១.២ ការចូលរួមរបស់យុវជនក្នុងការបោះឆ្នោត.....70
១១.៣ ការចូលរួមរបស់ក្រុមជនដែលត្រូវបានបណ្តេញចេញពីលំនៅដ្ឋាន.....71
១១.៤ ការចូលរួមរបស់ជនពិការក្នុងការបោះឆ្នោត.....72
១១.៥ ការចូលរួមរបស់ជនជាតិដើមភាគតិច.....75
១១.៦ អ្នកចេញទៅបោះឆ្នោត និងការបាត់បង់សិទ្ធិ.....76

១២. ការចូលរួមរបស់គណបក្សនយោបាយ.....79

១២.១ ការថយចុះចំនួនគណបក្សនយោបាយក្នុងការប្រកួតប្រជែង.....79

១២.២ ការកើនឡើងនៃចំនួនបេក្ខជនស្ត្រី.....80

១៣. ការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការសង្កេតការណ៍បោះឆ្នោត.....82

១៣.១ អ្នកសង្កេតការណ៍ជាតិ.....82

១៣.២ អ្នកសង្កេតការណ៍អន្តរជាតិ.....82

១៤. ទំនាស់ក្រោយពេលបោះឆ្នោត.....83

១៥. ការផ្លាស់ប្តូរអំណាចៈ ការបង្កើតសភា និងរដ្ឋាភិបាល.....88

១៥.១ ការបង្កើតរដ្ឋសភា.....88

១៥.២ ការតែងតាំងថ្នាក់ដឹកនាំរដ្ឋសភា និងរាជរដ្ឋាភិបាល.....91

១៦. អនុសាសន៍របស់ខុមហ្វ្រែល និងបន្ទប់ស្ថានការណ៍ស្តីពីយន្តការកំណែទម្រង់ការបោះឆ្នោត.....92

១៦.១. យន្តការកំណែទម្រង់បោះឆ្នោត.....93

១៦.២ អនុសាសន៍សំខាន់ៗសម្រាប់ការពិភាក្សា.....94

ឧបសម្ព័ន្ធទី១៖ សេចក្តីថ្លែងការណ៍របស់គណបក្សប្រជាជនកម្ពុជា.....98

ឧបសម្ព័ន្ធទី២៖ សេចក្តីថ្លែងការណ៍របស់គណបក្សសង្គ្រោះជាតិ.....100

ឧបសម្ព័ន្ធទី៣៖ សេចក្តីប្រកាសរួមនៃជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ 101

ឧបសម្ព័ន្ធទី៥៖ ការឆ្លើយតបរបស់ខុមហ្វ្រែលទាក់ទងទៅនឹងសៀវភៅសរបស់គ.ជ.ប.....102

ឧបសម្ព័ន្ធទី៦៖ កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ នៃការបោះឆ្នោតឆ្នាំ២០១៣.....106

ឧបសម្ព័ន្ធទី៧៖ សេចក្តីថ្លែងការណ៍រួមរបស់បន្ទប់ស្ថានការណ៍.....120

# របាយការណ៍ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
# នីតិកាលទី៥ ឆ្នាំ២០១៣

## ១. សង្ខេបការរកឃើញ

### ១.១ មុនការបោះឆ្នោត

មានបរិយាកាសបំភិតបំភ័យ និងការរំលោភសិទ្ធិ បំពានទៅលើអ្នកនយោបាយ និងអ្នកតំណាងរាស្ត្រ គណបក្សប្រឆាំងដែលបានកើតឡើងយ៉ាងគំហុកនៅក្នុងរយៈពេល៥ខែ ដើមឆ្នាំ២០១៣ ជាពិសេសនៅក្នុងខែឧសភា ឆ្នាំ២០១៣។

យោងតាមការសង្កេត តាមដាន ស្ថានភាពនយោបាយ និងរបាយការណ៍ស៊ើបអង្កេត បានកើតឡើងចាប់តាំងពីខែមករា ឆ្នាំ២០១៣ រហូតមកដល់ខែមិថុនា ឆ្នាំ២០១៣ បើទោះបីជាគ្មានអំពើហិង្សានយោបាយរហូតដល់របួស និងស្លាប់ធ្ងន់ធ្ងរ ប៉ុន្តែមានករណីគំរាមកំហែង បំភិតបំភ័យ និងការរំខានយាយីផ្នែកនយោបាយបានកើតឡើងជាបន្តបន្ទាប់ តាំងពីមូលដ្ឋានមកកំរិតថ្នាក់ជាតិ។ អាជ្ញាធរមូលដ្ឋាន ជាពិសេសមេភូមិ មេឃុំមួយចំនួនបានគំរាមលើប្រជាពលរដ្ឋណាដែលខ្លួនយល់ថា មិនមាននិន្នាការគាំទ្រគណបក្សកាន់អំណាចយ៉ាងហោច១៣ករណី([1]) ក្រោមរូបភាពដូចជា ការហាមឃាត់ប្រជាពលរដ្ឋមិនឲ្យចូលរួមស្តាប់ការប្រជុំនានាដែលរៀបចំឡើងដោយគណបក្សមិនកាន់អំណាច រំខានដល់វេទិកានានាដែលរៀបចំឡើងដោយគណបក្សផ្សេងៗប្រាប់ថា "មិនត្រូវអនុញ្ញាតឲ្យគណបក្សប្រឆាំងណាលើកស្លាកសញ្ញាគណបក្សនៅមុខផ្ទះរបស់ខ្លួននោះទេ"។ ក្នុងនោះដែរ មានការបំផ្លាញស្លាកគណបក្សនយោបាយ យ៉ាងហោចណាស់មាន៧ករណី([2]) (គិតត្រឹមខែមករា ដល់ខែឧសភា) ដូចជានៅខែឧសភា ឆ្នាំ២០១៣ នៅស្រុកពួក និងស្រុកប្រាសាទបាគង ខេត្តសៀមរាប រីឯ៣ករណីទៀតត្រូវបានកើតឡើងនៅខេត្តតាកែវ ដែលស្លាកគណបក្សសង្គ្រោះជាតិត្រូវបានបំផ្លាញ។ ចំពោះបញ្ហាកើតឡើងទាំងអស់នេះ អង្គការសង្គមស៊ីវិលបានពិនិត្យឃើញថា មិនបានចាត់វិធានការផ្លូវច្បាប់ណាមួយឲ្យបានម៉ឺងម៉ាត់ ដើម្បីនាំយកអ្នកប្រព្រឹត្តទាំងនោះទៅផ្តន្ទាទោស ដាក់ពិន័យតាមច្បាប់ឡើយ។ អង្គការសង្គមស៊ីវិលសង្កេតឃើញថា អាជ្ញាធរមូលដ្ឋានបានដើរតួនាទីមិនអព្យាក្រឹត្យក្នុងការចែកអំណោយរបស់គណបក្សប្រជាជនកម្ពុជាដូចជាសារ៉ុង និងសម្ភារៈដែលខុសនឹងច្បាប់បោះឆ្នោត ជាពិសេសក្នុងពេលឃោសនាបោះឆ្នោតអាចចាត់ទុកជាជាការទិញសន្លឹកឆ្នោត។

បរិយាកាសបំភិតបំភ័យ និងការរំលោភសិទ្ធិនៅដំណាក់កាលមុនការបោះឆ្នោតជាតិនេះ នៅមិនទាន់មានការធានាឲ្យបានពេញលេញ សេរីភាពបញ្ចេញមតិ និងទីលានប្រកួតប្រជែងស្មើគ្នាទេសម្រាប់ការប្រកួតប្រជែងការបោះឆ្នោត។ មានករណីគំរាមកំហែងផ្នែកនយោបាយទៅលើអ្នកនយោបាយ សកម្មជនគណបក្សមួយចំនួន ដូចជាករណីគំរាមប្តឹងហរបស់នាយករដ្ឋមន្ត្រីទៅលើគណបក្សប្រឆាំង ដែលបង្ហាប់លេខរៀងទី៤គណបក្សប្រជាជនកម្ពុជាថា "លេខ៤ នាំយួនចូលស្រុក" លោក គង់ គាំ និងករណីសលោក សម រង្ស៊ី ស្ថិតនៅក្រៅប្រទេស ដោយសារជាប់ករណីព្រហ្មទណ្ឌនៅក្នុងតុលាការ។ ក្រុមអង្គការសង្គមស៊ីវិលក៏មានការព្រួយបារម្ភផងដែរផលប៉ះពាល់ដល់ការបោះឆ្នោតរបស់ប្រជាពលរដ្ឋតាមឆន្ទៈដោយសេរី តាមរយៈការព្រមានរបស់

[1] យោងតាមរបាយការណ៍របស់ខុមហ្វ្រែល និងអាដហុក

[2] យោងតាមរបាយការណ៍របស់ខុមហ្វ្រែល

លោកនាយករដ្ឋមន្ត្រីហ៊ុន សែន អនុប្រធានគណបក្សប្រជាជនកម្ពុជា ការបោះឆ្នោតគាំទ្រគណបក្សប្រឆាំងដូចជាគណបក្សសង្គ្រោះជាតិជាដើមនោះ គឺនឹងបង្កឲ្យមានសង្គ្រាមផ្ទៃក្នុងប្រទេសកម្ពុជា និងសង្គ្រាមជាមួយប្រទេសជិតខាងកម្ពុជា ដែលជាការបោះឆ្នោតដើម្បីផ្ទេរពីសន្តិភាពទៅកាន់សង្គ្រាម។ មិនតែប៉ុណ្ណោះលោកនាយករដ្ឋមន្ត្រីបានលើកឡើងថា របបខ្មែរក្រហមអាចកើតឡើងម្តងទៀត ប្រសិនបើគណបក្សប្រជាជនកម្ពុជាចាញ់ឆ្នោត។ ព្រោះថាជាក់ស្តែង កងកំលាំងប្រដាប់អាវុធ មន្ត្រីនគរបាល កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ រួមទាំងអង្គរក្សរបស់នាយករដ្ឋមន្ត្រីដ៏ច្រើនសន្ធឹកសន្ធាប់មានសកម្មភាពមិនអាព្យាក្រឹត្យ មិនគោរពតាមច្បាប់គណបក្សនយោបាយ និងច្បាប់បោះឆ្នោតដែលគាំទ្រគណបក្សប្រជាជនកម្ពុជា និងប្រឆាំងគណបក្សផ្សេងៗ។

ការថ្លែងរបស់នាយករដ្ឋមន្ត្រីក្នុងការគាំទ្រឲ្យមានការធ្វើបាតុកម្មទ្រង់ទ្រាយធំ ការផ្សព្វផ្សាយទូរទស្សន៍រដ្ឋ និងឯកជនយ៉ាងខ្លាំង ដែលអាចបង្កើតកំហឹងនៅទូទាំងប្រទេសប្រឆាំងនឹងលោក កឹម សុខា(3) ដែលជាប្រធានស្តីទីគណបក្សសង្គ្រោះជាតិ និងបានបង្កើតបរិយាកាសអសន្តិសុខដល់មេដឹកនាំគណបក្សប្រឆាំងនេះ។ ជាក់ស្តែង ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ មានហ្វូងមនុស្សបានឃាត់ឡាន និងលោក កឹម សុខា។

ប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ ស៊ីធីអិន (CTN), ទូរទស្សន៍ជាតិកម្ពុជា (TVK), បាយ័នព័ត៌មាន (Bayon news) និងវិទ្យុFM105 ក្នុងអំឡុងខែមករា ដល់កុម្ភៈ ២០១៣ រកឃើញថា ទូរទស្សន៍បានផ្សព្វផ្សាយមិនសមធម៌ និងលំអៀងយ៉ាងខ្លាំងទៅរក ឬគាំទ្រមេដឹកនាំគណបក្សកាន់អំណាច ហើយប្រឆាំងមេដឹកនាំគណបក្សប្រឆាំង(4)។ ការបញ្ចេញឈ្មោះ និងមតិលោកអនុប្រធានគណបក្សប្រជាជនកម្ពុជា ហ៊ុន សែន ត្រូវបានទូរទស្សន៍ និងវិទ្យុផ្សាយរហូតដល់ជាង៤,០០០ដង ប៉ុន្តែមេដឹកនាំគណបក្សប្រឆាំងទាំងពីរនាក់លោក សម រង្ស៊ី និងលោក កឹម សុខា ត្រូវបានផ្សាយភាគច្រើនតាមវិទ្យុ FM105 បានតែ១២០០ដង ចំណែកមេដឹកនាំគណបក្សហ្វ៊ុនស៊ិនប៉ិច លោក ញ៉ិក ប៊ុនឆៃ ប្រមាណ១៧០ដងប៉ុណ្ណោះ។

ម្យ៉ាងវិញទៀត ការដកសមាជិកភាព និងបង្អាក់ប្រាក់ខែតំណាងរាស្ត្ររបស់គណបក្សនយោបាយដោយឡែកគណបក្សប្រឆាំង ដែលបង្កើតការបកស្រាយច្បាប់ និងការអនុវត្តន៍រដ្ឋធម្មនុញ្ញ(5) ក្នុងកំរិតបដិវាទធ្ងន់ធ្ងរ។ ពិសេសការពិភាក្សា និងអនុម័តច្បាប់ស្តីពី "ការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ" បានធ្វើឡើងដោយប្រញាប់ប្រញាល់ដែលគ្មានការចូលរួមពិភាក្សា និងដើម្បីបំរើផលប្រយោជន៍នយោបាយក្នុងន័យឆ្លើយតបមតិលោក កឹម សុខា ទាក់ទិនការបកស្រាយគុកទួល

(3) ការទាមទារឲ្យលោក កឹម សុខា សុំទោសចំពោះពាក្យសំដីនិយាយមិនត្រឹមត្រូវ ទាក់ទិនគុកទួលស្លែងរបស់របបខ្មែរក្រហម

(4) តាមរបាយការណ៍ខុមហ្វ្រែលទៅលើប្រព័ន្ធផ្សព្វផ្សាយ

(5) មាត្រា៩៥ ក្នុងករណីមានសមាជិក...ឬប្រាសចាកសមាជិកភាពដែលកើតឡើង៦ខែ យ៉ាងតិច មុនចប់នីតិកាល ត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះតាមលក្ខខណ្ឌក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងក្នុងច្បាប់បោះឆ្នោត។
មាត្រា៧៦៖ រដ្ឋសភាមានសមាជិកយ៉ាងតិច១២០រូប។
មាត្រា៥១៖ ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។
មាត្រា៧៧៖ តំណាងរាស្ត្រ អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ។

ស្លែង និងឧក្រិដ្ឋកម្មខ្មែរក្រហម។ ការដឹកនាំស្ថាប័នធំៗរបស់រដ្ឋទាំងមូល គឺស្ថិតនៅក្រោមគណបក្សប្រជាជនកម្ពុជាតែមួយដែលអវត្តមានដំណើរការប្រជាធិបតេយ្យពហុបក្សក្នុងអំឡុងពេលបោះឆ្នោតនេះ។

ស្ថានភាពខាងលើគ្មានភាពយុត្តិធម៌ក្នុងការបោះឆ្នោត ជាមួយការមិនទាន់ដោះស្រាយជាក់លាក់ដើម្បីធានាសិទ្ធិអ្នកបោះឆ្នោតជាង១លាននាក់ (ខុស ឬបាត់ឈ្មោះ) និងការមិនជឿទុកចិត្តលើសមាសភាពគណៈកម្មាធិការជាតិ/គណៈកម្មាការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់នាំមកនូវការបាត់បង់កិត្យានុភាពទាំងមូលនៃការបោះឆ្នោត។

## ១.២ អំឡុងពេលបោះឆ្នោត

### ១.២.១.ពេលឃោសនាបោះឆ្នោត និងថ្ងៃបោះឆ្នោត

#### ១.២.១.១ ពេលឃោសនាបោះឆ្នោត

អង្គការសង្គមស៊ីវិលដែលតាមដាន និងសង្កេតការណ៍ដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ បានសង្កេតឃើញស្ថានភាពវិជ្ជមាន ភាពមិនប្រក្រតី និងភាពមិនស្មើគ្នាមួយចំនួនក្នុងអំឡុងពេលនោះ។ ស្ថានភាពនយោបាយមានការធូរស្រាលដោយសារតែអំពើហឹង្សាមានការថយចុះច្រើន បើប្រៀបធៀបជាមួយអាណាណិត្តមុនៗ អំពើហឹង្សាធ្ងន់ធ្ងរនយោបាយបានធ្លាក់ចុះយ៉ាងច្រើន និងព្រះមហាក្សត្របានលើកលែងទោសឲ្យលោក សម រង្ស៊ី ដោយយោងតាមលិខិតស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រី ព្រមទាំងពុំមានការរំខានរារាំងដល់ដំណើរការឃោសនារបស់គាត់។ បន្ថែមលើសពីនេះប្រជាពលរដ្ឋកម្ពុជាជាពិសេសយុវជន មានការយល់ដឹងអំពីសិទ្ធិក្នុងសង្គមប្រជាធិបតេយ្យដោយពួកគេបានចូលរួមយ៉ាងសកម្មក្នុងយុទ្ធនាការឃោសនាបោះឆ្នោតយ៉ាងច្រើន ដែលខុសពីអាណត្តិមុនៗ ហើយប្រជាពលរដ្ឋកម្ពុជាហ៊ានបញ្ចេញមតិនយោបាយរបស់ខ្លួននៅតាមទីសាធារណៈនានាដោយពុំមានការភ័យខ្លាច។ ជាពិសេសប្រជាជនជាច្រើនមិនជឿងប់ងល់លើគណបក្សណាមួយឡើយ។

ក្រាហ្វិកទី១៖ ករណីឃាតកម្មទៅលើសកម្មជនគណបក្សនយោបាយពីឆ្នាំ១៩៩៣ដល់២០១៣




ប្រជាពលរដ្ឋបានតាមដានសកម្មភាពគណបក្សដែលគេគាំទ្រមុននឹងបន្តគាំទ្រ។ ប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា៖ Facebook, Twitter, Youtube...មានការរីកចំរើនក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោត និងគោលនយោបាយរបស់គណបក្សនយោបាយទៅដល់ប្រជា

ពលរដ្ឋ។ ទន្ទឹមនឹងភាពវិជ្ជមាន គេក៏សង្កេតឃើញភាពអវិជ្ជមានមួយចំនួនផងដែរ។ ភាពមិនប្រក្រតីទាំងនោះមានដូចជា៖ បញ្ជីឈ្មោះអ្នកបោះឆ្នោតមានភាពប៉ោង ចំនួននៃអ្នកបោះឆ្នោតលើសពី ១០០% ដែលនាំឲ្យមានមន្ទិល ថាមានការបន្លំសន្លឹកឆ្នោត ហើយអ្នកដែលបានបោះឆ្នោតកន្លងមកមួយចំនួនមិនមានឈ្មោះ និងបានបាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោត។ ការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ឲ្យការបោះឆ្នោតដ៏ច្រើនលើសលុប ដែលចំនួនខ្លះពុំមានភាពត្រឹមត្រូវ និងតម្លាភាព ក្នុងនោះ ១,០៩៨,៨៩៣សន្លឹក បានចេញក្នុងការបោះឆ្នោតមុនៗ និងក្នុងការបោះឆ្នោតលើកនេះមានចំនួនជាង៧០០,០០០សន្លឹកបន្ថែមទៀត។ បន្ថែមលើសពីនេះ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋាភិបាលបានធ្វើសកម្មភាព និងដឹកនាំការឃោសនាបោះឆ្នោត ព្រមទាំងប្រើប្រាស់ធនធានរដ្ឋថែមទៀតផង។ អាជ្ញាធរខេត្តមួយចំនួនបានហាមឃាត់ទីកន្លែងសាធារណៈមួយចំនួនមិនឲ្យធ្វើការហែក្បួន ឬជួបប្រជុំធ្វើសកម្មភាពឃោសនាបោះឆ្នោត ដែលធ្វើឲ្យប៉ះពាល់ដល់ភាពសេរី និងយុត្តិធម៌នៃដំណើរការបោះឆ្នោត។

ក្នុងដំណើរការឃោសនា គេឃើញមាន ការរំខាន និងប្រើហឹង្សាខ្លះៗ ជាពិសេសពេលមានក្បួនដង្ហែប៉ះគ្នា។ហើយក៏មានមានការប្រើរចនាសម្ព័ន្ធរដ្ឋ និងឯកជនគំរាមកំហែង និងគាបសង្កត់ទៅលើអ្នកបោះឆ្នោតឲ្យបោះឆ្នោតគាំទ្រគណបក្សណាមួយផងដែរ។ ជាមួយគ្នានេះដែរ គេក៏បានសង្កេតឃើញពីភាពមិនស្មើគ្នាក្នុងពេលឃោសនា បោះឆ្នោតនេះផងដែរ។ គណបក្សកាន់អំណាចគ្រប់គ្រងពេញ៣០ថ្ងៃនៅទីកន្លែងសាធារណៈមួយចំនួនផ្តាច់មុខក្នុងយុទ្ធនាការឃោសនារបស់ខ្លួន។ គណបក្សដែលមានធនធានច្រើនបានប្រើប្រាស់ច្រើនលើសលប់លើគណបក្សដែលមានធនធានតិចតួចនូវស្លាកសញ្ញាឃោសនានៅតាមដងផ្លូវ និងតាមទីសាធារណៈនានាដោយពុំស្មើភាពគ្នា។ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក(វិទ្យុ និងទូរទស្សន៍...)មានភាពលំអៀងច្រើនលើសលប់ទៅលើគណបក្សកាន់អំណាច។

**១.២.១.២ ថ្ងៃបោះឆ្នោត**

នៅថ្ងៃបោះឆ្នោតនេះ បន្ទប់ស្ថានការណ៍បោះឆ្នោត យល់ឃើញថា ដំណើរការបោះឆ្នោតនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣នេះ បានប្រព្រឹត្តទៅស្របតាមប្រតិទិន ដែលបានគ្រោងទុករបស់គ.ជ.ប បើទោះបីជាមានអំពើហឹង្សាតិចតួច និងភាពមិនប្រក្រតីខ្លះបានកើតឡើងក្នុងកំឡុងពេលថ្ងៃបោះឆ្នោតនេះ។

យ៉ាងណាមិញ សំរាប់ការបោះឆ្នោតនីតិកាលទី៥នេះ ប្រជាពលរដ្ឋមានការចូលរួមយ៉ាងសកម្មក្នុងការបោះឆ្នោត។

រកឃើញភាពមិនប្រក្រតីប្រមាណចំនួន១១,១៣៩ករណី ដែលកើតឡើងក្នុងពេលបោះឆ្នោត និងប្រមាណ២៦៣ករណីដែលមានភាពមិនប្រក្រតីកើតឡើងក្នុងពេលរាប់សន្លឹកឆ្នោត ដែលក្នុងនោះភាគច្រើនទាក់ទងទៅនឹងការបាត់ឈ្មោះ និងរកឈ្មោះមិនឃើញ ព្រមទាំងអាជ្ញាធរមានវត្តមាននៅតាមការិយាល័យបោះឆ្នោត។

មានភាពមិនប្រក្រតី ច្រើនជាងមួយម៉ឺនមួយពាន់ និងតាមការសិក្សាស្រាវជ្រាវរបស់ខុមហ្វ្រែលទៅលើអ្នកមានសិទ្ធិបោះឆ្នោតដែលគ្មានស្នាមទឹកខ្មៅនៅលើចង្អុលដៃបង្ហាញថា៤៨%បានទៅដល់ការិយាល័យបោះឆ្នោត ប៉ុន្តែពួកគាត់មិនបានបោះឆ្នោត ដោយសាររកឈ្មោះ ឬរកការិយាល័យបោះឆ្នោតមិនឃើញ គ្មានឯកសារបញ្ជាក់អត្តសញ្ញាណប្រើប្រាស់ក្នុងការបោះឆ្នោត និងខុសទិន្នន័យក្នុងបញ្ជីបោះឆ្នោតជាដើម។ ចំណែកការសង្កេតរបស់អង្គការតម្លាភាពកម្ពុជា និងសម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម បានរកឃើញថា ៦០%នៃការិយាល័យបោះឆ្នោតប្រជាពលរដ្ឋមានឯកសារបញ្ជាក់អត្តសញ្ញាណត្រឹមត្រូវប៉ុន្តែមិនអាចរកឈ្មោះឃើញក្នុងបញ្ជីបោះឆ្នោត។

បន្ថែមទៅលើនោះទៀត មានភាពមិនប្រក្រតីនៅថ្ងៃបោះឆ្នោតដែលងាយនឹងប៉ះពាល់ដល់លទ្ធផលបោះឆ្នោតគឺអាចកើតមាននៅក្នុងខេត្តកណ្ដាល ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប ព្រោះថាសន្លឹកឆ្នោតខុសគ្នារវាងគណបក្សមួយ ទៅគណបក្សមួយផ្សេងទៀត ដើម្បីទទួលបានអាសនៈនៅសល់ចុងក្រោយគឺមានចំនួនតិចតួចត្រឹមរយទៅពាន់សម្លេងឆ្នោត ជាពិសេសករណីនៅខេត្តកណ្ដាលគឺត្រឹមតែ ១៦៨សន្លឹកឆ្នោត ឬ ០.៣% នៃចំនួនសន្លឹកឆ្នោតមធ្យមភាគចុងក្រោយ ដែលអាចប្រែប្រួលអាសនៈមួយនៅសល់ចុងក្រោយ។ កំរិតភាពមិនប្រក្រតីនៅខេត្តកណ្ដាលក៏មានច្រើនគួរឲ្យចាប់អារម្មណ៍ផងដែរ ជាពិសេស គេឃើញមានការិយាល័យបោះឆ្នោតលេខ ១២០៤ នៅឃុំស្អាងភ្នំ ស្រុកស្អាងត្រូវបិទមុនពេលកំណត់។ និងម៉្យាងទៀតភាពមិនប្រក្រតីដោយគ្មានរបាយការណ៍លទ្ធផលបោះឆ្នោតទម្រង់១១០៨នៅ៨ការិយាល័យបោះឆ្នោតក្នុងសង្កាត់តាខ្មៅ ក្រុងតាខ្មៅ និង ការប្រែប្រួលចំនួនសន្លឹកឆ្នោតមិនបានការ និងសម្លេងឆ្នោតគណបក្ស។ អ្វីដែលគួរឲ្យកត់សំគាល់ភាគរយនៃអ្នកចេញទៅបោះឆ្នោតមានកំរិតទាបត្រឹមតែ៦៨% ដែលមានការថយចុះបើធៀបនឹងការបោះឆ្នោតជាតិអាណត្តិមុន។

## ១.៣ ក្រោយពេលបោះឆ្នោត

មានការព្រួយបារម្ភអំពីស្ថានការណ៍នៃភាពចម្រូងចម្រាសអំពីការខុសគ្នានៃលទ្ធផលបោះឆ្នោត និងភាពមិនប្រក្រតីបោះឆ្នោតដែលធ្វើអោយមានស្ថានការណ៍នយោបាយតានតឹង។ គ.ជ.ប គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ មិនទាន់ឈានទៅរកភាពស្រុះស្រួលគ្នាអំពីការបង្កើតគណៈកម្មការចម្រុះពិសេស ដើម្បីស៊ើបអង្កេតភាពមិនប្រក្រតីនៃការបោះឆ្នោត។ ម្យ៉ាងទៀត គ.ជ.ប មិនមានយន្តការ ឬសកម្មភាពជាក់លាក់ឆ្លើយតបនឹងការទាមទារបើកកិច្ចស៊ើបអង្កេតទេ ប៉ុន្តែ គ.ជ.ប ហាក់មានបំណងឱ្យដំណើរការដោះស្រាយទំនាស់ ឬបណ្ដឹងបោះឆ្នោតទៅតាមទំលាប់ និងប្រតិទិនរបស់ខ្លួនដោយមិនបានពិចារណាអំពីទំហំនៃភាពមិនប្រក្រតី ដែលអាចប៉ះពាល់ដល់លទ្ធផលបោះឆ្នោត និងសិទ្ធិអ្នកបោះឆ្នោត។

មានសំណើពីគណបក្សប្រឆាំងក្នុងការបង្កើតឲ្យមានការស៊ើបអង្កេតទៅលើភាពមិនប្រក្រតីដែលបានកើតឡើងនៅថ្ងៃបោះឆ្នោត ដោយក្នុងនោះខុមហ្វ្រែលតាងនាមឲ្យបន្ទប់ស្ថានការណ៍បានស្នើដល់ គ.ជ.ប បង្កើនតម្លាភាពបន្ថែមក្នុងការបើកចំហរផ្នែកឯកសារដូចជា បើកកញ្ចប់សុវត្ថិភាព "ក" ដោយផ្ដល់កំណត់ហេតុរាប់សន្លឹកឆ្នោតទំរង់១១០២ ដើម្បីធ្វើការផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោតតាមការិយាល័យនីមួយៗ, ផ្ដល់បញ្ជីឈ្មោះអ្នកដែលបានបោះឆ្នោតហើយ(បញ្ជីឈ្មោះដែលបានប្រើប្រាស់នៅតាមការិយាល័យបោះឆ្នោត) និងអនុញ្ញាតឲ្យថតចំលងគល់បញ្ជីនៃលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោតនៅខេត្តមួយចំនួ

ន។ ដោយឡែកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដើម្បីធានាតម្លាភាពក្នុងការដោះស្រាយភាពមិនប្រក្រតីមានភាពមិនច្បាស់លាស់ ថានឹងសហការផ្តល់ឯកសារទាំងនោះ ដែលពេលខ្លះមន្ត្រីគ.ជ.ប និយាយជាមួយអ្នកសារព័ត៌មានថា មិនអាចឱ្យចម្លងឯកសារទាំងនោះបានទេ ក្រោមហេតុផល«ការពារសិទ្ធិឯកជនរបស់បុគ្គល»។

មានការបន្តបំភិតបំភ័យ និងការគំរាមកំហែងរដោយមានការជ្រៀតជ្រែកពីរដ្ឋាភិបាល និងកងកម្លាំងប្រដាប់អាវុធក្នុងអំឡុងពេលដោះស្រាយទំនាស់បោះឆ្នោត និងមានការខកចិត្តអំពីការខ្វះភាពយុត្តិធម៌ក្នុងការចាត់ចែង និងការដោះស្រាយបណ្តឹងទៅលើភាពមិនប្រក្រតីនៃការបោះឆ្នោត ព្រោះគ្មានការអង្កេតដោយតម្លាភាព។ បន្ទប់ស្ថានការណ៍នៃអង្គការ សមាគមមិនមែនរដ្ឋាភិបាលក៏បានស្នើឲ្យក្រុមប្រឹក្សាធម្មនុញ្ញ និងគ.ជ.ប ពិនិត្យការបោះឆ្នោតឡើងវិញនៅការិយាល័យ ១២០៤ និងរាប់សន្លឹកឆ្នោតឡើងវិញនៅសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ស្នើឲ្យក្រុមប្រឹក្សាធម្មនុញ្ញ និងគណបក្សនយោបាយសំខាន់ៗយកចិត្តទុកដាក់ក្នុងការដោះស្រាយវិវាទបោះឆ្នោតតាមរយៈការសិក្សាស្រាវជ្រាវ ការអង្កេត ដោយមានការស្រុះស្រួលគ្នាប្រកបដោយតម្លាភាព។

រដ្ឋាភិបាលបានដាក់ពង្រាយកងកម្លាំងប្រដាប់អាវុធ និងគ្រឿងយុទ្ធភណ្ឌយោធា បណ្តាលឲ្យមានការបំភិតបំភ័យ ដល់ប្រជាពលរដ្ឋ ព្រមទាំងមានការចោទប្រកាន់តាមផ្លូវតុលាការទៅលើយុវជន និងយុវតីបួននាក់ទាក់ទិននឹងការជូនផ្កាដល់កងកំលាំងប្រដាប់អាវុធ។

ការបំភិតបំភ័យថ្មីមួយទៀត ក្រោយថ្ងៃបោះឆ្នោត អាជ្ញាធរមូលដ្ឋានបានបង្ខំម្ចាស់ឆ្នោត អោយផ្តិតមេដៃគាំទ្រលទ្ធផលបោះឆ្នោត ដែលនៅមានភាពចម្រូងចម្រាសនៅឡើយ។ មានការរាយការណ៍ពីសំណាក់ម្ចាស់ឆ្នោតថា មានការគំរាមកំហែងនៅក្នុងតំបន់មួយចំនួនដូចជា សង្កាត់អូរឬស្សី សង្កាត់ស្រះចក សង្កាត់ពងទឹក សង្កាត់បឹងប៉ាយ៉ាប សង្កាត់ទួលស្វាយព្រៃ១ សង្កាត់បឹងកេងកង២ និងសង្កាត់ចាក់អង្រែលើ។ ទង្វើទាំងនេះគឺជាការរំលោភច្បាប់ និង ជាការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើសេរីភាពបញ្ចេញមតិរបស់ម្ចាស់ឆ្នោតនៅកម្ពុជា។ លើសពីនេះទៅទៀត ទង្វើនេះបានគំរាមកំហែងដល់សិទ្ធិរក្សាការសម្ងាត់របស់ម្ចាស់ឆ្នោត និងបង្កើននូវភាពតានតឹង និងការភ័យខ្លាចដែលកំពុងកើតមាន។ ញត្តិទាំងឡាយណាដែលធ្វើឡើងក្រោមរូបភាពបង្ខិតបង្ខំ នឹងពុំជួយអ្វីដល់ភាពទទួលយកបាននៃលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនោះទេ។ ទង្វើរបស់អាជ្ញាធរដែនដីបែបនេះ វាកាន់តែធ្វើអោយខូចដល់សុចរិតភាពនៃកិច្ចដំណើរការបោះឆ្នោត។

មានការឯកភាពគ្នារវាងគណបក្សនយោបាយទាំងពីរក្នុងការបង្កើតគណៈកម្មការចម្រុះក្នុងការស៊ើបអង្កេតលើភាពមិនប្រក្រតីនៃដំណើរការបោះឆ្នោតនាថ្ងៃ២៨ កក្កដា ២០១៣ នេះ និងការឆ្លងឆ្លើយលិខិតនៃមេដឹកនាំគណបក្សទាំងពីរអំពីការបន្តការចរចា ប៉ុន្តែមិនមានការវិវត្តន៍រីកចម្រើនទៅមុខ ដែលបង្កឲ្យមានវិវាទបោះឆ្នោតកាន់តែមានភាពស្មុគស្មាញឡើង និងតានតឹង ដែលអាចឈានទៅដល់ការប្រទូសរាយក្នុងសង្គមដ៏ធ្ងន់ធ្ងរ។ ដោយយល់ឃើញអំពីស្ថានការណ៍បែកបនេះ បន្ទប់ស្ថានការណ៍នៃអង្គការ សមាគមមិនមែនរដ្ឋាភិ បាល បានផ្តល់នូវសំណើជាក់លាក់ថា គណបក្សនយោបាយទាំងពីរគួរបញ្ជូនប្រតិភូជាន់ខ្ពស់ដើម្បីជជែកគ្នាអំពីការបង្កើតគណកម្មការស៊ើបអង្កេតចម្រុះជាបន្ទាន់ ដើម្បីអង្កេតទៅលើភាពមិនប្រក្រតីដែលអាចធ្វើឲ្យប៉ះពាល់ដល់លទ្ធផលបោះឆ្នោត និងបន្ថែមផែនការ កំណែទម្រង់សំខាន់ៗទៅអនាគត។ ដែលក្នុងនោះមានការស្នើឲ្យមានសមាសភាពនៅក្នុងគណៈកម្មការចំរុះពិសេសដែលមានដូចជា តំណាងគណបក្សប្រជាជន

កម្ពុជា, តំណាងគណបក្សសង្គ្រោះជាតិ, អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិជាអ្នកសង្កេតការណ៍ និងក៏អាចផ្តល់បច្ចេកទេស ចំណែកអង្គការសង្គមស៊ីវិល ជាអ្នកស៊ើបអង្កេត(ផ្តល់របាយការណ៍ពីលទ្ធផលស្រាវជ្រាវ និងអនុសាសន៍)។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាអ្នកសម្របសម្រួលការប្រជុំ និងអ្នកគាំទ្រផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធចាំបាច់ក្នុងការអង្កេតស្រាវជ្រាវ។ (*កំណត់សំគាល់៖ គណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជាជាប្រធានផ្លាស់វេននៃគណកម្មការនេះ ដែលជាអ្នកសម្រេចទំហំនៃការអង្កេតស្រាវជ្រាវ ហើយជាអ្នកសម្រេចយកអនុសាសន៍ពីការអង្កេតស្រាវជ្រាវទៅឲ្យគ.ជ.ប អនុវត្តន៍។)*

បន្ទាប់ពីការចេញលទ្ធផលបោះឆ្នោតផ្លូវការរបស់គ.ជ.ប នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣រួចមក គណបក្សសង្គ្រោះជាតិបានធ្វើមហាបាតុកម្មអហឹង្សាលើកទី២ ចំនួនបីថ្ងៃ ពីថ្ងៃទី១៥ ដល់១៧ ខែកញ្ញា ឆ្នាំ២០១៣ ដោយមានអ្នកចូលរួមរាប់ម៉ឺននាក់ទាមទាររកយុត្តិធម៌។ មានការរិះគន់អំពីការវាយបន្ទាលួស និងបិទរបាំងផ្លូវ មិនឲ្យអ្នកដំណើរឆ្លងកាត់ ជាមូលហេតុនៃហឹង្សារវាងពលរដ្ឋ និងកម្លាំងប្រដាប់អាវុធដែលនាំឲ្យមានព្រឹត្តិការណ៍ប៉ះទង្គិចហិង្សាកើតឡើងនៅស្ពានក្បាល់ថ្នល់រវាងសមត្ថកិច្ចរាប់រាយនាក់ ប្រដាប់ដោយខែលដំបង គ្រាប់បែកផ្សែង កាំភ្លើងគ្រាប់ពិត ជាមួយនឹងក្រុមអ្នកតវ៉ាប្រមាណជិត ៣០នាក់ យ៉ាងហោចណាស់បានបណ្តាលឲ្យមនុស្សម្នាក់ ស្លាប់១៥នាក់រងរបួស និងមនុស្ស៦នាក់ ត្រូវសមត្ថកិច្ចចាប់ខ្លួន។



រូបភាពទី១៖ ការធ្វើបាតុកម្មរបស់គណបក្សសង្គ្រោះជាតិ និងការវាយបន្លាលួសបិទផ្លូវ

ដើមឡើយ គណបក្សប្រជាជនកម្ពុជាហាក់ដូចជាបានយល់ស្របដើម្បីបង្កើតគណៈកម្មការចម្រុះដើម្បីស៊ើបអង្កេតភាពមិនប្រក្រតីក្នុងពេលបោះឆ្នោតដែលស្នើដោយគណបក្សសង្គ្រោះជាតិ នេះបើយោងលើប្រសាសន៍របស់ លោក ហ៊ុន សែន បេក្ខជននាយករដ្ឋមន្ត្រីនៃគណបក្សប្រជាជនកម្ពុជា កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ក្នុងពេលចុះពិនិត្យការដ្ឋានសង់ស្ពានអាកាសស្ទឹងមានជ័យ។ ក្រោយជំនួបចរចាជាច្រើន

លើកច្រើនសាររវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ គណបក្សប្រជាជនកម្ពុជាបែរជាបដិសេធយន្តការនៃគណៈកម្មការចម្រុះទៅវិញ។

មានជម្លោះនយោបាយបន្ថែមលើទំនាស់បោះឆ្នោតដែលជម្លោះនេះមិនត្រឹមខុសគ្នាអំពីខ្លឹមសារ ប៉ុន្តែក៏មានការមិនទុកចិត្តគ្នាក្នុងការសន្ទនា។ ការវិវត្តន៍នៃជម្លោះនេះអាចចេញលទ្ធផលតាមរូបភាពផ្សេងៗដែលបន្តការចរចា និងបានសម្រេចការស្រុះស្រួលដោយបង្កើតបរិយាកាសជឿទុកចិត្តគ្នាវិញ និងមានកិច្ចព្រមព្រៀងច្បាស់លាស់។ នៅក្នុងករណីនេះមានការលំបាកជាខ្លាំងដែលស្ទើរមិនមានលទ្ធផលនៃដំណោះស្រាយនយោបាយ។ ម៉្យាងទៀត ជម្លោះទាំងនេះនឹងក្លាយទៅជាវិបត្តិនយោបាយធ្ងន់ធ្ងរ និងយូរអង្វែង ហើយមានរូបភាពក្នុងការទាមទារឱ្យបោះឆ្នោតឡើងវិញនៅក្នុងអាណត្តិ។ មានការកើនកំដៅខ្លាំងព្រោះថា ភាគីសាមីគណបក្សទាំងពីរខិតខំ រកកម្លាំងសម្ពាធដាក់ទៅលើគ្នាទៅវិញទៅមក។ កម្លាំងសម្ពាធនឹងមិនកើតមានដោយសន្តិវិធីទៀតឡើយ ប្រសិនបើនៅពេលដែលកម្លាំងដាក់សម្ពាធរបស់ម្ចាស់ឆ្នោតបែរត្រូវបានបង្ក្រាបយ៉ាងខ្លាំងក្លាដោយកងកម្លាំងប្រដាប់អាវុធ។ ករណីនេះនឹងអាចនាំមកនូវការបះបោរ និងអំពើហឹង្សា ហើយដែលពិបាកការប៉ាន់ប្រមាណ អំពីហានិភ័យអវិជ្ជមាន។

## ២. ការវាយតម្លៃទៅលើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ឆ្នាំ២០១៣

ខុមហ្វ្រែលជាមួយបន្ទប់ស្ថានការណ៍នៃសម្ព័ន្ធអង្គការសង្គមស៊ីវិល បានធ្វើការវាយតម្លៃអំពីដំណើរការ និងការចាត់ចែងការបោះឆ្នោតទាំងមូល (ក្នុងអំឡុងពេល និងក្រោយពេលបោះឆ្នោត) នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ថា «មិនទាន់សេរី និងយុត្តិធម៌ទេ» បើទោះបីជាមានការថយចុះករណីហិង្សាធ្ងន់ធ្ងរ និងគ្មានការសម្លាប់សកម្មជន អ្នកនយោបាយ និងការចូលរួមយ៉ាងសកម្មរបស់យុវជនក្នុងយុទ្ធនាការបោះឆ្នោតក៏ដោយ។

យុត្តិធម៌ និងសុចរិតភាពក្នុងការបោះឆ្នោតលើកនេះបានធ្លាក់ចុះ បើធៀបជាមួយការបោះឆ្នោតមុនៗ ចាត់ចែងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ដែលស្ថិតនៅក្រោមស្តង់ដារអន្តរជាតិ ការបោះឆ្នោតសេរី និងយុត្តិធម៌រួចទៅហើយ។ មានបញ្ហាសំខាន់ៗមិនត្រូវបានកែលម្អដែលប៉ះពាល់ដល់ដំណើរការ និងការចាត់ចែងរួមមាន ៖

ក) គ្មានភាពស្មើគ្នាក្នុងការផ្សព្វផ្សាយ និងការប្រើប្រាស់ ប្រព័ន្ធផ្សព្វផ្សាយរួមមាន ទូរទស្សន៍ និងវិទ្យុជាច្រើនលើសលុបបានផ្សាយលំអៀងយ៉ាងខ្លាំងទៅរកគណបក្សកាន់អំណាច ហើយផ្សព្វផ្សាយប្រឆាំងទៅនឹងគណបក្សដទៃទៀត។

ខ) បរិយាកាសខ្វះអព្យាក្រឹត្យ និងការជ្រៀតជ្រែករបស់រដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ កងនគរបាល និងមន្ត្រីតុលាការ ដែលបានធ្វើសកម្មភាពឃោសនាបោះឆ្នោត និងគាំទ្រគណបក្សកាន់អំណាច ព្រមទាំងរារាំងប្រឆាំងនឹងគណបក្សនយោបាយផ្សេងទៀត។

គ) បញ្ហាបញ្ជីឈ្មោះអ្នកបោះឆ្នោត ឈ្មោះស្ទួនប្រមាណជាង សាមសិបម៉ឺនឈ្មោះ ជាពិសេសការចេញលិខិតបញ្ជាក់អត្តសញ្ញាណសំរាប់បំរើឲ្យការបោះឆ្នោតនេះមានរហូតដល់ជាងមួយលានលិខិត ក្នុងនោះ

មានភាពមិនប្រក្រតីជាច្រើន រួមទាំង ការលុបលាងបានភ្លាមៗនូវទឹកខ្មៅលើម្រាមដៃ ដែលនាំឲ្យមិនអាចធានា មនុស្សម្នាក់បោះឆ្នោតបានតែម្តង។

ឃ) បញ្ហាបញ្ជីឈ្មោះបោះឆ្នោត អ្នកបោះឆ្នោតបាត់ឈ្មោះ (ដូរ ខុសឈ្មោះ ឬលុបឈ្មោះ ឬ...) អ្នកបោះឆ្នោតជាច្រើនបានបាត់បង់សិទ្ធិបោះឆ្នោត បើទោះបីពួកគេមានឆន្ទៈ និងបានចេញទៅដល់ការិយាល័យបោះឆ្នោត ប៉ុន្តែមិនបានបោះឆ្នោតមាន ៤៨%[6] នៃអ្នកមិនបានបោះឆ្នោត (អ្នកមិនមានទឹកខ្មៅលើម្រាមដៃ) និងភាពមិនប្រក្រតីប្រមាណជាង មួយម៉ឺនករណី នៅថ្ងៃបោះឆ្នោត រួមទាំងការដឹកជញ្ជូនអ្នកបោះឆ្នោត[7]ពីខេត្តមួយឲ្យបោះទៅខេត្តមួយផ្សេងទៀត។

ង) ការបាត់សិទ្ធិឈរឈ្មោះរបស់មេដឹកនាំគណបក្សប្រឆាំងលោក សម រង្ស៊ី ជាបេក្ខជនឲ្យគេបោះឆ្នោតបាន។

ច) ការលម្អៀង និងមិនឯករាជ្យរបស់ស្ថាប័នរៀបចំការបោះឆ្នោត និងការដោះស្រាយវិវាទបោះឆ្នោត (គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ) ដោយការខ្វះតម្លាភាព និងការខ្វះយុត្តិធម៌ ក្នុងការបំពេញភារកិច្ច និងតួនាទីរបស់ខ្លួន។ ស្ថាប័នទាំងនេះ ជានិច្ចកាលព្រងើយកន្តើយ ការអនុវត្តអនុសាសន៍ក្នុងការកែលម្អការបោះឆ្នោត ឬបដិសេធចោលស្ទើរតែទាំងស្រុងទៅនឹងបណ្តឹងតវ៉ា និងជំទាស់របស់គណបក្សនយោបាយផ្សេងដែលមិនមែនជាគណបក្សកាន់អំណាចដែលក្នុងនោះមានយ៉ាងតិចចំនួនប្រហែល៧០០បណ្តឹងក្នុងអំឡុងពេលបោះឆ្នោត។

ឆ) ការកើនឡើងនៃការប្រើប្រាស់ធនធានរដ្ឋមិនបានត្រឹមត្រូវ និងការយកទីធ្លាសាធារណៈយ៉ាងច្រើនសន្ធឹកសន្ធាប់មកប្រើប្រាស់ពីសំណាក់គណបក្សកាន់អំណាច ។

ជ) ការកើនឡើងនៃការទិញសន្លឹកឆ្នោតដោយគណបក្សកាន់អំណាច ជាពិសេសអំឡុងពេលមុនឃោសនាបោះឆ្នោត មានគម្លាតគ្នាយ៉ាងខ្លាំងក្នុងការចំណាយថវិកាឃោសនាបោះឆ្នោតរវាងគណបក្សកាន់អំណាច និងគណបក្សប្រកួតប្រជែងផ្សេងៗ។

មានបរិយាកាស ការបំភិតបំភ័យ ការគំរាមកំហែងដល់ម្ចាស់ឆ្នោត និងសកម្មជនគណបក្សនយោបាយប្រកួតប្រជែង ចាប់ពីអំឡុងពេលបោះឆ្នោតរហូតដល់ក្រោយពេលបោះឆ្នោត។ តាំងពីមន្ត្រីរដ្ឋាភិបាល អាជ្ញាធរ រហូតដល់ប្រព័ន្ធផ្សព្វផ្សាយ គាំទ្រគណបក្សកាន់អំណាចបានលើកឡើងជាញឹកញាប់លើការព្រមានអំពីលទ្ធភាព សង្គ្រាម ឬយោធាយកអំណាចវិញបើមានការផ្លាស់ប្តូររដ្ឋាភិបាល និងរហូតដល់មានសកម្មភាពជាក់ស្តែង ដូចជាការដាក់ពង្រាយកងទ័ពប្រដាប់អាវុធ យុទ្ធភ័ណ្ឌ យោធានៅក្នុងអំឡុងពេលដោះស្រាយវិវាទបោះឆ្នោត (ក្រោយពេលបោះឆ្នោត)។ បរិយាកាសបំភិតបំភ័យ គំរាមកំហែង និងដំណើរការ និងការចាត់ចែងបោះឆ្នោត ខ្វះយុត្តិធម៌ និងខ្វះសុចរិតភាពធ្ងន់ធ្ងរដែលប៉ះពាល់ដល់លទ្ធផលបោះឆ្នោតនាំឲ្យគណបក្សកាន់អំណាចមានប្រៀប ព្រមទាំងមិនឆ្លុះបញ្ចាំង ឆន្ទៈ ដោយសេរីរបស់អ្នកបោះឆ្នោតពេញលេញ និងមានការថយចុះចំនួនបេក្ខជនជាស្ត្រីជាប់ឆ្នោត។

[6] ការសិក្សាស្រាវជ្រាវរបស់ខុមហ្វ្រែលក្រោយពេលបោះឆ្នោត

[7] ករណីសិក្សារបស់លីកាដូ អាដហុក និចហ្វិច និងVOD/CCIM

## ៣. ក្របខណ្ឌច្បាប់

អង្គការសង្កេតការណ៍ជាតិ និងអន្តរជាតិនានាបានធ្វើការកត់សំគាល់ប្រហាក់ប្រហែលគ្នា និងបានធ្វើអនុសាសន៍ជាច្រើនសម្រាប់ធ្វើការកែទម្រង់ចំពោះ ស្ថាប័នបោះឆ្នោត ការធ្វើវិសោធនកម្មច្បាប់ និងកែលំអបញ្ញត្តិច្បាប់បោះឆ្នោត។

ស្ថាប័នរៀបចំការបោះឆ្នោត ជាស្ថាប័នមានតួនាទីយ៉ាងសំខាន់សម្រាប់ធ្វើអោយមានស្ថិរភាពនយោបាយតាមរយៈការរៀបចំអោយមានការបោះឆ្នោតមួយដែលត្រឹមត្រូវ យុត្តិធម៌ តម្លាភាព និងមានសារៈប្រយោជន៍ក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ។ ដើម្បីស្ថាប័ននេះបំពេញភារកិច្ចដោយប្រសិទ្ធិភាពខ្ពស់ លុះត្រាតែស្ថាប័ននេះមានឯករាជ្យភាព មានសមត្ថភាព មានសមត្ថកិច្ច និងមានលទ្ធភាពគ្រប់គ្រាន់ដើម្បីធ្វើកិច្ចការនេះ។ ក្នុងគោលគំនិតទាំងអស់នេះហើយបានជាច្បាប់រៀចំការបោះឆ្នោតបានកំណត់យ៉ាងច្បាស់ថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលជាស្ថាប័នកំពូលមានភារកិច្ចរៀបចំការបោះឆ្នោត ត្រូវតែជាស្ថាបន័ឯករាជ្យ និងអព្យាក្រឹត[8]។ ថ្វីត្បិតតែមាត្រា១២នៃច្បាប់ចែងធានានូវការចរឹតអនុវត្តការងារបោះឆ្នោតយ៉ាងដូច្នេះមែន ប៉ុន្តែនៅមានការរិះគន់ថាៈ

- សមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនឯករាជ្យ ដោយសារការជ្រើសរើសមិនមានតម្លាភាព និងតាមរយៈក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាល ។
- នៅក្នុងច្បាប់បោះឆ្នោតនេះ មិនបានយកចិត្តទុកដាក់ចែងពីតំណែងអគ្គលេខាធិការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាល់តែសោះ។ តាមការពិតទៅវិញនោះ តំណែងនេះមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំប្រតិបត្តិការការងាររបស់ គជ.ប ទាំងមូលទៅវិញ។.
- អំណាចវិនិច្ឆ័យវិវាទការបោះឆ្នោតត្រូវបាន គ.ជ.ប ផ្ទេរទៅអោយគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោមដែលនាំអោយមានការរិះគន់ថា មិនហ៊ានដោះស្រាយវិវាទធំៗ មានការលំអៀង និងមិនយុត្តិធម៌។
- ដោយសារកិច្ចការវិនិច្ឆ័យក្តីវិវាទបោះឆ្នោត ត្រូវការអោយមានជំនាញច្បាប់ និងមានជំនាញដោះស្រាយ ការណ៍នេះធ្វើអោយសាធារណៈជនមិនមានជំនឿទុកចិត្តលើការសម្រេចរបស់គណៈកម្មាធិការ និងគណៈកម្មការរៀបចំការបោះឆ្នោត ព្រោះសមាជិករបស់គណៈកម្មាធិការ និងគណៈកម្មការទាំងនោះមិនសូវជាមានអ្នកដែមានចំណេះដឹង និងបទពិសោធន៍ខាងច្បាប់ ខាងតុលាការនោះទេ។
- ថ្វីត្បិតតែច្បាប់បោះឆ្នោតបានកំណត់ថា គ.ជ.ប ត្រូវតែជាស្ថាប័នឯករាជ្យ និងអព្យាក្រិត ប៉ុន្តែយើងឃើញថា គ.ជ.ប មានចំណុចខ្សោយដូចតទៅៈ
  - ជាស្ថាប័នបង្កើតដោយ ច្បាប់បោះឆ្នោត មិនមែនជាស្ថាបន័ធម្មនុញ្ញនោះទេ។ឈ្មោះបេក្ខជនសមាជិក គ.ជ.ប ត្រូវស្នើឡើងដោយក្រសួងមហាផ្ទៃ ដែលហាក់ដូចជា ស្ថាប័ននេះបានកើតឡើងពីអំណាចនីតិប្រត្តិបត្តិផងដែរ។

[8] មាត្រា១២៖ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាអង្គការឯករាជ្យ និងអព្យាក្រិតក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន។

## ៣.១. ការដោះស្រាយវិវាទ

យោងតាមច្បាប់ស្តីពីការបោះឆ្នោតបច្ចុប្បន្ន គ.ជ.ប មានតួនាទីពីរគឺ រៀបចំការបោះឆ្នោត នឹងដោះស្រាយវិវាទបោះឆ្នោត។ ចំពោះតួនាទីដោះស្រាយវិវាទបោះឆ្នោត គ.ជ.ប ដំណើការប្រៀបបីដូចជាតុលាការមួយដូច្នោះដែរ។ ជាក់ស្តែងនៅក្នុងច្បាប់ស្តីពីការបោះឆ្នោត គ.ជ.ប មានអំណាចបដិសេធលទ្ធផលបោះឆ្នោត ដកបេក្ខភាពរបស់វន្តបុគ្គល ឬរបស់កណបក្សទាំងមូលជាដើម។ ប៉ុន្តែទោះជាច្បាប់បានផ្តល់អំណាងបែបនេះក៏ដោយ គេសង្កេតឃើញថា គ.ជ.ប មិនបានបំពេញតួនាទីរបស់ខ្លួនឲ្យបានពេញលេញនោះទេ ហើយមានការរិះគន់ជាច្រើនពីសាធារណៈជន និងពីអង្គការជាតិ អន្តរជាតិទាំងឡាយ។ ដូចនេះជាការចាំបាច់ណាស់ដែលត្រូវតែពិនិត្យលើអំណាចរបស់ គ.ជ.ប ជាថ្មីម្តងទៀត និងត្រូវធ្វើការកែលម្អដើម្បីឲ្យការងារបោះឆ្នោតអាចដំណើរការដោយប្រសិទ្ធភាព។

កន្លងមកមានការរិះគន់ពីនីតិវិធីកាត់ក្តីរបស់ គ.ជ.ប និងគណកម្មការរៀបចំការបោះឆ្នោតផ្សេងទៀត។ កុំថាឡើយដល់នីវិធីកាត់ក្តីរបស់ គ.ជ.ប និងគណកម្មការរៀបចំការបោះឆ្នោត សូម្បីតែនីតិវិធីតុលាការធម្មតាក៏មានបញ្ហា និងទទួលការិះគន់ផងដែរ។ ដូចនេះ ជាការប្រសើរត្រូវមាននីវិធីមួយពិសេស ដែលមានតម្លាភាព និងធានាឲ្យមាននូវភាពយុត្តិធម៌ដល់ភាគីវិវាទទាំឡាយ។

## ៣.២.ប្រព័ន្ធបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

បច្ចុប្បន្ននេះ ទាំងប្រព័ន្ធបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាប្រព័ន្ធសមាមាត្រ។ តាំងតែពីសេចក្តីព្រាងច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់មកម្ល៉េះនេះ ក្រុមអង្គការសង្គមស៊ីវិលបានធ្វើអនុសាសន៍ និងអំពាវនាវសុំឲ្យរាជរដ្ឋាភិបាលកុំប្រើប្រព័ន្ធសមាមាត្រ និងសុំឲ្យប្រើប្រព័ន្ធឯកត្តនាមវិញ ដោយមិនចង់ឲ្យមានការបែងចែកគណបក្សនយោបាយនៅក្នុងស្រទាប់ប្រជាពលរដ្ឋតាំងតែថ្នាក់មូលដ្ឋាននោះទេ។ ប៉ុន្តែការទាមទារនេះមិនត្រូវបានទទួលយក និងយកចិត្តទុកដាក់ពីអ្នកនយោបាយទេ។ ការទាមទារសុំឲ្យប្រើប្រព័ន្ធឯកត្តនាម ដោយសារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រតាមប្រព័ន្ធបច្ចុប្បន្ន (ប្រព័ន្ធសមាមាត្រ) ប្រជាពលរដ្ឋតែងត្អូញត្អែរថា តំណាងរបស់គេមិនមែនជាតំណាងរបស់រាស្ត្រពិតប្រាកដនោះទេ គឺឯកឧត្តម លោកជំទាវសមាជិកសភាទាំងនោះជាតំណាងបក្ស និងធ្វើការឲ្យបក្សដោយមិនសូវខ្វល់ពីសុខទុក្ខរាស្ត្រនោះឡើយ។ ម្យ៉ាងវិញទៀតប្រព័ន្ធសមាមាត្រអនុញ្ញាតបានតែអ្នកដែលជាសមាជិកគណបក្សប៉ុណ្ណោះទើបអាចឈរឈ្មោះឲ្យគេបោះឆ្នោតបាន។

អ្នកនយោបាយធ្លាប់លើកឡើងថា មូលហេតុយកប្រព័ន្ធសមាមាត្រ គឺក្នុងគោលបំណងឲ្យគណបក្សតូចៗអាចនឹងរួមចំណែក និងទទួលបានអាសនៈក្នុងរដ្ឋសភាផងដែរ។ ប៉ុន្តែជាលទ្ធផល រូបមន្តមធ្យមភាគធំបំផុត បានរារាំងមិនឲ្យគណបក្សតូចៗអាចនឹងដណ្តើមអាសនៈណាមួយនោះបានទេ ព្រោះគណបក្សតូចអាចសង្ឃឹមថា នឹងដណ្តើមបានតែអាសនៈនៅសល់ ប៉ុន្តែតាមរូបមន្តអាសនៈនៅសល់ត្រូវឲ្យគណបក្សដែលមានសំឡេងឆ្នោតច្រើនតែប៉ុណ្ណោះ។

ជាងនេះទៅទៀត ប្រសិនបើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជ្រើសតាំងនូវការអនុវត្តបែបចំរុះអនុវត្តទាំងប្រព័ន្ធសមាមាត្រ និងប្រព័ន្ធឯកត្តនាម ដោយមានបញ្ចូលនូវយន្តការនៃបញ្ជីបេក្ខជនឯករាជ្យទៀតនោះ នេះជាការឆ្លុះបញ្ចាំងឲ្យឃើញនូវជំហានវិវត្តថ្មីមួយទៀតចំពោះដំណើរការបោះឆ្នោតតាមលក្ខណៈប្រជា

ធិបតេយ្យសម្រាប់ប្រទេសកម្ពុជា។ ជាពិសេសវាក៏បង្ហាញនូវវិសាលភាពអនុវត្តស្របតាមស្មារតីរដ្ឋធម្មនុញ្ញ ដែលបានចែងថា អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ (មាត្រា ៥១ថ្មីនៃរដ្ឋធម្មនុញ្ញ) តាមរយៈការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (អ្នកបំរើរាស្ត្រ) បែបប្រព័ន្ធសមាមាត្រ និងអធិបតេយ្យប្រជាពលរដ្ឋតាមរយៈការបោះឆ្នោតដោយផ្ទាល់ចំពោះបុគ្គលជាអ្នកតំណាងទាំងនោះតែម្តង។ អំណាចជារបស់ពលរដ្ឋ ពលរដ្ឋជាម្ចាស់ រដ្ឋជាអ្នកបំរើសេវា។ មាត្រា ៥១ថ្មីនៃរដ្ឋធម្មនុញ្ញ មានតម្លៃមួយយ៉ាងប្រណិតល្អឥតខ្ចោះ ទាំងផ្នែកគតិយុត្តិ និងនយោបាយ វាបានបង្ហាញយ៉ាងច្បាស់អំពីគោលការណ៍នៃអធិបតេយ្យភាពរបស់ប្រជាពលរដ្ឋ។ ទាំងគោលការណ៍អធិបតេយ្យជាតិ និងអធិបតេយ្យពលរដ្ឋសុទ្ធតែមានតម្លៃគតិយុត្តិជាធម្មនុញ្ញទាំងអស់។ ស្មារតីខ្លឹមសារនៃរដ្ឋធម្មនុញ្ញ បើទោះជាឆ្លងកាត់នូវវិសោធនកម្មច្រើនលើកច្រើនសារយ៉ាងណាក៏ដោយ ក៏នៅតែរក្សាការអនុគ្គគោការណ៍មូលដ្ឋានគ្រឹះទាំងពីរនេះជាដរាប។ ដោយសារក្នុងពេលដំណាលគ្នា គេត្រូវអនុវត្តនូវគោលការណ៍រដ្ឋធម្មនុញ្ញទាំងពីរនេះដូចគ្នា ដូច្នេះយន្តការសម្របសម្រួលនៃបំរើបំរាស់គោលការណ៍ទាំងពីររវាងការបោះឆ្នោតតាមប្រព័ន្ធសមាមាត្រ (បញ្ជីគណបក្សនយោបាយ) និងប្រព័ន្ធឯកត្តនាម (បេក្ខជនបោះឆ្នោតដោយផ្ទាល់ ឬ/និងបេក្ខជនឯករាជ្យ) គួរកំណត់ឲ្យបានច្បាប់ ដើម្បីចៀសវាងនូវភាពប្រទាំងប្រទិសគ្នានៃការអនុវត្តការរក្សានូវតុល្យភាព និងអត្ថិភាពព្រមៗគ្នានៃគោលការណ៍ ព្រមទាំងចៀសវាងការអនុវត្តតែគោលការណ៍មួយហើយទុកចោលគោលការណ៍មួយទៀតឲ្យនៅតុណ្ហីភាព។

## ៣.៣. បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប

គ.ជ.ប បានរៀបចំឲ្យមានដំណើរការក្នុងការផ្តល់មតិរៀបចំកិច្ចប្រជុំពិភាក្សាចំនួនពីរដងនៅថ្ងៃទី១៣ និងទី១៥ ខែកុម្ភៈ ឆ្នាំ២០១៣ រវាងសមាជិក និងមន្ត្រីគ.ជ.បជាមួយនឹងភាគីពាក់ពន្ធ័សំខាន់ៗ ទៅលើអនុសាសន៍របស់អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយដែលបានដាក់ជូនទៅគ.ជ.ប សម្រាប់ធ្វើការកែលម្អសេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៥ ឆ្នាំ២០១៣ នេះ។

ដោយយោងទៅតាមសេចក្តីសម្រេចរបស់គ.ជ.ប ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ ចំពោះអនុសាសន៍របស់អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយតាមរយៈខុមហ្វ្រែល និងការវាយតម្លៃរបស់អគ្គលេខាធិការគ.ជ.បថា ៤០%នៃអនុសាសន៍ ត្រូវបានសម្រេចទទួលយកដោយ គ.ជ.បវាជាចំណុចវិជ្ជមានខ្លះសម្រាប់កែលម្អបទបញ្ជា និងនីតិវិធី។

អង្គការសង្គមស៊ីវិលឃើញថាសេចក្តីសម្រេចរបស់គ.ជ.ប យល់ព្រមតាមអនុសាសន៍ ឬការស្នើកែលម្អដែលមានចំណុចសំខាន់មួយចំនួយដូចជា៖

- *ការហាមមន្ត្រីរាជការ មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយក្នុងពេលឃោសនាបោះឆ្នោត។*

ការអនុវត្តន៍សំណើនេះអាចនាំមកនូវការអនុវត្តន៍ច្បាប់បោះឆ្នោត ច្បាប់គណបក្សនយោបាយ និងច្បាប់ផ្សេងៗទៀតបានត្រឹមត្រូវក្នុងការធានាអព្យាក្រឹត្យកងយោធពលខេមរភូមិន្ទ នគរបាល មន្ត្រីតុលាការក្នុងយុទ្ធនាការឃោសនាបោះឆ្នោត។

- ការឃោសនារបស់គណបក្សនយោបាយអាចធ្វើបាននៅទីសាធារណៈដូចជា ទីផ្សារ។ គ.ជ.ប និងអាជ្ញាធរត្រូវកំណត់កន្លែងសាធារណៈ និងធ្វើអន្តរាគមន៍ដើម្បីឲ្យគណបក្សនយោបាយអាច

លើកស្លាកសញ្ញាបានតាមគោលការណ៍ស្មើភាព។ ការអនុវត្តន៍សំណើនេះអាចបង្កើនភាពត្រឹមត្រូវក្នុងការឃោសនាបោះឆ្នោតដោយគណបក្សនយោបាយ។

- *ស្លាកសញ្ញារបស់គណបក្សនយោបាយ និងសម្ភារៈឃោសនារបស់គណបក្សនយោបាយមិនត្រូវស្ថិតនៅក្នុងបរិវេណ ឬលើអាគារ ឬការិយាល័យរបស់រដ្ឋ។*

ការអនុវត្តន៍សំណើនេះនាំមកការពង្រឹងច្បាប់ ការអនុវត្តន៍ច្បាប់ច.ប.ត.រ និងច្បាប់ផ្សេងៗទៀតក្នុងការប្រើប្រាស់អាគាររបស់រដ្ឋ។

- *ការហាមការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលមិនមានស្លាកលេខ ឬស្លាកលេខក្លែងក្លាយក្នុងពេលឃោសនាបោះឆ្នោត។*

ការអនុវត្តន៍សំណើនេះអាចបន្ថយការបន្លំក្នុង ការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនរបស់រដ្ឋក្នុងឃោសនាបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយ។

- *ការជ្រើសរើសមន្ត្រីរៀបចំការបោះឆ្នោតដែលត្រូវបន្ថយល័ក្ខខណ្ឌ័បច្ចេកទេសទាក់ទិនទៅនឹងបទពិសោធន៍បោះឆ្នោត និងបន្ថែមល័ក្ខខ័ណ្ឌបញ្ឈប់ការជ្រើសរើសចេញពីសាច់ញាតិបង្កើត ឬប្តីប្រពន្ធក្នុង គណៈកម្មការតែមួយ។*

ការអនុវត្តន៍សំណើនេះអាចនាំមកនូវការជ្រើសរើសមន្ត្រីរៀបចំការបោះឆ្នោតដូចជា ស្ត្រី យុវជន និងជនពិការបានច្រើន និងបន្ថយទំនាស់ផលប្រយោជន៍នៃបុគ្គលិកក្នុងគណៈកម្មការតែមួយ។

ទោះបីជាយ៉ាងណាក៏ដោយ អង្គការសង្គមស៊ីវិលមានការខកចិត្ត និងព្រួយបារម្ភអំពីភាពជឿបាននៃភាពស៊ីសង្វាក់គ្នារបស់ គ.ជ.ប ក្នុងការអនុវត្តន៍ច្បាប់ដែលមានជាធរមាន គោលការណ៍បោះឆ្នោតដោយសេរី និងយុត្តិធម៌ និងគោលការណ៍ការពារសិទ្ធិអ្នកបោះឆ្នោត មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ និងអង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាល។

ពេលខ្លះដើម្បីបង្កើនសិទ្ធិអ្នកបោះឆ្នោត គ.ជ.ប រក្សាទុកឲ្យមេឃុំ ចៅសង្កាត់ចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត ក្រោយពេលចុះឈ្មោះបោះឆ្នោត បើទោះបីគ្មានមាត្រាណាមួយនៃ ច.ប.ត.រ ចង្អុលបង្ហាញ និងទោះបីមានការចោទប្រកាន់អំពីការបន្លំចេញលិខិតនេះពីគណបក្សនយោបាយក៏ដោយ។ គោលបំណង ដូចគ្នាដើម្បីជួយបង្កើនសិទ្ធិអ្នកបោះឆ្នោតដដែលនៅពេលអនុសាសន៍ថា ឲ្យគ.ជ.ប អនុវត្តសមត្ថកិច្ចរបស់ខ្លួនដូចមានចែងក្នុងមាត្រា៧៤នៃ ច.ប.ត.រ ដើម្បីស្នើទៅរាជរដ្ឋាភិបាល និងក្រសួងព័ត៌មានបង្កើនម៉ោងនៃវិទ្យុ និងទូរទស្សន៍រដ្ឋដើម្បីផ្សាយ និងអប់រំដល់អ្នកបោះឆ្នោត ផ្ទុយទៅវិញ គ.ជ.ប បានបដិសេធដោយមិនទាន់ដាក់សំណើទៅរាជរដ្ឋាភិបាល។

អង្គការសង្គមស៊ីវិលស្នើសុំទាមទារដោយទទូចទៅគ.ជ.ប សូមធ្វើការពិចារណាឡើងវិញលើការបដិសេធអនុអនុសាសន៍របស់អង្គការសង្គមស៊ីវិល (គ.ជ.ប មិនទាន់យល់ព្រម) ពីព្រោះក្នុងចំណុចទាំងនោះគឺសុទ្ធសឹងតែជាធាតុយ៉ាងសំខាន់ក្នុងការធ្វើឲ្យមានការអនុវត្តគោលការណ៍ជឿទុកចិត្តពីសំណាក់អ្នកពាក់ព័ន្ធពិសេសគណបក្សនយោបាយប្រកួតប្រជែងក្នុងការបោះឆ្នោតនៅកម្ពុជា មានដូចជា៖

- បង្កើតគណៈកម្មការជ្រើសរើស និងត្រួតពិនិត្យការតែងតាំងសមាជិក គជ/ខប គឃ/សប និងគបក/គករ ដោយមានការចូលរួមពីគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា។

គ.ជ.ប ពន្យល់មូលហេតុនៃការរក្សាទុកដូចខ្លឹមសារនៃសេចក្តីព្រាងបទបញ្ជា និងនីតិវិធីដោយយោង

មាត្រា១២ថ្មីថា គ.ជ.ប ជាអង្គការឯករាជ្យ និងអព្យាក្រឹត្យ។ ប៉ុន្តែស្មារតីនៃសេចក្តីព្រាងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប បានបញ្ជាក់ថា **អព្យាក្រឹត្យ និងឯករាជ្យ**នៃ គ.ជ.ប និយាយយោងទៅ**តំណាងទស្សនៈក្រុមទាំងអស់នៃសង្គមរួមមាន មន្ត្រីរាជការ គណបក្សនយោបាយ និងសង្គមស៊ីវិល**។ គណបក្សនយោបាយចូលរួមក្នុងការផ្តល់យោបល់អំពីការជ្រើសរើស និងត្រួតពិនិត្យការដាក់សំណើដោយគធ/ខប និងការតែងតាំងដោយ គ.ជ.បដែលមិនប៉ះពាល់ដល់ឯករាជ្យ និងអព្យាក្រឹត្យ ក្នុងការអនុវត្តន៍ការងារ។ ហើយនីតិវិធីនៃការតែងតាំងត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់ គ.ជ.ប ហើយគធ/ខប ក៏ត្រូវអនុវត្តសមត្ថកិច្ចក្នុងការបញ្ជូនសំណើបេក្ខជនសម្រាប់សមាជិក គឃ/សប និងគករ/គគរ ដូចមាននៅក្នុងច.ប.ត.រ ដដែល។

លក្ខខ័ណ្ឌនៃការជ្រើសរើស បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌សម្រាប់សមាជិកគណកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់នឹងត្រូវបានអនុវត្តដើម្បីពង្រឹងឯករាជ្យ និងអព្យាក្រឹត្យរបស់សមាជិកទាំងនោះក្នុងសមត្ថកិច្ច និងការអនុវត្តន៍ការងារបោះឆ្នោត។

- *អនុញ្ញាតឲ្យភ្នាក់ងារគណបក្សនយោបាយ «ឈរពីក្រោយលេខាធិការនៃការិយាល័យបោះឆ្នោតដែលអាចមើលឃើញច្បាស់ ហើយមានសិទ្ធិស្នើការផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោត នៅក្នុងបញ្ជីបោះឆ្នោតជាមួយនឹងឯកសារដែលយកមកបោះឆ្នោត»។ គោលការណ៍នេះត្រូវបានដាក់បញ្ចូលក្នុងនីតិវិធី និងសៀវភៅណែនាំដោយបង្ហាញរូបភាពផង។*

គ.ជ.បពន្យល់មូលហេតុនៃការរក្សាទុកដូចសេចក្តីព្រាងថា តំណាងគណបក្សនយោបាយមានសិទ្ធិតវ៉ា ឬជំទាស់។ ការស្នើនេះមិនសំដៅទៅលើការតវ៉ា ឬជំទាស់ទេ ប៉ុន្តែឲ្យភ្នាក់ងារគណបក្សនយោបាយឈរពីក្រោយលេខា។ គោលការណ៍ "ផ្ទៀងផ្ទាត់"ទិន្នន័យអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតជាមួយនឹងឯកសាររបស់អ្នកបោះឆ្នោតនេះមានលក្ខណៈដូចដំណើរការផ្ទៀងផ្ទាត់រាប់សន្លឹកឆ្នោត ដែលភ្នាក់ងារគណបក្សនយោបាយស្នើឲ្យសមាជិកនៃ គ.ក.ប/គ.ក.រ បង្ហាញសន្លឹកឆ្នោត ឬអានឲ្យខ្លាំងៗឡើងវិញ នៅពេលភ្នាក់ងារគណបក្សនយោបាយមើល ឬស្តាប់មិនទាន់។ គោលការណ៍នៃការផ្ទៀងផ្ទាត់នេះមិនមែនស្នើការប្តឹងនោះទេ ប៉ុន្តែវាគ្រាន់តែស្នើឲ្យមានការពិនិត្យឡើងវិញ ដើម្បីភាពជឿទុកចិត្តគ្នាក្នុងការបោះឆ្នោត។

- *ត្រូវយករបាយការណ៍ចំណូល ចំណាយរបស់គណបក្សនយោបាយក្នុងពេលឃោសនាបោះឆ្នោតដើម្បីបង្ហាញដល់សាធារណជន។*

គ.ជ.ប បានរក្សាជំហររបស់ខ្លួនដោយយោងមាត្រា៨២ កថាខ័ណ្ឌទី២នៃច.ប.ត.រ ដើម្បីរក្សាបញ្ញត្តិនៃសេចក្តីព្រាងបទបញ្ជា និងនីតិវិធីថា គ.ជ.ប អាចត្រួតពិនិត្យសៀវភៅគណនីនេះនៅ**ពេលមាន «ការចាំបាច់»** ដើម្បីរក្សាទុកដដែលដូចសេចក្តីព្រាង។ ប៉ុន្តែ **«ការចាំបាច់»** អាចត្រូវបានពន្យល់ថា គ.ជ.ប ត្រូវពង្រឹងតម្លាភាព និងការអនុវត្តន៍មាត្រា៨២ និង៨៣នៃ ច.ប.ត.រ ឲ្យមានប្រសិទ្ធិភាព។ **«ការចាំបាច់»** មិនមែននិយាយត្រឹមតែវិធានការត្រួពពិនិត្យនៅពេលមានភាពមិនប្រក្រតី ឬបញ្ហាបានកើតនោះទេ ប៉ុន្តែ**ការចាំបាច់**ក៏ត្រូវនិយាយទៅដល់វិធានការដើម្បី **ទប់ស្កាត់** បញ្ហា ឬភាពមិនប្រក្រតីផងដែរ ពោលគឺមានភាពចាំបាច់ដើម្បីទប់ស្កាត់បញ្ហា ឬភាពមិនប្រក្រតីនៃការបោះឆ្នោត។

- *មិនត្រូវទទួលស្គាល់ការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោតលើសពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣។ ឯកសារពាក់ពន្ធ័ទាំងនេះត្រូវបានគ្រប់គ្រងដោយ គឃសប/ ហើយត្រូវបិទផ្សាយជាសាធារណៈ។*

គ.ជ.ប បានបកស្រាយការរក្សាទុកដដែលដូចដំណើរការលើកមុន ដោយពន្យល់អំពីមូលហេតុដែលអាចធ្វើឲ្យបាត់បង់សិទ្ធិអ្នកចុះឈ្មោះបោះឆ្នោត។ សំណួរហេតុអ្វី គ.ជ.ប មិនបន្តចុះឈ្មោះអ្នកបោះឆ្នោតរហូតដល់ថ្ងៃស ចម្លើយព្រោះថា ច្បាប់បោះឆ្នោតបានកំណត់ពេលវេលាចុះឈ្មោះបោះឆ្នោត ចំណែកការចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោតនេះ ក៏ត្រូវមានពេលកំណត់ច្បាស់លាស់ ដើម្បីធានាពីតម្លាភាព និងភាពត្រឹមត្រូវក្នុងដំណើរការបោះឆ្នោត។ ម្យ៉ាងទៀត គ.ជ.ប អាចជួបហានិភ័យក្នុងការអនុវត្តន៍ច្បាប់នៅពេលមានការប្តឹងមន្ត្រីអំពីនីតិវិធីនៃការចេញលិខិតបញ្ជាក់សម្រាប់បម្រើឲ្យការបោះឆ្នោត ពីព្រោះថាគ្មានមាត្រាណាមួយនៃ ច.ប.ត.រ ចែងអនុញ្ញាតឲ្យមេឃុំ ចៅសង្កាត់ចេញលិខិតនេះក្រោយពេលដំណើរការចុះឈ្មោះនោះទេ។

បើសិនជាគ្មានការស្រុះស្រួលរវាងគណបក្សនយោបាយ និង គ.ជ.ប ដើម្បី**កំណត់រយៈពេលច្បាស់លាស់** និងធ្វើឲ្យមានតម្លាភាពក្នុងការចេញលិខិតបញ្ជាក់សម្រាប់បម្រើឲ្យការបោះឆ្នោតនេះទេ ក្នុងករណីមានការបន្លំ និងភាពមិនប្រក្រតីណាមួយ នោះការដាក់បន្ទុកនៃការចោទប្រកាន់ គ.ជ.ប ចំពោះនីតិវិធីក្នុងការចេញលិខិតនេះ ដែលនិយាយទៅដល់ការរំលោភ និងការខុសច្បាប់ ច.ប.ត.រ ទាំងស្រុង។

- *ត្រូវកែលម្អប្រការ ៧» និងប្រការផ្សេងៗដោយដកបទល្មើស ១០.មិនអព្យាក្រឹត្យ «របស់អង្គការមិនមែនរដ្ឋាភិបាល និងសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិលើកលែងអង្គការសមាគម ចូលរួមសង្កេតការណ៍បោះឆ្នោត ដែលទទួលស្គាល់ដោយ គ ជ.ប។.*

គ.ជ.ប រក្សាបទបញ្ជា និងនីតិវិធីរបស់ខ្លួនអាចគ្របដណ្តប់សមត្ថកិច្ចរបស់គ.ជ.ប ក្នុងការគ្រប់គ្រងអព្យាក្រិត្យភាពរបស់អង្គការមិនមែនរដ្ឋាភិបាល សមាគម ក្នុងស្រុក និងសមាគម អង្គការអន្តរជាតិទូទៅ។ ប៉ុន្តែ ច.ប.ត.រ បានឲ្យគ.ជ.ប ពាក់ពន្ធ័ជាមួយអង្គការ និងសមាគម «**ចូលរួម**សង្កេតការណ៍បោះឆ្នោតដោយមានការទទួលស្គាល់ពី គ.ជ.ប ។ គ.ជ.ប ត្រូវអនុវត្តច្បាប់ ច.ប.ត.រ ចំណុចទី៤ នៃមាត្រា១៦តែមានច្បាប់មានជាធរមានប៉ុណ្ណោះ»។ ម្យ៉ាងទៀត គណបក្សនយោបាយ ដោយឡែកគណបក្សប្រជាជនកម្ពុជា នៅក្នុងលក្ខន្តិកៈរបស់ខ្លួនមានបូកបញ្ចូលអង្គការមហាជនក្នុងការធ្វើសកម្មភាពគាំទ្រគណបក្សរបស់ខ្លួន។

អង្គការមហាជនគឺជានីតិបុគ្គលមិនមែនគណបក្សនយោបាយ និងមិនមែនជាស្ថាប័នរដ្ឋ ដូចនេះវាជានីតិបុគ្គល ឬផ្នែកមួយនៃអង្គការ សមាគមមិនមែនរដ្ឋាភិបាល ឬសង្គមស៊ីវិល។
ក្នុងករណី គ.ជ.ប អនុវត្តបទបញ្ជា និងនីតិវិធីទាក់ទិនអព្យាក្រឹតភាពចំពោះអង្គការ សមាគម ឯករាជ្យ ប៉ុន្តែមិនអនុវត្តចំពោះអង្គការមហាជនរបស់គណបក្សនយោបាយ ដែលនាំឲ្យមានការអនុវត្តន៍មិនស្របច្បាប់រួមមានការរើសអើង និងមាននិយាមពីរ (Double Standards ) ក្នុងការអនុវត្តន៍បទបញ្ជា និងនីតិវិធីបោះឆ្នោត។
ការបដិសេធមិនទទួលយកអនុសាសន៍ទាំងនេះ នឹងអាចជះឥទ្ធិពលអវិជ្ជមានដល់គុណភាពនៃដំណើរការ និងលទ្ធផលបោះឆ្នោត។

## ៤. ការជ្រើសរើសសមាជិកគណកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត(PEC) និងការគណកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត(CEC)

ការជ្រើសរើសគណកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត (គធ/ខប) បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី ០៨ ដល់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣។ ដំណើរការជ្រើសរើសនេះ គ.ជ.ប មិនបានធ្វើឡើងដោយទូលំទូលាយទេ ដោយតំណែងប្រធាន គធ/ខប ទាំងអស់ និងអនុប្រធាន គធ/ខប ចំនួន ១២រាជធានី/ខេត្ត ដែល

រួមមាន ខេត្តកំពត ស្វាយរៀង ព្រៃវែង បន្ទាយមានជ័យ កំពង់ស្ពឺ កំពង់ធំ តាកែវ បាត់ដំបង សៀមរាប កណ្ដាល កំពង់ចាម និងរាជធានី ភ្នំពេញ មិនត្រូវបានបើកឲ្យមានការជ្រើសរើសទេ ពោលគឺប្រធានលេខាធិការដ្ឋានរាជធានី/ខេត្តរៀបចំការបោះឆ្នោត (លធ/ខប)ទាំងអស់ និងអនុប្រធាន លធ/ខប ទាំង១២ខេត្តនោះបានក្លាយជាប្រធាន និងអនុប្រធាន គធ/ខប តែម្តង។ ករណីនេះគណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលមួយចំនួន បានសម្តែងការព្រួយបារម្ភព្រោះថា ការអនុវត្តន៍បែបនេះគឺវាមានលក្ខណៈមិនស្មើភាព និងមិនតម្លាភាព ដែលហាក់ផ្ទុយពីបទបញ្ជា និងនីតិវិធីបោះឆ្នោតដែលបានកំណត់ថា នីតិវិធីជ្រើសរើសមន្ត្រី បុគ្គលិកនៃ គ.ជ.ប សមាជិក និងបុគ្គលិកនៃ គធ/ខប គឃ/សប និងគកប/គករ ត្រូវឈរលើគោលការណ៍ស្មើភាព ដោយត្រឹមត្រូវ តម្លាភាព...។ អំពីការជ្រើសរើសមន្ត្រីទាំងនេះដែរ គជ.ប តែងតែធ្វើការច្រានចោលនូវសំណើរបស់អង្គការ. សង្គមស៊ីវិល និងគណបក្សនយោបាយដែលបានស្នើសុំឲ្យមានតំណាងគណបក្សនយោបាយដែលមានអាសនៈក្នុងសភាត្រូវបានអនុញ្ញាតឲ្យចូលរួមដោយផ្ទាល់ក្នុងត្រួតពិនិត្យការជ្រើសរើស និងការតែងតាំងនេះ ដើម្បីឲ្យការជ្រើសរើសប្រព្រឹត្តដោយតម្លាភាព បើកចំហ និងមានការពិនិត្យគ្នាទៅវិញទៅមក។

ក្នុងដំណាក់កាលនេះខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍នៅគ្រប់រាជធានីខេត្ត។ ការសង្កេតបានរកឃើញនូវចំណុចប្រក្រតី និងមិនប្រក្រតីមួយចំនួនដូចខាងក្រោម៖

- មានការប្រកាស ឬផ្សព្វផ្សាយសេចក្តីជូនដំណឹងពីការជ្រើសរើសនៅគ្រប់រាជធានី ខេត្ត។
- ការប្រកាស ឬផ្សព្វផ្សាយសេចក្តីជូនដំណឹងពីការជ្រើសរើស គធ/ខប ធ្វើនៅតែនោះស្នាក់ការលេខាធិការដ្ឋានរៀបចំការបោះឆ្នោត រួមមានខេត្តកណ្តាល ក្រចេះ និងខេត្តស្ទឹងត្រែង។ ជាមួយគ្នានេះការផ្សព្វផ្សាយគឺធ្វើតាមរយៈតែមួយមធ្យោបាយ ការបិទផ្សាយ) គឺមាននៅក្នុងខេត្ត)កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល ក្រចេះ តាកែវ មណ្ឌលគីរី ព្រៃវែង រតនគិរី សៀមរាប ព្រះសីហនុ ស្ទឹងត្រែង និងឧត្តរមានជ័យ។
- ដោយឡែកនៅខេត្តខ្លះទៀតគឺមានការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ក្នុងខេត្តផងដែរ។
- ស្ទើរគ្រប់ខេត្តទាំងអស់មានការប្រកាសលើកទឹកចិត្តដល់ស្ត្រី ជនពិការ និងជនជាតិដើមភាគតិចឲ្យមកចូលរួមដាក់ពាក្យ។ ដោយឡែកគឺមានតែខេត្តព្រៃវែង ដែលការសង្កេតមិនឃើញថា មិនបានបញ្ជាក់អំពី ការលើកទឹកចិត្តដល់ក្រុមទាំងនេះ។
- មានការចែកជូនពាក្យសុំដោយទូលំទូលាយ ដោយសេរី និងមិនគិតថ្លៃ។
- មិនមានការបដិសេធន៍មិនទទួលពាក្យរបស់បេក្ខជនទេ។
- ខេត្តភាគច្រើនគឺមានការសម្ភាសន៍បេក្ខជនដែលបានសំរាំងយក ដើម្បីបញ្ជូនទៅធ្វើការតែងតាំងនៅ គ.ជ.ប។ ប៉ុន្តែការសង្កេតបានរកឃើញថា នៅខេត្តបាត់ដំបង និងមណ្ឌលគីរី មានបេក្ខជនដែលត្រូវបានសំរាំងយកមួយចំនួនមិនបានឆ្លងកាត់ការធ្វើបទសម្ភាសន៍ទេ។
- បេក្ខជនដែលត្រូវបានសម្រេចជ្រើសរើសដើម្បីបញ្ជូនទៅ គ.ជ.ប ក្នុងមួយមុខតំណែង១ គឺភាគច្រើន មិនគ្រប់ចំនួនតាមការកំណត់ទេ។ នីតិវិធីជ្រើសរើសក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប បានកំណត់ថា គណៈកម្មការជ្រើសរើសត្រូវសំរាំងយកបេក្ខជនចំនួនបីនាក់ក្នុងមួយមុខតំណែង ដើម្បីបញ្ជូនមក គ.ជ.ប ធ្វើការតែងតាំង។

- មានបេក្ខជនជាស្ត្រីប្រមាណ ៣០% និងបក្ខជនជាយុវជនអាយុ ចន្លោះពី១៨ឆ្នាំ ដល់៣០ឆ្នាំ ប្រមាណតែ ១០% ប៉ុណ្ណោះនៃសមាជិក គធ/ខប ដែលត្រូវបានសំរាំងយក និងបញ្ជូនមក គ.ជ.ប . ដើម្បីធ្វើការតែង តាំង។ និង
- បេក្ខជនដែលត្រូវបានសម្រេចជ្រើសរើសដើម្បីបញ្ជូនទៅធ្វើការតែងតាំងជាសាច់ញាតិនៅក្នុង គណៈកម្មការតែមួយ កើតមានក្នុងខេត្តឧត្ដរមានជ័យ។

## ៥. ការរៀបចំការបោះឆ្នោត

### ៥.១ ការចុះឈ្មោះ និងសម្អាតបញ្ជីឈ្មោះបោះឆ្នោត

គ.ជ.ប ក្រុមប្រឹក្សាឃុំ/សង្កាត់ និងស្មៀនមួយចំនួនធំបានខិតខំបំពេញតួនាទីដោយបានចុះឈ្មោះអ្នកបោះឆ្នោតថ្មីលើសពីការប៉ាន់ស្មាន ពោលគឺចុះឈ្មោះបោះឆ្នោតបានចំនួន ៩១៦,៧៥៧នាក់ នៃចំនួនប៉ាន់ស្មានចំនួន ៦១៩,៦៣០នាក់។ ការប៉ាន់ស្មានអំពីស្ថិតិប្រជាពលរដ្ឋចុះឈ្មោះបោះឆ្នោតថ្មីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នៅតែបន្តមានភាពលំអៀងក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២ ដើម្បីផលិតបញ្ជីបោះឆ្នោតសម្រាប់បម្រើឲ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣។ បើតាមលទ្ធផលផ្លូវការរបស់ គ.ជ.ប ចំនួនអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១២គឺមានចំនួន ៩,៦៧៥,៤៥៣នាក់ ដែលចំនួននេះគឺជាចំនួនមួយដែលច្រើនជាងចំនួនអ្នកមានសិទ្ធិបោះឆ្នោតសរុបក្នុងឆ្នាំ២០១២។ ជាទូទៅនីតិវិធីនៃការលុបឈ្មោះនេះគឺនៅដដែល ដោយពឹងផ្អែកភាគច្រើនទៅលើក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលមកពីគណបក្សប្រជាជនកម្ពុជា។

ក្នុងដំណើរការនេះគណបក្សប្រឆាំងសំខាន់ចំនួន២ គឺគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស បានបដិសេធក្នុងការបញ្ជូនភ្នាក់ងាររបស់ខ្លួនទៅចូលរួមសង្កេតការណ៍ក្នុងដំណើរការនេះ ដោយអះអាងថានីតិវិធីនៃការចុះឈ្មោះ ការលុបឈ្មោះអ្នកបោះឆ្នោតអត់មានការផ្លាស់ប្ដូរ ដែលវាបានបង្កការលំបាក និងមានភាពស្មុគស្មាញដល់ប្រជាពលរដ្ឋ។ ទន្ទឹមគ្នានេះមន្ត្រីប្រតិបត្តិការចុះឈ្មោះបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ភាគច្រើនគឺមកពីគណបក្សប្រជាជនកម្ពុជា។ ជាក់ស្ដែងសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់មកពីគណបក្សប្រឆាំង ត្រូវបានហាមឃាត់មិនឲ្យលូកដៃចូលក្នុងដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតនេះទេ ព្រោះសមាជិកក្រុមប្រឹក្សាទាំងនោះមិនបានចុះឈ្មោះជាអ្នកសង្កេតការណ៍ ហើយពុំត្រូវបានចាត់តាំងពីប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ឲ្យជួយពិនិត្យមើលកិច្ចការរបស់ស្មៀន។ ស្ទើរតែទាំងអស់ក្នុងចំណោម ២៥០ឃុំ/សង្កាត់ដែលខុមហ្វ្រែលដាក់ពង្រាយអ្នកសង្កេតការណ៍រកឃើញថា គឺមានតែគណបក្សប្រជាជនកម្ពុជាទេ ដែលសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់របស់ខ្លួនបានរៀបចំការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។

គណបក្សទាំងពីរដែលមានតំណាងជាប់ឆ្នោតនៅថ្នាក់ឃុំ/សង្កាត់រហូតដល់ ២,៩៥៥នាក់ គួរមានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតសង្កេតឃ្លាំមើលការអនុវត្តន៍ការងារនេះ ដើម្បីធានាថា មន្ត្រីទទួលបន្ទុកទាំងនោះអនុវត្តត្រឹមត្រូវតាមច្បាប់ និងនីតិវិធីបោះឆ្នោត។

តាមរយៈSVRA Plus ខុមហ្វ្រែលបានធ្វើការសន្និដ្ឋានថា សំរាប់បញ្ជីឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ មាន ១៣,៥% នៃអ្នកចុះឈ្មោះបោះឆ្នោតមិនមានទិន្នន័យ ឬខុស

ឈ្មោះទាំងស្រុងក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការសំរាប់ការបោះឆ្នោត២០១៣ (ឈ្មោះរបស់ពួកគេមិនអាចរកឃើញ ឬឈ្មោះនោះអាចផ្លាស់ប្តូរទាំងស្រុង) ប្រហែលជាង ១,២៥លាននាក់ នៃអ្នកចុះឈ្មោះបោះឆ្នោតដែលអាចប្រឈមនឹងការបាត់បង់សិទ្ធិក្នុងការបោះឆ្នោតឆ្នាំ២០១៣ ចំនួននេះមានការថយចុះប្រមាណជាង ២ សែននាក់ ដោយយោងតាមរបាយការណ៍អង្កេតស្រាវជ្រាវបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១របស់ខុមហ្វ្រែល ប្រមាណ១,៥លាននាក់អ្នកចុះឈ្មោះបោះឆ្នោតបានបាត់ទិន្នន័យ ឬខុសឈ្មោះទាំងស្រុង ឬ១៧,២%នៃអ្នកចុះឈ្មោះបោះឆ្នោត។ ក្នុងចំណោមអ្នកចុះឈ្មោះដែលបាត់ទិន្នន័យ ឬខុសឈ្មោះទាំងស្រុង មានប្រមាណ២,៨៨% ត្រូវបានរកឃើញនៅក្នុងបញ្ជីលុបឈ្មោះអ្នកបោះឆ្នោត។ លទ្ធផលនេះបញ្ជាក់ថា ការលុបឈ្មោះអ្នកបោះឆ្នោតធ្វើឡើងដោយមានភាពមិនប្រក្រតីបានកើតឡើង ដោយសាម៉ីខ្លួននៅមានវត្តមាននៅក្នុងឃុំសង្កាត់ដែលខ្លួនរស់នៅ និងធ្លាប់បានចុះឈ្មោះបោះឆ្នោតក្នុងឃុំសង្កាត់នោះ ប៉ុន្តែឈ្មោះរបស់ពួកគេត្រូវបានលុបចេញពីបញ្ជីបោះឆ្នោតផ្លូវការសំរាប់ការបោះឆ្នោត២០១៣។ គ.ជ.ប បានធ្វើការលុបឈ្មោះ ៤៦៨,៤៨៥នាក់ ក្នុងអំឡុងពេលចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះឆ្នាំ២០១២ ដែលស្មើនឹងប្រមាណជិត ៥%នៃអ្នកចុះឈ្មោះសរុប។

យ៉ាងណាមិញ ការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោតរបស់NDI ដែលបានធ្វើការស្រាវជ្រាវពីបញ្ជីបោះឆ្នោតទៅមនុស្សក៏បានរកឃើញដែលថា ប្រជាពលរដ្ឋប្រមាណ៨២,៩%ប៉ុណ្ណោះ មានឈ្មោះក្នុងបញ្ជីបោះឆ្នោត។ ប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត ១០,៨% ដែលគិតថាខ្លួនមានឈ្មោះរួចហើយនោះ មិនត្រូវបានរកឃើញឈ្មោះក្នុងបញ្ជីបោះឆ្នោតទេ។

ដោយយល់ឃើញពីភាពមិនប្រក្រតីអំពីបញ្ជីឈ្មោះបោះឆ្នោត អនុសាសន៍របស់សង្គមស៊ីវិល និងគណបក្សនយោបាយមួយចំនួន ដែលស្នើសុំ គ.ជ.ប ធ្វើការបិទផ្សាយនៅតាមភូមិមុនការបោះឆ្នោត។ ការបិទផ្សាយនេះគឺបានជួយឲ្យអ្នកបោះឆ្នោតមានពេលវេលាច្រើនក្នុងការពិនិត្យឈ្មោះរបស់ខ្លួន ដែលជួយសម្រួលដល់អ្នកបោះឆ្នោតក៏ដូចជាមន្ត្រីការិយាល័យនៅថ្ងៃបោះឆ្នោត។ ប៉ុន្តែគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានធ្វើកែសម្រួលនីតិវិធីក្នុងការបិទផ្សាយបញ្ជីបោះឆ្នោត ដោយបានធ្វើការបិទផ្សាយបញ្ជីនេះជាសាធារណៈរយៈពេលមួយខែ (ចាប់ពីថ្ងៃទី២៧ ខែមិថុនា ដល់ថ្ងៃទី២៦ខែកក្កដា ឆ្នាំ២០១៣) នៅតាមទីស្នាក់ការគណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប)។ ទោះជាយ៉ាងនេះក្តី ការសង្កេតឃើញថា ការបិទផ្សាយនៅស្នាក់ការ គឃ/សប ហាក់មិនសូវមានប្រសិទ្ធិភាពទេ ព្រោះថា មានអ្នកបោះឆ្នោតតិចតួចបានទៅពិនិត្យឈ្មោះរបស់ខ្លួន។ មូលហេតុចំបងៗនៃការមិនសូវចាប់អារម្មណ៍ទៅពិនិត្យឈ្មោះរបស់អ្នកបោះឆ្នោតរួមមានដូចជា ការផ្សព្វផ្សាយមិនបានទូលំទូលាយ និងទីតាំងរបស់ស្នាក់ការ គឃ/សប ភាគច្រើនស្ថិតនៅក្នុងសាលារៀន ដែលធ្វើឲ្យប្រជាពលរដ្ឋភាគច្រើនមិនបានចាប់អារម្មណ៍ និងមិនបានទទួលព័ត៌មាន។

ជុំវិញបញ្ជីបោះឆ្នោតនេះដែរ ការសង្កេតឃើញថា ការដាក់បង្ហោះនៅគេហទំព័រ គ.ជ.ប ដែលមានអាស័យដ្ឋាន www.voterlist.org.kh គឺបានជួយសម្រួលច្រើនដល់អ្នកបោះឆ្នោតដែលមានលទ្ធភាពប្រើប្រាស់អ៊ិនធឺណែតក្នុងការស្វែងរកឈ្មោះរបស់ខ្លួន និងក្រុមខ្លួន ដែលវាមានភាពឆាប់រហ័ស និងងាយស្រួល ដោយមិនចាំបាច់ធ្វើដំណើរទៅពិនិត្យនៅស្នាក់ការ គឃ/សប ក៏ដូចជានៅឃុំ/សង្កាត់។ ដោយឡែកបើយោងតាមប្រកាសលេខ ០៧.០៧៦/១៣ របស់ គ.ជ.ប ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៣ បានសម្រេចបញ្ឈប់ដំណើរការគេហ

ទំព័រនេះ ដោយយោងហេតុផលថា ដើម្បីទប់ស្កាត់នូវភាពគ្មានសណ្តាប់ធ្នាប់ និងភាពមិនប្រក្រតី និងដើម្បីជៀសវាងការប្រមូលផ្តុំអ្នកបោះឆ្នោតមកពិនិត្យឈ្មោះក្នុងបញ្ជី បោះឆ្នោតតាមគេហទំព័រ ដោយភាគីណាមួយនៅថ្ងៃទី២៧ និង២៨ ខែកក្កដា ឆ្នាំ២០១៣។ ខុមហ្វ្រែលមានការសោកស្តាយចំពោះការប្រកាសបិទនេះ ហើយយល់ឃើញថា មូលហេតុ គ.ជ.ប បានលើកឡើងគឺមិនត្រឹមត្រូវ ព្រោះថាការបន្តដំណើរការគេហទំព័រនេះនៅថ្ងៃ «ស» និងថ្ងៃបោះឆ្នោតពិតជានឹងសម្រួលដល់អ្នកបោះឆ្នោត។

## ៥.២ ការចុះឈ្មោះបេក្ខជនគណបក្សនយោបាយ

ការចុះឈ្មោះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជន ប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៩ ខែមេសា ដល់ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៣។ មានគណបក្សនយោបាយចំនួន ០៨ បានស្នើសុំចុះបញ្ជី ហើយ គ.ជ.ប ក៏បានសម្រេចទទួលចុះបញ្ជីឲ្យគណបក្សទាំងនោះ ដើម្បីចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតនេះ។ គណបក្សទាំងនោះរួមមាន គណបក្សសញ្ជាតិកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ គណបក្សប្រជាជនកម្ពុជា គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច គណបក្សខ្មែរឈប់ក្រ គណបក្សសង្គ្រោះជាតិ និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។

គណបក្សនយោបាយដែលចូលរួមឈរបោះឆ្នោតក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺមានការថយចុះពីអាណត្តិមួយ ទៅអាណត្តិមួយ។ ជាក់ស្តែងនៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៣មានគណបក្សនយោបាយឈរឈ្មោះចំនួន ២០គណបក្ស ឆ្នាំ១៩៩៨ មាន ៣៩គណបក្ស ឆ្នាំ២០០៣ មាន ២៣គណបក្ស និងឆ្នាំ២០០៨ មាន ១១គណបក្ស។

តារាងទី១៖ ការចុះឈ្មោះគណបក្សនយោបាយ និងបេក្ខជនគណបក្សនយោបាយ

| 1993 | 1998 | 2002 | 2003 | 2007 | 2008 | 2012 | 2013 |
|---|---|---|---|---|---|---|---|
| 20 | 39 | 8 | 23 | 12 | 11 | 10 | 8 |

ក្នុងចំណោមគណបក្សនយោបាយដែលបានចុះបញ្ជីចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ មានតែគណបក្សនយោបាយចំនួន៥ប៉ុណ្ណោះដែលបានដាក់បេក្ខជននៅគ្រប់រាជធានីខេត្ត ដែលក្នុងនោះរួមមានគណបក្សសញ្ជាតិកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។ ដោយឡែកគណបក្សនយោបាយចំនួន៣ ដែលក្នុងនោះរួមមានគណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច និងគណបក្សខ្មែរឈប់ក្រ មិនបានដាក់បេក្ខជនគ្រប់រាជធានីខេត្តនោះទេ។

## ៥.៣ ការបែងចែកប័ណ្ណព័ត៌មានបោះឆ្នោត

នៅមុនការបោះឆ្នោតមកដល់ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតមានចំនួន ៨,៣២៨,១២០សន្លឹក ស្មើនឹង ៨៦,០៧% ត្រូវបានបែងចែកជូនអ្នកបោះឆ្នោតសំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣។

រូបភាពទី២៖ ការបែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត




Source: mediakampuchea

មានការរកឃើញថា មូលហេតុមួយក្នុងចំណោមមូលជាច្រើនទៀតដែលបណ្តាលឲ្យមានការបាត់សិទ្ធិអ្នកបោះឆ្នោតគឺបណ្តាលមកពីការចែកប័ណ្ណព័ត៌មានដោយមានការរើងអើង និងការបញ្ជាក់ពីគោលបំណងមិនច្បាស់លាស់ដែលធ្វើឲ្យអ្នកបោះឆ្នោត និងមន្ត្រីការិយាល័យរៀបចំការបោះឆ្នោតមួយចំនួនមានការភ័ន្តច្រឡំ។ គួរបញ្ជាក់លទ្ធផលស្រាវជ្រាវទៅលើអ្នកបោះឆ្នោតរបស់ខុមហ្វ្រែលក្នុងឆ្នាំ២០០៩ បានរកឃើញថា មានអ្នកមានសិទ្ធិបោះឆ្នោត ៩% មិនបានទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៤ ឆ្នាំ២០០៨ ដោយសារពួកគេគ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត។

សកម្មភាពចែកប័ណ្ណនេះបានធ្វើឡើងដោយគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) សហការជាមួយអាជ្ញាធរមូលដ្ឋានភូមិឃុំ ហើយត្រូវបានធ្វើឡើងជាពីរដំណាក់កាលគឺការបែងចែកនៅតាមភូមិ ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី០១ ខែមិថុនា ដល់ថ្ងៃទី២៥ខែមិថុនា ឆ្នាំ២០១៣ ដែលនៅក្នុងនោះចែកបានប្រមាណ៨,១លានសន្លឹក (៨៤,០៥% នៃឈ្មោះលើបញ្ជីបោះឆ្នោត) ត្រូវបានចែកដោយផ្ទាល់ដល់អ្នកបោះឆ្នោត។ និងចំនួនដែលនៅសល់រក្សាទុកនៅ គឃ/សប សម្រាប់ឲ្យអ្នកបោះឆ្នោតមកយកដោយខ្លួនឯងរហូតដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ដែលនៅក្នុងនោះដែរត្រូវបានអ្នកបោះឆ្នោតមកយកបន្ថែមទៀតចំនួន១៩៥,៤៤០សន្លឹក។ ការបែងចែកនេះធ្វើឡើងក្នុងគោលបំណងជូនដំណឹងដល់អ្នកបោះឆ្នោតម្នាក់ៗមុនការបោះឆ្នោតអំពីទិន្នន័យបោះឆ្នោតសំខាន់ៗរបស់ពួកគេ។ ការចែកប័ណ្ណព័ត៌មានជូនដល់អ្នកបោះឆ្នោតគឺមានសារៈសំខាន់ព្រោះថា ព័ត៌មានសំខាន់ៗរួមមានឈ្មោះ ភេទ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត របស់អ្នកបោះឆ្នោតម្នាក់ៗ ពេលវេលាបោះឆ្នោត និងឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតត្រូវបានដាក់បញ្ចូលនៅប័ណ្ណនេះ។ ខុមហ្វ្រែល តែងតែបង្ហាញការគាំទ្រចំពោះការចែកប័ណ្ណនេះ ព្រោះវាមានសារៈសំខាន់ដូចបានបញ្ជាក់ជូនខាងដើម ប៉ុន្តែអ្វីដែលអ្វីដែលសោកស្តាយនោះគឺដំណើរការបែងចែកនេះមិនបានប្រព្រឹត្តទៅដូចអ្វីដែលភាគីពាក់ព័ន្ធរំពឹងទុកនោះទេព្រោះថា អ្នកមានតួនាទីបែងចែក ជាពិសេសអាជ្ញាធរមូលដ្ឋានមានការរើសអើងក្នុងការបែងចែក និងបានប្រើប្រាស់វាសម្រាប់ផលចំណេញនយោបាយទៅវិញ ដោយសារតែប័ណ្ណព័ត៌មានមួយចំនួនត្រូវបានកិបភ្ជាប់ជាមួយប័ណ្ណឃោសនារបស់គណបក្សប្រជាជនកម្ពុជា។ ម្យ៉ាងវិញទៀត ការផ្តល់ព័ត៌មានមិនច្បាស់លាស់អំពីគោលបំណងនៃប័ណ្ណនេះ ដែលធ្វើឲ្យអ្នកមានសិទ្ធិបោះឆ្នោតបានបាត់បង់សិទ្ធិដោយសារតែឯកសារមួយនេះ។

## ៥.៤ លិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត

ពាក់ព័ន្ធនឹងការចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ការសង្កេតបានរកឃើញថា មេឃុំ ចៅសង្កាត់មួយចំនួន ដែលទទួលបន្ទុកការងារនេះមិនបានអនុវត្តតាមសេចក្តីណែនាំរបស់ គ.ជ.ប និងមានបញ្ហាមិនប្រក្រតីមួយចំនួនទៀត។ បើតាមសេចក្តីណែនាំរបស់ គ.ជ.ប បានតម្រូវឲ្យមេឃុំ ចៅសង្កាត់ធ្វើរបាយការណ៍អំពីការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោតនេះចំនួន៤ច្បាប់ ដែល១ច្បាប់ត្រូវបិទផ្សាយនៅសាលាឃុំ/ សង្កាត់នៅពេលបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។ ជុំវិញបញ្ហានេះការសង្កេតបានរកឃើញមេឃុំចៅសង្កាត់មួយចំនួនមិនបានអនុវត្តតាមសេចក្តីណែនាំនេះទេ ពោលគឺមិនមានធ្វើការបិទផ្សាយ ឬយឺតយ៉ាវក្នុងការបិទផ្សាយរបាយការណ៍នេះ។ ឃុំ/សង្កាត់ទាំងនោះរួមមានៈ ឃុំកញ្ច្រៀច ស្រុកកញ្ច្រៀច ឃុំបឹងដោល ស្រុកព្រះស្តេច ឃុំស្វាយជ្រំ ស្រុកមេសាង ខេត្តព្រៃវែង ឃុំកណ្តៀង ឃុំស្យា ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះ ឃុំជើងព្រៃ ស្រុកបាធាយ ខេត្តកំពង់ចាម ឃុំព្រែកក្មេង ស្រុកល្វាឯម ខេត្តកណ្តាលជាដើម។

គួរបញ្ជាក់ថា ការចេញលិខិតនេះគឺចាប់ផ្តើមពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១១ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១២។ ការចេញលិខិតនេះធ្វើឡើងនៅបន្ទាប់ពី គ.ជ.ប សម្រេចបញ្ឈប់ប្រើប្រាស់ទម្រង់ ១០១៨ ដែលត្រូវបានរកឃើញថា មានបញ្ហាមិនប្រក្រតីច្រើនក្នុងការចេញ និងការប្រើប្រាស់កន្លងមក។

គិតចាប់តាំងពីឆ្នាំ២០១១ រហូតមកដល់ការបោះឆ្នោតក្នុងឆ្នាំ២០១៣នេះ លិខិតនេះត្រូវបានចេញប្រមាណ ១,៨លានលិខិត ដែលក្នុងនោះ ១លាន៥ម៉ឺនលិខិតត្រូវបានចេញក្នុងការបោះឆ្នោតឆ្នាំ២០១២ និង៧៥ម៉ឺនលិខិត ចេញក្នុងការបោះឆ្នោតឆ្នាំ២០១៣នេះ។ អ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺចំនួនដ៏ច្រើននៃការចេញលិខិតនេះ ជាពិសេសនៅដំណាក់កាលក្រោយការផ្តល់សុពលភាពបញ្ជីបោះឆ្នោត (ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៣) ដែលមានប្រមាណ២៧ម៉ឺនសន្លឹក។ ចំនួនដ៏ច្រើននេះបានបង្កឲ្យមានការសង្ស័យអំពីភាពមិនប្រក្រតីនៃការចេញលិខិតនេះរបស់អាជ្ញាធរឃុំ សង្កាត់។ ជុំវិញចំនួនលិខិតនេះដែរ ការសិក្សាស្រាវជ្រាវរបស់ខុមហ្វ្រែលនៅក្រោយការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២បានរកឃើញថា អ្នកមានសិទ្ធិបោះឆ្នោតប្រមាណតែ ២៣ម៉ឺននាក់បាន និងកំពុងប្រើប្រាស់លិខិតនេះ។ ខេត្តដែលមានការចេញប័ណ្ណនេះច្រើនជាងគេរួមមាន ខេត្តកំពង់ចាម បាត់ដំបង តាកែវ ព្រៃវែង និងខេត្តកណ្តាល។ បើទោះជាមានការកែសម្រួលទ្រង់ទ្រាយខុសពីទម្រង់ ១០១៨ ប៉ុន្តែនីតិវិធីនៃការចេញលិខិតនេះគឺមានភាពប្រហាក់ប្រហែលគ្នាហើយក៏នៅតែបន្តទទួលរងការរិះគន់ និងសង្កេតឃើញថា មានភាពមិនប្រក្រតីបានកើតឡើង។

ក្រៅពីបញ្ហាដូចបានរកឃើញខាងលើ ការសង្កេតក៏បានរកឃើញភាពមិនប្រក្រតីមួយចំនួនក្នុងការចេញ និងការប្រើប្រាស់លិខិតនេះ។ បញ្ហាទាំងនោះរួមមាន ការចេញខុសពីរយៈពេលដែលបានកំណត់ ការចេញឲ្យអ្នកដែលគ្មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត ការចេញដោយគ្មានបោះត្រាឃុំ សង្កាត់ និងបិទរូបថតត្រឹមត្រូវ ការចេញដោយយកឈ្មោះគេផ្សេងមកបិទរូបថតអ្នកផ្សេងមួយទៀត គល់បញ្ជីមិនបានបំពេញត្រឹមត្រូវជាដើម និងបញ្ហាខ្វះតម្លាភាពក្នុងការចេញលិខិតនេះជាដើម។

ករណីមួយទៀតគឺស្មៀនជាអ្នកចេញលិខិតនេះឲ្យប្រជាពលរដ្ឋ ដោយចៅសង្កាត់បានចុះហត្ថលេខាទុកជាមុន ហើយនៅពេលមានការស្នើសុំពីប្រជាពលរដ្ឋ ស្មៀនគ្រាន់តែបំពេញបែបបទ និងបោះត្រាជាការស្រេច ហើយករណីនេះដែរបានកើតឡើងនៅខេត្តប៉ៃលិន។

## ៥.៥ ការឃោសនារបស់គណបក្សនយោបាយ

ការសង្កេតឃើញថា គណបក្សមួយចំនួនដូចជា គណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យជាដើម បានត្រៀមខ្លួនជាស្រេចសម្រាប់ការចូលរួមក្នុងការបោះឆ្នោតខាងមុខនេះ ដោយបាននិងកំពុងធ្វើសកម្មភាពជាបណ្ដើរៗមុនការឃោសនាបោះឆ្នោត ដូចជាៈ សកម្មភាពចុះពង្រឹងបណ្ដាញនៅមូលដ្ឋាន សកម្មភាពចែកអំណោយ ប្រកាសបញ្ចូលសមាជិកថ្មី ចងសម្ព័ន្ធភាព រៀបចំរចនាសម្ព័ន្ធគណបក្ស និងសកម្មភាពអូសទាញសមាជិក/អ្នកគាំទ្រគណបក្សផ្សេងៗឲ្យមកចុះចូលជាមួយគណបក្សខ្លួន និងសកម្មភាពលើកស្លាកសញ្ញាគណបក្ស។ ជាមួយគ្នានេះក៏មានសកម្មភាពផ្សព្វផ្សាយអំពីគោលនយោបាយ និងស្នាដៃនានារបស់គណបក្ស ឬមេដឹកនាំគណបក្សខ្លួនតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងសកម្មភាពមួយចំនួនទៀតទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានផងដែរ។

មានថាមវន្តនយោបាយថ្មី (New Political Dynamic) នៃការឃោសនាបោះឆ្នោតរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ (គណបក្សប្រឆាំង)។ គណបក្សទាំងពីរនេះបានធ្វើការឃោសនាយ៉ាងសកម្ម ហើយមានលក្ខណៈទ្រង់ទ្រាយធំ(ពីមួយម៉ឺនទៅបួនម៉ឺននាក់)នៅមណ្ឌលបោះឆ្នោតធំៗ។ បន្ទាប់ពីគណបក្សនេះ ក៏ឃើញមានគណបក្សហ្វ៊ុនស៊ិនប៉ិចបានធ្វើសកម្មភាពឃោសនាទ្រង់ទ្រាយធំ(តិចជាងមួយម៉ឺននាក់)ល្មមនៅរាជធានីភ្នំពេញ កំពង់ចាម និងតាកែវ។ សារនយោបាយ ចេញពីការឃោសនាមានឥទ្ធិពលទៅលើការឃោសនាបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ «ដូរ ឬមិនដូរ....ដូរ!» ។ ចំណែកគណបក្សប្រជាជនកម្ពុជា «ស្រលាញ់ ជឿ និងអាណិត ហ៊ុន សែន បោះឲ្យគណបក្សប្រជាជនកម្ពុជា» ឬ «ហ៊ានថា ហ៊ានធ្វើ!»។ សាខាគណបក្សប្រជាជនកម្ពុជាជាច្រើនបានផ្ដល់ថវិកាពី៥០០០រៀល ទៅ៣០០០០រៀលម្នាក់ក្នុងមួយថ្ងៃក្នុងមួយនាក់សំរាប់សកម្មជន និងអ្នកចូលរួមមួយចំនួនធ្វើសកម្មភាពឃោសនាបោះឆ្នោត។ ចំណែកឯគណបក្សសង្គ្រោះជាតិវិញ បានបង្កើតជាមូលនិធិ និងរៃអង្គាសប្រាក់។

រូបភាពទី៣៖ ការឃោសនារបស់គណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ និងគណបក្សហ្វ៊ុនស៊ិនប៉ិច







ការចូលរួមរបស់យុវជននៅក្នុងសកម្មភាពនយោបាយកាន់តែខ្លាំងឡើងៗ នៅក្នុងការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយមួយចំនួន ជាពិសេសគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។ បើទោះបីគណបក្សសង្គ្រោះជាតិរៀបចំហែក្បួនឃោសនារបស់ខ្លួនដោយមានសមត្ថកិច្ចនគរបាល (រក្សាសន្តិសុខបោះឆ្នោត)តិចតួចជួយធ្វើការសម្របសម្រួលក៏ដោយ ប៉ុន្តែសកម្មភាពទាំងនោះអាចដំណើរការបានដោយសារតែយុវជនចូលរួមយ៉ាងសស្រាក់សស្រាំ។

រូបភាពទី៨៖ ការចូលរួមរបស់យុវជនក្នុងសកម្មភាពឃោសនារបស់គណបក្សនយោបាយ



ដោយឡែក អាជ្ញាធរដែលមានតួនាទីជាអ្នកសម្របសម្រួលឲ្យគណបក្សនយោបាយទាំងអស់ទទួលបានភាពស្មើគ្នានៅទីកន្លែងសាធារណៈ ប៉ុន្តែបែរជាអាជ្ញាធរមានភាពលំអៀងយ៉ាងខ្លាំងទៅវិញ។ ការបិទខិត្តប័ណ្ណ ឬស្លាកសញ្ញានៅទីកន្លែងណាមួយតាមការស្នើសុំ ឬការជូនព័ត៌មានគណបក្សផ្សេងៗ ជាពិសេសគណបក្សសង្គ្រោះជាតិត្រូវបានបដិសេធដោយអាជ្ញាធរ។ សំរាប់ទីកន្លែងឯកជន ការបិទខិត្តប័ណ្ណ ឬក៏ការដាក់ស្លាកសញ្ញាគណបក្សរបស់គណបក្សប្រជាជនកម្ពុជាមិនត្រឹមតែមិនបានសុំទៅម្ចាស់ទៅម្ចាស់ផ្ទះប៉ុណ្ណោះទេ ប៉ុន្តែការបិទនោះត្រូវបានជួយជ្រោមជ្រែង ព្រមទាំងចាត់ចែងដោយអាជ្ញាធរថែមទៀតផង។ អាជ្ញាធរមិនត្រឹមតែចូលរួមក្នុងការរារាំងសកម្មភាពឃោសនារបស់គណបក្សផ្សេង(មិនមែនគណបក្សប្រជាជនកម្ពុជា) ហើយបានដាក់ពាក្យបណ្តឹងទៅគណបក្សប្រឆាំង ដូចជាគណបក្សសង្គ្រោះជាតិយ៉ាងហោច២៧បណ្តឹង ក្នុងនោះមាន១៥បណ្តឹងអំពីការបិទគោលនយោបាយនៅលើបង្គោលភ្លើងដោយគ្មានការអនុញ្ញាត។

មាន៣៧៣បណ្តឹង ត្រូវបានប្តឹងនៅគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ឃុំសង្កាត់ ហើយត្រូវបានបដិសេធចំនួន១៦៤បណ្តឹង (៤៣%)។ ដោយការមិនពេញចិត្តនៅការដោះស្រាយ ១២២បណ្តឹង ត្រូវបានប្តឹងបន្តនៅគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ខេត្ត/រាជធានី ដោយក្នុងនោះ ៨៤បណ្តឹងស្មើនឹង៦៨% ត្រូវបានបដិសេធ។ ៤៤បណ្តឹងត្រូវបានប្តឹងបន្តនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយនៅក្នុងចំណោមបណ្តឹងទាំងអស់នេះ ៤១បណ្តឹង ស្មើ៩៣% ត្រូវបានបដិសេធ។ យ៉ាងណាមិញ ១២បណ្តឹងត្រូវបានប្តឹងបន្តនៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលបណ្តឹងទាំងអស់នោះត្រូវបានបដិសេធចោលទាំងអស់។ បណ្តឹងភាគច្រើនទាក់ទងទៅនឹងការបំផ្លាញសំភារៈឃោសនា ការរំខានក្នុងពេលឃោសនា និងខុសនីតិវិធីក្នុងពេលឃោសនាបោះឆ្នោតជាដើម។ ការសង្កេតឃើញថា ការដោះស្រាយបណ្តឹងរបស់គ.ជ.ប មិនមានតម្លាភាពពីព្រោះបណ្តឹងមិនត្រូវបានដោះស្រាយដោយបើកចំហជាសាធារណៈ គឺភាគច្រើនធ្វើសវនការសង្ខេបប្រជុំ

សម្រេចផ្ទៃក្នុង។ អ្វីដែលគួរឲ្យកត់សំគាល់ គឺបណ្ដឹងដែលបានប្ដឹងគណបក្សសង្គ្រោះជាតិដោយអាជ្ញាធរក្រុង/ស្រុក/ខណ្ឌ អាជ្ញាធរឃុំសង្កាត់ និងអាជ្ញាធរកងរាជអាវុធហត្ថ។

ភាពមិនប្រក្រតីក្នុងដំណាក់កាលឃោសនាបោះឆ្នោត មានប្រមាណ ២៤៥ករណី ដែលក្នុងនោះមានដូចជា៖

- ការបំផ្លាញសម្ភារៈឃោសនារបស់គណបក្សនយោបាយភាគច្រើនគណបក្សសង្គ្រោះជាតិមាន ៤៦ករណី កើតឡើងនៅខេត្តកំពង់ចាម កណ្ដាល ក្រចេះ កំពត បន្ទាយមានជ័យ ព្រៃវែង ឧត្ដរមានជ័យ សៀមរាប កំពង់ស្ពឺ បាត់ដំបង កំពង់ធំ និងកំពង់ឆ្នាំង។
- ការបំភិតបំភ័យ គំរាមកំហែង និងហឹង្សា ភាគច្រើនទៅលើប្រជាពលរដ្ឋ និងសកម្មជនគណបក្សសង្គ្រោះជាតិមាន ៣៣ករណី កើតឡើងនៅខេត្តព្រៃវែង តាកែវ កំពត ឧត្ដរមានជ័យ បន្ទាយមានជ័យ ព្រៃវែង ភ្នំពេញ ប៉ៃលិន កណ្ដាល និងរតនគិរី។
- ការរំខានការឃោសនារបស់គណបក្សនយោបាយ ភាគច្រើនគណបក្សសង្គ្រោះជាតិ មាន២១ករណី នៅខេត្តព្រៃវែង ភ្នំពេញ និងកំពង់ឆ្នាំង។
- មិនមានអព្យាក្រឹត្យភាព និងការជ្រៀតជ្រែករបស់អាជ្ញាធរ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ដែល ក្នុងនោះ មេភូមិ អនុភូមិ និងអាជ្ញាធរដែនដីមាន ១២៤ករណី និងមានមន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ មន្ត្រី តុលាការចូលរួមធ្វើសកម្មភាពការឃោសនាឲ្យគណបក្សប្រជាជនកម្ពុជាមាន ករណី នៅខេត្តព្រៃវែង កំពង់ធំ កំពត រតនគិរី កំពង់ឆ្នាំង បាត់ដំបង ភ្នំពេញ កណ្ដាល ព្រះវិហារ សៀមរាប តាកែវ ស្វាយរៀង កំពង់ស្ពឺ កំពង់ចាម បាត់ដំបង និងកែប។
- ការចែកអំណោយរបស់គណបក្សប្រជាជនកម្ពុជាមាន១០ករណី មានលក្ខណៈការទិញទឹកចិត្តអ្នកបោះឆ្នោត នៅខេត្តរតនគិរី កំពង់ធំ កណ្ដាល កំពត និងកំពង់ចាម។
- ការចាប់ខ្លួនសកម្មជនគណបក្សសង្គ្រោះជាតិមានប្រមាណ០៦ករណី នៅខេត្តកំពតនិងកណ្ដាល
- ការប្រើប្រាស់យានយន្តរដ្ឋ និងយានយន្តគ្មានស្លាកលេខមានចំនួន១០ករណីដែលកើតឡើងនៅខេត្តកណ្ដាល ព្រៃវែង ប៉ៃលិន ឧត្ដរមានជ័យ កំពង់ឆ្នាំង សៀមរាបភ្នំពេញ។

## ៥.៦ ថ្ងៃបោះ និងរាប់សន្លឹកឆ្នោត

### ៥.៦.១ ភាពមិនប្រក្រតីនៅថ្ងៃស អំឡុងថ្ងៃបោះឆ្នោត

ចំនួនភាពមិនប្រក្រតីក្នុងកំឡុងពេលថ្ងៃស និងដំណើរការបោះឆ្នោត ព្រមទាំងរាប់សន្លឹកឆ្នោត ដែលរួមមានប្រមាណ១១,៦០៥ករណី (ថ្ងៃសមាន២០៣ករណី, កំឡុងពេលបោះឆ្នោតមាន ១១,១៣៩ករណី និងកំឡុងពេលរាប់សន្លឹកឆ្នោតមាន២៦៣ករណី) ដែលបានកើតឡើងភាពមិនប្រក្រតីនៅប្រមាណ២,១២៧ការិយាល័យបោះឆ្នោត ក្នុងចំណោមការិយាល័យអង្កេត៧,៧០០ការិយាល័យដែលកើតឡើងនៅគ្រប់ខេត្ត/រាជធានី ដូចជា កំពង់ចាម ៣,១៤៨ករណី, ភ្នំពេញ ២,១៨៥ករណី, កំពត ៨៦០ករណី, កណ្ដាល ៨៤០ករណី, ព្រៃវែង ៤៣៥ករណី, តាកែវ ៤៣១ករណី, សៀមរាប ៤១៣ករណី, ពោធិសាត់ ៣៨៣ករណី, ប៉ៃលិន ៣៥៤ករណី, បន្ទាយមានជ័យ ៣៤៤ករណី, បាត់ដំបង ៦៨៣ករណី, ក្រុងព្រះសីហនុ ២៦៥ករណី,

កោះកុង ២០២ករណី និងខេត្តផ្សេងៗទៀតក្រោម២០០ករណី។ ករណីទាំងអស់នេះត្រូវបានអ្នកសង្កេតការណ៍រាយការណ៍មកក្នុងនោះរួមមាន៖

១.១. ថ្ងៃស (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៣)

- ការធ្វើសកម្មភាពឃោសនាថ្ងៃសដោយខុសច្បាប់កើតមានយ៉ាងតិច១០៤ករណី នៅខេត្តកណ្តាល ព្រៃវែង កំពង់ចាម បន្ទាយមានជ័យ បាត់ដំបង កំពត ភ្នំពេញ មណ្ឌលគិរី ពោធិសាត់ រតនគិរី សៀមរាប ស្វាយរៀង តាកែវ និងប៉ៃលិន។
- បរិយាកាសដែលគ្មានសុវត្ថិភាពនៅក្នុងភូមិជុំវិញការិយាល័យបោះឆ្នោតចំនួនយ៉ាងតិច៦៤ករណី កើតឡើងនៅខេត្តកណ្តាល កំពង់ចាម ភ្នំពេញ ព្រៃវែង កំពត កំពង់ធំ បន្ទាយមានជ័យ និងតាកែវ។
- ករណីខ្វះសម្ភារៈមួយចំនួនដែលនាំឲ្យមានការរាំងស្ទះ ឬយឺតយ៉ាវដល់ដំណើរការនៃការបើកការិយាល័យបោះឆ្នោតមាន ៣៥ករណី នៅខេត្តកណ្តាល កំពង់ចាម ភ្នំពេញ កំពត ព្រៃវែង កំពង់ធំ តាកែវ ក្រុងព្រះសីហនុ រតនគិរី និងភ្នំពេញ។

១.២ ថ្ងៃបោះឆ្នោត (ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣)

- ការបាត់សិទ្ធិអ្នកបោះឆ្នោតមានរហូតដល់៨,៤៩០ករណី ដែលកើតមានឡើងនៅទូទាំងប្រទេសកម្ពុជា។ គួរបញ្ជាក់ថា ករណីនេះអ្នកបោះឆ្នោតដែលមានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ ឬអ្នកបោះឆ្នោតបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ២០១២ តែមិនមានឈ្មោះបោះឆ្នោតឆ្នាំ២០១៣នេះទេ។
- ការឃោសនាតាមរយៈការចែកអំណោយ ឬឃោសនាដោយចែក/បិទផ្ទាំងរូបភាព ឬខិត្តប័ណ្ណដើម្បីគាំទ្របេក្ខជន ឬគណបក្សនយោបាយរបស់ខ្លួនមាន១២៥ករណី ដែលកើតមាននៅខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពត កណ្តាល មណ្ឌលគិរី ភ្នំពេញ ព្រះវិហារ ព្រៃវែង ពោធិសាត់ រតនគិរី ស្វាយរៀង និងប៉ៃលិន។
- ការរារាំងបង្កឧបសគ្គ ឬហាមអ្នកសង្កេតការណ៍ចូលសង្កេតមានចំនួន ដូចជានៅតាមការិយាល័យមួយចំនួន២៧ករណី ដែលកើតឡើងនៅខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពត កណ្តាល កោះកុង ភ្នំពេញ ព្រៃវែង តាកែវ និងកែប។
- វត្តមានដោយខុសច្បាប់របស់អាជ្ញាធរមូលដ្ឋាន ជាពិសេស មេភូមិ និងអាជ្ញាធរមូលដ្ឋាន ឬ/និងកងកម្លាំងប្រដាប់អាវុធ (ដែលមិនមានពាក់ប្រឡង់ដៃសន្តិសុខរបស់គ.ជ.ប ឬមិនមានអាវុធ) នៅមុខ ឬក្បែរការិយាល័យបោះឆ្នោត ឬស្លៀកពាក់ឯកសណ្ឋាន ឬមានសកម្មភាពបំភិតបំភ័យអ្នកបោះឆ្នោតមានចំនួន២៩៦ករណី។ ករណីទាំងនេះកើតឡើងនៅស្ទើរគ្រប់ខេត្តរាជធានី។
- ការរារាំងអ្នកបោះឆ្នោត ដោយវិធីផ្តល់លុយកាក់ ឬសម្ភារៈដើម្បីកុំឲ្យទៅបោះឆ្នោតមាន ៤ករណី ដែលកើតឡើងក្នុងខេត្តកំពត កណ្តាល និងតាកែវ។
- មានអ្នកបោះឆ្នោតច្រើននាក់នៅកកកុញស្វែងរកឈ្មោះនៅមុខការិយាល័យបោះឆ្នោត ដែលធ្វើឲ្យអ្នកខ្លះបោះបង់ចោលការស្វែងរកឈ្មោះ ហើយត្រឡប់ទៅវិញមាន៦១៣ករណី ដែលកើតឡើងនៅខេត្តស្ទើរគ្រប់ខេត្ត/រាជធានី។

- នីតិវិធីនៃការបោះឆ្នោត មិនត្រូវបានគោរពពេញលេញដោយមន្ត្រីការិយាល័យ ដែលនាំមកនូវភាពមិនប្រក្រតីចំនួន១,១៩១ករណី នៅក្នុងការិយាល័យបោះឆ្នោត។ ករណីទាំងនេះកើតមានឡើងនៅគ្រប់ខេត្ត/រាជធានីដែលក្នុងនោះរួមមាន៖
  - មិនមានបង្ហាញហិបឆ្នោតទទេ មុនពេលចាប់ផ្តើមដំណើរការបោះឆ្នោតមាន២៨ករណី
  - ការបើកការិយាល័យយឺតជាងម៉ោង ៧:០០ព្រឹក (បើកមិនតាមពេលកំណត់) មាន៦៧ករណី។
  - ភាពមិនប្រក្រតីនានាដែលនាំឲ្យបាត់ភាពសម្ងាត់នៃដំណើរការបោះឆ្នោតមាន២៥២ករណី
  - អ្នកបោះឆ្នោតដែលមិនមែនជាជនពិការ(មិនអាចបោះឆ្នោតដោយខ្លួនឯងបាន) បានស្នើសុំឲ្យមន្ត្រីការិយាល័យបោះឆ្នោតជួយគូសសន្លឹកឆ្នោតឲ្យមាន១៨៥ករណី។
  - ការមិនពិនិត្យមើលម្រាមដៃ ឬមិនជ្រលក់ទឹកខ្មៅលាងមិនជ្រះ ឬមិនពិនិត្យផ្ទៀងផ្ទាត់បញ្ជីឈ្មោះជាមួយឯកសារ ឬការឲសន្លឹកឆ្នោតលើសពីមួយសន្លឹកមានចំនួន១៣៨ករណី។
  - ការផ្អាក ឬបិទការិយាល័យនៅពេលកំពុងដំណើរការបោះឆ្នោតមានចំនួន២០ករណី។
  - ការបដិសេធមិនឲ្យតំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ឈរពីក្រោយ ឬក្បែរលេខាការិយាល័យបោះឆ្នោតដែលអាចផ្ទៀងផ្ទាត់ឯកសារបញ្ជាក់អត្តសញ្ញាណអ្នកបោះឆ្នោតជាមួយបញ្ជីបោះឆ្នោតមានចំនួន៧៨ករណី។
  - ការហែកសន្លឹកឆ្នោតចេញពីគល់បញ្ជីសៀវភៅសន្លឹកឆ្នោត និង/ឬទុកមុនច្រើនលើសពីមួយសន្លឹកដោយមន្ត្រីការិយាល័យបោះឆ្នោតមាន ២៩៤ករណី។
  - មានអ្នកគ្មានសិទ្ធិបោះឆ្នោត ឬអ្នកមានស្នាមទឹកខ្មៅនៅម្រាមដៃសម្គាល់ថា បានបោះឆ្នោតរួចហើយ អនុញ្ញាតឲ្យបោះឆ្នោតម្តងទៀតមានចំនួន៨៥ករណី។
  - មានអ្នកបោះឆ្នោតព្យាយាមយកសន្លឹកឆ្នោតចេញមកក្រៅដើម្បីឲ្យអ្នកបោះឆ្នោតផ្សេងៗទៀតគូសមានចំនួន៩ករណី។
  - ការបដិសេធ ឬមិនអើពើ ឬមិនព្រមប្រគល់ទម្រង់ប្តឹងតវ៉ា ឬជំទាស់(ទម្រង់លេខ ១២០២) ទៅអ្នកបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយពីសំណាក់មន្ត្រីរៀបចំការបោះឆ្នោតមានចំនួន៣៥ករណី។

ទន្ទឹមនឹងនេះ ខុមហ្វ្រែល ក៏បានរកឃើញនូវភាពមិនប្រក្រតីផ្សេងៗដែលកើតឡើងក្រៅពីភាពមិនប្រក្រតីដែលបានរៀបរាប់ខាងលើ កើតមានដល់ទៅ៣៦៤ករណីបន្ថែមទៀតដែលមាននៅស្ទើរតែគ្រប់ ខេត្ត/ក្រុង។

### ១.៣ ភាពមិនប្រក្រតីក្នុងដំណើរការរាប់សន្លឹកឆ្នោត និងបូកសរុបលទ្ធផល

#### ១.៣.១ ភាពមិនប្រក្រតីក្នុងការថែរក្សាសុវត្ថិភាពសន្លឹកឆ្នោត

បន្ទាប់ដំណើរការនៃការបោះឆ្នោតបានបញ្ចប់នៅម៉ោង៣រសៀល ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ខុមហ្វ្រែលនៅបន្តពិនិត្យលើការថែរក្សា សុវត្ថិភាពសន្លឹកឆ្នោតរបស់មន្ត្រីរៀបចំការរាប់សន្លឹកឆ្នោតដែលក្នុងនោះ ខុមហ្វ្រែល បានរកឃើញនូវភាពមិនប្រក្រតីមួយចំនួនដូចជា៖

- ការអនុញ្ញាតឲ្យមនុស្សគ្មានភារកិច្ចដើរចេញចូលការិយាល័យបោះឆ្នោត នៅពេលប្រកាសបិទការិយាល័យ មានចំនួន២៨ករណីកើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ចាម មណ្ឌលគិរី ភ្នំពេញ ព្រៃវែង ពោធិសាត់ សៀមរាប ព្រះសីហនុ តាកែវ និងកែប។
- ករណីមិនមូលភ្ជិតសន្ទះបិទប្រឡោះសម្រាប់សន្លឹកឆ្នោត និងមិនចាក់សោឃ្លុំហិបឆ្នោតមានចំនួន៦ករណី កើតមាននៅខេត្តកំពង់ចាម រតនគិរី ព្រះសីហនុ និងតាកែវ។
- ការរំខាន រារាំង ដល់ដំណើរការរាប់សន្លឹកឆ្នោតមាន៣២ករណីកើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កំពត កណ្តាល ភ្នំពេញ ព្រៃវែង ពោធិសាត់ សៀមរាប ព្រះសីហនុ តាកែវ និងកែប។
- មានអ្នកយកអាវុធជាតិផ្ទុះចូលទៅខាងក្នុងការិយាល័យរាប់សន្លឹកឆ្នោតមាន៣ករណី ដែលកើតមានឡើងនៅខេត្តបន្ទាយមានជ័យ កំពង់ចាម រតនគិរី។

***ករណីសិក្សាទៅលើភាពមិនប្រក្រតីក្នុងថ្ងៃបោះឆ្នោត***

បន្ទាប់ពីថ្ងៃបោះឆ្នោត ស្របពេលដែលភាពមិនប្រក្រតីកើតឡើងជាច្រើនដែលអាចធ្វើឲ្យប៉ះពាល់លទ្ធផលបោះឆ្នោតនោះ អង្គការសង្គមស៊ីវិលរួមសហការគ្នាដោយសិក្សាទៅលើករណីដូចជា ការដឹកជញ្ជូនអ្នកបោះឆ្នោតដើម្បីបោះឆ្នោតនៅកន្លែងផ្សេង។ ក្នុងនោះអង្គការលីកាដូ បានរកឃើញថា នៅមណ្ឌលបោះឆ្នោតសាលារៀន ត្រពាំងក្រសាំង ដែលមានការិយាល័យបោះឆ្នោតលេខ១១៤៣ ១១០៣ ១១៧៣ និង០៨១៥ នៅក្នុងភូមិគោកធ្លោត ឃុំគោកចក ស្រុកវ៉ារិន្ទ ទាហានប្រហែល១,២០០នាក់ មកពីកងពិសេសលេខ ៩១១ (មកពីតំបន់បុស្សូរ នៅភាគខាងកើតនៃខេត្តព្រះវិហារ និងមកពីឃុំត្រពាំងត្រាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ) ត្រូវបានដឹកមកបោះឆ្នោតនៅទីនោះ។ ហើយអ្នកទាំងនោះសុទ្ធតែមានស្នាមទឹកខ្មៅជាប់នឹងម្រាមដៃរបស់ពួកគេរួចទៅហើយ។ គួរកត់សំគាល់ផងដែរ ភូមិត្រពាំងក្រសាំង គឺជាភូមិថ្មី ដែលមានមណ្ឌលបោះឆ្នោតចំនួនពីរ។

ការសិក្សារបស់អង្គការលីកាដូនៅស្រុកវ៉ារិន្ទ នៅការិយាល័យបោះឆ្នោតលេខ ១១៤២ និង០៨៧៧ នៅក្នុងសាលាបឋមសិក្សារួមរន់ថ្មី បានឃើញទាហ៊ានចំនួន ៦០០នាក់ ដែលមកពីកងពិសេសលេខ៩១១ ដូចគ្នា មកបោះឆ្នោតនៅក្នុងមណ្ឌលនេះ។ ទាហ៊ានទាំងនោះ ត្រូវបានដឹកជញ្ជូនមកដោយរថយន្តយោធាចំនួន៨គ្រឿង ពាក់ស្លាកលេខកងយុទ្ធពលខេមរភូមិន្ទ។ ក្រៅពីទាហ៊ានទាំងនោះមានតែពី២០ ទៅ៤០នាក់ប៉ុណ្ណោះជាប្រជាពលរដ្ឋស៊ីវិល។ ការិយាល័យលេខ១១៤២ ជាការិយាល័យថ្មីមួយដែរ បង្កើតឡើងក្នុងឆ្នាំបោះឆ្នោតនេះ។ ការិយាល័យនេះដែរមានចំនួនស្ត្រីតិច ធៀបនឹងចំនួនបុរសនៅក្នុងបញ្ជីបោះឆ្នោត។

ចំណែកឯនៅក្នុងមណ្ឌលបោះឆ្នោតសាលាបឋមសិក្សា ចាន់គិរី ភូមិគោកកណ្តាល ឃុំល្វាក្រាំង ស្រុកវ៉ារិន្ទ ខេត្តសៀមរាប មានការិយាល័យបោះឆ្នោតចំនួន២។ ការិយាល័យបោះឆ្នោតលេខ០៧៨១ ត្រូវបានបង្កើតឡើងសំរាប់ជនស៊ីវិល ហើយការិយាល័យលេខ ១១៥ សំរាប់ទាហ៊ាន។ មានអ្នកបោះឆ្នោតសរុបចំនួន ៦៩២នាក់ នៅការិយាល័យលេខ១១១៥ ដោយ៦៥០នាក់សុទ្ធតែជាបុរស ស្ត្រីមានតែ២នាក់ប៉ុណ្ណោះ។

ការសិក្សារបស់សមាគមអាដហុកទៅលើភាពមិនប្រក្រតីនានាដែលកើតឡើងក្នុងអំឡុងពេលបោះឆ្នោត បានរកឃើញថា ករណីដឹកជញ្ជូនអ្នកបោះឆ្នោតពីកន្លែងផ្សេងមកបោះឆ្នោតនៅគ្រប់ការិយាល័យនៅក្នុងឃុំក្រាំងយ៉ូវ តាមរយៈការដឹកជញ្ជូនដោយឡានទំនើបតូចៗ។ អ្នកបោះឆ្នោតទាំងអស់នោះប្រើលិខិតបញ្ជាក់

អត្តសញ្ញាណ បម្រើឲ្យការបោះឆ្នោត។ ករណីភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត។ ជាការកត់សម្គាល់លិខិតទាំងនោះប្រមាណ៥០ភាគរយធ្វើឡើងមិនត្រឹមត្រូវតាមនីតិវិធីពោលគឺគ្មានស្នាមមេដៃនៅគល់បញ្ជី និងមិនមានបិទរូបថត។ ការចេញលិខិតនេះគឺធ្វើឡើងដោយស្មៀន និងមេឃុំពីគណបក្សប្រជាជនកម្ពុជា ដោយមានការចូលរួមតិចតួចពីសមាជិកក្រុមប្រឹក្សាឃុំពីគណបក្សសម រង្ស៊ី និងសិទ្ធិមនុស្ស ហើយមិនមានការបើកចំហឲ្យធ្វើការពិនិត្យគល់បញ្ជីទេ សូម្បីតែចំនួនក៏មានការលាក់លៀមដែរ។ ទោះជាយ៉ាងណាស្មៀនឃុំបានបញ្ជាក់ថា ការខ្វះចន្លោះនីតិវិធីខ្លះគឺដោយសារប្រជាពលរដ្ឋសម្រុកមកធ្វើនៅពេលបិទបញ្ចប់ និងដល់ពេលដែលឃុំត្រូវបញ្ជូនគល់បញ្ជីទៅ គជ/ខប។ ចំនួនដែលបានចេញឲ្យអ្នកបោះឆ្នោតក្នុងឃុំនេះគឺប្រមាណជាង ៣០០០លិខិត។ ជាមួយគ្នានេះក៏មានការបញ្ជាក់ថាលិខិតនេះភាគច្រើនគឺចេញឲ្យអ្នកមកពីក្រៅ ដែលមិនមែនជាប្រជាពលរដ្ឋរស់នៅក្នុងឃុំទេ។

ការសិក្សាមួយទៀតត្រូវបានធ្វើឡើងនៅសង្កាត់កោះដាច់ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញដោយអង្គការនិកហ្វិច បានរកឃើញភាពមិនប្រក្រតីមួយចំនួនដូចជា៖ ករណីភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត។ ប្រភពពីប្រជាពលរដ្ឋបានឲ្យដឹងថា នៅថ្ងៃបោះឆ្នោតពួកខ្លួនចាប់បានអ្នកប្រើលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោតក្លែងក្លាយ ដោយលិខិតទាំងនោះមានការផ្តិតមេដៃជាសាក្សីពីអាជ្ញាធរភូមិឃុំកោះដាច់ទាំងអស់។ ក៏មានការបញ្ជាក់ថាអ្នកបោះឆ្នោតទាំងនោះភាគច្រើន គឺមកពីខេត្ត មិនមែនជាប្រជាពលរដ្ឋរស់នៅក្នុងភូមិឃុំនោះទេ។ ករណីជាក់ស្តែងមួយ មានអ្នកបោះឆ្នោតម្នាក់ឈ្មោះ ម៉ៅ វណ្ណនី បានកាន់លិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោតទៅបោះឆ្នោត បានធ្វើការបញ្ជាក់ថាខ្លួនមិនបានដឹងអ្វីនោះទេគឺខ្លួនត្រូវបានម្ចាស់ហាងភោជនីយដ្ឋាន ១០៨ បញ្ជូនខ្លួនមកបោះឆ្នោតនៅឃុំនេះ។ ករណីត្រូវបានស្មៀនឃុំកោះដាច់ធ្វើការបញ្ជាក់ថា ឃុំបានចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោតជូនអ្នកបោះឆ្នោត ចំនួន ៤៦១ច្បាប់ ហើយលិខិតទាំងនោះមិនមានការផ្តិតមេដៃធ្វើសាក្សីពីអាជ្ញាធរភូមិឃុំនោះទេ។

រីឯការសិក្សារបស់វិទ្យុសម្លេងប្រជាធិបតេយ្យ (VOD) បានរកឃើញនូវបញ្ហាមិនប្រក្រតីនៅឃុំគ្រឿងរាយ ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង មានករណីដឹកជញ្ជូនអ្នកបោះឆ្នោតពីកន្លែងផ្សេងមកបោះឆ្នោតនៅតាមទីតាំងការិយាល័យទាំងអស់ក្នុងឃុំ។ ប្រជាពលរដ្ឋ និងមន្ត្រីគណបក្សប្រឆាំងបានបញ្ជាក់ថា មានក្រុមការងារគណបក្សប្រជាជនកម្ពុជាបានដឹកជញ្ជូនអ្នកបោះឆ្នោត ដែលមិនមែនជាប្រជាពលរដ្ឋក្នុងភូមិឃុំ និងជនជាតិវៀតណាម ប្រមាណជិត៣០០នាក់ ឲ្យមកបោះឆ្នោតនៅតាមទីតាំងការិយាល័យទាំងអស់ក្នុងឃុំ។ ប្រភពដដែលបានបន្ថែមទៀតថា មានឡានជិត៣០គ្រឿងបានដឹកជនប្លែកមុខទាំងនោះ។ ករណីនេះលោក ប៉ែន ថុន មេឃុំគ្រឿងរាយ បានទទួលស្គាល់ថា ពិតជាមានជនប្លែកមុខមួយចំនួនចូលមកបោះឆ្នោនៅក្នុងឃុំគ្រឿងរាយមែន ប៉ុន្តែអ្នកទាំងនោះជាជនជតិខ្មែរ មិនមែនជនជាតិវៀតណាមទេ។ លោកបញ្ជាក់ថា អ្នកទាំងនោះជាក្រុមការងាររបស់គណបក្សប្រជាជនកម្ពុជា ដែលចុះមកពង្រឹង និងធ្វើការអភិវឌ្ឍន៍នៅស្រុកកញ្ជ្រៀច ហើយអ្នកទាំងនោះមានលិខិតបេសកម្ម និងប្តូរទីលំនៅមកស្រុកកញ្ជ្រៀចត្រឹមត្រូវ។

រូបភាពទី៥៖ អំពើហឹង្សាកើតឡើងនៅថ្ងៃបោះឆ្នោតនៅស្ទឹងមានជ័យដោយការបញ្ហាបោះឆ្នោត និងការហាមឃាត់ជនជាតិវៀតណាមមិនអឲ្យបោះឆ្នោត





## ៥.៧ ការរាប់សន្លឹកឆ្នោត និងលទ្ធផលបោះឆ្នោត

១.៣.២ ភាពមិនប្រក្រតីក្នុងដំណើរការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៅការិយាល័យរាប់សន្លឹកឆ្នោត

នៅពេលរាប់សន្លឹកឆ្នោត ការសង្កេតឃើញថា មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោត មិនបានគោរពបទបញ្ញា និងនីតិវិធីព្រមទាំងសេចក្តីណែនាំនានារបស់គ.ជ.ប ដែលធ្វើឲ្យមានភាពមិនប្រក្រតីមួយចំនួនកើតឡើងដូចខាងក្រោម៖

- ការពន្យារពេលរាប់សន្លឹកឆ្នោតក្នុងការិយាល័យរាប់សន្លឹកឆ្នោត មានចំនួន១៥ករណី ដែលកើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ចាម មណ្ឌលគិរី ភ្នំពេញ ពោធិសាត់ ស្វាយរៀង តាកែវ និងឧត្តរមានជ័យ។
- ការមិនអនុញ្ញាតឲ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចូលរួមសង្កេតដំណើរការរាប់សន្លឹកឆ្នោតមានយ៉ាងហោចណាស់មាន៦ករណី ដែលកើតឡើងនៅខេត្តកំពង់ចាម កណ្តាល និងព្រៃវែង។
- ការមិនបង្ហាញឲ្យអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយចូលរួមពិនិត្យ សោឃ្លុំមុននឹងបើកគំរបហិបឆ្នោតមានយ៉ាចហោចណាស់មាន៨ករណី ដែលកើតឡើងនៅខេត្តបន្ទាយមានជ័យ កំពង់ចាម ភ្នំពេញ និងព្រៃវែង។
- ការបិទទ្វារ ឬបង្អួចការិយាល័យរាប់សន្លឹកឆ្នោតនៅពេលកំពុងដំណើរការរាប់សន្លឹកឆ្នោតមាន៣៣ករណី ដែលកើតឡើងនៅខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ធំ កំពតកណ្តាល មណ្ឌលគិរី ភ្នំពេញ ពោធិសាត់ ព្រះសីហនុ តាកែវ និងកែប។
- ការបិទទីតាំងការិយាល័យរាប់សន្លឹកឆ្នោតនៅពេលកំពុងដំណើរការរាប់សន្លឹកឆ្នោតមាន៧ករណី ដែលកើតមាននៅខេត្តកំពង់ចាម ភ្នំពេញ និងរតនគិរី។
- ការអានញាប់ពេកមិនច្បាស់ ឬមិនបង្ហាញសន្លឹកឆ្នោតទៅអ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយមានចំនួន៥២ករណី ដែលកើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ចាម កំពត កណ្តាល ភ្នំពេញ ព្រៃវែង ពោធិសាត់ សៀមរាប ព្រះសីហនុ តាកែវ និងកែប។

- ភាពមិនត្រឹមត្រូវក្នុងការប្រកាសលទ្ធផលនៃការរាប់សន្លឹកឆ្នោតមានចំនួន១៨ករណីដែលកើតឡើងជាពិសេសនៅខេត្តកំពង់ចាម កំពង់ឆ្នាំង កំពត ភ្នំពេញ រតនគិរី សៀមរាប និងតាកែវ។
- ការទទួលស្គាល់សន្លឹកឆ្នោតបានការ និងការបដិសេធលើសន្លឹកឆ្នោតមិនបានការដោយមិនអនុញ្ញាតឲ្យអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយបានធ្វើការត្រួតពិនិត្យមាន២០ករណី ដែលកើតមាននៅខេត្តកំពង់ចាម កំពត ភ្នំពេញ សៀមរាប ព្រះសីហនុ និងតាកែវ។
- បញ្ហាខ្វះខាតសម្ភារៈសំខាន់ៗ ធ្វើឲ្យរាំងស្ទះដល់ដំណើរការរាប់សន្លឹកឆ្នោតមានចំនួន១០ករណីដែលកើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ចាម ភ្នំពេញ ព្រៃវែង ពោធិសាត់ និងស្វាយរៀង។

១.៣.៣ ភាពមិនប្រក្រតីក្នុងការរៀបចំ និងការវេចខ្ចប់សម្ភារៈឯកសារបោះឆ្នោត

- ការមិនបង្ហាញកំណត់ហេតុបោះឆ្នោត និងរាប់សន្លឹកឆ្នោតចំពោះអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយមានចំនួន១០ករណី ដែលកើតឡើងនៅខេត្តកំពង់ចាម កំពង់ធំ និងព្រៃវែង។
- ការមិនអនុញ្ញាតឲ្យអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយសង្កេតមើលរាល់ដំណើរការនៃការរៀបចំ និងវេចខ្ចប់សម្ភារៈឯកសារបោះឆ្នោត សម្រាប់បញ្ជូនពីការិយាល័យរាប់សន្លឹកឆ្នោតទៅគឃ/សប មានចំនួន៤ករណី នៅខេត្តកំពង់ចាម និងព្រៃវែង។
- ការមិនផ្តល់ព័ត៌មានដល់អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សយោបាយ អំពីផ្ទះ ឬទីតាំងសុវត្ថិភាពដែលរក្សាទុកលទ្ធផលបោះឆ្នោតទៅគករមានចំនួន១៨ករណីដែលកើតឡើងនៅខេត្តបាត់ដំបង កំពង់ចាម កំពត កណ្តាល មណ្ឌលគិរី ភ្នំពេញ រតនគរី ព្រះសីហនុ និងស្វាយរៀង។

## ៦. ប្រព័ន្ធផ្សព្វផ្សាយ

### ៦.១ ការរំលោភក្រមសីលធម៌ និងបទបញ្ញារបស់គ.ជ.ប

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានសង្កេតឃើញ ថាប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅកម្ពុជារួមមានវិទ្យុ និងទូរទស្សន៍ គឺមិនទាន់មានមាត្រដ្ឋានត្រឹមត្រូវណាមួយដើម្បីចាក់ផ្សាយនោះទេ ព្រោះកម្ពុជាមិនទាន់មានច្បាប់ស្តីពីការគ្រប់គ្រងការផ្សាយព័ត៌មាននៅឡើយនោះទេ។ ស្ថានីយ៍វិទ្យុដែលផ្សាយផ្ទាល់ និងផ្សាយបន្តមានចំនួន ៩៧ ស្ថានីយ៍ នៅទូទាំងរាជ ធានីខេត្ត និងស្ថានីយទូរទស្សន៍ចំនួន ៥៤ យោងតាម របាយការណ៍ស្តីពីស្ថិតិស្ថានីយវិទ្យុ ទូរទស្សន៍ដែលដំណើរការផ្សាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា របស់នាយកដ្ឋានសោតទស្សន៍នៃក្រសួងព័ត៌មានដែលចេញផ្សាយកាលពីឆ្នាំ២០០៩។ ដោយសារតែច្បាប់ស្តីពីការគ្របគ្រងការផ្សាយព័ត៌មាននៅមិនទាន់បានបង្កើតឡើង ដូច្នេះការផ្សាយរបស់ស្ថានីយវិទ្យុភាគច្រើន និងទូរទស្សន៍ទាំងអស់ មិនបានមិនគោរពតាមក្រមសីលធម៌វជ្ជាជីវៈនិងគោលការណ៍ណែនាំរបស់ គ.ជ.ប ទាក់ទងនឹងតុល្យភាពនៃព័ត៌មាន និងគោលការណ៍ស្មើភាពគ្នានោះ

ទេ ជាពិសេសការផ្សាយដែលពាក់ព័ន្ធនឹងបញ្ហានយោបាយ។ ជាក់ស្តែង ខុមហ្វ្រែលឃើញថា ទូរទស្សន៍ទាំងអស់ និងស្ថានីយវិទ្យុមួយចំនួនធំមាននិន្នាការចំពោះ ឬត្រូវបានគ្រប់គ្រងដោយផ្ទាល់ ដោយគណបក្សប្រជាជនកម្ពុជា ជាគណបក្សកាន់អំណាច ខណៈដែលវិទ្យុមួយចំនួនតូចគាំទ្រគណបក្សប្រឆាំង និងផ្សេងទៀតដែលមិនមាននិន្នាការចំពោះគណបក្សនយោបាយ។ ហើយការប្រើប្រាស់ភាសាក្នុងការផ្សាយកម្មវិធីដែលពាក់ព័ន្ធនឹង រឿងនយោបាយនៅក្នុងស្ថានីយវិទ្យុទាំងនោះគឺមានលក្ខណៈប្រមាថ ញុះញ៉ង់ និងចោទប្រកាន់គ្នាទៅវិញទៅមក។

ស្ថានីយ៍វិទ្យុបាយ័ន FM 95 MHz ដែលត្រូវបានគេស្គាល់ថា ស្ថិតនៅក្រោមការគ្រប់គ្រងរបស់កូនស្រីលោកនាយរដ្ឋមន្ត្រីជាថ្នាក់ដឹកនាំកំពូលរបស់គណបក្សប្រជាជនកម្ពុជា បាននិងកំពុងបន្តផលិតកម្មវិធីដែលមានឈ្មោះថា "នាទីវប្បធម៌ខ្មែរ" ដែលអនុញ្ញាតឲ្យអ្នកចូលរួមសម្តែងមតិទស្សនៈនយោបាយរបស់ខ្លួន។ ក្នុងកម្មវិធីនោះ គេសង្កេតឃើញថារាល់មតិយោបល់ ឬទស្សនៈនយោបាយមិនត្រឹមតែសុទ្ធតែគាំទ្រគណបក្សប្រជាជនកម្ពុជានោះទេ តែថែមទាំងបាន ប្រមាថ ញុះញង់ និងចោទប្រកាន់ថ្នាក់ដឹក នាំគណបក្សប្រឆាំងផងដែរ។ ឧទាហរណ៍ការសង្កេតឃើញមានការហៅមេដឹកនាំគណបក្សប្រឆាំងថាជាជនអគតិ និងធ្វើការផ្សព្វផ្សាយថា បើគណបក្សប្រឆាំងមានឱកាសគ្រប់គ្រងប្រទេសជាតិ នោះនឹងបង្កឲ្យមានសង្គ្រាម ឬរបបប៉ុលពតនឹងអាចកើតសាជាថ្មីជាមិនខានឡើយ។

ស្ថានីយ៍វិទ្យុសំបុកឃ្មុំ FM 105 MHz ដែលអ្នកគ្រប់គ្រងស្ថានីយវិទ្យុនេះហាក់ដូចជាត្រូវបានគេ ចាត់ទុក ជាអ្នកនយោបាយ គឺ លោក ម៉ម សូណង់ដូ បានលក់ម៉ោងផ្សាយរបស់ស្ថានីយរបស់ខ្លួនទៅឲ្យគ្រប់បណ្តាគណបក្សនយោបាយ និងកម្មវិធីដែលមាននិន្នាការគាំទ្រគណបក្សនយោបាយផងដែរ។ គណបក្សសង្គ្រោះជាតិតែងតែផ្សាយសកម្មភាព និងសារនយោបាយរបស់ខ្លួនតាមរយៈស្ថានីយវិទ្យុនេះ។ បើពិនិត្យពីការប្រើប្រាស់ភាសាក្នុងការផ្សាយកម្មវិធីរបស់គណបក្សសង្គ្រោះជាតិនៅក្នុងស្ថានីយ វិទ្យុនោះ ឃើញថា មិនមានការខុសប្លែកគ្នានឹងការផ្សាយរបស់ស្ថានីយវិទ្យុបាយ័ននោះទេ។ គណបក្សសង្គ្រោះជាតិ ជារឿយៗបានរិះគន់ និងចោទប្រកាន់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលរួមមាន៖ ជាអាយ៉ងយួន និង ជាចោរលួចជាតិ ជាដើម។ បន្ថែមលើពីនេះទៀត ស្ថានីយ៍វិទ្យុមួយនេះក៏បានលក់ម៉ោងផ្សាយរបស់ ខ្លួនឲ្យកម្មវិធីពលរដ្ឋវិជ្ជា ដែលត្រូវបានគេស្គាល់ថាជាកម្មវិធីមួយគាំទ្ររាជរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ហើយកម្មវិធីស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ គឺលោកបណ្ឌិត ឈឹម ផល វរុណ។ កម្មវិធីនេះបានផ្សាយការរិះគន់ ប្រមាថមើលងាយចោទប្រកាន់ថ្នាក់ដឹកនាំគណបក្សសង្គ្រោះ ជាតិ រួមទាំងវាយប្រហារ លោក ខឹម វាសនា ប្រធានគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យផងដែរ។ មេនិកាយសាសនាកុលសម្ព័ន្ធជេរ គឺជាពាក្យមួយដែលត្រូវបានគេឮក្នុងកម្មវិធីពលរដ្ឋវិជ្ជា ហើយពាក្យនេះត្រូវបានគេប្រើសម្រាប់ហៅ លោក ខឹម វាសនា ដែលតែងតែយកទ្រឹស្តី ព្រះពុទ្ធសាសនា ផ្សារភ្ជាប់ជាមួយគោលនយោបាយរបស់គណបក្សខ្លួន។

ដោយឡែកក្នុងអំឡុងពេលឃោសនាបោះឆ្នោត គឺនៅថ្ងៃទី២៣ និង២៤ ខែកក្កដា ឆ្នាំ២០១៣ ស្ថានីយវិទ្យុ ABC កម្ពុជា FM 107.5 MHz បានផ្សាយការអត្ថាធិប្បាយរបស់ពិធីករវិទ្យុនេះ ដែលមានខ្លឹមសារប្រសិនបើគណបក្សសង្គ្រោះជាតិជាប់ឆ្នោត ហើយបង្កើតរដ្ឋាភិបាល អ្នកវិនិយោគទាំងអស់នឹងដកការបណ្តាក់ទុនពីកម្ពុជា ក្រោយការបង្កើតរដ្ឋាភិបាលបាន ៣ខែ នឹងមានទាហានចូលមកគ្រប់គ្រងប្រទេស ប្រទេសទាំងមូលនឹងបិទ (មិនមានទំនាក់ទំនងជាមួយអន្តរជាតិ) និងមានឈាមស្រោចផែនដីម្តងទៀត (ដូចរបបខ្មែរ

ក្រហម)...ជាដើម។ ជាមួយគ្នានេះ ពិធីករទាំងពីរក៏មានការប្រើពាក្យសម្ដីមិនសមរម្យ (អសីលធម៌) ចំពោះគណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតផងដែរ។ ខ្លឹមសារនៃការអត្ថាធិប្បាយខាងលើនេះ បង្ហាញយ៉ាងច្បាស់ថា ស្ថានីយ៍វិទ្យុបានផ្ញើសារបំភិតបំភ័យ និងប៉ះពាល់ដល់ឆន្ទៈដោយសេរីរបស់អ្នកបោះឆ្នោត និងធ្វើឲ្យខូចសណ្ដាប់ធ្នាប់សង្គម អសីលធម៌ និងប្រមាថដល់កងកំលាំងប្រដាប់អាវុធនៃព្រះរាជាណាចក្រកម្ពុជា។

ក្រឡេកទៅមើលការផ្សាយរបស់ស្ថានីយ៍ទូរទស្សន៍វិញ ខុមហ្វ្រែលសង្កេតឃើញថាក្រៅពីស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា ស្ថានីយ៍ទូរទស្សន៍ឯកជនស្ទើរតែទាំងអស់សុទ្ធតែបានធ្វើការផ្សាយរិះគន់ វាយប្រហារ ប្រមាថ ចោទប្រកាន់គណបក្សប្រឆាំងគឺគណបក្សសង្គ្រោះជាតិ តាមរយៈពាក្យសម្ដីចំៗ ឬបញ្ចិតបញ្ចៀងជាដើម។ ជាក់ស្ដែងស្ថានីយទូរទស្សន៍បាយ័ន ស្ថានីយ៍ បណ្ដាញទូរទស្សន៍កម្ពុជា (CTN) និងស្ថានីយ៍ទូរទស្សន៍អប្សរា បាននិងកំពុងបង្កើតកម្មវិធីរបស់ខ្លួនក្រោមរូបភាពជាការវិភាគនយោបាយ ប៉ុន្តែប្រើប្រាស់កម្មវិធីទាំងនោះក្នុងគោលបំណងវាយប្រហារ ប្រមាថ ចោទប្រកាន់ទៅកាន់ថ្នាក់ដឹកនាំគណបក្សប្រឆាំងគឺគណបក្សសង្គ្រោះជាតិ ព្រមទាំងស្ថាប័ន និងបុគ្គលដែលមាននិន្នាការ ផ្ទុយពីគណបក្សកាន់អំណាច។ ជាក់ស្ដែងនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៣ លោក ជុំ កុសល ដែលត្រូវបានស្គាល់ថាជាអ្នកអត្ថាធិប្បាយទូរទស្សន៍គាំទ្រគណបក្សប្រជាជនកម្ពុជា បានថ្លែងក្នុងកម្មវិធីសន្ទនា ថ្ងៃព្រហស្បត៍របស់ស្ថានីយ៍ទូរទស្សន៍ ស៊ី ធី អិន ថា " លោក សម រង្ស៊ី និងលោក កឹម សុខា គឺជាមនុស្សអសមត្ថភាព មិនអាចឲ្យដឹកនាំប្រទេសបានទេ បើតាមភាសាសហគមន៍ជាមនុស្សអន់បំផុត ហើយប្រជាពលរដ្ឋមិនគាំទ្រឲ្យដឹកនាំប្រទេស កុំប្រៀបធៀបសម្ដេចតែជោទៅនឹងកម្រិតយល់ដឹងរបស់ លោក សម រង្ស៊ី..................."។ មួយវិញទៀតក្នុងកម្មវិធីវេទិកាលាតត្រដាងការពិតរបស់ស្ថានីយ៍ទូរទស្សន៍បាយ័នព័ត៌មាន កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ លោកសត្យារក្ស ដែលត្រូវបានគេស្គាល់ថា ជាអ្នកវាយប្រហារថ្នាក់ដឹកនាំគណបក្សប្រឆាំងមួយរូប បាននិយាយថា "លោក កឹម សុខា កិត្តិយសរបស់គាត់លក់ត្រឹមតែ ២ម៉ឺនដុល្លា ហើយគាត់ឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយមិនត្រឹមតែអញ្ចឹងទេ ឆ្អិនត្រង់ណាបេះស៊ីត្រង់ហ្នឹង ធ្វើយ៉ាងម៉េចឲ្យបានស៊ី"។

ទោះជាច្បាប់ស្ដីពីរបបសារព័ត៌មានត្រូវបានបង្កើតឡើងតាំងពីថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ១៩៩៥ ហើយច្បាប់ នេះកំណត់របបសារព័ត៌មាន និងធានាការពារសេរីភាពសារព័ត៌មាន និងសេរីភាពខាងបោះពុម្ពផ្សាយឲ្យបានសមស្របតាមមាត្រា ៣១ និងមាត្រា ៤១នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា ០៧ ចំនុច០៣ ឃ្លាចុងក្រោយបានចែងថា អ្នកសារព័ត៌មានមិនត្រូវបំបាត់ចោលនូវព័ត៌មានសំខាន់ៗ ឬក្លែងបន្លំឯកសារផ្សេងៗឡើយ។ ស្ថាប័នសារព័ត៌មានមួយចំនួនធំដូចជាមាននិន្នាការនយោបាយ ឬស្ថិតនៅក្រោមឥទ្ធិពលនយោបាយ ជាពិសេសគណបក្សប្រជាជនកម្ពុជា តាមការសង្កេតជាក់ស្ដែង ស្ថាប័ន សារព័ត៌មានដែលមាននិន្នាការទាំងនោះ ហាក់ដូចជាបានរំលោភនឹងបញ្ញត្តិខាងលើ ដោយសារតែធ្វើការបោះពុម្ព ឬផ្សព្វផ្សាយព័ត៌មានមិនពេញលេញ ក្នុងគោលបំណងបម្រើឲ្យផលប្រយោជន៍គណបក្សនយោបាយ។

ក្នុងដំណាក់កាលឃោសនាបោះឆ្នោតដែលមានរយៈពេលមួយខែ ពីថ្ងៃទី២៧ ខែមិថុនា រហូត ដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានតម្រូវឲ្យស្ថានីយ៍វិទ្យុ និងទូរទស្សន៍ឯកជនដែលមានបំណងលក់ម៉ោង ឬម៉ោងផ្សាយត្រូវប្រកាសជាសាធារណៈអំពីចំនួនម៉ោងដែលខ្លួនមានសម្រាប់លក់ ឬជួលក្នុងរយៈពេល៣០ថ្ងៃនៃថ្ងៃឃោសនាបោះឆ្នោតនេះ។ អ្នកគ្រប់គ្រង ស្ថានីយ៍វិទ្យុ និង

ទូរទស្សន៍ ត្រូវជូនដំណឹងពីការលក់ម៉ោង ឬជួលម៉ោងផ្សាយនេះ មកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងជូនដំណឹងទៅគ្រប់គណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុង ការបោះឆ្នោតជ្រើសតាំងតំណាងនីតិកាលទី៥។ នេះបើយោងតាមគោលការណ៍របស់ គ.ជ.ប សម្រាប់ ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ឯកជន ក្នុងការលក់ម៉ោង ឬជួលម៉ោងចាក់ផ្សាយឲ្យគណបក្សនយោបាយ ដើម្បីធ្វើការចាក់ផ្សាយអំពីកម្មវិធីនយោបាយក្នុងពេលឃោសនាបោះឆ្នោត ក្នុងចំណុច ១.១ និង ១.៣ ដែលបានចេញផ្សាយនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០១៣។

ទោះបីជាមានគោលការណ៍ដូចបានរៀបរាប់ខាងលើ ក៏គណបក្សនយោបាយដែលបានចូលរួម ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ មិនបានទទួលព័ត៌មានពីម៉ោងផ្សាយទំនេររបស់ស្ទើរតែគ្រប់ស្ថានីយ៍វិទ្យុ ជាពិសេស គ្រប់ទូរទស្សន៍ទាំងនោះឡើយ។ ទាក់ទងនិងបញ្ហានេះ លោក ខឹម វាសនា ជាប្រធានគណបក្សសម្ព័ន្ធ ដើម្បីប្រជាធិបតេយ្យ បានអះអាងថា គណបក្សនេះមិនត្រឹមតែមិនទទួលបានព័ត៌មានពីម៉ោងទំនេររបស់ស្ថានីយ៍វិទ្យុនោះទេ ប៉ុន្តែស្ថានីយ៍វិទ្យុទាំងនោះមិនព្រមលក់ ឬជួលម៉ោងទំនេររបស់ខ្លួនឲ្យគណបក្សទៀតផង។ បញ្ហានេះត្រូវបានពន្យល់ដោយនាយករងទទួលបន្ទុកផ្នែកព័ត៌មានសាធារណៈ របស់ គ.ជ.ប ថា គ.ជ.ប មិនបានទទួលព័ត៌មានពីម៉ោងផ្សាយទំនេររបស់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ដោយសារស្ថានីយ៍ទាំងនោះមិនមានម៉ោងទំនេរសម្រាប់លក់ ឬជួល ដល់គណបក្សនយោបាយ ។

ទោះបីជាបានចេញគោលការណ៍ណែនាំអំពីរឿងនេះក្តី ប៉ុន្តែគ.ជ.បនៅតែគ្មានយន្តការដើម្បីពិនិត្យ និងតាមដានលើការអនុវត្តន៍គោលការណ៍ខាងលើនេះទេ។ ដោយផ្អែកលើព័ត៌មានការអង្កេតលើប្រព័ន្ធផ្សព្វផ្សាយ ខុមហ្វ្រែលបានដាក់លិខិតស្នើសុំការអន្តរាគមន៍ពី គ.ជ.ប ប៉ុន្តែយើងទទួលបានការឆ្លើយជាវិជ្ជមានតិចតួចបំផុត។ គ.ជ.ប បានព្រងើយកន្តើយ និងមិនចាត់វិធានការអ្វីទាល់តែសោះ ជាពិសេស ពាក់ព័ន្ធនឹងគណបក្សប្រជាជនកម្ពុជា ដែលបានប្រើប្រាស់ប្រព័ន្ធផ្សាយទូរទស្សន៍រំលោភនឹងគោលការណ៍ណែនាំរបស់ គ.ជ.ប។

## ៦.២ ការទទួលបានការផ្សព្វផ្សាយជាពិសេសទូរទស្សន៍ និងវិទ្យុ

គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ អាចប្រើប្រាស់រាល់មធ្យោបាយ និងលទ្ធភាពរបស់ក្នុងការផ្សាយសកម្មភាព និងគោលនយោបាយរបស់គណបក្សតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា។ សម្រាប់ប្រទេសកម្ពុជា ប្រព័ន្ធផ្សព្វផ្សាយ វិទ្យុ និងទូរទស្សន៍ឯកជនបានដើរតួនាទីសំខាន់ជាងប្រព័ន្ធផ្សាយរបស់រដ្ឋក្នុងការផ្សព្វផ្សាយព័ត៌មានទៅកាន់ប្រជាពលរដ្ឋដែលរស់នៅទីប្រជុំជន ជាពិសេសតំបន់ដាច់ស្រយាលផងដែរ ដោយសារតែប្រព័ន្ធព្យព្វផ្សាយឯកជនទាំងនោះមានលទ្ធភាព និងសមត្ថភាពខ្ពស់ជាងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋក្នុងការផ្សព្វផ្សាយព័ត៌មាន។ ដូច្នេះប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជនទាំងនោះដើរតួសំខាន់ណាស់ក្នុងការផ្តល់ឱកាសឲ្យគណបក្សនយោបាយប្រកួតប្រជែងដោយស្មើភាពគ្នា។ ប៉ុន្តែយើងសង្កេតឃើញថា នៅកម្ពុជា ប្រព័ន្ធផ្សព្វផ្សាយឯកជនភាគច្រើន (លើកលែងស្ថានីយ៍វិទ្យុសំបុកឃ្មុំ FM 105 MHz ) គឺមិនបានផ្តល់ឱកាសស្មើគ្នាដល់គណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ជាពិសេសការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥។ ប្រព័ន្ធផ្សព្វផ្សាយឯកជនមួយចំនួន បង្ហាញពីនិន្នាការគាំទ្រគណបក្សនយោបាយណាមួយយ៉ាងច្បាស់ ខណៈដែលប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតរក្សាគោលជំហរមិនជាប់ពាក់ព័ន្ធនឹងគណបក្សនយោបាយ ឬគាំទ្រដោយប្រយោលក៏ថាបាន។

តារាងទី២៖ ប្រព័ន្ធផ្សព្វផ្សាយឯកជននៅរាជធានីភ្នំពេញដែលមានទំនាក់ទំនងជិតស្និទ្ធិជាមួយគណបក្សនយោបាយ និងដែលឯករាជ្យ៖

| | គណបក្សប្រជាជនកម្ពុជា | គណបក្សសង្គ្រោះជាតិ | គណបក្សហ៊្វុនស៊ិនប៉ិច | ឯករាជ្យ |
|---|---|---|---|---|
| ស្ថានីយ៍វិទ្យុ | FM 95 MHz | FM 93.5 MHz | FM 90 MHz<br>FM 90.5 MHz | FM 92 MHz (RFI)<br>FM 102 MHz<br>FM 105 MHz<br>FM 106.5 MHz (VOD) |
| ស្ថានីយ៍ទូរទស្សន៍ | គ្រប់ស្ថានីយ៍ | គ្មាន | គ្មាន | គ្មាន |

### ៦.២.១. ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ (វិទ្យុជាតិ និង ទូរទស្សន៍ជាតិ)




គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានសហការជាមួយប្រព័ន្ធផ្សព្វផ្សាយវិទ្យុ ទូរទស្សន៍របស់រដ្ឋបាន ផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតតែប៉ុណ្ណោះ។ ហើយគណបក្សនយោបាយនីមួយៗត្រូវបានផ្តល់ពេលវេលាស្មើៗគ្នា ក្នុងការផ្សព្វផ្សាយគោលនយោបាយរបស់ខ្លួនតាម រយៈប្រព័ន្ធផ្សព្វផ្សាយទាំងនោះ។ ក្នុងរយៈពេល៣០ថ្ងៃ ពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០១៣ រហូតដល់ ២៦ ខែកក្កដា ឆ្នាំ២០១៣ ដែលជាពេលឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ទូរទស្សន៍ជាតិកម្ពុជា (ទទក) និងវិទ្យុ FM 96 MHz និងវិទ្យុវត្តភ្នំ FM 105.70 MHz បានចាក់ផ្សាយកម្មវិធីនយោបាយរបស់គណបក្សរយៈពេល០៤ម៉ោងជារៀងរាល់ថ្ងៃ។ ទូរទស្សន៍ជាតិកម្ពុជា (ទទក) និងវិទ្យុ FM 96 MHz បានផ្សាយ០២ម៉ោងសម្រាប់ពេលរសៀល និង ០២ ម៉ោងសម្រាប់ពេលយប់ ចំណែកឯវិទ្យុវត្តភ្នំបានផ្សាយ០២ម៉ោងសម្រាប់ពេលព្រឹក និង ០២ ម៉ោងសម្រាប់ពេលយប់។

បន្ថែមលើកម្មវិធីរបស់ផ្សាយរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងអំឡុងពេលឃោសនាបោះឆ្នោត ទូរទស្សន៍ជាតិកម្ពុជាបានចាក់ផ្សាយកម្មរបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) ដែលជាកម្មវិធី

ពិភាក្សាដេញដោលរវាងតំណាងគណបក្ស ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥។ កម្មវិធីនោះត្រូវបានចាក់ផ្សាយចំនួន៤លើក ដែលមានរយៈពេល០១ម៉ោង និង៣០នាទីក្នុងមួយលើកៗ។

បើមើលថយក្រោយបន្តិច ទូរទស្សន៍ជាតិកម្ពុជា ក្រោមការឧបត្ថម្ភរបស់ UNDP បានផលិតកម្មវិធីមួយដែលមានឈ្មោះថា កម្មវិធីសមធម៌។ កម្មវិធីនេះផ្តល់ឱកាសឲ្យគណបក្សនយោបាយសំដែងមតិ និងការយល់ឃើញរបស់ខ្លួនចំនួនបញ្ហាសង្គមដែលផលិតឡើងសម្រាប់ចាក់ផ្សាយ។ ប៉ុន្តែគួរឲ្យសោកស្តាយកម្មវិធីដែលមានរយៈពេល៤០នាទី និងចាក់ផ្សាយចំនួន ០៤ ដងរៀងរាល់សប្តាហ៍ (ផ្សាយឡើងវិញ ០៣ដង) ត្រូវបានផ្អាក និងបញ្ឈប់ការផ្សាយតាំងពីខែវិច្ឆិកា ឆ្នាំ២០១៣។

### ៦.២.២.ប្រព័ន្ធផ្សព្វផ្សាយរបស់ឯកជន

- **គណបក្សប្រជាជនកម្ពុជា**

គណបក្សប្រជាជនកម្ពុជា ជាគណបក្សបាន និងកំពុងកាន់អំណាចអស់រយៈពេលពីរ ឬបីទសវត្សមកហើយ។ ដោយសារតែជាគណបក្សកាន់អំណាច គណបក្សគឺមានឥទ្ធិពលចំពោះប្រព័ន្ធផ្សព្វផ្សាយឯកជនស្ទើតែទាំងអស់។ ទោះបីជាយ៉ាងនេះ គណបក្សនេះមិនបានប្រើប្រាស់វិទ្យុឯកជនទាំងអស់នោះ ដើម្បីឃោសនា ឬផ្សព្វផ្សាយសកម្មភាព និងគោលនយោបាយរបស់ខ្លួននោះទេ។ ប៉ុន្តែឥទ្ធិពលរបស់គណបក្សធ្វើឲ្យវិទ្យុឯកជនទាំងនោះមិនហ៊ានលក់ ឬជួលម៉ោងផ្សាយរបស់ខ្លួនឲ្យគណបក្សនយោបាយដ៏ទៃ ជាពិសេសគណបក្សនយោបាយដែលមាននិន្នាការប្រឆាំងនឹងរាជរដ្ឋាភិបាល។

គណបក្សប្រជាជនកម្ពុជា បានប្រើប្រាស់ស្ថានីយ៍វិទ្យុបាយ័ន FM 95 MHz ក្នុងការផ្សព្វផ្សាយសកម្មភាព របស់ថ្នាក់ដឹកនាំ និងគោលនយោបាយរបស់គណបក្ស។ ស្ថានីយវិទ្យុនេះបាននិងកំពុងរៀបចំកម្មវិធីរបស់ខ្លួន ដើម្បីវាយប្រហារ និងឆ្លើយតបចំពោះការលើកឡើងរបស់ថ្នាក់ដឹកនាំគណបក្សផ្សេងទៀត ដែលមាននិន្នាការផ្ទុយពីរាជរដ្ឋាភិបាល ជាពិសេសគណបក្សប្រឆាំង។ ចំពោះស្ថានីទូរទស្សន៍ឯកជនវិញ មានស្ថានីយ៍ទូរទស្សចំនួនបីដែលតែងតែមានកម្មវិធីបម្រើឲ្យប្រយោជន៍គណបក្សប្រជាជនកម្ពុជា។ ស្ថានីយ៍ទាំងបីនោះមានដូចជា៖ ស្ថានីយ៍ទូរទស្សន៍បាយ័ន (រួមទាំងស្ថានីយ៍ទូរទស្សន៍បានយ័នព័ត៌ មាន) ស្ថានីយ៍ទូរទស្សន៍បណ្តាញទូរទស្សន៍កម្ពុជា ស៊ីធីអិន ដែលរួមបញ្ចូលទាំងស្ថានីយ៍ទូរទស្សន៍ ស៊ី អិន ស៊ី និងស្ថានីយ៍ទូរទស្សន៍អប្សរា។ ស្ថានីយ៍ទូរស្សន៍ទាំងបីនេះ តែងតែផលិតកម្មវិធីរបស់ខ្លួនដែលមាន និន្នាការគាំទ្ររាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា ដើម្បីចាក់ផ្សាយជារៀងរាល់សប្តាហ៍។ បន្ថែមលើពីនេះកម្មវិធិកំសាន្តនានារបស់កម្មវិធីក៏បានជ្រៀបនូវសារនយោបាយដែលគាំទ្រ គណបក្សប្រជាជនកម្ពុជា និងវាយប្រហារគណបក្សប្រឆាំងផងដែរ ជាពិសេសក្នុងអំឡុងពេលឃោសនា បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥។

- **គណបក្សសង្គ្រោះជាតិ**

គណបក្សសង្គ្រោះជាតិ ជាគណបក្សប្រឆាំងដ៏មានប្រជាប្រិយភាពក្នុងការដណ្តើមជ័យជំនះជាមួយគណ បក្សកាន់អំណាច។ គណបក្សនេះទទួលបានការផ្សព្វផ្សាយ និងប្រើប្រាស់ស្ថានីយ៍វិទ្យុចំនួនពីរដែលបានផ្សព្វផ្សាយពីគោលនយោបាយ និងសកម្មភាពថ្នាក់ដឹកនាំគណបក្សជាប្រចាំថ្ងៃ។ ស្ថានីយ៍ទាំងពីរមានដូច

ជា៖ ស្ថានីយ៍វិទ្យុសំបុកឃ្មុំ FM 105 MHz និងស្ថានីយ៍វិទ្យុ 93.5 MHz ផ្សាយពីរលើក និងមានរយៈពីរម៉ោងជារៀងរាល់ថ្ងៃ។ ចំពោះការផ្សព្វផ្សាយតាមរយៈទូរទស្សន៍ឯកជន គណបក្សសង្គ្រោះជាតិពុំមានឱកាស និងលទ្ធភាពក្នុងការផ្សព្វផ្សាយនោះទេ ដោយសារស្ថានីយ៍ទូរទស្សន៍ឯកជនទាំងនោះមានការរើសអើងនយោបាយ បើទោះបីជាគណបក្សមានលទ្ធភាពទិញ ឬជួលម៉ោងផ្សាយ។ ក្នុងដំណាក់ឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ គណបក្សសង្គ្រោះបានមានលទ្ធភាពប្រើប្រាស់ស្ថានីយវិទ្យុមួយ នៅខេត្តបាត់ដំបង ដើម្បីធ្វើការផ្សាយបន្តពីគោលនយោបាយ និងសកម្មភាពថ្នាក់ដឹកនាំគណបក្សផងដែរ។

- **គណបក្សហ៊្វុនស៊ិនប៉ិច**

ទោះបីជាគណបក្សហ្វ៊ុនស៊ិនប៉ិច ជាគណបក្សសម្ព័ន្ធភាព ឬដៃគូជាមួយគណបក្សកាន់អំណាចក៏ដោយ គណបក្សនេះនៅបន្តផ្សព្វផ្សាយគោលនយោបាយ និងព័ត៌មានផ្សេងៗអំពីគណបក្សរបស់ខ្លួន តាមប្រព័ន្ធផ្សព្វផ្សាយឯកជនដូចជា វិទ្យុ FM 90 MHz និង វិទ្យុ FM 90.5 MHz។ វិទ្យុទាំងពីរនេះបានផ្សាយព័ត៌មានទាក់ទងនឹងគណបក្សហ្វ៊ុនស៊ិនប៉ិចរយៈពេលពីរម៉ោងក្នុងជារៀងរាល់ថ្ងៃ។ ខ្លឹមសារនៃ ការការផ្សាយរបស់គណបក្សនេះគឺមានដូចជា ចំណុចចអវិជ្ជមាននៃការដឹកនាំរបស់រាជរដ្ឋាភិបាល ព្រមទាំងស្នាដៃដែលបានបន្សល់ទុកក្រោមការដឹកនាំប្រទេសរបស់គណបក្សនេះកាលពីអតីតកាល។

គណបក្សសម្ព័នដើម្បីប្រជាធិបតេយ្យមិនខុសគ្នាពីគណបក្សសង្គ្រោះជាតិ និងគណបក្សហ្វ៊ុនស៊ិនប៉ិចទេ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យដែលមានទស្សនៈវិស័យផ្លាស់ប្តូរផ្នត់គំនិតប្រជាពលរដ្ឋ ក៏មិនមានធ្វើការផ្សព្វផ្សាយសកម្មភាពនយោបាយរបស់ខ្លួនតាមរយៈស្ថានីយ៍ទូរស្សន៍ផងដែរ។ បើមើលថយក្រោយ គេឃើញថាសកម្មភាពនយោបាយរបស់គណបក្សត្រូវបានផ្សព្វផ្សាយតាមបណ្តាស្ថានីយវិទ្យុមួយចំនួននៅតាមបណ្តាខេត្តដូចជា សៀមរាប បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ចាម និងកំពត ផងដែរ។ ប៉ុន្តែការផ្សាយទាំងអស់នោះក្រោមឈ្មោះជាកម្មវិធីរបស់អង្គការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ ដែលអង្គការនេះបម្រើទស្សនៈនយោបាយរបស់គណបក្សនេះ។ ប៉ុន្តែក្នុងរយៈពេលចុងក្រោយនេះការផ្សាយរបស់គណបក្សតាមបណ្តាខេត្តទាំងអស់ខាងលើត្រូវបានបញ្ឈប់ ដោយសារតែម្ចាស់ស្ថានីយ៍វិទ្យុខ្លះឈប់ជួល ឬលក់ម៉ោងឲ្យដើម្បីបន្តការផ្សាយ និងមូលហេតុមួយទៀតគឺដោយសារមន្ទីរព័ត៌មាននៃខេត្តមួយចំនួនខាងលើមិនអនុញ្ញាតឲ្យស្ថានីយ៍វិទ្យុចាក់ផ្សាយកម្មវិធីរបស់គណបក្សនេះ។ មកដល់ពេលនេះ គណបក្សនេះមានប្រព័ន្ធផ្សាយតាមរយៈវិទ្យុតែមួយគត់ គឺស្ថានីយ៍វិទ្យុ FM 105 MHz ដែលមានរយៈពេលផ្សាមួយម៉ោងជារៀងរាល់ថ្ងៃ។ ក្នុងដំណាក់កាលឃោសនាបោះឆ្នោតកន្លងទៅថ្មីៗនេះ គណបក្សក៏បានផ្សាយកម្មវិធីនយោបាយរបស់ខ្លួនតាមរយៈវិទ្យុមួយនៅខេត្តបាត់ដំបងផងដែរ។







ក្រាហ្វិកទី២៖ ការចាក់ផ្សាយរបស់ទូរទស្សន៍បាយ័នព័ត៌មាន និងស៊ីធីអិនសម្រាប់គណបក្សនយោបាយនីមួយៗក្នុងអំឡុងពេលឃោសនាបោះឆ្នោត

### ៦.២.៣. តួអង្គនយោបាយមានឥទ្ធិពលដែលត្រូវបានលើកឡើងក្នុងប្រព័ន្ធផ្សព្វផ្សាយ

ខុមហ្វ្រែលបានធ្វើការអង្កេតទៅប្រព័ន្ធផ្សព្វផ្សាយមួយចំនួនដែលកំពុងពេញលើការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋ។ ប្រព័ន្ធផ្សព្វផ្សាយទាំងនោះមានដូចជា៖ ទូរទស្សន៍ស៊ីធីអិន (CTN) ទូរទស្សន៍ជាតិកម្ពុជា (TVK) និងទូរទស្សន៍បាយ័នព័ត៌មាន (Bayon TV News) ធ្វើឡើងពីម៉ោង ដែលត្រូវបានអង្កេតពីម៉ោង ០៥ ទៅដល់ម៉ោង១១យប់ និង វិទ្យុសំបុកឃ្មុំ FM105MHz ត្រូវបានអង្កេតពីម៉ោង១២រសៀលដល់ ០៥ល្ងាច តែធ្វើការអង្កេតតែកម្មវិធីនយោបាយរបស់គណបក្សសង្គ្រោះជាតិ (CNRP) គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ(LDP) និងគណបក្សហ៊្វុនស៊ិនប៉ិច (FUNCINPEC)។ ខាងក្រោមនេះជាទិន្នន័យ តួអង្គនយោបាយដែលត្រូវបានលើកឡើងក្នុងប្រព័ន្ធផ្សាយផ្សាយខាងលើពីខែ មករា រហូតដល់ ខែ កក្កដា ឆ្នាំ២០១៣ ៖

តារាងទី៣៖ តួអង្គនយោបាយត្រូវបានលើកឡើងក្នុងប្រព័ន្ធផ្សព្វផ្សាយ

| ល.រ | អ្នកនយោបាយ | FM 105 | CTN | Bayon News | TVK | សរុប |
|---|---|---|---|---|---|---|
| ១ | លោក ហ៊ុន សែន | ៨២៨ | ៧៦៤ | ៤១៩៥ | ៤០៤០ | ៩៨៣៦ |
| ២ | លោក កឹម សុខា | ១៥៧០ | ៤៣៣ | ២៥៧ | ១៤ | ២២៦៣ |
| ៣ | លោក សម រង្ស៊ី | ១២២៥ | ៤៣១ | ១៣៥ | ២២ | ១៨១៣ |
| ៤ | លោក ហេង សំរិន | ៣៦ | ៦៣ | ២៥៧ | ៤២៤ | ៧៨០ |
| ៥ | លោក ជា ស៊ីម | ២១ | ៣៥ | ៤៣ | ២០៦ | ៤០៥ |
| ៦ | លោក ខឹម វាសនា | ៣៤៧ | ០ | ០ | ៣ | ៣៥០ |
| ៧ | សម្តេច នរោត្តម អារុណរស្មី | ២៣៥ | ០ | ៤ | ២៤ | ២៦៣ |
| ៨ | លោក ញឹក ប៊ុនឆៃ | ២០០ | ៤ | ៥ | ៤១ | ២៥០ |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | លោក សៅវ៉ានី | ២០០ | ០ | ១ | ០ | ២០១ |
| ១០ | លោក គង់ គាំ | ១៤០ | ១៣ | ២០ | ៥ | ១៧៨ |
| ១១ | លោក ប៉ុល ហំម | ១២៩ | ០ | ០ | ០ | ១២៩ |
| ១២ | លោក សុន ឆៃ | ៦៣ | ០ | ៤ | ៤ | ៧១ |
| ១៣ | លោក ប៉ែន សុវណ្ណ | ៦១ | ០ | ២ | ០ | ៦៣ |
| ១៤ | លោក យ៉ែម បុញ្ញរិទ្ធិ | ៥២ | ០ | ៦ | ០ | ៥៨ |
| ១៥ | លោកស្រី មូ សុខហួ | ៣៤ | ០ | ៤ | ០ | ៣៨ |
| ១៦ | លោក អ៊ូ ចាន់រិទ្ធិ | ៣០ | ០ | ១ | ០ | ៣១ |
| ១៧ | លោកអេង ឆៃអៀង | ២៩ | ០ | ០ | ០ | ២៩ |
| ១៨ | លោក យឹម សុវណ្ណ | ១៥ | ០ | ៣ | ១ | ១៩ |
| ១៩ | លោក កែវ ពុធរស្មី | ១៧ | ០ | ០ | ០ | ១៧ |
| ២០ | លោក ហូ វ៉ាន់ | ១២ | ០ | ១ | ០ | ១៣ |
| ២១ | លោក យូ ហុកគ្រី | ៩ | ០ | ០ | ០ | ៩ |
| ២២ | លោក គឹម សូភារិទ្ធិ | ៤ | ០ | ០ | ០ | ៤ |

ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ខុមហ្វ្រែលដែលបានធ្វើការអង្កេតទៅលើប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ទាំងបីដូចជា ទូរទស្សន៍ជាតិកម្ពុជា(ទទក) ទូរទស្សន៍ស៊ីធីអិន និងបាយ័នព័ត៌មានពីម៉ោង៥ល្ងាចដល់ម៉ោង១១យប់ (លើកលែងថ្ងៃអាទិត្យ) បានរកឃើញថា គណបក្សប្រជាជនកម្ពុជាត្រូវបានឮប្រមាណ ៨៧,៩៨%នៃការផ្សព្វផ្សាយរបស់ទូរទស្សន៍បាយ័នព័ត៌មាន ដែលទូរទស្សន៍នេះត្រូវបានដឹងថាម្ចាស់ស្ថានីយនេះជាកូនស្រីរបស់នាយករដ្ឋមន្ត្រីហ៊ុន សែន។ ចំណែកទូរទស្សន៍ស៊ីធីអិន ក៏គណបក្សប្រជាជនកម្ពុជាត្រូវបានផ្សព្វផ្សាយ៧៥% ខណៈដែលគណបក្សសង្គ្រោះជាតិត្រូវបានផ្សព្វផ្សាយក្នុងទូរទស្សន៍ទាំងពីរនេះប្រមាណជាង១០% ហើយក៏ត្រូវបានឮភាគច្រើនក្នុងកម្មវិធីសន្ទនាដែលមានការរិះគន់ពីពិធីការមួយចំនួនដែលផ្ទុយពីគណបក្សប្រជាជនកម្ពុជាដែលបានឮតែពីការលើកសរសើរក្នុងការដឹកនាំប្រទេសជាតិ។

តារាងទី៤៖ ចំនួនម៉ោងដែលគណបក្សនយោបាយត្រូវបានផ្សព្វផ្សាយក្នុងពេលឃោសនា

| N | គណបក្សនយោបាយ | TVK | | CTN | | Bayon News | |
|---|---|---|---|---|---|---|---|
| | | ចំនួនម៉ោង | % | ចំនួនម៉ោង | % | ចំនួនម៉ោង | % |
| ១ | គណបក្សសញ្ញាតិកម្ពុជា | 05h55mn02s | 12.32 | 00h00mn07s | 0.21 | | 0 |
| ២ | គណបក្សហ៊្វុនស៊ិនប៉ិច | 05h54mn25s | 12.42 | 00h02mn51s | 1.94 | 00h02mn 16s | 0.41 |
| ៣ | គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ | 04h50mn31s | 10.23 | 0 | 0 | 0 | 0 |
| ៤ | គណបក្សប្រជាជនកម្ពុជា | 09h19mn22s | 19.51 | 06h45mn25s | 75.60 | 16h26mn | 87.98 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | 30s | |
| ៥ | គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | 02h47mn51s | 6.08 | 0 | 0 | 0 | 0 |
| ៦ | គណបក្សខ្មែរឈប់ក្រ | 05h48mn16s | 12.16 | 00h00mn05s | 0.15 | 0 | 0 |
| ៧ | គណបក្សសង្គ្រោះជាតិ | 07h15mn41s | 15.32 | 01h42mn28s | 19.71 | 02h00mn 56s | 11.48 |
| 8 | គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | 05h44mn02s | 11.94 | 00h08mn29s | 2.37 | 00h00mn 08s | 0.11 |

## ៦.៣ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងហ្វេសបុក

នៅក្នុងរយៈពេលចុងក្រោយនេះ បណ្តាញផ្សព្វផ្សាយសង្គមកាន់តែដើរតួនាទីយ៉ាងសកម្មពាក់ព័ន្ធនឹងរឿងនយោបាយ។ បណ្តាញផ្សព្វផ្សាយសង្គមទាំងនោះមានដូចជា៖ Facebook Youtube Twitter G+។ មកដល់ពេលនេះ នៅកម្ពុជាគេមិនទាន់ឃើញមានច្បាប់ ឬបទបញ្ញត្តិណាមួយដែលបានចែងដើម្បីគ្រប់គ្រងបណ្តាញផ្សព្វផ្សាយសង្គមនៅឡើយទេ។ ក្នុងចំណោមប្រព័ន្ធផ្សព្វផ្សាយសង្គមខាងលើ ហ្វេសបុក និង Youtube ជាគេហទំព័រដែលគេសង្កេតឃើញថាកាន់តែពេញនិយមចំពោះអ្នកប្រើប្រាស់ ជាពិសេសយុវវ័យ និងមនុស្សវ័យកណ្តាល។ តាមការផ្សាយរបស់វិទ្យុអាស៊ីសេរី មកដល់ពេលនេះ មានអ្នកប្រើប្រាស់ Facebook ប្រមាណ ១,០០០,០០០នាក់នៅប្រទេសកម្ពុជា។ នៅក្នុងសង្គមកម្ពុជា អ្នកប្រើប្រាស់ផ្សព្វផ្សាយសង្គមមួយនេះបានយកគេហទំព័រនេះទៅប្រើប្រាស់ជាមធ្យាបាយដ៏សំខាន់មួយក្នុងការចែករំលែកដំណឹងផ្សេងៗដែលកើតមាននៅក្នុងសង្គម និងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។

គេសង្កេតឃើញថា គណបក្សនយោបាយដែលបាន និងកំពុងបន្តសកម្មភាពរបស់ខ្លួនជាប្រចាំដូចជា គណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ គណបក្សហ៊្វុនស៊ិនប៉ិច និង គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានងាកមកចាប់អារម្មណ៍ចំពោះការស្វែងរកការគាំទ្រ និងប្រជាប្រិយភាពរបស់ខ្លួនតាមរយៈគេហទំព័រផ្សព្វផ្សាយសង្គមដែលមានការពេញនិយមមួយនេះផងដែរ។ ជាក់ស្តែង នៅក្នុងគេហទំព័ររបស់គណបក្សនយោបាយទាំងនោះ គេឃើញមានតំណរភ្ជាប់ដើម្បីឲ្យអ្នកទស្សនាមានឱកាស និងលទ្ធភាពចែករំលែកព័ត៌មានអំពីគណបក្សខ្លួនទៅកាន់ទិន្នន័យFacebook របស់អ្នកប្រើប្រាស់។ ហើយគណបក្សនយោបាយទាំងអស់នោះក៏មានគេហទំព័រ Facebook ផ្ទាល់ខ្លួនផងដែរ (គណបក្សប្រជាជនកម្ពុជាមានទិន្នន័យក្នុងគេហ៍រទំព័រ Facebook ប៉ុន្តែគណបក្សមិនបានផ្តល់ព័ត៌មានបញ្ជាក់ទិន្នន័យ ពិតជារបស់គណបក្សឬយ៉ាងណានោះទេ)។ បន្ថែមលើសពីនេះថ្នាក់ដឹកនាំកំពូលមួយចំនួននៃគណបក្សនយោបាយ ក៏បានប្រើប្រាស់គេហទំព័រនេះ ដើម្បីផ្សព្វផ្សាយសារនយោបាយ ក៏ដូចជាសកម្មភាពរបស់ខ្លួន។ ជាក់ស្តែង គេហទំព័ររបស់ លោក សម រង្ស៊ី



ប្រធានគណបក្សសង្គ្រោះជាតិ មានអ្នកគាំទ្ររហូតដល់ ២៥៤,៩៤០ និងគេហទំព័ររបស់ លោក កឹម សុខា ត្រូវបានគេគាំទ្រចំនួន ២០១,២២៤ គិតត្រឹមថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣។ ទោះបីជាលោកនាយរដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់បានអះអាងជាសាធារណៈថា រូបលោកមិនបានប្រើប្រាស់ គេហទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គម មួយនេះក៏ដោយ គេឃើញមាន profile មួយដែលមានឈ្មោះថា Samdech Hun Sen, Cambodian Prime Minister ដែលជារឿងតែងតែបានផ្សព្វផ្សាយរាល់សកម្មភាពដែលទាក់ទងនឹងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយថែមទាំងធ្វើការឆ្លើយតប និងធ្វើការអំពាវនាវផ្សេងៗក្នុងនាមលោកនាយករដ្ឋមន្ត្រី ទៅកាន់ប្រជាពលរដ្ឋផងដែរ។ ហើយគេហទំព័រនេះត្រូវបានការទទួលគាំទ្រ ចំនួន ១១៧,៤៥៥ នាក់។ ក្រៅពីទិន្នន័យរបស់ថ្នាក់ដឹកនាំគណបក្សនយោបាយ គេក៏សង្កេតឃើញមានទិន្នន័យមួយចំនួនផ្សេងទៀតដែលបង្កើតឡើងដើម្បីគាំទ្រគណបក្សនយោបាយដែលខ្លួនពេញចិត្ត និងធ្វើការរិះគន់ចំពោះបុគ្គលនយោបាយ ឬគណបក្សនយោបាយផ្សេងទៀត។




នៅរយៈពេលចុងក្រោយនេះ ស្របពេលដែលកម្ពុជាមានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គេហទំព័រនេះ មិនត្រឹមតែជាឧបករណ៍សម្រាប់ចែកចាយព័ត៌មានពីការបោះឆ្នោត ឬដំណឹងផ្សេងៗនោះទេ វាបានដើរតួយ៉ាងសំខាន់ក្នុងការសំដែងការគាំទ្រ ផ្សព្វផ្សាយពីគោលនយោបាយ និងរិះគន់ ឬវាយប្រហារថ្នាក់ដឹកនាំរបស់គណបក្សនយោបាយដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឆ្នាំ២០១៣នេះទៀតផង។

ក្នុងដំណាក់កាល មុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទីកាល៥ ជាពិសេសក្នុងដំណាក់កាលឃោសនាបោះឆ្នោតដែលមានរយៈមួយខែមុនថ្ងៃបោះឆ្នោត Facebook បានដើរតួនាទីយ៉ាងសំខាន់ដើម្បីជួយគណបក្សគណបក្សប្រឆាំង ជាពិសេសគណបក្សង្គ្រោះជាតិក្នុងការស្វែងរកការគាំទ្រពីប្រជាពលរដ្ឋ ដោយសារតែប្រព័ន្ធផ្សព្វផ្សាយនានាដូចជាទូរទស្សន៍ វិទ្យុ កាសែត ស្ទើរទាំងអស់ត្រូវបានគ្រប់គ្រង និងទទួលឥទ្ធិពលពីគណបក្សកាន់អំណាចគឺគណបក្សប្រជាជនកម្ពុជា។

ដោយសារតែមានការរិះគន់ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាចកំពុងដឹកនាំរាជរដ្ឋាភិបាល និងដោយសារការផ្សព្វផ្សាយព័ត៌មានពីចំណុចអវិជ្ជមាន ឬភាពអសកម្មមន្ត្រីរាជរដ្ឋាភិបាល នៅមុនពេលបោះឆ្នោត គេទំព័រនេះក៏ធ្លាប់ត្រូវបានរាជរដ្ឋាភិបាលរៀបចំចាត់វិធានការ ដើម្បីគ្រប់គ្រង់លើប្រព័ន្ធផ្សព្វផ្សាយនេះផងដែរ។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបានធ្លាប់ស្នើសុំទិន្នន័យអ្នកប្រើប្រាស់គេហទំព័រនេះ នេះបើតាមរបាយការណ៍របស់ក្រុមហ៊ុន Facebook ដែលចេញកាលពីថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៣។ ប៉ុន្តែក្រោយពីការបោះឆ្នោតបានបញ្ចប់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីដំបូងនៃនីតិកាលទី៥ កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ បានប្រកាសជាសាធារណៈថា រាជរដ្ឋាភិបាលនឹងមិនត្រឹមតែមិនមានវិធានការអ្វីដើម្បីបិទគេហទំព័រនោះទេ ថែមទាំងលើកទឹកចិត្តឲ្យមានការប្រើប្រាស់បច្ចេកវិជ្ជាបែបនេះបានទូលំទូលាយជាងមុនទៀតផង។

# ៧. ការទិញទឹកចិត្ត និងការចំណាយរបស់គណបក្សនយោបាយ

## ៧.១ ការទិញទឹកចិត្ត

យ៉ាងហោចណាស់ នៅក្នុងអំឡុងពេលឃោសនាបោះឆ្នោតក៏មានករណីទិញទឹកចិត្តអ្នកបោះឆ្នោត។

ច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតបានហាមឃាត់ការទិញទឹកចិត្តប្រជាពលរដ្ឋ ជាពិសេសការផ្តល់ជូនថវិកា ក៏ដូចជាសម្ភារៈនានាក្នុងអំឡុងពេលឃោសនាបោះឆ្នោតក៏ដោយ ។

ក្នុងនោះនៅថ្ងៃទី ខែកក្កដា ឆ្នាំ២០១៣ នាយករដ្ឋមន្ត្រីហ៊ុន សែនបានប្រកាសផ្តល់ថវិកាចំនួន ៥០០,០០០ដុល្លារសំរាប់ការសាងសង់ផ្សារឡើងវិញនៅស្រុកក្រឡាញ់ ខេត្តសៀមរាប បន្ទាប់ពីត្រូវបានដុតបំផ្លាញ។ ចំណែកឯកឧត្តម ស ខេង បានប្រកាសប្រើប្រាស់ថវិកាផ្ទាល់ខ្លួនសម្រាប់ឧបត្ថម្ភជូនលោកយាយលោកតាពីអាយុ៦៥ឆ្នាំឡើងហើយមានជំងឺសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឧបត្ថម្ភស្ត្រីសម្រាលកូន ចូលបុណ្យគ្រួសារសពសំរាប់ប្រជាពលរដ្ឋនៅក្នុងខេត្តព្រៃវែង ដែលក្នុងនោះឧបត្ថម្ភពី១០០,០០០រៀល ទៅ ៥០០,០០០រៀល។ ករណីទាំងនេះជាទឡ្ហីករមួយដែលបង្ហាញពីការទិញទឹកចិត្តប្រជាពលរដ្ឋ ទឹកចិត្តអ្នកបោះឆ្នោត ដែលកើតឡើងក្នុងពេលឃោសនាបោះឆ្នោត

## ៧.២ ការចំណាយរបស់គណបក្សនយោបាយ

ដោយសារតែពុំមានច្បាប់ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយពេលឃោសនាបោះឆ្នោត ដើម្បីកំណត់ពីភាពស្មើគ្នាក្នុងការចំណាយក្នុងការឃោសនាបោះឆ្នោត គណបក្សនយោបាយនីមួយៗបានប្រើប្រាស់ធនធានដែលខ្លួនមាន ដើម្បីធ្វើការឃោសនា ដូច្នេះហើយគណបក្សនយោបាយធំៗបានធ្វើការចំណាយច្រើនជាងគណបក្សតូចៗ។ ជាក់ស្តែងខុមហ្វ្រែលបានធ្វើការអង្កេត និងប៉ាន់ស្មានលើការចំណាយរបស់គណបក្សនយោបាយចំនួនបី ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ឆ្នាំ ២០១៣ ដែលនៅក្នុងនោះបានរកឃើញថា គណបក្សប្រជាជនកម្ពុជា ក្នុងមួយខេត្តចំណាយគិតជាមធ្យមប្រមាណ ៦០០,០០០ ដុល្លារសហរដ្ឋអាមេរិក ហើយបើគិតការចំណាយទូទាំងប្រទេសជាមធ្យមចំណាយប្រមាណ ១៥,០០០,០០០ ដុល្លារសហរដ្ឋអាមេរិក។ ចំណែកគណបក្សសង្គ្រោះជាតិចំណាយប្រមាណ ៣,៥០០,០០០ ដុល្លារសហរដ្ឋអាមេរិកទូទាំងប្រទេស (ក្នុងមួយខេត្តចំណាយគិតជាមធ្យមប្រមាណ ១៥០,០០០ដុល្លារសហរដ្ឋអាមេរិក ) រីឯគណបក្សហ៊្វុនស៊ិនប៊ិចចំណាយប្រមាណតែ៥០០,០០០ដុល្លារសហរដ្ឋអាមេរិក (ក្នុងមួយខេត្តចំណាយគិតជាមធ្យមប្រមាណ ២០,០០០ដុល្លារសហរដ្ឋអាមេរិក)។

ការប៉ាន់ស្មានរបស់ខុមហ្វ្រែល គឺផ្អែកទៅលើការគណនាទឹកប្រាក់ចំណាយលើសម្ភារៈ និងសកម្មភាពឃោសនារបស់គណបក្សនយោបាយ មានដូចជា ការប្រគុំតន្ត្រី ការផ្តល់ថវិកាដល់អ្នកចូលរួមឃោសនា ការប្រើប្រាស់មធ្យោបាយធ្វើដំណើរសម្រាប់ឃោសនា គ្រឿងឧបភោគបរិភោគ និងសម្ភារៈចាំបាច់មួយចំនួនទៀត ដូចជាខិត្តប័ណ្ណ បាដា ទង់ជាតិ និងទង់បក្សជាដើម ដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលបានសង្កេតឃើញ។ ប៉ុន្តែការចំណាយមួយចំនួនទៀត ដូចជាប្រាក់លើកទឹកចិត្តចំពោះសកម្មជន និងមន្ត្រីរបស់គណបក្សមិនត្រូវបានគណនាបញ្ចូលក្នុងការប៉ាន់ការចំណាយនេះទេ។

# ៨. ការប្រើប្រាស់ធនធានរដ្ឋ

ការសង្កេតទៅលើការប្រើប្រាស់ធនធានរដ្ឋ រួមទាំងធនធានមនុស្ស និងសម្ភារៈដើម្បីបម្រើឲ្យផលប្រយោជន៍គណបក្សនយោបាយ ធ្វើឡើងក្នុងអំឡុងពេលពីខែកញ្ញា ឆ្នាំ២០១២ ដល់ ខែកក្កដា ឆ្នាំ ២០១៣។

ខុមហ្វ្រែលបានធ្វើការសង្កេតតាមរយៈប្រព័ន្ធផ្សព្វផ្សាយដែលក្នុងនោះ ទូរទស្សន៍ចំនួនបីដែលត្រូវបានធ្វើការអង្កេត ដូចជាទូរទស្សន៍ជាតិកម្ពុជា(ទទក) ទូរទស្សន៍ស៊ីធីអិន (CTN) និងទូរទស្សន៍បាយ័នព័ត៌មាន និងតាមរយៈវេបសាយនានា។ លទ្ធផលនៃការសង្កេតនេះបានឲ្យដឹងថា មានការប្រើប្រាស់ធនធានរដ្ឋបម្រើឲ្យគណបក្សនយោបាយចំនួន ៣៤៣ ករណី ដែលក្នុងនោះមានករណីមួយចំនួនដូចជា៖ ការប្រើប្រាស់យានជំនិះរបស់រដ្ឋ សម្ភារៈ ឬទីធ្លាសាធារណៈរបស់រដ្ឋមាន ការសំដែងមតិប្រឆាំង ឬគាំទ្រចំពោះគណបក្ស និងថ្នាក់ដឹកនាំគណបក្ស និងការចូលរួមពីសំណាក់កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការស៊ីវិលជាដើម។ ហើយករណីដែលបានរៀបរាប់នេះគឺ ត្រូវបានគេឃើញមាននៅក្នុងសកម្មភាព ឬក្នុងពិធីដូចជា ការប្រជុំ ការចែកអំណោយ និងការឃោសនាគណបក្សនយោបាយ ការបង្រៀនគូសសន្លឹកឆ្នោតគាំទ្រគណបក្សនយោបាយ។

ក្នុងចំណោមករណីខាងលើ ខុមហ្វ្រែលសង្កេតឃើញការចូលរួមពីសំណាក់កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការស៊ីវិលក្នុងសកម្មភាព ឬកម្មវិធីនានាដែលបានរៀបចំដោយគណបក្សប្រជាជនកម្ពុជា ហាក់ដូចជាមានលក្ខណៈជាប្រព័ន្ធព្រោះលទ្ធផលនៃការសង្កេតបានបង្ហាញថា មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធតែងតែមានវត្តមានក្នុងកម្មវិធីដែលរៀបចំដោយគណបក្សប្រជាជនកម្ពុជា ទោះបីជាក្នុងថ្ងៃធ្វើការ ឬថ្ងៃឈប់សម្រាកផងដែរ។ កាន់តែច្បាស់ជាងនេះទៅទៀត ខុមហ្វ្រែលបានពិនិត្យឃើញថា មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ពីកំរិតថ្នាក់ជាតិស្ទើរទៅដល់កំរិតមូលដ្ឋាន ដូចជា ថ្នាក់ដឹកនាំរាជធានី/ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ/សង្កាត់ផងដែរ ត្រូវបានទទួលមុខដំណែងក្នុងគណបក្សប្រជាជនកម្ពុជាទៅតាមឋានានុក្រមផ្សេងៗ រួមមាន៖ ប្រធាន អនុប្រធាន ឬគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណបក្សប្រចាំរាជធានី ខេត្ត ក្រុងស្រុកខណ្ឌ និងឃុំ សង្កាត់ជាដើម។

### *ការប្រើប្រាស់ធនធានមនុស្សសាធារណៈបម្រើឲ្យគណបក្សនយោបាយ*

ខុមហ្វ្រែល បានបែងចែកការប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋបម្រើឲ្យគណបក្សនយោបាយជាពីរករណីរួមមាន មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធដែលធ្វើសកម្មភាពបម្រើឲ្យគណបក្សនយោបាយ ក្នុងថ្ងៃធ្វើការរបស់ខ្លួន និងមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធដែលធ្វើសកម្មភាពនេះនៅថ្ងៃឈប់សម្រាក។ ខុមហ្វ្រែលបានរកឃើញថាមាន ១២៦ (៤១,០៤%) ករណីជាសកម្មភាពនៅក្នុងថ្ងៃធ្វើការ និង ១៨១ (៥៨,៩៥%) ករណីជាសកម្មភាពនៅ ថ្ងៃឈប់សម្រាករបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធដែលមានដំណែង ឬតួនាទីនៅក្នុងគណបក្សប្រជាជនកម្ពុជា។ ជាក់ស្តែងយោងតាមគេហទំព័រដើមអំពិល ដែលបានផ្សាយកាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៣ លោក ជាន់ សុផេង ស្នងការនគរបាលខេត្តកំពង់ធំ និងជាសមាជិកអចិន្ត្រៃយ៍គណបក្សប្រជាជនកម្ពុជាខេត្តកំពង់ធំ បានធ្វើការប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចមហាសន្និបាតគណបក្សប្រជាជនកម្ពុជា។

រាជធានីភ្នំពេញ និងខេត្តណ្តាល គឺមានការប្រើប្រាស់ធនធាន សម្រាប់បម្រើឲ្យគណបក្សច្រើនជាងគេ បើប្រៀបធៀបនឹងខេត្តដទៃទៀត។ ទោះបីជាគណបក្សប្រជាជនកម្ពុជាបានប្រើប្រាស់ធនធានរដ្ឋយ៉ាងច្រើនដើម្បីពង្រឹងប្រជាប្រិយភាពរបស់ខ្លួននៅរាជធានីភ្នំពេញ និងខេត្តកណ្តាល ប៉ុន្តែគណបក្សនេះបែរជាមិនទទួលបានជ័យជំនះនៃការបោះឆ្នោតសម្រាប់មណ្ឌលទាំងពីរនេះទេ។ ខាងក្រោមនេះគឺជាតារាងបែងចែកចំនួនករណី ការប្រើប្រាស់ធនធានរដ្ឋទាំងនោះនៅថ្ងៃធ្វើការ និងថ្ងៃឈប់សម្រាក តាមខេត្តនីមួយៗ៖

តារាងទី៥៖ ការប្រើប្រាស់ធនធានរដ្ឋក្នុងថ្ងៃធ្វើការ និងឈប់សម្រាក

| ល.រ | រាជធានី/ ខេត្ត | ថ្ងៃធ្វើការ | ថ្ងៃឈប់សម្រាក | សរុប |
|---|---|---|---|---|
| ០១ | បន្ទាយមានជ័យ | ០៧ | ០៧ | ១៤ |
| ០២ | បាត់ដំបង | ០៤ | ០៩ | ១៣ |
| ០៣ | ពោធិ៍សាត់ | ០៤ | ០២ | ០៦ |
| ០៤ | កំពង់ឆ្នាំង | ០២ | ០២ | ០៤ |
| ០៥ | កណ្តាល | ២៣ | ៤៣ | ៦៦ |
| ០៦ | ភ្នំពេញ | ២៣ | ២៨ | ៥១ |
| ០៧ | តាកែវ | ០៤ | ១០ | ១៤ |
| ០៨ | កែប | ០១ | ០០ | ០១ |
| ០៩ | ព្រៃវែង | ០៦ | ១៣ | ១៩ |
| ១០ | ស្វាយរៀង | ០២ | ០៩ | ១១ |
| ១១ | កំពង់ស្ពឺ | ០៤ | ០៨ | ១២ |
| ១២ | កំពង់ចាម | ១២ | ១៣ | ២៥ |
| ១៣ | ក្រចេះ | ០៣ | ០៥ | ០៨ |
| ១៤ | ព្រះវិហារ | ០៩ | ០៥ | ១៤ |
| ១៥ | ឧត្តរមានជ័យ | ០៧ | ០៣ | ១០ |
| ១៦ | សៀមរាប | ០១ | ០៦ | ០៧ |
| ១៧ | កំពង់ធំ | ០៧ | ១៥ | ២២ |
| ១៨ | ប៉ៃលិន | ០៤ | ០២ | ០៦ |
| ១៩ | រតនគិរី | ០១ | ០១ | ០២ |
| ២០ | ព្រះសីហនុ | ០១ | ០០ | ០១ |
| ២១ | ស្ទឹងត្រែង | ០១ | ០០ | ០១ |
| សរុប | | ១២៦ (៤១,០៤%) | ១៨១ (៥៨,៩៥%) | ៣០៧ |

ការប្រើប្រាស់ធនធានរបស់រដ្ឋសម្រាប់បម្រើឲ្យគណបក្សនយោបាយ ជាពិសេសគណបក្សកំពុងកាន់អំណាចបានជះឥទ្ធិពលអវិជ្ជមានជាច្រើនចំពោះដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា។ មាត្រា២៧ ជំពូកទី៦នៃច្បាប់ស្តីពីគណបក្សនយោបាយត្រង់ចំណុចទី៥បានចែងថា ហិរញ្ញវត្ថុរបស់គណបក្សនយោបាយជាទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់គណបក្សនយោបាយ។ រាល់សកម្មភាពទាំងឡាយរបស់គណបក្សនយោបាយ ត្រូវតែជាការចំណាយហិរញ្ញវត្ថុរបស់គណបក្សនយោបាយនោះផ្ទាល់ដោយមិនអនុញ្ញាតឲ្យយកទ្រព្យសម្បត្តិរបស់រដ្ឋដើម្បីបម្រើឲ្យគណបក្សនយោបាយឡើយ។ ជាក់ស្តែងមាត្រា៨១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានចែងថា ចំណាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយ និងរបស់បេក្ខជនម្នាក់ៗជាបន្ទុករបស់គណបក្សនយោបាយ ឬបេក្ខជនផ្ទាល់។ ដូចទ្រព្យសម្បត្តិរបស់រដ្ឋដូចជា

អាគារ និងធនធានមនុស្សរបស់រដ្ឋជាដើមមិនត្រូវបានអនុញ្ញាតិយកទៅប្រើប្រាស់បម្រើឲ្យគណបក្សនយោបាយណាមួយនោះឡើយ។ នៅពេលដែលគណបក្សកាន់អំណាច ប្រើប្រាស់ធនធានរដ្ឋបម្រើឲ្យសកម្មភាពគណបក្សខ្លួន នោះលទ្ធផលស្របច្បាប់ដែលកើតចេញពីការបោះឆ្នោតនឹងនៅមានមន្ទិលសង្ស័យពីភាពសេរី និងយុត្តិធម៌នៃការបោះឆ្នោតនេះ។ ម្យ៉ាងវិញទៀតការចូលរួមសកម្មភាពនយោបាយពីកងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការស៊ីវិល ដូចជាមន្ត្រី តុលាការជាដើម ធ្វើឲ្យមានការគំរាមកំហែងដោយផ្ទាល់ ឬដោយប្រយោលទៅដល់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត។ សកម្មភាពទាំងនេះ គឺបានបង្កើតឲ្យមានបរិយាកាសភ័យខ្លាចទៅដល់ម្ចាស់ឆ្នោតរហូតធ្វើឲ្យការបោះឆ្នោតមិនមានភាពសេរី និងយុត្តិធម៌ទៀតផង។

***ការប្រើប្រាស់វេទិការបស់រដ្ឋបម្រើឲ្យគណបក្សនយោបាយ***

ដូចដែលបានរៀបរាប់បញ្ញត្តិច្បាប់ក្នុងជំពូក៦ មាត្រា២៧ នៃច្បាប់ស្តីគណបក្សនយោបាយ គណបក្សនយោបាយមិនអាចប្រើប្រាស់ធនធានរដ្ឋ ដើម្បីធ្វើសកម្មភាពបម្រើឲ្យផលប្រយោជន៍គណបក្សខ្លួនបានឡើយ។ ប៉ុន្តែគណបក្សប្រជាជនកម្ពុជាដែលជាគណបក្សកំពុងកាន់អំណាចជារឿយៗ បានយកវេទិការបស់រាជរដ្ឋាភិបាលដើម្បីប្រើប្រាស់កេណ្ឌផលប្រយោជន៍នយោបាយរបស់ខ្លួន តាមអង្កេតលើប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ គេឃើញថា ពីខែកញ្ញា ឆ្នាំ២០១២ ដល់ ខែកក្កដា ឆ្នាំ២០១៣ គណបក្សកាន់អំណាចបានប្រើប្រាស់វេទិកា ឬកម្មវិធីដែលរៀបចំដោយរដ្ឋចំនួន៧៣លើក ដើម្បីបម្រើប្រយោជន៍គណបក្សរបស់ខ្លួន។ ក្នុងនោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាថ្នាក់ដឹកនាំកំពូលរបស់គណបក្សប្រជាជនកម្ពុជា បានប្រើវេទិកាសាធារណៈ ឬកម្មវិធីរបស់រាជរដ្ឋាភិបាលចំនួន៧១ករណី ដើម្បីថ្លែងពីសារនយោបាយរបស់គណបក្សខ្លួនទៅកាន់ប្រជាពលរដ្ឋ បន្ថែមលើពីនេះលោក ហេង សំរិន ប្រធានរដ្ឋសភា និងអនុប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា បានប្រើប្រាស់វេទិកា ឬកម្មវិធីរបស់រដ្ឋចំនួន០២ផងដែរ។ ករណីទាំងអស់នោះមានដូចជា កម្មវិធីបើកការដ្ឋានសាងសង់ ឬ សម្ភោធសមិទ្ធផលផ្សេងៗមាន ៣៨ករណី កម្មវិធីសំណេះសំណាលចែកប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋមាន១៦ករណី កម្មវិធីចែកសញ្ញាបត្រនៃសកលវិទ្យាល័យរដ្ឋនានាមាន០៣ករណី វេទិកាបិទ និងបើកសន្និបាតរបស់ស្ថាប័នរដ្ឋនានា ០៨ករណី និងកិច្ចប្រជុំផ្សេងៗមាន០៨ករណី។ ថ្នាក់ដឹកនាំកំពូលគណបក្សនយោបាយទាំងពីរនេះតែងតែប្រើប្រាស់វេទិកា ឬកម្មវិធីសាធារណៈទាំងអស់នេះដើម្បីថ្លែងពីគុណបំណាច់របស់គណបក្សប្រជាជនកម្ពុជាចំពោះជាតិ ដូចជាការលើកឡើងថាគណបក្សប្រជាជនកម្ពុជាជាគណបក្សរំលោះកម្ពុជាពីរបបកាប់សម្លាប់ ប៉ុល ពត ជាដើម។ បន្ថែមលើពីនេះ មេដឹកនាំគណបក្សទាំងពីរជាពិសេសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាញឹកញយតែងតែយកវេទិកា ឬកម្មវិធីរបស់រដ្ឋទាំងនេះដើម្បីវាយប្រហារគណបក្សប្រឆាំងផងដែរ។

បើយើងធ្វើការប៉ាន់ស្មាន ពីតម្លៃនៃការចំណាយក្នុងការរៀបចំវេទិកា ឬកម្មវិធីដែលបានរៀបចំដោយរដ្ឋ គឺប្រហែលជាត្រូវការចំនួនទឹកប្រាក់ប្រមាណជាមធ្យមពី១០,០០០ ទៅ២០,០០០ដុល្លារសហរដ្ឋអាមេរិកដើម្បីរៀបចំកកម្មវិធី ឬវេទិកានីមួយៗ។ ដូចនេះគណបក្សកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជាបាន និងកំពុងប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់រដ្ឋដើម្បីបម្រើផលប្រយោជន៍នយោបាយរបស់ខ្លួន។

***ការប្រើប្រាស់កន្លែងសាធារណៈបម្រើឲ្យគណបក្សនយោបាយ***

ក្នុងចំណោម ៣៤៣ ករណីខាងលើ ខុមហ្វ្រែលបានរកឃើញការប្រើប្រាស់ទីកន្លែងសាធារណៈរបស់រដ្ឋ ចំនួន ២៧ ករណី ក្នុងគោលបំណងបម្រើឲ្យគណបក្សប្រជាជនកម្ពុជាដែលជាគណបក្សកាន់អំណាច។

នេះបង្ហាញថា គ្មានភាពស្មើភាពរវាងគណបក្សកាន់អំណាច និងគណបក្សផ្សេងៗទៀតដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតនោះទេ។

យោងតាមច្បាប់ស្ដីពីការបោះឆ្នោត ទីធ្លាសាធារណៈ(លើកលែងតែអាគាររដ្ឋ) ត្រូវបានផ្ដល់ឱកាសឲ្យប្រើប្រាស់ស្មើគ្នា ចំពោះគ្រប់គណបក្សនយោបាយទាំងអស់ ប៉ុន្តែតាមការសង្កេតជាក់ស្ដែង គណបក្សប្រជាជនកម្ពុជាទទួលបានការប្រើប្រាស់ទីធ្លាសាធារណៈទាំងអស់នោះច្រើនជាងគណបក្សផ្សេងៗទៀត។ ក្នុងចំណោម ២៧ករណី ដែលខុមហ្វ្រែលបាន រកឃើញនោះ មាន ១៩ ករណី ដែលគណបក្សប្រជាជនកម្ពុជាបានយកទីធ្លាវត្តអារាមដើម្បីធ្វើសកម្មភាពនយោបាយរបស់ខ្លួន។ ជាក់ស្ដែង លោក ញឹម វណ្ណដា អនុប្រធានទីមួយនៃគណៈកម្មាធិការជាតិគ្រោះមហន្តរាយ និងជាប្រធានក្រុមការងារពង្រឹងមូលដ្ឋាន ស្រុកពោធិ៍រៀង ខេត្តព្រៃវែង បានប្រើប្រាស់វត្តចំប៉ាសួស្ដីដើម្បីសំណេះសំណាលអំពីគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជាជាមួយប្រជាពលរដ្ឋ និងសមាជិកគណបក្សនេះបើតាមការផ្សាយរបស់ទូរទស្សន៍បាយ័នក្នុងកម្មវិធីព័ត៌មាន កាលពីថ្ងៃ ០៥ ខែកក្កដា ឆ្នាំ២០១៣។

ខុមហ្វ្រែលក៏បានសង្កេតឃើញថាគ្រឹះស្ថានរបស់រដ្ឋមួយចំនួនត្រូវបានប្រើប្រាស់ដើម្បីផលប្រយោជន៍របស់គណបក្សប្រជាជនកម្ពុជាផងដែរ។ ទីកន្លែងទាំងអស់នោះរួមមាន៖ សាលារាជធានី/ខេត្ត សាលាឃុំ/សង្កាត់ គ្រឹះស្ថានសិក្សា ទីបញ្ជាការអង្គរក្ស ព្រមទាំងទីកន្លែងៗផ្សេងៗទៀតផងដែរ។ តាមកម្មវិធីព័ត៌មានរបស់ទូរទស្សន៍បាយ័នដែលបានផ្សាយ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ លោក ប៉ា សុជាតិវង្ស អភិបាលរាជធានីភ្នំពេញបាននិយាយឃោសនាឲ្យគណបក្សប្រជាជនកម្ពុជា នៅក្នុងសាលារាជធានីភ្នំពេញតាមរយៈថ្លែងទៅកម្មករមន្ទីរសាធារណការ និងដឹកជញ្ជូន ក្នុងកម្មវិធីតំឡើងប្រាក់បៀវត្សដល់កម្មករទាំងនោះ។ ចំណែក លោក ហ៊ីង ប៊ុនហៀង អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ បានសំណេះសំណាលជាមួយយុវជនគណបក្សប្រជាជនកម្ពុជាខេត្តកណ្ដាល នៅទីបញ្ជាការដ្ឋានអង្គរក្សទួលក្រសាំង នេះបើតាមព័ត៌មានដែលបានផ្សាយកាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣។

***ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ គណបក្សកាន់អំណាច***

ស្ថានីយទូរទស្សន៍ជាតិកម្ពុជា(ទទក) គឺជាស្ថាប័នរបស់រដ្ឋតែមួយគត់។ ស្ថានីយទូរទស្សន៍នេះតែងតែចាក់ផ្សាយរាល់បេសកកម្មការងារ ឬសកម្មភាពផ្សេងៗរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា។ តាមរយៈការសង្កេតយើងឃើញថា សកម្មភាពទាំងអស់នោះមិនត្រឹមតែជាសកម្មភាពការងាររបស់រាជរដ្ឋាភិបាល ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជានោះទេ តែស្ថានីយ៍ទូរទស្សន៍នេះក៏បានផ្សព្វផ្សាយពីសកម្មភាពឯកជនរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលដែលជាថ្នាក់ដឹកនាំគណបក្សប្រជាជនផងដែរ។ ខុមហ្វ្រែលសង្កេតឃើញថា សកម្មភាពសប្បុរសធម៌ជាច្រើនរបស់ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាត្រូវបានចាក់ផ្សាយក្នុងស្ថានីយទូរស្សន៍នេះ។ ជាក់ស្ដែងសកម្មភាពចុះសួរសុខទុក្ខ របស់អ្នកតំណាងរាស្ដ្រគណបក្សប្រជាជនកម្ពុជា ជារឿយៗត្រូវបានចាក់ផ្សាយ ផ្ទុយមកវិញ សកម្មភាពដូចគ្នាប៉ុន្តែដឹកនាំដោយតំណាងរាស្ដ្រគណបក្សដទៃមិនត្រូវបានផ្សាយក្នុងស្ថានីយ៍ទូរទស្សន៍នេះទេ។ លើសពីនេះទៅទៀតស្ថានីយ៍ទូរទស្សន៍រដ្ឋមួយនេះតែងតែធ្វើការផ្សាយពីការផ្ដល់អំណោយជូនប្រជាពលរដ្ឋក្នុងកម្មវិធីផ្សេងៗក្រោមរូបភាពម្ចាស់អំណោយគឺ លោកនាយរដ្ឋមន្ត្រី ហ៊ុន សែន ដែលជាថ្នាក់ដឹកនាំកំពូលមួយរូបរបស់គណបក្សប្រជាជនកម្ពុជា។ ថ្ងៃទី០៥ មិថុនា ២០១៣ លោក ណឹម ចាន់ដារ៉ា តំណាងរាស្ដ្ររបស់គណបក្សប្រជា

ជនកម្ពុជាសម្រាប់មណ្ឌលកំពត បានចុះសួរសុខទុកប្រជាពលរដ្ឋក្នុងមូលដ្ឋាន ហើយសកម្មភាពត្រូវបានចាក់ផ្សាយក្នុងកម្មវិធីទូរទស្សន៍ជាតិកម្ពុជា (ទទក) កាលពីថ្ងៃទី ០៧ តុលា ២០១៣។ ផ្ទុយមកវិញ តំណាងរាស្ត្រគណបក្សផ្សេងៗ ជាពិសេសគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស (គណបក្សសង្គ្រោះជាតិ) មិនត្រូវបានស្ថានីយ៍ទូរទស្សន៍រដ្ឋមួយបានធ្វើការផ្សាយនោះទេ។ នេះបើយោងតាមការសង្កេតប្រព័ន្ធផ្សព្វផ្សាយរបស់អង្គការខុមហ្វ្រែល។

នេះបង្ហាញឲ្យឃើញថា ស្ថាបន័ទូរទស្សន៍ជាតិមួយនេះកំពុងតែបានក្លាយខ្លួនជាឧបករណ៍មួយបម្រើ និងគាំទ្រគណបក្សនយោបាយដែលកំពុងកាន់អំណាចគឺគណបក្សប្រជាជនកម្ពុជា និយាយម្យ៉ាងវិញទៀត គណបក្សនេះកំពុងតែបានប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនក្នុងការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយមួយនេះផងដែរ។

### *ការប្រើប្រាស់ធនធានរដ្ឋបម្រើឲ្យគណបក្សនយោបាយអំឡុងពេលឃោសនា*

ដោយឡែក ពីថ្ងៃទី២៧ ខែមិថុនា រហូតដល់ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣ ដែលជាអំឡុង ពេលនៃការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ដោយសារគណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត បានធ្វើសកម្មភាពរបស់ខ្លួនយ៉ាងសកម្មក្នុងអំឡុងពេលនោះ។ ទន្ទឹមគ្នានោះដែរ ការប្រើប្រាស់ធនធានបម្រើឲ្យគណបក្សកំពុងកាន់អំណាច គណបក្សប្រជាជនកម្ពុជា ក៏កើតមានជាបន្តបន្ទាប់ផងដែរ។ តាមការសង្កេតលើប្រព័ន្ធផ្សព្វផ្សាយនានានៅក្នុងស្រុក ដូចជា៖ ទូរទស្សន៍ជាតិកម្ពុជា (ទទក) ទូរទស្សន៍ ស៊ី ធី អិន និងទូរទស្សន៍បាយ័នព័ត៌មាន ព្រមទាំងគេហទំព័រផ្សព្វផ្សាយព័ត៌មានជាច្រើនទៀត ក្នុងអំឡុងពេលឃោសនាមានការប្រើប្រាស់ធនធានរដ្ឋបម្រើឲ្យ គណបក្សនយោបាយ គឺគណបក្សប្រជាជនកម្ពុជា ចំនួន២៩ករណី ហើយភាគច្រើនលើសលុបនៃការប្រើប្រាស់ធនធានរដ្ឋទាំងនោះ គឺការឃោសនា និងចូលរួមសកម្មភាពឃោសនារបស់មន្ត្រីរាជការ និងកងម្លាំងប្រដាប់អាវុធសម្រាប់គណបក្សនយោបាយ មានចំនួន២៤ករណី (៦២%)។ ការប្រើប្រាស់ទីធ្លាវត្តអារាមដើម្បីប្រជុំ និងឃោសនាគណបក្សនយោបាយមានចំនួន០៥ ករណី (៣៨%)។

**រូបភាពទី៦៖ការប្រើប្រាស់រថយន្តដែលគ្មានស្លាកលេខក្នុងពេលឃោសនាបោះឆ្នោតរបស់គណបក្សប្រជាជនកម្ពុជា**







Source: PEFOC,J

## ៩. ការទទួល និងដោះស្រាយបណ្តឹង

ការសង្កេតឃើញថា ស្ថាប័នទាំងពីរនេះមិនទាន់មាននីតិវិធីច្បាស់លាស់ក្នុងការដោះស្រាយបណ្តឹង ជាពិសេសពុំមានយុទ្ធវិធីក្នុងការស្វែងរកភស្តុតាង និងស៊ើបអង្កេតដោយខ្លួនឯងក្នុងការដោះស្រាយវិវាទបោះឆ្នោត។

## ៩.១ ដំណើរការដោះស្រាយបណ្តឹង

### *៩.១.១ការដោះស្រាយបណ្តឹងដោយគ.ជ.ប*

គ.ជ.ប ដើរតួនាទីជាស្ថាប័នតុលាការដោះស្រាយវិវាទបោះឆ្នោតមួយសម្រាប់ដោះស្រាយពីភាពមិនប្រក្រតីនៃការបោះឆ្នោត និងការតវ៉ាពីលទ្ធផលបណ្តោះអាសន្នដែលគ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតណាមិនសុខចិត្តទៅនឹងការប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្នរបស់គ.ជ.ប។ តាមក្របខណ្ឌច្បាប់នៃការរៀបចំការបោះឆ្នោត គ.ជ.ប មានសិទ្ធិបដិសេធមិនទទួលដោះស្រាយ ប្រសិនបើ គ.ជ.ប ឃើញថាមិនត្រឹមត្រូវតាមទម្រង់ ឬគតិច្បាប់ ឬ/និងមិនមានអំណះអំណាងណាមួយពាក់ព័ន្ធនឹងកម្មវិត្ថុនៃបណ្តឹងដែលអាចយកមកដោះស្រាយបាន ឬ/និងអំណះអំណាងស្រពេចស្រពិលមិនច្បាស់លាស់ ឬ/និងតាមការស៊ើបអង្កេតស្រាវជ្រាវ របស់ គ.ជ.ប ។ គ.ជ.ប បដិសេធដោយធ្វើលិខិតជូនដំណឹងតាមបែបបទរដ្ឋបាលក្នុង រយៈពេលសមស្របមួយទៅដើមបណ្តឹងដើម្បីជូនជ្រាបថា បណ្តឹងនោះមិនត្រូវបានយកមកដោះស្រាយទេ។

បើទោះជាការបដិសេធមិនដោះស្រាយដោយផ្អែកទៅលើការស៊ើបអង្កេតរបស់គ.ជ.ប ក៏ដោយ ក៏នៅតែមិនមានយន្តការស៊ើបអង្កេតអោយបានច្បាស់លាស់សម្រាប់អោយដើមបណ្តឹងអាចទទួលយកបាននូវការបដិសេធរបស់គ.ជ.ប ក្នុងការមិនដោះស្រាយបណ្តឹងរបស់ខ្លួនដែរ។ យន្តការស៊ើបអង្កេតបច្ចុប្បន្នរបស់គ.ជ.ប មិនបានទទួលការទុកចិត្តពីគ្រប់ភាគីពាក់ពន្ធ័ទេ ពីព្រោះតែកាខ្វះខាតខាងធនធានមនុស្ស ជំនាញបច្ចេកទេស និងក្របខណ្ឌច្បាប់បន្ថែមទៀត។ រាល់ការកង្វះខាតនេះនាំអោយការការបដិសេធរបស់គ.ជ.ប ដោយផ្អែកទៅលើការស៊ើបអង្កេតស្រាវជ្រាវ និងការពិនិត្យទៅលើទម្រង់ និងគតិច្បាប់ សុទ្ធតែជាហេតុផលដែលមិនមានតម្លាភាព មិនមានជំនាញ និងអពម្មានុរូប។

គ.ជ.ប អាចធ្វើការពិនិត្យទៅលើបណ្តឹងបាន លុះត្រាតែដើមបណ្តឹងបានបំពេញទម្រង់បណ្តឹង និងតម្រូវអោយបង្ហាញនូវព័ត៌មានមួយចំនួនសម្រាប់ធ្វើជាមូលដ្ឋានក្នុងការស៊ើបអង្កេត និងដំណើរការដោះស្រាយបណ្តឹងរបស់គ.ជ.ប នេះបើយោងតាមលក្ខ័ណ្ឌច្បាប់។ ជាក់ស្តែងនៅថ្ងៃបោះឆ្នោត ទម្រង់បណ្តឹង ឬហៅថាទម្រង់១២០២ ដែលសម្រាប់អោយអ្នកតវ៉ាបំពេញពាក្យបណ្តឹងមិនត្រូវបានផ្តល់ជូនដោយមន្ត្រីរៀបចំការបោះឆ្នោតទេ ដែលទង្វើនេះផ្ទុយទាំងស្រុងទៅនឹងក្របខណ្ឌច្បាប់បោះឆ្នោត និងការអនុវត្តសិទ្ធិរបស់អ្នកបោះឆ្នោត។

សវនាការរបស់ គ.ជ.ប ដែលទាក់ទងទៅការដោះស្រាយបណ្តឹង គឺតម្រូវអោយមានការបើកសវនាការជាសាធាណៈ និងតម្រូវអោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ឬ/និងតំណាង និងសាក្សីពាក់ព័ន្ធនានាទៀត។ ផ្ទុយទៅវិញ គ.ជ.ប មិនដែលបានបើកសវនាការជាសាធារណៈណាមួយឡើយ ដោយគ្រាន់តែមានការប្រជុំសម្រេចនៅក្នុងចំណោមមន្ត្រីគ.ជ.ប ដើម្បីធ្វើការសម្រេចទៅលើបណ្តឹង និងជូនដំណឹងដើមបណ្តឹងដោយមិនមានការពន្យល់អំពីហេតុផល និងលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួនអោយបានច្បាស់លាស់ ឬ/និងការសាកសួរសាក្សីនោះទេ។

### *៩.១.២ ការដោះស្រាយបណ្តឹងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ*

ក្រុមប្រឹក្សាធម្មនុញ្ញពុំមាននីតិវិធីច្បាស់លាស់សម្រាប់កាដោះស្រាយបណ្តឹង និងដំណើរការនៃសវនាការរបស់ខ្លួនទេ បើទោះបីក្រុមប្រឹក្សានេះមានច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ

បទបញ្ជាស្តីពីនីតិវិធី និងបទបញ្ជាផ្ទៃក្នុង។ ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញគ្រាន់តែផ្អែកលើរបាយការណ៍របស់ចុងចម្លើយ(គ.ជ.ប) ដោយពុំមាននីតិវិធីស៊ើបអង្កេតដោយខ្លួនឯង បើទោះបីជាមានការស៊ើបអង្កេតដោយត្រឹមតែបើកកញ្ចប់សុវត្ថិភាព«ក» ក៏ក្រុមប្រឹក្សាធម្មនុញ្ញបានប្រគល់ភារកិច្ចនៃការផ្ទៀងផ្ទាត់ឲ្យទៅគ.ជ.ប ដែលជាចុងចម្លើយជាអ្នកអនុវត្ត ក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកតាមដានដំណើរការនេះទៅវិញ។ ចំណែកឯការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញឲ្យមានការផ្ទៀងផ្ទាត់សម្លេងឆ្នោតនៅការិយាល័យមួយចំនួនក៏ខុសទៅនឹងកម្មវត្ថុនៃពាក្យបណ្តឹង ហើយក៏មិនមានមូលហេតុសំអាងផងដែរ ជាពិសេសបណ្តឹងទាំងអស់បានប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់គ.ជ.បទាក់ទងលទ្ធផលបណ្តោះអាសន្ន ប៉ុន្តែការដោះស្រាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញមិនត្រឹមតែតម្កល់សេចក្តីសម្រេចរបស់គ.ជ.ប ទុកជាបានការ ដោយគ្រាន់តែសម្រេចឲ្យគ.ជ.ប ចាត់វិធានការលើមន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅខេត្តមួយចំនួនទៅវិញ។

❖ ***សមាសភាពក្រុមប្រឹក្សាធម្មនុញ្ញ***

សមាសភាពភាគច្រើនរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាពិសេសប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកទទួលខុសត្រូវបណ្តឹងនេះនៅតែជាមន្ត្រីរបស់គណបក្សប្រជាជនកម្ពុជា(ជាសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលរបស់គណបក្សប្រជាជនកម្ពុជា) ដោយមិនគោរពតាមប្រការ៤នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាធម្មនុញ្ញដែលបានបញ្ជាក់ថា *"សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវកាន់កាប់ក្នុងគណបក្សនយោបាយណាមួយនូវមុខតំណែងទទួលខុសត្រូវ..."*។

**រូបភាពទី៧៖ ដំណើរការដោះស្រាយបណ្តឹងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ និងការបញ្ជាឲ្យគ.ជ.ប បើកញ្ចប់សុវត្ថិភាព ក**





## ៩.២ បណ្តឹងកំឡុងពេលឃោសនាបោះឆ្នោត

នៅក្នុងដំណើរការឃោសនាបោះឆ្នោតនីតិកាលទី៥នេះ បណ្តឹងមានការកើនឡើងបើប្រៀបធៀបទៅនឹងការបោះឆ្នោតឆ្នាំមុនៗ។ ខុមហ្វ្រែលសង្កេតឃើញថា ចំនួននៃការបដិសេធបណ្តឹងមានការកើនឡើងនៅគណកម្មាការរៀបចំការបោះឆ្នោតឃុំសង្កាត់។ នៅក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ៣៧៣ បណ្តឹងត្រូវបានដាក់ទៅគណកម្មាការរៀបចំការបោះឆ្នោតថ្នាក់ឃុំសង្កាត់ គឃ/សប ហើយនៅក្នុងនោះដែរ ១៦៤បណ្តឹងត្រូវបានបដិសេធ ដែលចំនួននេះបើធៀបនឹងការបោះឆ្នោតឆ្នាំ២០០៨ មាន១២បណ្តឹងប៉ុណ្ណោះដែលបានបដិសេធ។

មានបណ្តឹងចំនួន១២២ បានប្តឹងបន្តទៅគណកម្មាការរៀបចំការបោះឆ្នោតថ្នាក់ខេត្ត (គធ/ខប) និងមាន៤៤បណ្តឹងត្រូវបានប្តឹងបន្តទៅគ.ជ.ប នៅពេលដែលមានការមិនពេញចិត្តនឹងការដោះស្រាយ របស់គឃ/សប និងគធ/ខប។ យ៉ាងណាមិញ មាន១២បណ្តឹងត្រូវបានប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ ហើយក៏ត្រូវបានបដិសេធទាំងអស់។ ខុមហ្វ្រែលសង្កេតឃើញថា បណ្តឹងភាគច្រើនត្រូវបានប្តឹងដោយគណបក្សសង្គ្រោះជាតិ

មិនត្រឹមតែគណបក្សនយោបាយដែលចូលរួមប្រកួតប្រជែង និងប្រជាពលរដ្ឋដាក់ពាក្យបណ្តឹងប៉ុណ្ណោះទេ ប៉ុន្តែអាជ្ញាធរមូលដ្ឋានដូចជា អាជ្ញាធរក្រុង/ស្រុក/ខណ្ឌ អាជ្ញាធរឃុំសង្កាត់ អាជ្ញាធរកងរាជអាវុធហត្ថ ព្រមទាំងមន្ទីរខេត្តដែលគួរតែមានតួនាទីជាអ្នកសម្របសម្រួល ក៏បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងការឃោសនារបស់គណបក្សសង្គ្រោះជាតិដែរ ដោយយោងលើមូលហេតុនៃការបិទខិត្តប័ណ្ណនៅលើបង្គោលភ្លើងដោយពុំមានការអនុញ្ញាតជាដើម។

បណ្តឹងភាគច្រើនទាក់ទងទៅនឹងការបំផ្លាញសំភារៈឃោសនា ការរំខានក្នុងពេលឃោសនា ការការហែកខិត្តប័ណ្ណ ភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត និងការប្រើប្រាស់រថយន្តរដ្ឋទៅធ្វើការឃោសនា។

ចំពោះការដោះស្រាយបណ្តឹង គណបក្សនយោបាយមួយចំនួនហាក់ដូចជាមិនសុខចិត្តទៅលើការដោះស្រាយរបស់គណកម្មការរៀបចំការបោះឆ្នោតថ្នាក់ឃុំសង្កាត់ដែលព្យាយាមធ្វើការសំរបសំរួល ដោយពួកគេយល់ឃើញថាការសម្របសម្រួលនេះជារឿងមិនត្រឹមត្រូវ ដែលបណ្តឹងខ្លះជាករណីបទល្មើសដែលអ្នកប្រព្រឹត្តត្រូវតែទទួលពិន័យ។ គណបក្សខ្លះបានលើកឡើងថា ការសម្របសម្រួលនេះ ហាក់បីដូចជាការបិទបាំងបញ្ចប់ដើម្បីឲ្យបណ្តឹងទាំងនោះត្រូវបញ្ចប់ ជាពិសេសគណកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់(គឃ/សប) ព្យាយាមពន្យារពេលនៃការទទួលពាក្យបណ្តឹងដែលធ្វើឲ្យដំណើរការដាក់ពាក្យបណ្តឹងមានភាពស្មុគស្មាញ។

ដោយឡែកបើយោងតាមសៀវភៅស ស្តីពីការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥នៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣ របស់គ.ជ.ប បើទោះបីជាពុំមានការបើកសវនការជាសាធារណៈដែលអាចបង្ហាញពីតម្លាភាពនៃការដោះស្រាយបណ្តឹង គ.ជ.ប បានចាត់វិធានការប្រឆាំងនឹងអ្នកប្រព្រឹត្តបទល្មើសចំនួន២៤នាក់ ដែលក្នុងនោះ ១៦នាក់ ព្រមានជាលាយលក្ខណ៍អក្សរ, ១នាក់ ព្រមានផ្ទាល់មាត់, ៣នាក់ ពិន័យប្រាក់ចំនួន ៥ ០០០ ០០០រៀល,១នាក់លុបឈ្មោះចេញពីបញ្ជីបោះឆ្នោតរយៈពេល៣ឆ្នាំ, ម្នាក់ផ្តល់ការក្រើនរំលឹក និង២នាក់ទៀតត្រូវបានបញ្ជូនទៅក្រសួងមហាផ្ទៃ និងក្រសួងអប់រំ យុវជន និងកីឡាតាមស្ថាប័នរៀងៗខ្លួន ដើម្បីដាក់ទណ្ឌកម្ម។

## ៩.៣ បណ្តឹងអំឡុងពេលបោះ និងរាប់សន្លឹកឆ្នោត

បើយោងតាមសៀវភៅស ស្តីពីការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥នៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣របស់គ.ជ.ប បណ្តឹងចំនួន២៨១ ត្រូវបានដាក់មកគណកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់ក្នុងថ្ងៃបោះឆ្នោត។ ក្នុងចំណោមបណ្តឹងទាំងអស់នោះ មាន១៥១បណ្តឹង ប្តឹងដោយគណបក្សសង្គ្រោះជាតិ, ៦៥បណ្តឹងប្តឹងដោយគណបក្សប្រជាជនកម្ពុជា, ៥០បណ្តឹងប្តឹងដោយប្រជាពលរដ្ឋ, ១បណ្តឹងប្តឹងដោយគណបក្សហ្វ៊ុនស៊ិនប៉ិច, ១៣បណ្តឹងដោយអ្នកសង្កេតការណ៍, ១បណ្តឹងប្តឹងដោយមន្ត្រីរៀបចំការបោះឆ្នោត។ បណ្តឹងទាំងអស់នេះ ភាគច្រើនទាក់ទងទៅនឹងការរំខានដល់ដំណើរការបោះឆ្នោត បំភិតបំភ័យអ្នកបោះឆ្នោត រារាំងអ្នកបោះឆ្នោតមិនឲ្យទៅបោះឆ្នោត ការអនុញ្ញាតឲ្យអ្នកបោះឆ្នោតបានបោះឆ្នោតដោយពុំមានឯកសារបញ្ជាក់អត្តសញ្ញាណគ្រប់គ្រាន់ ការអនុញ្ញាតឲ្យជនអន្តោប្រវេសន៍បោះឆ្នោត ព្រមទាំងរារាំងតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលអនុវត្តសិទ្ធិហួសពីការកំណត់។

ក្នុងចំណោម២៨១បណ្តឹង ៥៦%នៃបណ្តឹងត្រូវបានបដិសេធ ដោយក្នុងនោះមាន១០៩ បណ្តឹងបាន ប្តឹងបន្តទៅគណកម្មាការខេត្តរៀបចំការបោះឆ្នោតដោយសារការមិនពេញចិត្តនឹងការដោះស្រាយរបស់គណក ម្មាការឃុំសង្កាត់រៀបចំការបោះឆ្នោត ហើយ ៨៥% ត្រូវបានបដិសេធ។ ក្នុងចំណោម បណ្តឹងដែលប្តឹងទៅ គណកម្មាការខេត្តរៀបចំការបោះឆ្នោត មាន៣៨បណ្តឹង បានប្តឹងតវ៉ាមកគ.ជ.ប ហើយក៏ត្រូវបានបដិសេធ ប្រមាណ៨៩% ហើយនៅក្នុងនោះមាន១២បណ្តឹងត្រូវបានប្តឹងបន្តទៅក្រុមប្រឹក្សាធម្មនុញ្ញ ហើយក៏បាន សម្រេចលើពាក្យបណ្តឹងទាំងនោះដោយធ្វើការតំកល់សេចក្តីសម្រេចទាំងស្រុង និងការកែសម្រួលលើសេចក្តី សម្រេចរបស់គ.ជ.ប ព្រមទាំងបដិសេធមិនដោះស្រាយផងដែរ។

បើយោងតាមសៀវភៅស ចេញដោយគ.ជ.ប បណ្តឹងដែលមានភស្តុតាងសំអាងគ្រប់គ្រាន់ មន្ត្រី រៀបចំការបោះឆ្នោត ព្រមទាំងគ.ជ.ប បានចាត់វិធានការចំពោះអ្នកប្រព្រឹត្តបទល្មើស ដូចជា ១១នាក់ បានធ្វើ ការព្រមានជាលាយលក្ខណ៍អក្សរ ១១នាក់លុបឈ្មោះចេញពីបញ្ជីបោះឆ្នោតរយៈពេល៣ឆ្នាំ ១នាក់ដកសិទ្ធិ បោះឆ្នោតរយៈពេល៣ឆ្នាំ និង២នាក់ ត្រូវបានបញ្ជូនទៅក្រសួងមហាផ្ទៃដើម្បីដាក់ទណ្ឌកម្ម។

យ៉ាងណាមិញ តាមសេចក្តីប្រកាសរបស់គ.ជ.ប ពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការដាក់ និង ទទួលនូវរាល់របាយការណ៍ស្តីពីភាពមិនប្រក្រតីក្នុងការបោះឆ្នោតនៅគ.ជ.ប និងនៅគណកម្មាការរាជធានី ខេត្តរៀបចំការបោះឆ្នោតពីថ្ងៃទី២ ដល់ទី៦ ខែសីហា ឆ្នាំ២០១៣។ ក្នុងនោះគ.ជ.ប បានទទួលរបាយការណ៍ សរុបចំនួន៤៨ ពីរាជធានីខេត្តចំនួន១១ ហើយរបាយការណ៍នោះ ត្រូវបានដាក់ដោយគណបក្សសង្គ្រោះជាតិ គណបក្សប្រជាជនកម្ពុជា គណបក្សហ្វ៊ុនស៊ិនប៉ិច អាជ្ញាធរ និងប្រជាពលរដ្ឋ។ របាយការណ៍របស់គណបក្ស សង្គ្រោះជាតិ ត្រូវបានលើកឡើងពីភាពមិនប្រក្រតីទាក់ទងទៅនឹងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១២ លិខិត បញ្ជាក់អត្តសញ្ញាណ និងហេតុការណ៍នៅថ្ងៃបោះឆ្នោត។ គ.ជ.ប បដិសេធក្នុងការពិនិត្យលើរបាយការណ៍នេះ ដោយសម្អាងថា គណបក្សមិនបានផ្តល់ជូននូវភស្តុតាងដល់គ.ជ.ប។

ចំណែករបាយការណ៍ភាពមិនប្រក្រតីរបស់គណបក្សផ្សេង និងភាគីពាក់ព័ន្ធដទៃទៀតដែលទាក់ទង ទៅនឹងការឃោសនានៅថ្ងៃហាមឃាត់ ការអុកឡុក រំខានការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ការធ្វើឲ្យបាត់ ជំនឿលើការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ការរារាំង ការគំរាមកំហែង អ្នកបោះឆ្នោតមិនឲ្យទៅបោះឆ្នោត ការ ធ្វើឲ្យអ្នកបោះឆ្នោតភ័យខ្លាចមិនហ៊ានទៅបោះឆ្នោត ការទិញទឹកចិត្ត ទិញសន្លឹកឆ្នោត ការរំខានការងារមន្ត្រី បោះឆ្នោត ការដឹកជញ្ជូនអ្នកបោះឆ្នោត និងការធ្វើសកម្មភាពប្រមូលប្រជាពលរដ្ឋឲ្យដាក់ពាក្យប្តឹងនៅក្រោយ ថ្ងៃបោះឆ្នោត។ ដោយឡែកដោយយោងតាមរបាយការណ៍នេះ គ.ជ.ប បានចាត់ទុកថា ករណីទាំងនេះបាន កើតឡើងនៅខាងក្រៅការិយាល័យបោះឆ្នោត ដែលមិនចាត់ទុកថា ជាភាពមិនប្រក្រតីដែលត្រូវដោះស្រាយ នោះឡើយ។

## ៩.៤ បណ្តឹងទាក់ទងទៅនឹងលទ្ធផលបណ្តោះអាសន្ន

បើយោងតាមមាត្រា១១៤នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្រ្ត និងច្បាប់ស្តីពីវិសោធន កម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្រ្ត "បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្នក្នុងរយៈ ពេលចិតសិបពីរ (៧២) ម៉ោងយ៉ាងយូរ គ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត អាចប្តឹង តវ៉ាអំពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ឬទៅក្រុមប្រឹក្សាធម្មនុញ្ញដោយផ្ទាល់ក៏បាន......" ដូច្នេះបន្ទាប់ពីការចេញលទ្ធផលបណ្តោះអាសន្នរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតរួចមក មានតែគណបក្សសង្គ្រោះជាតិតែមួយគត់ដែលបានដាក់ពាក្យបណ្តឹងតវ៉ាទៅលើលទ្ធផលបណ្តោះអាសន្នទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ដែលសរុបមានចំនួន ១៧បណ្តឹង។ បណ្តឹងទាំងអស់នោះមានចំនួន១៦ បណ្តឹង ប្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅតាមមណ្ឌលរាជធានីខេត្ត និងចំនួន១បណ្តឹង ប្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៅទូទាំងប្រទេស។ បណ្តឹងដែលគណបក្សសង្គ្រោះជាតិបានប្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៅតាមមណ្ឌលខេត្តមានដូចជា ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល ក្រចេះ ភ្នំពេញ ព្រៃវែង ពោធិសាត់ សៀមរាប ព្រះសីហនុ ស្វាយរៀង តាកែវ និងលទ្ធផលបោះឆ្នោតនៅទូទាំងប្រទេស។

ការតវ៉ានេះដោយហេតុថា បញ្ជីឈ្មោះបោះឆ្នោតប៉ោងទិន្នន័យ ភាពមិនប្រក្រតីនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត ទឹកខ្មៅលុបលាងមិនជ្រះអាចលុបលាងបាន អនុញ្ញាតឲ្យអ្នកបោះឆ្នោត ដែលគ្មានឯកសារបញ្ជាក់អត្តសញ្ញាណណាមួយអាចបោះឆ្នោតបាន តាមរយៈការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រប់បម្រើឲ្យការបោះឆ្នោត ដែលមិនត្រឹមត្រូវតាមនីតិវិធី បាត់ឈ្មោះអ្នកបោះឆ្នោតពីបញ្ជីបោះឆ្នោត និងការមិនអនុញ្ញាតឲ្យអ្នកបឆ្នោតដែលមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអាចបោះឆ្នោតបាន ដោយមានទិន្នន័យបន្តិចបន្តួច និងការប្រើប្រាស់បណ្តាញសារព័ត៌មានរួមមានទូរទស្សន៍ និងវិទ្យុបម្រើឲ្យគណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ សុំឲ្យមានការបើកញ្ញប់សុវត្ថិភាព "ក" ដើម្បីពិនិត្យលើទម្រង់ ១១០១, ១១០២, ១១០៤ និង ១១០៨ ដោយបង្កើតក្រុមការងារបច្ចេកទេស និងវាយតម្លៃភាពមិនប្រក្រតីដោយអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ មានជំនាញកិច្ចការបោះឆ្នោត និងតំណាងរបស់ អ.ស.ប ជាអ្នកសង្កេតការណ៍ និងស្នើសុំឲ្យប្រជាពលរដ្ឋដែលបាត់ឈ្មោះ បានបោះឆ្នោតឡើងវិញ។

### ៩.៥ ការដោះស្រាយបណ្តឹងតវ៉ាទាក់ទងទៅនឹងលទ្ធផលបណ្តោះអាសន្នដោយគ.ជ.ប

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានទទួលពាក្យបណ្តឹងតវ៉ាទៅលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតចំនួន ១៧ ពាក្យបណ្តឹងពីតំណាងគណបក្សសង្គ្រោះជាតិ បន្ទាប់មក គ.ជ.ប កោះអញ្ជើញគូភាគីមកធ្វើការសាកសួរ និងឆ្លើយបំភ្លឺ និងបានបើកកិច្ចប្រជុំពេញអង្គដើម្បីពិនិត្យ និងបានសម្រេចធ្វើទៅលើពាក្យបណ្តឹងទាំងនោះ។ គ.ជ.ប បានសម្រេចបដិសេធពាក្យបណ្តឹងចំនួន ១៣ បណ្តឹងតាមរយៈលិខិតជូនដំណឹងបដិសេធជាបន្តបន្ទាប់ ដែលក្នុងនោះចំនួន ០១ បណ្តឹងនៅទូទាំងប្រទេស និងចំនួន ១២ បណ្តឹងនៅតាមមណ្ឌលរាជធានី ខេត្ត រួមមាន៖ ១-មណ្ឌលខេត្តបន្ទាយមានជ័យ, ២-មណ្ឌលខេត្តកំពង់ចាម, ៣-មណ្ឌលខេត្តកំពង់ឆ្នាំង, ៤-មណ្ឌលខេត្តកំពង់ស្ពឺ, ៥-មណ្ឌលខេត្តកំពង់ធំ, ៦-មណ្ឌលខេត្តកំពត, ៧-មណ្ឌលរាជធានីភ្នំពេញ, ៨-មណ្ឌលខេត្តព្រៃវែង, ៩-មណ្ឌលខេត្តពោធិសាត់, ១០-មណ្ឌលខេត្តព្រះសីហនុ, ១១-មណ្ឌលខេត្តស្វាយរៀង និង ១២-មណ្ឌលខេត្តតាកែវ។ មូលហេតុដែល គ.ជ.ប សំអាងយកមកធ្វើការបដិសេធលើពាក្យបណ្តឹងរបស់តំណាងគណបក្សសង្គ្រោះជាតិរួមមាន ៖

១- ករណីការបាត់ឈ្មោះ ឈ្មោះស្ទួន និងខុសទិន្នន័យនៅក្នុងបញ្ជីបោះឆ្នោត គ.ជ.ប បានពិនិត្យ និងអំពាវនាវឲ្យប្រជាពលរដ្ឋទាំងនោះទៅធ្វើការចុះឈ្មោះបោះឆ្នោត លុបឈ្មោះដែលលើសនៅក្នុងបញ្ជី និងកែទិន្នន័យឈ្មោះរបស់ខ្លួនក្នុងបញ្ជីឈ្មោះបោះឆ្នោតរួចរាល់ហើយ។

២- ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីឲ្យ គ.ជ.ប អាចយកមកពិនិត្យ និងវាយតម្លៃលើភាពមិនប្រក្រតីដែលបានកើតមានទាំងនោះបានឡើយ។

៣- ពុំបានផ្តល់ភស្តុតាងពីភាពមិនប្រក្រតីណាមួយធ្ងន់ធ្ងរដែលអាច គ.ជ.ប រៀបចំការបោះឆ្នោតឡើងវិញបានទេ ម្យ៉ាងទៀតដោយ គ.ជ.ប សំអាងថាតំណាងគណបក្សសង្គ្រោះជាតិបានចុះហត្ថលេខាលើកំណត់ហេតុទាំងអស់នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

៤- មិនបានបញ្ជាក់ពីភាពមិនប្រក្រតីរបស់ គណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុស រួមទាំងមិនមានឯកសារភស្តុតាងគ្រប់គ្រាននោះដែរ។

៥- តំណាងគណបក្សសង្គ្រោះជាតិ មិនបានផ្តល់ភស្តុតាងច្បាស់លាស់ពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយដែលឲ្យ គ.ជ.ប ធ្វើការផ្ទៀងផ្ទាត់ទម្រង់មួយចំនួននៅតាមការិយាល័យដែលបានស្នើសុំនោះទេ។

ដោយឡែក គ.ជ.ប បានពិត្យលើពាក្យបណ្តឹងចំនួន ០៤ នៃរាជធានី ខេត្ត ចំនួន ០៤ រួមមានៈ ខេត្តបាត់ដំបង ខេត្តក្រចេះ ខេត្តកណ្តាល និងខេត្តសៀមរាប ដែលបានប្តឹងជំទាស់ទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត តាមរយៈការប្រជុំសវនាការសង្ខេប ដោយសម្រេចឲ្យមានការពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត នៅលើទម្រង់មួយនានាតាមការិយាល័យមួយចំនួន ដែលស្ថិតនៅក្រៅកញ្ចប់សុវត្ថិភាព "ក" តាមពាក្យបណ្តឹងរបស់គណបក្សសង្គ្រោះជាតិដែលរួមមាន ៖

មណ្ឌលខេត្តក្រចេះ ក្រុមការងារផ្ទៀងផ្ទាត់របស់ គ.ជ.ប បានយកទម្រង់ ១១០២ មកផ្ទៀងផ្ទាត់ជាមួយនឹងទម្រង់ ១១០៤ ដែលស្ថិតនៅក្រៅកញ្ចប់ "ក" ចំនួន ១៣ ការិយាល័យ។

មណ្ឌលខេត្តបាត់ដំបង ក្រុមការងារផ្ទៀងផ្ទាត់របស់ គ.ជ.ប បានយកទម្រង់ ១១០៩ ទម្រង់ ១១១០ របស់ គ.ជ.ប មកធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងតារាងលទ្ធផលបោះឆ្នោតប្រចាំឃុំ/សង្កាត់ ដែលបំពេញដោយគណបក្សសង្គ្រោះជាតិមកធ្វើការផ្ទៀងផ្ទាត់គ្នា ចំនួន ១០២ ឃុំ សង្កាត់នៃខេត្តនេះ។

មណ្ឌលខេត្តសៀមរាប ក្រុមការងារផ្ទៀងផ្ទាត់របស់ គ.ជ.ប បានយកទម្រង់ ១១០២ ដែលនៅក្រៅកញ្ចប់សុវត្ថិភាព "ក" មកធ្វើការផ្ទៀង ចំណែកឯតំណាងគណបក្សក៏មានទម្រង់ ១១០៤ ដែលភ្នាក់ងារទទួលបាននៅតាមការិយាល័យមកធ្វើការផ្ទៀងផ្ទាត់ផងដែរ នូវចំនួន ៧៥ ការិយាល័យនៃខេត្តនេះ។

មណ្ឌលខេត្តកណ្តាល ក្រុមការងារផ្ទៀងផ្ទាត់របស់ គ.ជ.ប បានយកទម្រង់ ១១០២ និង ១១០៨ ដែលនៅក្រៅកញ្ចប់សុវត្ថិភាព "ក" មកធ្វើការផ្ទៀង ចំណែកឯតំណាងគណបក្សក៏មានទម្រង់ ១១០៤ ដែលភ្នាក់ងារទទួលបាននៅតាមការិយាល័យមកធ្វើការផ្ទៀងផ្តាត់ផងដែរ នូវចំនួន ១៩៩ ការិយាល័យនៃខេត្តនេះ។

ខុមហ្វ្រែលបានចូលរួមសង្កេតការណ៍ទៅលើដំណើរការដោះស្រាយបណ្តឹងតវ៉ាទាក់ទងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានពិនិត្យលើបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិនៅមណ្ឌលខេត្តក្រចេះ។ ហើយគ.ជ.បបានបន្តពិនិត្យលើបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិនៅមណ្ឌលខេត្តកណ្តាល បាត់ដំបង និងសៀមរាប នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ ។

ខុមហ្វ្រែលសង្កេតឃើញថា ការផ្ទៀងផ្ទាត់លទ្ធផលនៅក្នុង១៣ការិយាល័យនៅមណ្ឌលខេត្តក្រចេះ គ.ជ.បបានយកទម្រង់១១០៤[9] ផ្ទៀងផ្ទាត់ជាមួយនឹងទម្រង់ ១១០២[10] ដែលនៅក្រៅកញ្ចប់សុវត្ថិភាព«ក»។ ទម្រង់១១០២ ដែលគ.ជ.បយកមកធ្វើការផ្ទៀងផ្ទាត់នោះគឺជាឯកសារដែលគេអាចកែ ឬធ្វើថ្មី បានព្រោះមិនមែនជាឯកសារដើមដែលរក្សាទុកនៅក្នុងកញ្ចប់សុវត្ថិភាព «ក» ។ ដោយឡែកទម្រង់១១០២ ដែលគ.ជ.បយកមកធ្វើការផ្ទៀងផ្ទាត់នោះមានស្នាមប្រើប្រាស់ទឹកលុបច្រើនលើទម្រង់ទាំងនោះ។ ជាមួយគ្នានេះទម្រង់១១០៤ វិញ ឃើញថា អក្សរនៅលើទម្រង់ទាំង១៣ការិយាល័យនៅខេត្តក្រចេះនោះភាគច្រើនគឺដូចគ្នា ដែលយើងអាចសន្និដ្ឋានបានថា អាចមានការសរសេរឡើងវិញនៅថ្នាក់ណាមួយអាចជាថ្នាក់គឃ/សប ឬគជ/ឧប។

បន្ទាប់មក ខុមហ្វ្រែលបានធ្វើការពិនិត្យលទ្ធផលបោះឆ្នោតពីទម្រង់១១០២របស់គ.ជ.ប ធៀបជាមួយលទ្ធផលក្នុងទម្រង់១១០៤ នៅខេត្តក្រចេះដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបានពីមន្ត្រីការិយាល័យរាប់សន្លឹកឆ្នោតឃើញថា ក្នុងចំណោម១៣ការិយាល័យមាន២ការិយាល័យដូចគ្នាទាំងស្រុង ហើយ១១ការិយាល័យផ្សេងទៀតលទ្ធផលរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិដូចគ្នា ប៉ុន្តែលទ្ធផលរបស់គណបក្សផ្សេង ទៀតខុសគ្នា ពោលគឺទម្រង់១១០៤ដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបានពីមន្ត្រីការិយាល័យរាប់សន្លឹកឆ្នោត មិនមានកត់ត្រាលទ្ធផលរបស់គណបក្សទាំងនោះទេ។ បន្ថែមពីលើនេះទៀតចំនួនសន្លឹកឆ្នោតបានការ និងមិនបានការក៏មានការខុសគ្នាផងដែរ។

សម្រាប់ការផ្ទៀងផ្ទាត់ខេត្តបាត់ដំបង គ.ជ.បបានយកទម្រង់១១០៩[11] ទម្រង់១១១០[12] និងតារាងលទ្ធផលបោះឆ្នោតប្រចាំឃុំ/សង្កាត់ ដែលបំពេញដោយគណបក្សសង្គ្រោះជាតិមកធ្វើការផ្ទៀងផ្ទាត់។ ក្នុងដំណើរការផ្ទៀងផ្ទាត់នេះ គ.ជ.បបានយកចំនួនសម្លេងឆ្នោតសរុបនៃគណបក្សនីមួយៗប្រចាំឃុំ(ទំរង់១១០៩) មកធ្វើការផ្ទៀងផ្ទាត់ជាមួយលទ្ធផលឆ្នោតរបស់គណបក្សទាំងនោះក្នុងទំរង់១១១០ ដោយមិនបានបូកសរុបលទ្ធផលតាមការិយាល័យនីមួយៗនៅក្នុងទំរង់១១០៩នោះទេ មុននឹងផ្ទៀតផ្ទាត់លទ្ធផលសរុប។

ចំណែកឯការផ្ទៀងផ្ទាត់ខេត្តសៀមរាបវិញ គ.ជ.បបានយកទម្រង់១១០២ និងទម្រង់១១០៤ មកធ្វើការផ្ទៀងផ្ទាត់ ហើយតំណាងគណបក្សក៏មានទម្រង់១១០៤មកធ្វើការផ្ទៀងផ្ទាត់ដែរ។ ការសង្កេតឃើញថាមានការិយាល័យបោះឆ្នោតចំនួន៤ការិយាល័យនៃខេត្តនេះ(០៩៨២, ០៤២៦, ០៩៨៨, ០០២៥) មិនមានទំរង់១១០២ មកធ្វើការផ្ទៀង ហើយក្រុមផ្ទៀងផ្ទាត់លទ្ធផលបានយកទំរង់១១០៩មកធ្វើការផ្ទៀងផ្ទាត់ជាមួយទំរង់១១០៤ ជំនួសវិញ ក្រៅពីនេះយើងនៅសង្កេតឃើញទៀតថា មានការិយាល័យចំនួន២ គឺ(១០២៤, ០២៦២) ដែលមានទំរង់១១០២ និងទំរង់១១០៤ មានទិន្នន័យមិនដូចគ្នា និងការិយាល័យ០៩៨២ មានទិន្នន័យមិនត្រឹមត្រូវ(ការបូកលេខមិនត្រឹមត្រូវ)។

ដោយឡែកការផ្ទៀងផ្ទាត់ខេត្តកណ្តាល គ.ជ.បបានយកទម្រង់១១០២ និងទម្រង់១១០៨ មកធ្វើការផ្ទៀងផ្ទាត់ ហើយតំណាងគណបក្សក៏មានទម្រង់១១០៤ មកធ្វើការផ្ទៀងផ្ទាត់ដែរ។ ដោយឡែក៨ការិយាល័យបោះឆ្នោតក្នុងសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល គ.ជ.ប ពុំមានទម្រង់១១០៨ មកធ្វើការ

[9] ១១០៤ គឺជាក្រដាសលទ្ធផលបឋមនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

[10] ១១០២ គឺជាកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (បំពេញដោយគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត)

[11] ១១០៩ គឺជាតារាងបូកលទ្ធផលនៃការបោះឆ្នោតក្នុងឃុំសង្កាត់

[12] ១១១០ តារាងបូកលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ដែលបំពេញដោយគជ/ឧប

ផ្ទៀងផ្ទាត់ មានតែទម្រង់១១០២ និងទម្រង់១១០៤ មកធ្វើការផ្ទៀងផ្ទាត់។ ចំណុចមានការសង្ស័យថា មានភាពមិនប្រក្រតីក្នុងទម្រង់ ១១០៨ ដែលជាហេតុនាំឲ្យ គ.ជ.ប មិនបញ្ចេញទម្រង់នេះក្នុងការិយាល័យទាំង៨ មកធ្វើការផ្ទៀងផ្ទាត់។

ជាមួយគ្នានេះការសង្កេតក៏បានរកឃើញដែរថា ទម្រង់១១០២ក្នុងដៃគ.ជ.ប និង១១០៤ក្នុងដៃរបស់គណបក្សសង្គ្រោះជាតិមានការខុសគ្នា ជាពិសេសនៅត្រង់សន្លឹកឆ្នោតក្នុងហិបសរុប សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ។ ការខុសគ្នាមួយវិញទៀត គឺសម្លេងឆ្នោតរបស់គណបក្សតូចៗ ពោលគឺទម្រង់ ១១០៤ដែលតំណាងគណបក្សសង្គ្រោះជាតិ ទទួលបានពីមន្ត្រីការិយាល័យរាប់សន្លឹកឆ្នោតភាគច្រើនមិនមានកត់ត្រាសន្លឹកឆ្នោតក្នុងហិបសរុប សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ។ ចំណុចនេះធ្វើឲ្យមានការមិនទុកចិត្តចំពោះការបូកសរុបលទ្ធផលបណ្តោះអាសន្នរបស់គ.ជ.ប ដោយយកទម្រង់១១០២ជាមូលដ្ឋាន។ ដូចនេះ ក្រុមផ្ទៀងផ្ទាត់របស់គ.ជ.បត្រូវបើកកញ្ចប់សុវត្ថិភាព«ក» ដើម្បីយកទម្រង់១១០២មកធ្វើការផ្ទៀងផ្ទាត់ចំពោះការិយាល័យ ឬឃុំ សង្កាត់ណាដែលលទ្ធផលរបស់ គ.ជ.ប និងគណបក្សសង្គ្រោះជាតិមិនដូចគ្នា។

ជាសរុបមានភាពមិនប្រក្រតីផ្នែកបច្ចេកទេសដែលទាក់ទងទៅនឹងលទ្ធផលបោះឆ្នោតក្នុងទម្រង់ ១១០២ និង១១០៤នៅតាមការិយាល័យបោះឆ្នោត។ បើទោះបីជាយ៉ាងណា ការផ្ទៀងផ្ទាត់ទំរង់នេះមិនអាចសន្និដ្ឋានថា កំរិតភាពមិនប្រក្រតីទាំងនេះបាន ឬមិនបានធ្វើឲ្យប៉ះពាល់សុចរិតភាព និងលទ្ធផលបោះឆ្នោត ខណៈដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មិនបានបើកឲ្យមានការផ្ទៀងផ្ទាត់សំណាកជាលក្ខណៈប្រព័ន្ធនូវកញ្ចប់សុវត្ថិភាព «ក» ។

បន្ទាប់ពីគ.ជ.បយល់ព្រមធ្វើការដោះស្រាយនូវចំនុចមួយចំនួននៃពាក្យបណ្តឹងចំនួន៤ ដោយអនុញ្ញាតឲ្យមានការផ្ទៀងផ្ទាត់ទម្រង់មួយចំនួន ដែលស្ថិតនៅក្រៅកញ្ចប់សុវត្ថិភាព"ក" គ.ជ.ប បានសម្រេចបដិសេធចោលបណ្តឹងទាំង ០៤ ចោលទាំងអស់ដោយសំអាងថា ការផ្ទៀងផ្ទាត់របស់ គ.ជ.ប ទៅលើទម្រង់នានានៃខេត្តទាំងនោះមានភាពត្រឹមត្រូវទាំងស្រុងដោយមិនមានអ្វីប្រែប្រួលទេ។ ការសម្រេចរបស់គ.ជ.ប មិនបានបើកសវនាការជាសាធារណៈដើម្បីកាត់សេចក្តីទៅអង្គហេតុ និងកម្មវត្ថុដែលតំណាងគណបក្សបានដាក់មកនោះទេ និងមិនមានយន្តការស៊ើបអង្កេត ដោយមានតែការធ្វើសវនាការសង្ខេប (ការប្រជុំសម្រេចរបស់ គ.ជ.ប) ទៅលើបណ្តឹងទាំងអស់នោះ។ ដោយ គ.ជ.ប គ្រាន់តែបានកោះហៅភាគីដើមបណ្តឹងមកធ្វើការឆ្លើយបំភ្លឺ បន្ទាប់មកធ្វើការសម្រេចសេចក្តីតាមរយៈកិច្ចប្រជុំផ្ទៃក្នុងរបស់ខ្លួន។

## ៩.៦ បណ្តឹង និងការដោះស្រាយជំលោះលទ្ធផលបោះឆ្នោតដោយក្រុមប្រឹក្សាធម្មនុញ្ញ

មានពាក្យបណ្តឹងចំនួន ១៥ ដែលបានដាក់ក្រុមប្រឹក្សាធម្មនុញ្ញ ដោយមានដើមបណ្តឹងតែមួយគត់គឺគណបក្សសង្គ្រោះជាតិដែលប្តឹងជំទាស់បដិសេធសេចក្តីសម្រេចរបស់គ.ជ.ប ដោយសំអាងថា ការសម្រេចរបស់ គ.ជ.ប មិនមានភាពត្រឹមត្រូវ និងដោយសារតែមិនមានយន្តការដោះស្រាយភាពមិនប្រក្រតីដែលកើតមានយ៉ាងច្រើននៅថ្ងៃបោះឆ្នោត។ ការប្តឹងជំទាស់បដិសេធសេចក្តីសម្រេចនោះធ្វើឡើងនៅខេត្តទាំង១៥ ដែលរួមមាន៖ ១-បន្ទាយមានជ័យ, ២-បាត់ដំបង, ៣-កំពង់ស្ពឺ, ៤-កំពង់ធំ, ៥-កំពត, ៦-កណ្តាល, ៧-ក្រចេះ, ៨-ភ្នំពេញ, ៩-ព្រៃវែង, ១០-ពោធិសាត់, ១១-សៀមរាប, ១២-ព្រះសីហនុ, ១៣-ស្វាយរៀង, ១-តាកែវ និង ១៥-លទ្ធផលទូទាំងប្រទេសទាំងមូល។

មកដល់ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣ ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចបដិសេធពាក្យបណ្ដឹងរបស់គណបក្សសង្គ្រោះជាតិចំនួន១០បណ្ដឹង ដោយសំអាងថាខុសគតិច្បាប់ និងបានតម្កល់សេចក្ដីសម្រេចរបស់ គ.ជ.ប ទុកជាបានការទាំងស្រុង ដែលបណ្ដឹងទាំងអស់នោះមានដូចជាបណ្ដឹងប្ដឹងជំទាស់លទ្ធផលបណ្ដោះអាសន្ននៅមណ្ឌលខេត្តកំពង់ធំ, កំពត, ព្រៃវែង, កំពង់ស្ពឺ, ពោធិសាត់, ភ្នំពេញ, បន្ទាយមានជ័យ, តាកែវ, ស្វាយរៀង, ព្រះសីហនុ។ ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញមិនមានយន្តការស៊ើបអង្កេតណាក្រៅពីហៅគូភាគីតំណាងគ.ជ.ប ដែលជាចុងចម្លើយ និងតំណាងគណបក្សសង្គ្រោះជាតិដែលជាដើមបណ្ដឹងមកសាកសួរនោះទេ។

ក្រៅពីបណ្ដឹងដែលបានបដិសេធខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញបានបញ្ជាឲ្យមានការស៊ើបអង្កេតបឋមលើបណ្ដឹងចំនួន៤ ដែលក្នុងនោះរួមមានបណ្ដឹងប្ដឹងជំទាស់លទ្ធផលបណ្ដោះអាសន្ននៅមណ្ឌលខេត្តក្រចេះ បាត់ដំបង សៀមរាប និងកណ្ដាល។

ការដាក់ពាក្យបណ្ដឹងរបស់គណបក្សសង្គ្រោះជាតិ និងការទទួលពាក្យបណ្ដឹងដោយក្រុមប្រឹក្សាធម្មនុញ្ញនៃខេត្តទាំងនោះ ពាក្យបណ្ដឹងបីក្នុងចំណោមបួន គឺស្របតាមនីតិវិធីដែលមានកម្មវត្ថុនៃបណ្ដឹងត្រឹមត្រូវ លើកលែងតែកម្មវត្ថុពាក្យបណ្ដឹងនៃខេត្តក្រចេះ គឺមិនមានភាពច្បាស់លាស់ទៅតាមគតិច្បាប់ដែលមានចែងនៅក្នុងមាត្រា១១៧នៃច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ។ ថាតើពាក្យបណ្ដឹងនេះប្ដឹងតវ៉ា និងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ឬប្ដឹងតវ៉ាបដិសេធលើសេចក្ដីសម្រេចរបស់គ.ជ.ប.។ គណបក្សសង្គ្រោះជាតិបានដាក់ពាក្យបណ្ដឹងនៅខេត្តក្រចេះនេះក្រោមកម្មវត្ថុ *"ប្ដឹងតវ៉ានឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រនីតិកាលទី៥ឆ្នាំ២០១៣ នៅមណ្ឌលខេត្តក្រចេះ"* នៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២១០៣។ ក្នុងករណីនេះ បណ្ដឹងដែលគណបក្សសង្គ្រោះជាតិប្ដឹងក្រោមកម្មវត្ថុខាងលើ គឺបានហួសអាជ្ញាយុកាលនៃបណ្ដឹង។ ច្បាប់បានទុករយៈពេលតែ ៧២ ម៉ោង សម្រាប់ដាក់ពាក្យបណ្ដឹងចំពោះកម្មវត្ថុនៃពាក្យបណ្ដឹងដូចបានលើកឡើង បន្ទាប់ពី គ.ជ.ប បានប្រកាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ បើយោងតាម មាត្រា១១៤ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាង និង មាត្រា ២៤ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ។ ដូចនេះពាក្យបណ្ដឹងនៅខេត្តក្រចេះបានដាក់កម្មវត្ថុខុស ដែលគេគួរដាក់កម្មវត្ថុនៃពាក្យបណ្ដឹងនោះថា"ប្ដឹងតវ៉ាជំទាស់ ឬបដិសេធនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប ចេញថ្ងៃទី១៥ ខែសីហា ២០១៣"។

ថ្ងៃទី៣១ខែសីហា និង ថ្ងៃទី០៤ ដល់ ទី០៥ ខែកញ្ញា ឆ្នាំ២០១៣ ខុមហ្វ្រែលបានចូលសង្កេតសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទាក់ទងទៅនឹងបណ្ដឹងតវ៉ាលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រនីតិកាលទី៥ សម្រាប់ទាំងបួនខេត្តខាងលើ។

អង្គសវនាការសម្រាប់ខេត្តនីមួយៗបានប្រើប្រាស់ពេលវេលាប្រមាណពីបី ទៅបួនម៉ោងនៅពេលព្រឹក ហើយប្រកាសសេចក្ដីសម្រេចនៅពេលរសៀល។ ដោយសារតែក្រុមប្រឹក្សាធម្មនុញ្ញមិនមាននីតិវិធីគ្រប់គ្រាន់ និងច្បាស់លាស់ក្នុងការបើកសវនាការជាសាធារណៈ មិនអាចត្រូវបានបញ្ជាក់ថា ជាប្រភេទសវនាការអ្វីមួយ សវនាការប្រតិបក្ស ឬសវនាការសួរដេញដោល។ អ្នកចូលរួមត្រូវបានអញ្ជើញជាសាធារណៈ ប៉ុន្តែមានអ្នកសង្កេតការណ៍មួយក្រុមដែលត្រូវបានចាត់ចែង និងត្រូវបានរៀបចំទុកជាមុនក្នុងការចូលទៅអង្គុយ ក្នុងសាលសវនាការស្ទើរពេញកន្លែង។ តាមការសង្កេតការណ៍ និងព័ត៌មានដែលទទួលបាននៅទីនោះផ្ទាល់ ក្រុមអ្នក

សង្កេតការណ៍ដែលបានរៀបចំ និងចាត់ចែងទុកជាមុននេះ គឺជាសមាជិកសហភាពសហព័ន្ធយុវជនកម្ពុជា។ ទោះបីជាមានការផ្សាយបន្តទៅទូរស្សន៍មួយនៅខាងក្រៅ សវនាការនេះមិនសម្រួលដល់ការចូលរួមសង្កេតការណ៍ចម្រុះពីសាធារណជននៅក្នុងបន្ទប់ដោយផ្ទាល់នោះទេ។ នៅក្នុងសវនាការជាសាធារណៈនៃខេត្តទាំងបួននេះ គេមិនឃើញមានបង្ហាញភស្តុតាងអ្វីផ្សេងក្រៅពីកំណត់ហេតុនៃការបើកកញ្ចប់សុវត្ថិភាព"ក" តែមួយនោះទេ ហើយនិងមិនបានកោះហៅសាក្សីនៃវិវាទ ឬជនសង្ស័យក្នុងបញ្ហានៃភាពមិនប្រក្រតីបោះឆ្នោត ដូចជាមន្ត្រីការិយាល័យបោះឆ្នោត មន្ត្រីឃុំសង្កាត់រៀបចំការបោះឆ្នោត និងមន្ត្រីខេត្តរៀបចំការបោះឆ្នោត មកចូលឆ្លើយបំភ្លឺនៅមុខក្រុមប្រឹក្សាជំនុំជម្រះនោះដែរ។

ក្នុងដំណើរសវនាការ មានការដាក់សំណួររបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញទៅតំណាង គ.ជ.ប និងតំណាងគណបក្សសង្គ្រោះជាតិផងដែរ។ ក្រុមប្រឹក្សាជំនុំជម្រះបានផ្តល់ឱកាសឲ្យភាគីទាំងសងខាងលើកទឡ្ហីករណ៍រៀងៗខ្លួនជូនអង្គសវនាការស្តាប់ និងឆ្លើយសំណួរខ្លះរបស់ក្រុមប្រឹក្សាជំនុំជំរះដែលភាគច្រើនទាក់ទងតែទៅនឹងអង្គហេតុ និងអង្គច្បាប់មួយចំនួនផងដែរ ក្រុមប្រឹក្សាជំនុំជម្រះមិនអនុញ្ញាតឲ្យគូភាគីធ្វើការសួរដេញដោលគ្នានៅចំពោះមុខសវនាការទេ។

ក្នុងករណីដោះស្រាយបណ្តឹងខេត្តក្រចេះ តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានអានរបាយការណ៍ស៊ើបអង្កេតរបស់ខ្លួនដែលគ្រាន់តែជាការឆ្លើយបំភ្លឺរបស់មន្ត្រីការិយាល័យបោះឆ្នោតដែលពាក់ព័ន្ធទៅនឹងវិវាទនៅក្នុងខេត្តនោះ។ មន្ត្រី គ.ជ.ប មួយរូបបានឲ្យដឹងថា របាយការណ៍ស៊ើបអង្កេតដែលបានអានចំពោះមុខក្រុមប្រក្សាជំនុំជម្រះ គឺទទួលបានមកពីគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្តក្រចេះ ផ្ទុយទៅវិញ មន្ត្រីបោះឆ្នោតនៃការិយាល័យដែលពាក់ព័ន្ធនោះបានប្រាប់វិទ្យុអាស៊ីសេរីថា ពួកគេមិនបានចូលរួមឆ្លើយបំភ្លឺដូចដែលបានសរសេរក្នុងកំណត់ហេតុស៊ើបអង្កេតដែលត្រូវបានប្រើប្រាស់ក្នុងសវនាការជំនុំជម្រះនោះទេ។ ហើយពួកគេបានបន្តថា មន្ត្រីបោះឆ្នោតឃុំ/សង្កាត់ស្វាយជ្រះជាអ្នកប្រាប់ឲ្យពួកគេចំហមាត់កញ្ចប់សុវត្ថិភាព "ក"។

ក្នុងករណីសវនាការដោះស្រាយពាក្យបណ្តឹងនៅខេត្តសៀមរាប ក្នុងនាមជាភាគីចុងចម្លើយ លោក ឯម សូផាត សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានឆ្លើយបំភ្លឺចំពោះមុខក្រុមប្រឹក្សាអង្គជំនុំជម្រះនៃក្រុមប្រឹក្សាធម្មនុញ្ញទាក់ទងនឹងរឿងការអនុញ្ញាតឲ្យមានការដឹកជញ្ជូនកងទ័ពទៅបោះឆ្នោត ថាច្បាប់ផ្តល់ឆន្ទានុសិទ្ធិដល់ គ.ជ.ប ចេញសេចក្តីសម្រេចក្នុងការចាត់ចែងការងារបោះឆ្នោត។ សមាជិកក្រុមប្រឹក្សាជំនុំជម្រះបានដាក់សំណួរទៅ គ.ជ.ប អំពីការប្រើប្រាស់ឆន្ទានុសិទ្ធិនេះផ្ទុយបទបញ្ញា និងនីតិវិធិសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលបានបង្កើតឡើងដោយ គ.ជ.ប [ត្រង់ ប្រការ ៧.៤.១] គឺបានហាមឃាត់មិនឲ្យមានការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោតនោះទេ។ ដូចនេះសេចក្តីសម្រេចដែល គ.ជ.ប បានចេញទាក់ទងនឹងការអនុញ្ញាតឲ្យមានការដឹកជញ្ជូនកងទ័ពទៅបោះឆ្នោតនេះ គឺផ្ទុយពីអ្វីដែលមានចែងក្នុងបទបញ្ញា និងនីតិវិធីរបស់ខ្លួន។

ចំណែកក្នុងករណីសវនាការដោះស្រាយបណ្តឹងនៅខេត្តកណ្តាលវិញ អង្គជំនុំជម្រះនៃក្រុមប្រឹក្សាធម្មនុញ្ញ បានបន្តសវនាការ ដោយមិនមានវត្តមានដើមបណ្តឹង លោក អេង ឆៃអ៊ាង និង លោក មេធាវី កែត ឃីតំណាងឲ្យគណបក្សសង្គ្រោះជាតិ ដោយលោកទាំងពីរបានដើរចេញពីសវនាការ នៅពេលដែលចាប់ផ្តើមនីតិវិធីជំនុំជម្រះ។ លោក ឯក សំអុល ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះបានថ្លែងនៅក្នុង

សវនានោះថា ការបោះបង់សិទ្ធិរបស់ដើមបណ្តឹងក្នុងការចូលរួមសួរដេញដោលក្នុងសវនាការពេលនេះ គឺមិនប៉ះពាល់ដល់ដំណើរការនីតិវិធីសវនាការឡើយ។

ការសង្កេតរកឃើញថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានតំកល់សេចក្តីសម្រេចរបស់គ.ជ.ប ទាក់ទងខេត្តទាំងបួននេះទុកនៅដដែល។ ហើយសេចក្តីសំរេចមួយចំនួនបានបញ្ជាឲ្យ គ.ជ.ប ដាក់ទណ្ឌកម្មតាមច្បាប់កំណត់ ចំពោះមន្ត្រីការិយាល័យបោះ/រាប់សន្លឹកឆ្នោតនៅខេត្តក្រចេះ និងសៀមរាប ដែលបានប្រព្រឹត្តខុសនឹងនីតិវិធីច្បាប់ និងដាក់កំហុស គ.ជ.ប ក្នុងការទទួលខុសត្រូវចំពោះការងាររបស់ខ្លួន។ ការតំកល់សេចក្តីសម្រេចរបស់ គ.ជ.ប និងការបញ្ជារបស់ក្រុមប្រឹក្សាធម្មនុញ្ញឲ្យ គ.ជ.ប ដាក់ទណ្ឌកម្មចំពោះមន្ត្រីរៀបចំការបោះឆ្នោតនោះ គឺមិនឆ្លើយតបកម្មវត្ថុបណ្តឹង ព្រមទាំងខ្វះមូលដ្ឋានយុត្តាធិការ ឬផ្អែកទៅលើក្របខ័ណ្ឌច្បាប់ណាមួយ មិនមានមូលដ្ឋានអង្គហេតុដែលមានភស្តុតាង និងសាក្សីជាក់ស្តែង។ ក្នុងសេចក្តីសម្រេចនោះក្រុមប្រឹក្សាធម្មនុញ្ញក៏បានបញ្ជាឲ្យ គ.ជ.ប ទទួលខុសត្រូវចំពោះមុខច្បាប់ ករណីដែលអនុញ្ញាតឲ្យមានការដឹកជញ្ជូនកងទ័ពទៅបោះឆ្នោត ប៉ុន្តែក្រុមប្រឹក្សាធម្មនុញ្ញ មិនបានពិចារណាអំពីភាពមិនប្រក្រតីនេះដែលមានផលប៉ះពាល់លើលទ្ធផលបោះឆ្នោត ព្រោះថាគណបក្សសង្គ្រោះជាតិ ខ្វះតែ៤០៨៣សម្លេងនឹងទទួលបានអាសនៈមួយបន្ថែមទៀតសម្រាប់មណ្ឌលខេត្តសៀមរាប។

ចំពោះករណីសវនាការដោះស្រាយពាក្យបណ្តឹងនៅខេត្តកណ្តាល ស្តីពីការបិទការិយាល័យបោះឆ្នោតលេខ ១២០៤ ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញហាក់ដូចជាផ្អែកទៅលើការបកស្រាយមិនច្បាស់លាស់របស់ តំណាង គ.ជ.ប ទៅវិញ។ លោក មាន សទិ សមាជិក គ.ជ.ប បានលើកឡើងថា ការបិទការិយាល័យបោះឆ្នោតលេខ ១២០៤ខាងលើ នាថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ គឺគ្មានហេតុផលណាឲ្យ គ.ជ.ប រៀបចំការឆ្នោតសាជាថ្មីឡើងវិញឡើយ ព្រោះការបិទការិយាល័យនោះមិនមែនដោយសារមូលហេតុ ប្រធានស័ក្តិ ឬអសន្តិសុខ ដែលបានកំណត់ក្នុងបទបញ្ជា និងនីតិវិធីបោះឆ្នោតនោះទេ។ ការលើកឡើងនេះអំពីបទបញ្ជា និងនីតិវិធីបោះឆ្នោតទាក់ទិនករណីប្រធានស័ក្តិ គឺជាការចង្អុលបង្ហាញអំពីកាតព្វកិច្ចរបស់ គ.ជ.ប ក្នុងការរៀបចំការបោះឆ្នោតសាជាថ្មីតែម្តង ប៉ុន្តែមិនទាក់ទិនការដោះស្រាយបណ្តឹងលើភាពមិនប្រក្រតីដើម្បីឲ្យបោះឆ្នោតសាជាថ្មីនោះទេ។ មាត្រា ១១១ថ្មី នៃច្បាប់បោះឆ្នោតបញ្ជាក់ថា ក្នុងករណីមានបណ្តឹង "អំពីភាពមិនប្រក្រតីធ្ងន់ធ្ងរ" ណាមួយ គ.ជ.ប ពិនិត្យសម្រេចលើបណ្តឹងនោះ បើយល់ថាភាពមិនប្រក្រតីធ្ងន់ធ្ងរនោះធ្វើឲ្យប៉ះពាល់ដល់លទ្ធផលឆ្នោត នោះការបោះឆ្នោតសាជាថ្មីត្រូវធ្វើក្នុងរយៈពេល០៨ថ្ងៃយ៉ាងយូរបន្ទាប់ពីការសម្រេចនេះ។ការសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញមិនបានពិចារណាអំពីផលប៉ះពាល់លើលទ្ធផលបោះឆ្នោតខេត្តកណ្តាលនេះទេ។ គណបក្សសង្គ្រោះជាតិត្រូវការសន្លឹកឆ្នោតចំនួន១៦៨សម្លេង ដើម្បីទទួលបានអាសនៈមួយបន្ថែមទៀត ខណៈប្រជាពលរដ្ឋចំនួនប្រមាណជិត២០០នាក់ដែលមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតមិនទាន់បានបោះឆ្នោតនៅការិយាល័យ១២០៤ នោះ។

ជាសរុប ការដោះស្រាយបណ្តឹងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ បានដំណើរការក្រោមរូបភាពជាសវនាការសាធារណៈ ព្រោះមានសំណួរដេញដោលដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទៅតំណាង គ.ជ.ប ឬតំណាងគណបក្សសង្គ្រោះជាតិជាដើមបណ្តឹង។ ដំណើរការនៃការដោះស្រាយបណ្តឹងនេះ មានតម្លាភាពជាងការដោះស្រាយបណ្តឹងដូចគ្នានៅខេត្តទាំងបួនដោយ គ.ជ.ប។ ទោះបីជាយ៉ាងនេះក្តី ដំណើរការសវនាការនេះគ្មាននីតិវិធីច្បាស់លាស់ ហើយក៏មិនមានសក្សីផ្ទាល់ផ្តល់សក្ខីកម្មដល់អង្គជំនុំជម្រះផងដែរ។ ម្យ៉ាងទៀតសមាជិកក្រុម

ប្រឹក្សាធម្មនុញ្ញ ជាពិសេសប្រធានក្រុមប្រឹក្សាធម្មនុញ្ញដែលមានឧត្តមភាពក្នុងការសំរេចចិត្ត មិនត្រូវបានសន្មត់ថា អព្យាក្រឹត្យ ដោយសារជាមន្ត្រីនៃគណបក្សប្រជាជនកម្ពុជា។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទាំងបួនករណី មិនបានផ្អែកលើអង្គច្បាប់ និងអង្គហេតុដែលមិនបានពិចារណាអំពី "ហេតុផល" ទាក់ទិននឹង កម្មវត្ថុបណ្តឹងអំពី ភាពមិនប្រក្រតី និងផលប៉ះពាល់លើលទ្ធផលបោះឆ្នោត។ បើទោះបីជារដ្ឋធម្មនុញ្ញចង្អុលបង្ហាញថា ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធអំណាចដោះស្រាយវិវាទបោះឆ្នោត និងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានណែនាំថា ក្រុមប្រឹក្សាធម្មនុញ្ញដោះស្រាយបណ្តឹងទាក់ទិនសិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះបោះឆ្នោត និងការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត តែសេចក្តីសម្រេចនៃសវនាការទាំងនោះដែលដាក់ទណ្ឌកម្មដល់មន្ត្រីការិយាល័យបោះឆ្នោតកាន់តែមានភាពមិនច្បាស់លាស់ដោយសារតែខ្វះយុត្តាធិការ និងខ្វះភស្តុតាងផងក្នុងការធ្វើសេចក្តីសម្រេចនោះ។

**ការសង្ខេបពាក្យបណ្តឹងទាំង៤ដែលបណ្តឹងដោយគណបក្សសង្គ្រោះជាតិ៖**

១. ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ តំណាងគណបក្សសង្គ្រោះជាតិ លោក កែវ ភីរម្យ បានដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្រោមកម្មវត្ថុនៃបណ្តឹង "ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ ២០១៣ នៅមណ្ឌលក្រចេះ"។ ពាក្យបណ្តឹងត្រូវបានដាក់ក្នុងរយៈពេល៧២ ម៉ោងក្រោយពីបានទទួលសម្រង់សេចក្តីសំរេចបដិសេធរបស់ គ.ជ.ប។ ក្នុងពាក្យបណ្តឹងមានការទាមទារដូចខាងក្រោម៖

- ទាមទារឲ្យ គ.ជ.ប បង្ហាញហេតុផលដែលប្រជាពលរដ្ឋបាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០១២ នៅមណ្ឌលក្រចេះ។
- ទាមទារឲ្យរាប់សន្លឹកឆ្នោត និងបោះឆ្នោតឡើងវិញនៅការិយាល័យទាំង ១៣ នៅឃុំស្វាយជ្រះ។
- ទាមទារឲ្យរាប់សន្លឹកឆ្លោតឡើងវិញ នៅការិយាល័យលេខ ០០១១ ឃុំដំរីផុង និងការិយាល័យ ០០២៤ ឃុំកំពង់ដំរី។
- និងទាមទារឲ្យបោះឆ្នោតឡើងវិញនៅការិយាល័យ ០២៩២ ឃុំវឌ្ឍនៈ។

២. លោក សួន ចំរើន តំណាងគណបក្សសង្គ្រោះជាតិ បានដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០១៣។ កម្មវត្ថុនៃពាក្យបណ្តឹងនោះ គឺប្តឹងតវ៉ានឹងសេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប។ ក្នុងពាក្យបណ្តឹងមានការទាមទារដូចខាងក្រោម៖

-បង្គាប់ឲ្យ គ.ជ.ប បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីយកទម្រង់ ១១០២ និង ១១០៨ ធ្វើការពិនិត្យផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោតចំនួន ១១៧ការិយាល័យ។

-បង្គាប់ឲ្យ គ.ជ.ប បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីយកសន្លឹកឆ្នោតនៃ ១១៦ការិយាល័យមកពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ។

៣. តំណាងគណក្សសង្គ្រោះជាតិ លោកស្រី កែ សុវណ្ណរតន៍ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ បានដាក់ពាក្យបណ្តឹងក្រោមកម្មវត្ថុ ប្តឹងសុំតវ៉ានឹងសេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប ទៅក្រុមប្រឹក្សធម្មនុញ្ញ។ ក្នុងពាក្យបណ្តឹងមានការទាមទារដូចខាងក្រោម៖

- បង្គាប់ឲ្យគ.ជ.បរៀបចំបោះឆ្នោតសាជាថ្មីចំនួន១៦ការិយាល័យនៅស្រុកស្វាយលើ និងស្រុកវ៉ារិន។

- បង្គាប់ឲ្យ គ.ជ.ប បើកកញ្ចប់សុវត្ថិភាព "ក" ពិនិត្យរាប់សន្លឹកឆ្នោត និងផ្តល់សុពលភាពសន្លឹកឆ្នោតមិនបានការឡើងវិញចំនួន២០០ការិយាល័យក្នុងមណ្ឌលខេត្តសៀមរាប។

- បង្គាប់ឲ្យ គ.ជ.ប បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីយកទម្រង់ ១១០២ និង ១១០៨ មកផ្ទៀងផ្ទាត់លទ្ធផលជាមួយទំរង់ ១១០៤ចំនួន ៧៥ការិយាល័យ។

៤. ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ លោក អេង ឆៃអ៊ាង តំណាងគណបក្សសង្គ្រោះជាតិបានដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្រោមកម្មវត្ថុ ប្តឹងសុំតវ៉ានឹងសេចក្តីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប។ ប៉ុន្តែនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ បានដាក់ពាក្យសុំកែតម្រូវពាក្យបណ្តឹង ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយសុំកែតម្រូវលើកំហុសមួយចំនួននៅក្នុងពាក្យបណ្តឹងដែលបានដាក់នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣។ ក្នុងពាក្យបណ្តឹងមានការទាមទារដូចខាងក្រោម៖

- បង្គាប់ឲ្យ គ.ជ.ប រៀបចំបោះឆ្នោតសាជាថ្មីនៅការិយាល័យ១២០៤ ឃុំស្អាងភ្នំ។

- បង្គាប់ឲ្យ គ.ជ.ប បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីយកទម្រង់ ១១០២ និង ១១០៨ ធ្វើការពិនិត្យផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោតចំនួន ០៨ ការិយាល័យ នៅសង្កាត់តាខ្មៅ។

- បង្គាប់ឲ្យ គ.ជ.ប បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីយកសន្លឹកឆ្នោតមិនបានការ ទាំង ៧២ ការិយាល័យ មកពិនិត្យផ្ទៀងផ្ទាត់ និងផ្តល់សុពលភាពសន្លឹកឆ្នោតមិនបានការឡើងវិញ។

## ១០. លទ្ធផលបោះឆ្នោត ការផ្ទៀងផ្ទាត់ និងការវិភាគ

### ១០.១ ការផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោត

#### ១០.១.១ លទ្ធផលបោះឆ្នោតអ្នកសង្កេតការណ៍PVT របស់ខុមហ្វ្រែល ផ្ទុយពី លទ្ធផលផ្លូវការរបស់ គ.ជ.ប

នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៣ ខុមហ្វ្រែលបានចេញលទ្ធផលបឋម និងមិនផ្លូវការអំពីលទ្ធផលបោះឆ្នោតនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣។ លទ្ធផលនេះប្រមូលចេញពីអ្នកសង្កេតការណ៍លទ្ធផលឆ្នោតលឿន (PVT) ប្រមាណ១៤៧០ការិយាល័យរាប់សន្លឹកឆ្នោតនៅទូទាំងប្រទេស ដែលកំណត់ចេញពីអ្នកចុះឈ្មោះបោះឆ្នោតសំណាកសរុបចំនួន ៦៨៧,០៧៩នាក់ ក្នុងចំណោមអ្នកបានចុះឈ្មោះបោះឆ្នោតសរុបចំនួន ៩,៦៧៥,៤៥៣នាក់ ក្នុងកំរិតជឿជាក់ (Confident Level) ៩៩% និងកំរិតលំអៀង (Margin of Error) ០,១៥% និងកំរិតលំអៀងសំរាប់ការិយាល័យ ២,៦២% (កំរិតលំអៀងសំរាប់ការិយាល័យក្នុងខេត្តនីមួយៗមាន៥%)។ លទ្ធផលបោះឆ្នោតលឿននេះបានបង្ហាញថា គណបក្សប្រជាជនកម្ពុជាទទួលបានសម្លេងឆ្នោត ៤៩,៤៩% ដោយទទួលបានអាសនៈចំនួន៦៧ និងគណបក្សសង្គ្រោះជាតិទទួលបានសម្លេងឆ្នោតសរុបប្រមាណ ៤៣,០៥%។ លទ្ធផលរបស់ខុមហ្វ្រែលមានការខុសគ្នាជាមួយនឹងលទ្ធផលរបស់ផ្លូវការរបស់គ.ជ.ប បានបង្ហាញថា គណបក្សប្រជាជនកម្ពុជាទទួលបានសម្លេងឆ្នោត៤៨,៨២% ដោយទទួលបានអាសនៈចំនួន ៦៨ រីឯគណបក្សសង្គ្រោះជាតិទទួលបានសម្លេងឆ្នោត ៤៤,៤៥% ដោយទទួលបានអាសនៈចំនួន៥៥។

#### ១០.១.២ ការផ្ទៀងផ្ទាត់លទ្ធផលតាមការិយាល័យបោះឆ្នោតក្នុងទម្រង់ ១១០៤

ខុមហ្វ្រែលស្រាវជ្រាវលើករណីទម្រង់ ១១០៤ ដែលបានចេញដោយ គកស នៅក្នុងខេត្តមួយចំនួន ដូចជា កណ្ដាល សៀមរាប បាត់ដំបង ជាពិសេសក្នុងខេត្តក្រចេះ មានការិយាល័យចំនួន ១៣ ដែលខុមហ្វ្រែល ធ្វើការបង្ហាញនូវទម្រង់ ដែលបានប្រមូលមកពីប្រភពចំនួន ៣ដូចខាងក្រោមៈ

- ទីមួយបណ្ដាញខុមហ្វ្រែលដែលបានយកមកពីការិយាល័យរាប់ដោយផ្ទាល់
- ទីពីរចម្លងមកពី គឃ/ខប
- ទីបីប្រមូលមកពីភ្នាក់ងារគណបក្សនយោបាយ

សូមមើលចំណុចខុសគ្នា លើទម្រង់ដូចខាងក្រោម៖

| ទម្រង់បានពីបណ្ដាញខុមហ្វ្រែល | ទម្រង់បានពីភ្នាក់ងារគណបក្ស | ទម្រង់បានពី គឃ/ខប |
|---|---|---|
|  |  |  |

ផ្អែកតាមរូបភាពទម្រង់ដែលខុមហ្វ្រែលបានធ្វើការអង្កេតខាងលើ ការសន្និដ្ឋានមានដូចខាងក្រោមៈ

- **ចំណុចទី១** បានបង្ហាញថា អក្សរដែលសរសេរលើទម្រង់គឺជាមនុស្សផ្សេងគ្នា ព្រោះទម្រង់អក្សរនេះមិនដូចគ្នា ករណីនេះបើយើងមើលលើសេចក្ដីណែនាំ គកប/គកស ប្រធានត្រូវចាត់លេខាធិការឲ្យសរសេរ ដោយផ្ទៀងផ្ទាត់លទ្ធផលឲ្យដូចកំណត់ហេតុ ១១០២ និងចុះហត្ថលេខាដោយប្រធាន និងលេខាធិការជូនដល់ភ្នាក់ងារគណបក្សនយោបាយ ហេតុនេះហើយបើសិនជាមានការខុសគ្នាវាជាការទទួលខុសត្រូវរបស់លេខាធិការ និងប្រធានការិយាល័យ។
- **ចំណុចទី២** សម្រង់លទ្ធផលដែលបានចម្លងដាក់នៅក្នុងទំរង់ ១១០៤ គឺខុសគ្នា ព្រោះថា ទី១ ទម្រង់ ១១០៤ បានពីបណ្ដាញខុមហ្វ្រែល មានទិន្នន័យដូចគ្នាទៅនឹងទម្រង់ ១១០៤ ដែលបានមកពី គឃ/ខប តែវាខុសគ្នាត្រង់សន្លឹកឆ្នោតមិនបានការ គឺទិន្នន័យខុមហ្វ្រែលមាន ចំនួន២៧សន្លឹក តែ គឃ/ខប មានតែ ១០សន្លឹក។ តែបើមើលពីទម្រង់ ១១០៤ របស់បណ្ដាញខុមហ្វ្រែល និង គឃ/ខប ផ្ទៀងជាមួយ ១១០៤ មកពីភ្នាក់ងារគណបក្សនយោបាយវិញ ឃើញថាខុសគ្នាត្រង់លទ្ធផល

ឆ្នោតគឺ ១១០៤ មកពីភ្នាក់ងារគណបក្សនយោបាយ មិនមានលទ្ធផលគ្រប់គណបក្សទេ ម៉្យាងទៀត លទ្ធផលឆ្នោតសរុប ៣៥៦ ដូចគ្នា តែសន្លឹកឆ្នោតមិនបានចំនួនខុសគ្នា។

- **ចំណុចទី៣** ការសិក្សាលើផលប៉ះពាល់ជាមួយទម្រង់ខុសគ្នា ដែលមានចំនួន ១៣ការិយាល័យ បានបង្ហាញឲ្យឃើញថាៈ

| **លទ្ធផលចេញពីទម្រង់ ១១០៤ របស់ គជ/ខប** | | | | **លទ្ធផលចេញពីទម្រង់ ១១០៤ របស់ភ្នាក់ងារគណបក្ស** | | | |
|---|---|---|---|---|---|---|---|
| សន្លឹកឆ្នោតបានការ= | 4497 | | | សន្លឹកឆ្នោតបានការ = | 4187 | | |
| កូតាកៅអីសរុប= | 1499 | | | កូតាកៅអីសរុប= | 1395 | | |
| ចំនួនកៅអីសរុប= | 3 | | | ចំនួនកៅអីសរុប= | 3 | | |
| **សម្លេងឆ្នោតដែលទទួលបាន** | | | | **សម្លេង ដែលទទួលបាន** | | | |
| **សម្លេងសរុប** | | **អសនៈ** | **សម្លេងសល់** | **សម្លេងសរុប** | | **អសនៈ** | **សម្លេងសល់** |
| ប្រ.ជ= | 2010 | 1 | 511 | ប្រ.ជ= | 2010 | 1 | 615 |
| គ.ស.ជ= | 1847 | 1 | 348 | គ.ស.ជ= | 1847 | 1 | 452 |
| ហ៊្វុនស៊ិនប៉ិច= | 330 | 0 | 330 | ហ៊្វុនស៊ិនប៉ិច= | 330 | 0 | 330 |
| កៅអីនៅសល់ | | 1 | | កៅអីនៅសល់ | | 1 | |

ដោយយោងលើ ទម្រង់ដែលបានបង្ហាញខាងលើ រួមជាមួយការគណនាសម្លេងឆ្នោត បានបង្ហាញថា ការបញ្ចូលសម្លេងឆ្នោតគ្រប់គណបក្ស និងការបាត់បង់សម្លេងឆ្នោតនៃគណបក្សតូចៗ

១០.១.៣ ការផ្ទៀងផ្ទាត់របាយការណ៍អ្នកសង្កេតការណ៍ខុមហ្វ្រែល ជាមួយទំរង់១១០៩ ឬ/និង ទំរង់១១០៤

តាមនីតិវិធីនៃការបោះឆ្នោតចំនួនអ្នកបានបោះឆ្នោតត្រូវស្មើនឹងចំនួនអ្នកបានចុះឈ្មោះបោះឆ្នោតនៅក្នុងការិយាល័យនោះ។ ដោយផ្អែកលើនីតិវិធីនេះ ខុមហ្វ្រែលបានវិភាគលើលទ្ធផលបោះឆ្នោតដែលខុមហ្វ្រែលមានចំនួន១៥០៧៥ការិយាល័យ ឃើញថា២៦ការិយាល័យមានអ្នកបោះឆ្នោតច្រើនជាងអ្នកបានចុះឈ្មោះ។ ក្នុងចំណោម២៦ការិយាល័យនោះ មាន១ការិយាល័យជារបស់មន្ត្រីគជប ជាអ្នកបំពេញដូចជាទម្រង់ ១១០៤ ក្រៅពីនោះគឺទទួលបានពីអ្នកសង្កេតការណ៍របស់ខុមហ្វ្រែលដែលធ្វើការអង្កេត និងចម្លងចេញពីទម្រង់១១០៩។

### *១០.១.៣ ការផ្ទៀតផ្ទាត់លទ្ធផលបោះឆ្នោតក្នុងការិយាល័យថ្មី*

ក្នុងឆ្នាំ២០១១ បញ្ជីឈ្មោះបោះឆ្នោតសរុបមានចំនួន ១៨១០៧ការិយាល័យ ដែលជាការិយាល័យសម្រាប់ការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១២។ រហូតមកដល់ឆ្នាំ២០១៣ ការិយាល័យបោះឆ្នោតមានចំនួន ១៩០០៩ការិយាល័យ មានន័យថាការិយាល័យថ្មីដែលទើបតែបង្កើតមានចំនួន ៩០២ការិយាល័យ នៃការិយាល័យប៉ាន់ស្មានចំនួន ៩៨១ការិយាល័យ។

*មានការកត់សម្គាល់នោះគឺបច្ចេកទេសនៅក្នុងបញ្ជីការិយាល័យបោះឆ្នោតឆ្នាំ២០១២ សម្រាប់បោះឆ្នោតឆ្នាំ២០១៣ គជប មិនបានបង្ហាញថា ការិយាល័យណាថ្មីឲ្យបានពិតប្រាកដដូចរបាយការណ៍សរុបនៃតារាងលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២ ដែលបានចេញនៅថ្ងៃទី ៣១ ខែ*

*ឆ្នាំ២០១២នោះទេ។ នោះមានន័យថាការិយាល័យបង្កើតថ្មីដាក់លាយឡំជាមួយនិងជួរឈរនៃការិយាល័យចាស់ រីឯលេខការិយាល័យដែលបង្កើតថ្មីឃើញមានតួលេខចំនួន ១៤៥ការិយាល័យប៉ុណ្ណោះ។*

ការសិក្សាជារួមជាមួយលទ្ធផលបោះឆ្នោតឆ្នាំ២០១៣ បានបង្ហាញឲ្យឃើញថា ក្នុងចំណោម៩០២ ការិយាល័យ ដែលបានបង្កើតថ្មីគឺគណបក្សសង្គ្រោះជាតិឈ្នះសម្លេងឆ្នោត ក្នុងការិយាល័យចំនួន ៤០៥ ការិយាល័យ (៤៤,៩%) និងផ្ទុយមកវិញ ៤៩៧ ការិយាល័យ (៥៥,១%) ត្រូវទទួលជ័យជំនះដោយគណបក្សប្រជាជនកម្ពុជា។

លទ្ធផលក្នុងការិយាល័យដែលបានបង្កើតថ្មីបានបង្ហាញទៀតថា មាន១៥ខេត្តដែលគណបក្សប្រជាជនកម្ពុជាបានទទួលសម្លេងឆ្នោតឈ្នោះគណបក្សដទៃនៅក្នុងការិយាល័យទើបតែបង្កើតថ្មី មានដូចជា បន្ទាយមានជ័យ (បង្កើតថ្មី ៤០ គណបក្សប្រជាជនកម្ពុជាឈ្នះ ២៦ការិយាល័យ) បាត់ដំបង (បង្កើតថ្មី ៩៧ គណបក្សប្រជាជនកម្ពុជាឈ្នះ ៦៧ការិយាល័យ) កំពង់ឆ្នាំង (បង្កើតថ្មី ២៤ គណបក្សប្រជាជនកម្ពុជាឈ្នះ ១៩ការិយាល័យ) សៀមរាប (បង្កើតថ្មី ៨២ គណបក្សប្រជាជនកម្ពុជាឈ្នះ ៦១ការិយាល័យ) ព្រះសីហនុ (បង្កើតថ្មី ១២ គណបក្សប្រជាជនកម្ពុជាឈ្នះ ៩ការិយាល័យ) ស្វាយរៀង(បង្កើតថ្មី ១៣ គណបក្សប្រជាជនកម្ពុជាឈ្នះ ១១ការិយាល័យ) និងខេត្តដែលមានការិយាល័យបោះឆ្នោត សម្រាប់គណបក្សប្រជាជនកម្ពុជាទទួលបានសម្លេងឆ្នោតឈ្នះឆ្នោត ពីគណបក្សដទៃទៀត ១០០% នៃការិយាល័យបង្កើតថ្មីមាន មណ្ឌលគិរី (បង្កើតថ្មី ១១ គណបក្សប្រជាជនកម្ពុជាឈ្នះ ១០ការិយាល័យ) កោះកុង (បង្កើតថ្មី ៤ គណបក្សប្រជាជនកម្ពុជាឈ្នះ ៤ការិយាល័យ) ព្រះវិហារ (បង្កើតថ្មី ២២ គណបក្សប្រជាជនកម្ពុជាឈ្នះ ២០ការិយាល័យ) ពោធិ៍សាត់ (បង្កើតថ្មី ១៨ គណបក្សប្រជាជនកម្ពុជាឈ្នះ ១៨ការិយាល័យ) រតនគីរី (បង្កើតថ្មី ១៥ គណបក្សប្រជាជនកម្ពុជាឈ្នះ ១៥ការិយាល័យ) ស្ទឹងត្រែង (បង្កើតថ្មី ៦ គណបក្សប្រជាជនកម្ពុជាឈ្នះ ៦ ការិយាល័យ) ឧត្តរមានជ័យ (បង្កើតថ្មី ៤០ គណបក្សប្រជាជនកម្ពុជាឈ្នះ ៤០ការិយាល័យ) កែប (បង្កើតថ្មី ៣ គណបក្សប្រជាជនកម្ពុជាឈ្នះ ៣ការិយាល័យ) ប៉ៃលិន (បង្កើតថ្មី ២ គណបក្សប្រជាជនកម្ពុជាឈ្នះ ២ ការិយាល័យ)។

សម្រាប់គណបក្សសង្គ្រោះជាតិវិញ បានទទួលសម្លេងឆនោតឈ្នះគណបក្សដទៃនៅក្នុងការិយាល័យបង្កើតថ្មីចំនួ៦ខេត្ត ដូចជា កំពង់ចាម (បង្កើតថ្មី ៨៩ គណបក្សសង្គ្រោះជាតិឈ្នះ ៥២ការិយាល័យ) កំពង់ស្ពឺ (បង្កើតថ្មី ៤៨ គណបក្សសង្គ្រោះជាតិឈ្នះ ២៧ការិយាល័យ) កណ្តាល (បង្កើតថ្មី ៧០ គណបក្សសង្គ្រោះជាតិឈ្នះ ៤៣ការិយាល័យ) ភ្នំពេញ (បង្កើតថ្មី ១០៣ គណបក្សសង្គ្រោះជាតិឈ្នះ ៩៤ការិយាល័យ) ព្រៃវែង (បង្កើតថ្មី ៤៦ គណបក្សសង្គ្រោះជាតិឈ្នះ ៣១ការិយាល័យ) តាកែវ (បង្កើតថ្មី ៤៣ គណបក្សសង្គ្រោះជាតិឈ្នះ ២៣ការិយាល័យ) ។

បើក្រឡេកមើលពីការិយាល័យដែលគណបក្សទាំងពីទទួលបានស្មើគ្នាក្នុងការិយាល័យបង្កើតថ្មីវិញ ឃើញមានចំនួន ៣ ខេត្ត ដូចជា កំពង់ធំ (ប្រ.ជ ១៨ និង គ.ស.ជ ១៩) កំពត (២៣ និង២៣) ក្រចេះ (ប្រ.ជ ១៦ និង គ.ស.ជ ១៥)។ គួរកត់សម្គាល់ទៀតថា ការិយាល័យដែលបង្កើតថ្មី ក្នុងមណ្ឌលមួយដែលមានគណបក្សតែមួយឈ្នះគ្រប់ការិយាល័យ ដូចជា ឧត្តរមានជ័យ (បង្កើតថ្មី ៤០ការិយាល័យ គណបក្សប្រជាជនឈ្នះទាំង ៤០) រតនគីរី (បង្កើតថ្មី ១៥ ប្រ.ជ ឈ្នះទាំង ១៥) ពោធិ៍សាត់ (បង្កើតថ្មី ១៨ ឈ្នះទាំង ១៨) និងស្ទើរតែ

គ្រប់ការិយាល័យមាន ភ្នំពេញ (បង្កើតថ្មី ១០៣ គ.ស.ជ ឈ្មុះ ៩៤ការិយាល័យ) កំពង់ចាម (បង្កើតថ្មី ៨៩ គ.ស.ជ ឈ្មុះ ៥២ការិយាល័យ) កណ្តាល (បង្កើតថ្មី ៧០ គ.ស.ជ ឈ្មុះ ៤៣)។

### *១០.១.៤ សន្លឹកឆ្នោតដែលមិនបានការ*

ទោះបីទម្រង់របាយការណ៍របស់ខុមហ្វ្រែលផ្ទាល់ ដែលទទួលបានពីអ្នកសង្កេតការណ៍នៅការិយាល័យមានចំនួនតែ ៥៣៧៤នាក់ក៏ពិតមែន ប៉ុន្តែលទ្ធផលបោះឆ្នោតវិញ ខុមហ្វ្រែលបានទទួលរហូតដល់ចំនួន ១៥០៧៥ការិយាល័យ ពីថ្នាក់មូលដ្ឋាន ក្នុងនោះមានទម្រង់ ១១០៤ ទម្រង់អ្នកសង្កេតការណ៍រយៈពេលខ្លី (អេសធីអូ ឬ ទម្រង់ ខ.៧) ទម្រង់អ្នកសង្កេតការណ៍បញ្ជូនលទ្ធផលឆ្នោតលឿន (ភីវីធី) និងទម្រង់ ១១០៩ របស់មន្ត្រីគណកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត (គឃសប)។

យោងតាមលទ្ធផលផ្លូវការរបស់គ.ជ.បចេញថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣ ចំនួនសន្លឹកឆ្នោតដែលមិនបានការសរុបទូទាំងប្រទេសមានចំនួន១,៦% ហើយនៅក្នុងនោះដែរ មណ្ឌលដែលមានសន្លឹកឆ្នោតមិនបានការច្រើនជាងគេគឺ មណ្ឌលព្រះវិហារ (៤,០៥%), មណ្ឌលរតនគីរី (៣,៦៦%), មណ្ឌលមណ្ឌលគីរី (២,៩២%), មណ្ឌលស្ទឹងត្រែង (២,៧៨%) និងមណ្ឌលកោះកុង (២,៥៨%)។ រីឯមណ្ឌលដែលមានសន្លឹកឆ្នោតមិនបានការតិចជាងគេ គឺមណ្ឌលភ្នំពេញ។

ដោយឡែកយោងលើទម្រង់១១០៩ ដែលអ្នកសង្កេតការណ៍ប្រមូលបានពីគណកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតបានបង្ហាញឲ្យឃើញថា សន្លឹកឆ្នោតមិនបានការមានចំនួនមួយគួរឲ្យកត់សម្គាល់ បើគិតចាប់ពីសន្លឹកឆ្នោតមិនបានការចំនួន២០សន្លឹកក្នុងមួយការិយាល័យ រហូតដល់ ១០០សន្លឹកក្នុងមួយការិយាល័យ ឃើញមានចំនួន៥១៨ការិយាល័យ និងចាប់ពី១០០សន្លឹកនៃសន្លឹកឆ្នោតមិនបានការក្នុងមួយការិយាល័យទៅ ៥០០សន្លឹកក្នុងមួយការិយាល័យគឺមានចំនួន៧៧ការិយាល័យ។

## ១០.២ ការពិព័ណ៌នាលទ្ធផលបោះឆ្នោត

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ជាថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ដែលមានគណបក្សនយោបាយចំនួន៨បានចូលរួមប្រកួតប្រជែង។ ជាលទ្ធផលបានបង្ហាញថា ក្នុងចំណោមគណបក្សនយោបាយទាំង៨ មានតែ២គណបក្សនយោបាយប៉ុណ្ណោះ ដែលទទួលបានអាសនៈក្នុងរដ្ឋសភា គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។

យោងតាមលទ្ធផលផ្លូវការដែលចេញនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៣ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣នេះ បានបង្ហាញថា ម្ចាស់ឆ្នោតបានមកបោះឆ្នោតចំនួន ៦,៧៣៥,២៤៤នាក់ នៃអ្នកបានចុះឈ្មោះបោះឆ្នោត ចំនួន ៩,៦៧៥,៤៥៣នាក់ ស្មើនឹង ៦៩,៦១% ប៉ុន្តែជាលទ្ធផលនៃសន្លឹកឆ្នោតបានការមានតែចំនួន៦,៦២៧,១៥៩នាក់ និងសន្លឹកឆ្នោតមិនបានការមានចំនួន ១,៦%។

យោងតាមលទ្ធផលនេះ គណបក្សប្រជាជនកម្ពុជានៅតែឈ្នះការបោះឆ្នោត ដោយទទួលបាន អាសនៈចំនួន ៦៨ និងសម្លេងគាំទ្រពីម្ចាស់បោះឆ្នោតចំនួន ៤៨,៨៣% (៣,២៣៥,៩៦៩សម្លេង) រីឯគណបក្សសង្គ្រោះជាតិទទួលបានអាសនៈចំនួន៥៥ និងសម្លេងគាំទ្រពីម្ចាស់បោះឆ្នោតចំនួន៤៤,៤៦% (២,៩៤៦,១៧៦ សម្លេង)។ ប៉ុន្តែផ្ទុយមកវិញគណបក្សនយោបាយទាំង៦ផ្សេងទៀត មិនត្រូវបានទទួលអាសនៈក្នុងរដ្ឋភានីតិ

កាលទី៥នេះទេ គ្រាន់តែមានសម្លេងគាំទ្រពីម្ចាស់ឆ្នោតដូចជា គណបក្សហ៊្វុនស៊ិនប៉ិច មានសម្លេងគាំទ្រចំនួន ៣,៦៦% (២៤២,៤១៣សម្លេង) គណបក្សសញ្ជាតិកម្ពុជា មានសម្លេងគាំទ្រចំនួន០,៥៨% (៣៨,១២៣សម្លេង) គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យមានសម្លេងគាំទ្រចំនួន ០,៥១% (៣៣,៧១៥សម្លេង) គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ចមានសម្លេងគាំទ្រចំនួន០,២៩% (១៩,១៥២សម្លេង) គណបក្សខ្មែរឈប់ក្រមានសម្លេងគាំទ្រចំនួន០,៦៥% (៤៣,២២២សម្លេង) គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យមានសម្លេងគាំទ្រចំនួន ១,០៣% (៦៨,៣៨៩សម្លេង)។

បើប្រៀបធៀបជាមួយលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៤ ឆ្នាំ២០០៨វិញ ឃើញថា សម្លេងគាំទ្ររបស់គណបក្សនយោបាយមានការប្រែប្រួលគួរឲ្យកត់សម្គាល់ ជាពិសេសគណបក្សប្រជាជនកម្ពុជាដែលធ្លាប់ទទួលបាន ៩០អសនៈ ក្នុងសម្លេងគាំទ្រ ៥៨,១១% (៣,៤៩២,៣៧៤សម្លេង) នៅក្នុងនីតិកាលទី៤ ឆ្នាំ២០០៨ ត្រូវបានថយចុះមកត្រឹមចំនួន៦៨អសនៈ ក្នុងសម្លេងគាំទ្រ ៤៨,៨៣% (៣,២៣៥,៩៦៩សម្លេង)។ ផ្ទុយមកវិញ គណបក្សសង្គ្រោះជាតិដែលចេញពីការបង្រួបបង្រួមរវាងគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ដែលក្នុងនីតិកាលទី៤ ឆ្នាំ ២០០៨ គណបក្សនយោបាយទាំងពីរមានចំនួន២៩អាសនៈ (គណបក្សសមរង្ស៊ីមាន២៦អាសនៈ និងគណបក្សសិទ្ធិមនុស្សចំនួន៣អាសនៈ) ឬស្មើនឹងអ្នកបោះឆ្នោត ២៨,៥៣% (១,៧១៤,៥៣០សម្លេង ដែលបានមកពី គណបក្សសមរង្ស៊ី ១,៣១៦,៧១៤សម្លេង បូកនឹងគណបក្សសិទ្ធិមនុស្ស ៣៩៧,៨១៦សម្លេង) បានកើនឡើងមកដល់ ៥៥អាសនៈ ស្មើនឹង ៤៤,៧២% (២,៩៤៦,១៧៦សម្លេង)។ គណបក្សហ៊្វុនស៊ិនប៉ិច ធ្លាប់មានការបែកបាក់ផ្ទៃក្នុងជាច្រើន ព្រមទាំងជាដៃគូជាមួយគណបក្សប្រជាជនកម្ពុជាផងនោះ ហើយកាលពីនីតិកាលទី៤ ឆ្នាំ២០០៨ មានអ្នកគាំទ្រចំនួន ៣០៣,៧៦៤សម្លេង ស្មើនឹង ៥,០៥% និងទទួលបាន២អាសនៈ មានការធ្លាក់ចុះចំនួនអ្នកបោះឆ្នោតគាំទ្រ ហើយមិនទទួលបានអាសនៈ ក្នុងរដ្ឋសភាសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥នេះ។

មានការប្រែប្រួលសម្លេងឆ្នោតរបស់គណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងនៅតាមបណ្តាញខេត្តមួយចំនួនដូចខាងក្រោម៖

- គណបក្សហ៊្វុនស៊ិនប៉ិច បើធៀបជាមួយលទ្ធផលចុងក្រោយគឺ៖
    - បាត់ដំបងកើនឡើង២៣០សម្លេង, សៀមរាបកើន ២០៣សម្លេង, តាកែវកើន ៤៨៦ ក្រៅពីនោះកើនក្រោម ៥០សម្លេង
    - កំពង់ចាមថយចុះ ៦៧៧សម្លេង
- គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ ឃើញមានសម្លេងធ្លាក់ចុះគួរឲ្យកត់សម្គាល់ ដូចជា
    - នៅបាត់ដំបង ធ្លាក់ចុះរហូតដល់ ៥៣២សម្លេង, ព្រះសីហនុធ្លាក់ចុះ១០២សម្លេង, តាកែវធ្លាក់ចុះ ៣១៤សម្លេង, សរុបទូទាំងប្រទេសធ្លាក់ចុះ រហូតដល់ ៨៥៤សម្លេង
    - ក្រៅពីនោះសម្លេងឆ្នោតធ្លាក់ចុះមានចំនួនតិចតួច
- គណបក្សប្រជាជនកម្ពុជា មានកើនឡើងសម្លេងឆ្នោតនៅក្នុងខេត្តបាត់ដំបង កំពង់ចាម ក្រចេះ ភ្នំពេញ ព្រះវិហារ តាកែវ ស្ទឹងត្រែង និងថយចុះ នៅក្នុងខេត្តព្រៃវែង និងសៀមរាប។
- គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ថយចុះខ្លាំងរហូតដល់ ៧០៥សម្លេងនៅក្នុងខេត្តកណ្តាល

- គណបក្សខ្មែរឈប់ក្រ ថយចុះខ្លាំងនៅក្នុងខេត្តបាត់ដំបង
- គណបក្សសង្គ្រោះជាតិ មានសម្លេងកើនខ្លាំងនៅក្នុងខេត្តទាំង៧ ដូចជា បាត់ដំបង កំពង់ចាម កណ្តាល ក្រចេះ ភ្នំពេញ ព្រះវិហារ និងតាកែវ។
- គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ មានសម្លេងធ្លាក់ចុះ ប្រហែល ១២៧៨សម្លេង
- គណបក្សតូចៗ និងគណបក្សប្រជាជនកម្ពុជា ក្រៅពីគណបក្សសង្គ្រោះជាតិ មានការធ្លាក់ចុះ រីឯគណបក្សសង្គ្រោះជាតិមានការកើនឡើង។

## ១០.៣ បេក្ខជនស្ត្រីជាប់ឆ្នោត

គណបក្សពីរប៉ុណ្ណោះដែលបានទទួលសម្លេងឆ្នោតគាំទ្រពីអ្នកបោះឆ្នោត និងអាសនៈក្នុងរដ្ឋសភាគឺ គណបក្សប្រជាជនកម្ពុជាទទួលបាន ៦៨អាសនៈ ក្នុងនោះ១៨ អាសនៈស្មើនឹង២៦,៦៧%ជាស្ត្រី និងគណបក្សសង្គ្រោះជាតិទទួលបាន៥៥អាសនៈ ក្នុងនោះស្ត្រីមានតែ៧អាសនៈស្មើនឹង១២,៧២%ប៉ុណ្ណោះ។

បើយោងតាមលទ្ធផលបណ្តោះអាសន្នរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ ចំនួនបេក្ខជនស្ត្រីដែលត្រូវជាប់ឆ្នោតមានការថយចុះ១,៦៣% (២នាក់) គឺពី ១៨នាក់ ស្មើនឹង១៤,៦៣% នៅនីតិកាលទី៤ ឆ្នាំ២០០៨(ជាប់ឆ្នោតភ្លាម) មក១៦នាក់ ស្មើនឹង១៣% នៅនីតិកាលទី៥ ឆ្នាំ២០១៣នៃអ្នកជាប់ឆ្នោតសរុប១២៣នាក់។ ប៉ុន្តែបើយោងតាមលទ្ធផលផ្លូវការរបស់គ.ជ.ប ចេញថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៣ បានបង្ហាញថា បេក្ខជនស្ត្រីជាប់ឆ្នោតមានចំនួនឡើងដល់២៥នាក់ ស្មើនឹង ២០,៣៣% ជាតំណាងរាស្ត្រសម្រាប់នីតិកាលទី៥នេះ បន្ទាប់ពីមានការលាលែងរបស់បេក្ខជនជាប់ឆ្នោតមួយចំនួនដែលភាគច្រើនជាបុរសនៃគណបក្សប្រជាជនកម្ពុជាមុនការប្រកាសលទ្ធផលបោះឆ្នោតផ្លូវការនៃនីតិកាលទី៤ ឆ្នាំ២០០៨។ ទោះបីជាយ៉ាងណា ចំនួននេះមានការថយចុះបន្តិចគឺ០,៨១% បើប្រៀបធៀបនឹងចុងនីតិកាលទី៤ មាន២៦នាក់ ស្មើនឹង ២១,១៤%។

ក្រាហ្វិកទី៣៖ បេក្ខជនស្ត្រីជាប់ឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥




## ១០.៤ យុវជនជាប់ឆ្នោត

បើតាមតួលេខរបស់ គ.ជ.ប បានបង្ហាញថា មានបេក្ខជនជាយុវជន (អាយុ២៥ ដល់៣៥ឆ្នាំ) ចំនួន ១៧៩នាក់ ស្មើនឹង២០% នៃចំនួនបេក្ខជនពេញសិទ្ធិសរុប ៨៨៦នាក់ ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេក្ខជនពេញសិទ្ធិនៃគណបក្សនយោបាយទាំងប្រាំបី។

បើទោះជាមានការដាក់បញ្ចូលបេក្ខជនពេញសិទ្ធិជាយុវជនច្រើនជាងការបោះឆ្នោតក្នុងអាណត្តិកន្លងមកក៏ដោយ ក៏បន្ទាប់ពីការបោះឆ្នោតថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣រួចមក បើយោងតាមលទ្ធផលបោះឆ្នោតរបស់ គ.ជ.បចេញថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៣ បានបង្ហាញពីបេក្ខជនជាយុវជនតិចតួចបំផុតបានជាប់ឆ្នោតជាតំណាងរាស្ត្រ។ លទ្ធផលនោះបង្ហាញថា មានបេក្ខជនជាយុវជនបីនាក់ ដែលមិនដល់១%ផង បានជាប់ឆ្នោតជាតំណាងរាស្ត្រ ដែលក្នុងនោះពីររូបមកពីគណបក្សប្រជាជនកម្ពុជា និងជាកូនរបស់លោកនាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រីសុខ អាន និងមួយរូបមកពីគណបក្សសង្គ្រោះជាតិ។ គួរបញ្ជាក់ថា ក្នុងអាណត្តិកន្លងៗមកក៏មិនមានយុវជនជាប់ឆ្នោតជាតំណាងរាស្ត្រទេ។

## ១១. ការចូលរួមរបស់ប្រជាពលរដ្ឋ និងការបាត់បង់សិទ្ធិបោះឆ្នោត

### ១១.១ ការចូលរួមរបស់ស្ត្រី និងការបាត់បង់សិទ្ធិ

នៅក្នុងបរិបទប្រទេសកម្ពុជា ការចូលរួមរបស់ស្ត្រីកាន់តែមានការរីកចំរើន និងវិវឌ្ឍន៍ទៅមុខជាលំដាប់ជាពិសេសស្ត្រីចូលរួមក្នុងវិស័យនយោបាយ។ ដោយឡែកនៅក្នុងដំណើរការបោះឆ្នោត មិនមែនមានត្រឹមតែស្ត្រីចូលរួមឈរឈ្មោះជាបេក្ខជនក្នុងការឲ្យប្រជាពលរដ្ឋបោះឆ្នោតឲ្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងស្ត្រីមានការចូលរួមតាមដានក្នុងដំណើរការបោះឆ្នោត ជាពិសេសការតាមដានទៅលើកិច្ចការការពារសិទ្ធិមនុស្សនៅក្នុងជីវភាពរស់នៅរបស់គេផងដែរ។

នៅក្នុងការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោតរបស់ខុមហ្វ្រែលបម្រើឲ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ បានបង្ហាញថា ស្ត្រីប្រមាណ៩៧% បានចុះឈ្មោះបោះឆ្នោត (ចំនួននេះមិនទាន់គិតអំពីអ្នកធ្លាប់បានចុះឈ្មោះ ប៉ុន្តែឈ្មោះរបស់ពួកគេត្រូវបានលុបពីបញ្ជីបោះឆ្នោត)។ បើយោងតាមលទ្ធផលផ្លូវការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត មានស្ត្រីប្រមាណ៥២,៥២%នៃអ្នកចុះឈ្មោះសរុបបាននិយាយថាបានចុះឈ្មោះបោះឆ្នោត។

ម្យ៉ាងវិញទៀត ការចូលរួមរបស់ស្ត្រីនៅក្នុងកិច្ចការបោះឆ្នោតដូចជាសមាជិកគណៈកម្មាការរាជធានីខេត្តរៀបចំការបោះឆ្នោត (គជ/ខប) និងគណកម្មាការឃុំសង្កាត់រៀបចំការបោះឆ្នោត(គឃ/សប) នៅមានចំនួនតិចនៅឡើយ។ ផ្អែកលើការសិក្សាស្រាវជ្រាវរបស់ខុមហ្វ្រែលស្ត្រីចូលរួមក្នុងកិច្ចការបោះឆ្នោតនៅប្រមាណ៥ខេត្ត ដូចជាខេត្តតាកែវ ព្រះវិហារ កំពង់ធំ កំពង់ចាម កំពង់ឆ្នាំង មានស្ត្រីចំនួនតែ៨នាក់ប៉ុណ្ណោះបានដាក់ពាក្យធ្វើជាសមាជិកគណកម្មាការរាជធានី ខេត្តរៀបចំការបោះឆ្នោត ហើយនៅក្នុងនោះដែរ មានស្ត្រីចំនួន៧នាក់ ស្មើនឹង១១%នៃចំនួនសរុប៦៣នាក់ត្រូវបានជាប់សំរាំងដើម្បីបញ្ជូនឈ្មោះទៅគ.ជ.ប ដើម្បីសម្រេច។ ចំណែកការសិក្សាស្រាវជ្រាវរបស់ខុមហ្វ្រែលស្ត្រីចូលរួមនៅក្នុងកិច្ចការបោះឆ្នោត និងជាសមាជិកគណកម្មាការឃុំសង្កាត់រៀបចំការបោះឆ្នោត(គឃ/សប)នៅប្រមាណ១០ឃុំសង្កាត់ នៅខេត្តចំនួន៥នេះដែរ ចំនួនស្ត្រីដែលបានដាក់ពាក្យបំរើការងារមានចំនួន ៣៥នាក់ (១០%នៃចំនួនសរុប៧៦នាក់ ហើយក្នុងនោះស្ត្រីចំនួន២៤នាក់ (៣៧%) នៃចំនួនសរុប៦៤នាក់ត្រូវបានជាប់សំរាំងដើម្បីបញ្ជូនទៅគណកម្មាការរាជធានីខេត្តរៀបចំការបោះឆ្នោត(គជ/ខប) ដើម្បីធ្វើការសម្រេច។

ដោយឡែកអ្នកអង្កេតការណ៍ស្ត្រីរបស់ខុមហ្វ្រែលប្រមាណ៦០នាក់បានធ្វើការអង្កេតនៅការិយាល័យចំនួន៦០នៅថ្ងៃបោះ និងរាប់សន្លឹកឆ្នោតក្នុងខេត្តគោលដៅចំនួន៥ ដូចជាខេត្តតាកែវ កំពង់ចាម កំពង់ធំ កំពង់ឆ្នាំង និងព្រះវិហារ។ ការិយាល័យចំនួន៤៩ ក្នុងការិយាល័យចំនួន៦០ មានសមាសភាពមន្ត្រីការិយាល័យ

បោះឆ្នោតជាស្ត្រីចំនួនសរុប១១៣នាក់ ស្មើនឹង៣១% (មន្ត្រីការិយាល័យចំនួន៦នាក់ក្នុងមួយការិយាល័យបោះឆ្នោត) ហើយពួកគាត់ភាគច្រើនជាលេខា ជំនួយការទី១ និងជំនួយការទី២។ មិនតែប៉ុណ្ណោះតាមការស្រាវជ្រាវនៃការប៉ាន់ប្រមាណនៃតួលេខស្ត្រីដែលបានបោះឆ្នោតនៅតាមការិយាល័យទាំង៥៩នេះ ប្រមាណ ១១,៥៧៩នាក់ ស្មើនឹង៥៧,២២%នៃចំនួនសរុប ២០,២៣៣នាក់ បានបោះឆ្នោតនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៣។

ថ្វីបើចំនួនបេក្ខជនស្ត្រីមានការកើនឡើងជាងការបោះឆ្នោតអាណត្តិមុនក្តី ប៉ុន្តែចំនួនស្ត្រីដែលជាប់ឆ្នោតជាតំណាងរាស្ត្រសម្រាប់នីតិកាលទី៥ ឆ្នាំ២០១៣នេះមានការថយចុះបន្តិចគឺពី ២៦នាក់ (២១,១៤%) នៅនីតិកាលទី៤ ឆ្នាំ២០០៨ មកត្រឹម ២៥នាក់ (២០,៣៣%) នៅនីតិកាលទី៥ ឆ្នាំ២០១៣។

ចំណែកការចូលរួមស្ត្រីនៅក្នុងការសម្រេចចិត្តខាងនយោបាយ ដូចជាការចូលរួមរបស់ស្ត្រីនៅក្នុងការបោះឆ្នោតដោយការឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យ។ ជាក់ស្តែងសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ គណបក្សនយោបាយចំនួន៨បានដាក់បេក្ខជនស្ត្រីប្រមាណសរុប១៦៨នាក់ ក្នុងចំណោម៨៨៦នាក់ ស្មើនឹង ១៨,៩៦% ដែលចំនួននេះមានចំនួនច្រើនជាងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៤ ឆ្នាំ២០០៨ ដែលមានត្រឹមតែ១៤,៨០%។

**១១.២ ការចូលរួមរបស់យុវជនក្នុងការបោះឆ្នោត**

សម្រាប់ការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១២ ដែលបម្រើឲ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣របស់ខុមហ្វ្រែល មានយុវជនប្រមាណ៩៣,៤% បានលើកឡើងថាបានចុះឈ្មោះបោះឆ្នោត(ចំនួននេះមិនទាន់គិតអំពីអ្នកធ្លាប់បានចុះឈ្មោះ ប៉ុន្តែឈ្មោះរបស់ពួកគេត្រូវបានលុបពីបញ្ជីបោះឆ្នោត)។ ចំពោះយុវជនដែលទើបគ្រប់អាយុ១៨ឆ្នាំគិតទៅដល់ថ្ងៃបោះឆ្នោតឆ្នាំ២០១៣ មានតែ ៨៦% បាននិយាយថា ពួកគេបានចុះឈ្មោះបោះឆ្នោត។ ចំនួនប្រមាណ៣២០,០០០នាក់ បើយោងតាមរបាយការណ៍ជំរឿនឆ្នាំ២០០៨ នៃវិទ្យាស្ថានជាតិស្ថិតិបង្ហាញថា យុវជនមានប្រមាណជាង ៣៧០,០០០នាក់ ដែលនឹងគ្រប់អាយុចុះឈ្មោះបោះឆ្នោតបើគិតទៅដល់ថ្ងៃបោះឆ្នោតឆ្នាំ២០១៣។

ម្យ៉ាងវិញទៀត ការចូលរួមរបស់យុវជននៅក្នុងកិច្ចការបោះឆ្នោតដូចជាសមាជិកគណកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គជ/ខប) និងគណកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត(គឃ/សប) នៅមានចំនួនតិចតួចនៅឡើយ។ ផ្អែកលើការសិក្សាស្រាវជ្រាវរបស់ខុមហ្វ្រែលស្តីពីការចូលរួមរបស់យុវជនក្នុងកិច្ចការបោះឆ្នោតនៅប្រមាណ២០ខេត្ត ចំនួន២០ឃុំសង្កាត់(លើកលែងខេត្ត) មានយុវជនចំនួន៩%ប៉ុណ្ណោះដែលជាប់ជាសមាជិកគណកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត (១៨ ដល់៣០ឆ្នាំ) និងមានយុវជនតែ១១% ដែលក្លាយជាសមាជិកគណកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត (គឃ/សប)។

ដោយឡែកអ្នកអង្កេតការណ៍យុវជនរបស់ខុមហ្វ្រែលប្រមាណ៦០នាក់បានធ្វើការអង្កេតនៅការិយាល័យចំនួន៦០នៅថ្ងៃបោះ និងរាប់សន្លឹកឆ្នោតក្នុងខេត្តគោលដៅចំនួន៥ ដូចជាខេត្តតាកែវ កំពង់ចាម កំពង់ធំ កំពង់ឆ្នាំង និងព្រះវិហារ។ លទ្ធផលនៃការសង្កេតបានរកឃើញថា មានយុវជនប្រមាណ៧០% នៃយុវជនដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានចេញទៅបោះឆ្នោតនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣។

ចំណែកឯការចូលរួមរបស់យុវជនក្នុងវិស័យនយោបាយក៏ដូចជាការសម្រេចចិត្តខាងនយោបាយវិញ បើតាមតួលេខរបស់គ.ជ.ប បានបង្ហាញថា មានបេក្ខជនជាយុវជន (២៥ ដល់ ៣៥ឆ្នាំ) ចំនួន១៧៩នាក់ ស្មើ

នឹង២០%នៃចំនួនបេក្ខជនពេញសិទ្ធិសរុប៨៨៦នាក់ ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេក្ខជនពេញសិទ្ធិរបស់គណបក្សនយោបាយទាំងប្រាំបី។ ក្នុងនោះដែរគណបក្សនយោបាយដែលដាក់យុវជនតិចជាងគេ គឺគណបក្សប្រជាជនកម្ពុជា៤នាក់ ស្មើនឹង៣% គណបក្សសង្គ្រោះជាតិ១៤នាក់ ស្មើនឹង១១% និងគណបក្សហ៊្វុនស៊ិនប៉ិច ៦នាក់ ស្មើនឹង ៥%។ ចំណែកឯគណបក្សដែលដាក់បញ្ចូលបេក្ខជនក្នុងបញ្ជីបេក្ខជន គឺគណបក្សសម្ព័ន្ធប្រជាធិបតេយ្យដើម្បីប្រជាធិបតេយ្យមានចំនួន៧០នាក់ ស្មើនឹង៥៧% និងគណបក្សខ្មែរឈប់ក្រចំនួន២៤នាក់ ស្មើនឹង២០%នៃចំនួនបេក្ខជនសរុបគណបក្សខ្លួន។

ខុសប្លែកពីការបោះឆ្នោតអាណត្តិមុនៗ ដែលពុំមានបេក្ខជនយុវជនជាប់ឆ្នោត និងអាសនៈក្នុងរដ្ឋសភាទាល់តែសោះ ហើយសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣នេះ ជាការចាប់ផ្តើមនៃបរិបទថ្មីនៅក្នុងប្រទេសកម្ពុជាដែលផ្តល់ឱកាសដល់យុវជនក្នុងការសម្រេចចិត្តខាងនយោបាយ ដែលយ៉ាងហោចក៏មានយុវជនចំនួន៣រូបបានជាប់ឆ្នោតជាតំណាងរាស្ត្រ ដែលក្នុងនោះ២រូបមកពីគណបក្សប្រជាជនកម្ពុជា និងមួយរូបមកពីគណបក្សសង្គ្រោះជាតិ។

### ១១.៣ ការចូលរួមរបស់ក្រុមជនដែលត្រូវបានបណ្តេញចេញពីលំនៅដ្ឋាន

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានដាក់ពង្រាយអ្នកសង្កេតការណ៍រយៈពេលវែងចំនួន ២នាក់ និងអ្នកសង្កេតការណ៍រយៈពេលខ្លី ២០ នាក់ ត្រូវបានជ្រើសរើស និងដាក់ពង្រាយ ដើម្បីសង្កេតតាមដានអំពីការចូលរួមរបស់ជនត្រូវបានបណ្តេញចេញពីលំនៅដ្ឋានក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ ដោយបានជ្រើសរើសតំបន់គោលដៅចំនួន២គឺ សហគមន៍បុរីកីឡានៅសង្កាត់វាលវង់ ខណ្ឌ៧មករា និងសហគមន៍បឹងកក់នៅសង្កាត់បឹងកក់១/២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ទាក់ទងទៅនឹងការចុះឈ្មោះ និងពិនិត្យឈ្មោះរបស់តំបន់គោលដៅខាងលើ ខុមហ្វ្រែលសង្កេតឃើញថា ប្រជាពលរដ្ឋមួយចំនួនមិនបានទទួលព័ត៌មានពីអាជ្ញាធរនោះទេ រហូតដល់ប្រជាពលរដ្ឋខ្លះ មិនបានទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតែម្តង។ មានប្រជាពលរដ្ឋតិចតួចណាស់ដែលបានទទួលព័ត៌មានតាមរយៈវិទ្យុ និងទូរទស្សន៍។ បន្ថែមលើសពីនេះប្រជាពលរដ្ឋនៅតំបន់បុរីកីឡាបានឲ្យដឹងថា ការពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅសហគមន៍ អាជ្ញាធរខ្វះការផ្សព្វផ្សាយ និងផ្តល់ ពត៌មានដល់ប្រជាពលរដ្ឋ លើសពីនេះទៀត អាជ្ញាធរហាក់មិនសប្បាយចិត្តសោះនៅពេលឃើញប្រជាពលរដ្ឋទៅពិនិត្យឈ្មោះ និងចុះឈ្មោះដោយពួកគេមិនចង់សហការ និងបង្កការលំបាកដល់ពួកគាត់។

ការឃោសនាបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣នេះមានរយៈពេល ៣០ ថ្ងៃ គឺចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ នៅក្នុងដំណាក់កាលនេះសង្កេតឃើញថា ក្រុមប្រជាពលរដ្ឋដែលត្រូវបណ្តេញចេញតែងតែធ្វើការតវ៉ា និងទាមទារឲ្យមានការដោះស្រាយបញ្ហាដីធ្លីរបស់ពួកគាត់ជាហូរហែ ចំណែកឯអាជ្ញាធរវិញដែលដឹកនាំដោយលោក ប៉ា សុជាតិវង្ស អភិបាលរាជធានីភ្នំពេញបានសន្យាថានឹងដោះស្រាយបញ្ហានេះជូនដល់ពួកគាត់នៅពេលបោះឆ្នោតត្រូវបានបញ្ចប់ ដោយមូលហេតុថាពេលនេះអាជ្ញាធរកំពុងតែជាប់រវល់ការរក្សាសន្តិសុខ សុវត្ថិភាពឃោសនា និងការបោះឆ្នោត។ នៅក្នុងនោះដែរឃើញមានតែគណបក្សចំនួន ០២ ប៉ុណ្ណោះដែលបានចូលទៅឃោសនានៅតំបន់

នេះ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ និងថែមទាំងបានសន្យាថា នឹងដោះស្រាយជូនប្រជាពលរដ្ឋដែលរងគ្រោះទៀតផងនៅពេលដែលគណបក្សរបស់ពួកគេជាប់ឆ្នោត។ នៅក្នុងអំឡុងពេលនេះដែរ សង្កេតឃើញមានករណីគំរាមកំហែងមកលើប្រជាពលរដ្ឋមួយចំនួននៅក្នុងសហគមន៍បឹងកក់ផងដែរ ដូចជាមានករណីជនមិនស្គាល់មុខតែងតែយកទឹកនោម ទឹកលូ ទឹកលាមកជះលើដំបូលផ្ទះប្រជាពលរដ្ឋ ការវាយបំផ្លាញតូបលក់ដូរ រួមទាំងមានការគំរាមសំលាប់ទៀតផង។

ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន ២០ នាក់ នៅការិយាល័យចំនួន ២០ ដើម្បីធ្វើការសង្កេតពីការចូលរួមរបស់ក្រុមជនបណ្តេញចេញនៅក្នុងការបោះឆ្នោត និងភាពមិនប្រក្រតីនានាដែលបានកើតមាននៅតាមការិយាល័យ ក្នុងនោះបានសង្កេតឃើញថាប្រជាពលរដ្ឋនៅតំបន់បុរីកីឡា ដែលជាជនរងគ្រោះពីការបណ្តេញចេញ បានចេញទៅបោះឆ្នោតមានចំនួន ៧៤%។ ចំណែកប្រជាពលរដ្ឋនៅតំបន់បឹងកក់ ដែលរងគ្រោះដោយការបណ្តេញចេញវិញមាន៥០% អ្នកចេញទៅបោះឆ្នោត និងចំនួន៥% ឈ្មោះគាត់ ត្រូវបានគេបោះឆ្នោតរួច។

ក្រោយពីការបោះឆ្នោត និងរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់មួយថ្ងៃ ពោលគឺនៅថ្ងៃទី២៩ ខែកក្កដា អ្នកសង្កេតការណ៍ទាំង ១០នាក់ បានបន្តសម្ភាសន៍ជនបណ្តេញចេញដែលបានទៅបោះឆ្នោតចំនួន៤០នាក់ (ស្រី ២៥នាក់) ដោយពួកគាត់បានបញ្ជាក់ពីមូលហេតុដែលជម្រុញឲ្យពួកគាត់ចូលរួមបោះឆ្នោត មានកត្តាចំនួន៣ សំខាន់ៗ គឺ ទី១.ចង់អនុវត្តសិទ្ធិជាប្រជាពលរដ្ឋខ្មែរ ទី២.ចង់ឲ្យមានការផ្លាស់ប្តូរ និងទី៣.ចង់ឲ្យមានយុត្តិធម៌ ឯករាជ្យ និងលទ្ធិប្រជាធិប្បតេយ្យ។

រូបភាពទី៨៖ អ្នកដែលត្រូវបានបណ្តេញចេញពីលំនៅដ្ឋានដោយរដ្ឋាភិបាល




## ១១.៤ ការចូលរួមរបស់ជនពិការក្នុងការបោះឆ្នោត

មានការលើកឡើងទាក់ទងទៅនឹងការលំបាករបស់ជនពិការក្នុងការពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោតដោយសារតែការពិបាកក្នុងការធ្វើដំណើរ។ ជាពិសេសពួកគាត់ក៏ពុំទទួលបានព័ត៌មានអំពីការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត បើយោងតាមការសិក្សារបស់ខុមហ្វ្រែលក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២។

ទោះបីជាយ៉ាងណា សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ នេះ មានការយកចិត្តទុកដាក់ទៅលើជនពិការចូលរួមការបោះឆ្នោត ជាក់ស្តែងនៅដើមឆ្នាំ២០១៣នេះ អង្គការជនពិការកម្ពុជា (CDPO) បានរៀបចំខ្លឹមសារដើម្បីផលិតស្ពតអប់រំទាក់ទងនឹងជនពិការ និងការបោះឆ្នោតដើម្បីចាក់ផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ ដូចជាទូរទស្សន៍ និងវិទ្យុជាដើម។ ការផលិតស្ពតនេះ គឺមានបំណងឲ្យប្រជាពលរដ្ឋជាជនពិការបានយល់ដឹងអំពីសិទ្ធិ និងអត្ថប្រយោជន៍នៃការចូលរួមក្នុងដំណើរការនៃការបោះឆ្នោត។

ដោយឡែកដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋជាជនពិការក្នុងដំណើរការបោះឆ្នោត អង្គការជនពិការកម្ពុជាក្រោមកិច្ចសហការជាមួយអង្គការនិកហ្វិច និងAGENDA ក៏បានរៀបចំសិក្ខាសាលាមួយក្រោមប្រធានបទ "ការធានាសិទ្ធិនយោបាយរបស់ជនពិការ" នៅថ្ងៃទី២១ ដល់២២ ខែមីនា ឆ្នាំ២០១៣ នៅសណ្ឋាគារអ៊ីនធើកង់ទីណង់តាល់។ សិក្ខាសាលានេះមានគោលបំណងដើម្បីផ្តល់ចំណេះដឹងអំពីសិទ្ធិ អត្ថប្រយោជន៍ ក៏ដូចជាផលលំបាករបស់ជនពិការនៅក្នុងដំណើរការបោះឆ្នោត និងដើម្បីជួយសំរួល និងធានាការចូលរួមរបស់ជនពិការនៅក្នុងដំណើរការបោះឆ្នោតខាងមុខនេះ ទៅដល់មន្ត្រីគណកម្មការរៀបចំការបោះឆ្នោតរាជធានីខេត្ត ចំនួន១៦ ព្រមទាំងមន្ត្រីគ.ជ.ប នៅថ្នាក់ជាតិ។

អង្គការជនពិការកម្ពុជា បានចូលរួមពិភាក្សាជាមួយឯកឧត្តម អ៊ឹម សួស្តី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដោយបានស្នើឡើងនូបញ្ហាចំនួនពីរ គឺទី១ ស្នើសុំឲ្យគ.ជ.ប បង្កើតតារាងមួយនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតសម្រាប់បង្ហាញឈ្មោះជនពិការ ថាតើមានជនពិការប៉ុន្មាននាក់ចូលរួមការបោះឆ្នោត។ ទី២ សុំកិច្ចសហការបណ្តុះបណ្តាលដល់មន្ត្រីរៀបចំការបោះឆ្នោត ដើម្បីឲ្យមន្ត្រីទាំងនោះយល់ដឹងថា តើត្រូវធ្វើកិច្ចការយ៉ាងដូចម្តេច ដើម្បីជួយជនពិការក្នុងពេលបោះឆ្នោត។

ប៉ុន្តែទោះជាយ៉ាងណា សំណូមពរនេះ ឯកឧត្តម អ៊ឹម សួស្តី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានលើកឡើងថា ការបង្ហាញឈ្មោះជនពិការនៅលើបញ្ជីឈ្មោះបោះឆ្នោតសម្រាប់នីតិកាលនេះ គឺមិនអាចធ្វើបាននោះទេ ដោយសារតែបញ្ជីឈ្មោះបោះឆ្នោត្រូវបានផ្តល់សុពលភាពរួចរាល់ហើយ។ ប៉ុន្តែគ.ជ.ប បានធ្វើការណែនាំដល់មន្ត្រីលេខាធិការដ្ឋានរាជធានី/ខេត្តរៀបចំការបោះឆ្នោតឲ្យពិចារណា និងពិនិត្យមើលថា តើត្រូវជួយដល់ជនពិការយ៉ាងដូចម្តេចនៅថ្ងៃបោះឆ្នោតនាពេលខាងមុខនេះ។ ជាពិសេស គ.ជ.ប បានរៀបចំសឺម៉ីសំរាប់ជនពិការភ្នែកនៅទូទាំងប្រទេស។

សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានធ្វើការសង្កេត ប្រមូលព័ត៌មានអំពីការចូលរួមរបស់ក្រុមជនពិការ និងដាក់ពង្រាយអ្នកសង្កេតការណ៍រយៈពេលវែងចំនួន២នាក់ និងអ្នកសង្កេតការណ៍រយៈពេលខ្លីចំនួន២០នាក់ ក្នុងសង្កាត់រកាធំ ក្រុងច្បារមន និងឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

ពាក់ព័ន្ធទៅនឹងការចុះឈ្មោះ និងពិនិត្យឈ្មោះបោះឆ្នោត តាមការសង្កេត សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ មានប្រជាពលរដ្ឋក្នុងបញ្ជីបោះឆ្នោតសរុប ចំនួន១០,៥៤១នាក់ ដែលក្នុងនោះមានអ្នកចុះឈ្មោះថ្មីចំនួន៩២៦នាក់ ហើយជនពិការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន១៧០នាក់ (ស្ត្រី៨៧នាក់) ហើយសង្កាត់នេះ មាន២០ទីតាំងការិយាល័យបោះឆ្នោត។ តាមការសាកសួរទៅលើជនពិការ ដែលមិនបានទៅ

ពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត បានឲ្យដឹងថាភាគច្រើនមិនបានទទួលព័ត៌មានអំពីការចុះឈ្មោះ និងពិនិត្យឈ្មោះបោះឆ្នោត និងម្យ៉ាងទៀតដោយសារពិបាកក្នុងការធ្វើដំណើរដោយសារពួកគាត់ជាជនពិការ។

ការជ្រើសរើសមន្ត្រីគណកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់ មានការផ្សព្វផ្សាយសេចក្តីជូនដំណឹងនៅតាមសាលាឃុំ និងតាមសាលារៀន តែមិនមានការប្រកាសតាមវិទ្យុ ទូរទស្សន៍ ឬកាសែតនោះទេ។ នៅក្នុងសេចក្តីប្រកាសនោះឃើញថា តម្រូវឲ្យបេក្ខជនមានបទពិសោធន៍ការងារបោះឆ្នោត ហើយក៏មានការលើកទឹកចិត្តដល់ស្ត្រី និងជនពិការចូលរួមដាក់ពាក្យផងដែរ ដោយក្នុងនោះមានការចែកជូនពាក្យដោយឥតគិតថ្លៃ។ ទោះជាបែបនេះក្តី តាមការសង្កេតបានឲ្យដឹងថា ជាទូទៅ មានបេក្ខជនត្រឹមតែ៨ ទៅ១០នាក់ប៉ុណ្ណោះបានដាក់ពាក្យនៅតាមឃុំសង្កាត់នីមួយៗ។ ភាគច្រើននៃបេក្ខជនទាំងនោះ គឺជាអ្នកដែលធ្លាប់បម្រើការងារជាមន្ត្រី គឃ/សបប សម្រាប់ការបោះឆ្នោតមុនៗ ហើយពួកគាត់មានមុខងារជាគ្រូបង្រៀន ឬនាយកនៅតាមសាលារៀនរដ្ឋ។ តាមរបាយការណ៍របស់អ្នកសង្កេតការណ៍ប្រចាំស្រុករបស់អង្គការខុមហ្វ្រែលបានឲ្យដឹងថា មិនមានបេក្ខជនជាជនពិការបានចូលរួមដាក់ពាក្យសម្រាប់មុខតំណែងជាមន្ត្រីគណៈកម្មការខេត្តរៀបចំការបោះឆ្នោតទេ។ ជនពិការចំនួន៩នាក់ ដែលផ្តល់បទសម្ភាសន៍បានលើកហេតុផលស្រដៀងគ្នាថា ខ្លួនគ្មានចំណេះដឹង និងសមត្ថភាពមិនគ្រប់គ្រាន់សម្រាប់មុខតំណែងសំខាន់ៗទាំងនេះ។

ទោះជាយ៉ាងនេះក្តី ក៏អ្នកសង្កេតការណ៍ខុមហ្វ្រែលមិនបានឃើញមានការចូលរួមរបស់ជនពិការនៅក្នុងដំណើរការឃោសនារកសម្លេងឆ្នោតទាំងនោះទេ ហើយគណបក្សនយោបាយនានា ក៏មិនបានលើកឡើងពីគោលនយបាយរបស់គណបក្សខ្លួនដែលយកចិត្តទុកដាក់លើកស្ទួយសិទ្ធិ និងការចូលរួមរបស់ជនពិការដែរ។ ជនពិការ៣នាក់មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ដែលបានសម្ភាសន៍ក្នុងអំឡុងពេលនេះ បានលើកឡើងថា ពួកគាត់មិនឃើញគណបក្សនយោបាយណាមួយមកសួរនាំគាត់ ឬលើកទឹកចិត្តគាត់ឲ្យចូលរួមបោះឆ្នោតនោះទេ ហើយពួកគាត់ក៏មិនបានស្តាប់ឮនូវអ្វីដែលជាការយកចិត្តទុកដាក់លើកស្ទួយសិទ្ធិជនពិការ នៅក្នុងការឃោសនារកសម្លេងឆ្នោតរបស់គណបក្សនយោបាយទាំងនោះដែរ។

ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ អ្នកសង្កេតការណ៍ខុមហ្វ្រែលទាំង២០រូប ត្រូវបានដាក់ពង្រាយនៅតាមការិយាល័យបោះឆ្នោតចំនួន២០ ក្នុងចំណោមទីតាំងការិយាល័យបោះឆ្នោតទាំង ៣៦ នៅក្នុងឃុំស្គុះ និងសង្កាត់រកាធំ ក្នុងខេត្តកំពង់ស្ពឺ ដើម្បីសង្កេតការណ៍ទៅលើការចូលរួមបោះឆ្នោតរបស់ជនពិការ និងភាពមិនប្រក្រតីកើតឡើងនៅតាមការិយាល័យបោះឆ្នោតទាំងនោះ។ ខុមហ្វ្រែលបានរកឃើញថា ជនពិការប្រហែលជា២ ទៅ៣នាក់ប៉ុណ្ណោះ (ក្នុងនោះមានស្ត្រី១នាក់) បានទៅបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោតដែលបានសង្កេតនីមួយៗ លើកលែងតែការិយាល័យលេខ០១១៣ មានអ្នកបោះឆ្នោតជាជនពិការចំនួន១៥នាក់ (ស្ត្រី៧នាក់) ការិយាល័យលេខ០១២៤ មានអ្នកបោះឆ្នោតជាជនពិការចំនួន៨នាក់ (ស្ត្រី២នាក់) និងការិយាល័យលេខ០១១៧ មានអ្នកបោះឆ្នោតជនពិការចំនួន៦នាក់ (ស្ត្រី២នាក់)។ ជនពិការដែលមកបោះឆ្នោតភាគច្រើន ត្រូវបានកូនរបស់គាន់ជូនមក ខ្លះជិះរទេះរុញ ខ្លះកូនដឹកដៃ និងលើកបីយកមកបោះឆ្នោតតែម្តង។ ពួកគាត់ត្រូវបានប្រធានការិយាល័យអនុញ្ញាត និងសម្រួលឲ្យបានបោះឆ្នោតមុនដោយមិនចាំបាច់ឈរតម្រង់ជួរដូចមនុស្សដែលមានកាយសម្បទាធម្មតាទូទៅ។

ក្រោយពីកាលបោះឆ្នោត និងរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់នៅថ្ងៃទី២៩ ខែកក្កដា អ្នកសង្កេតការណ៍

ទាំង២០នាក់ បានបន្តសម្ភាសន៍ជនពិការចំនួន៨០នាក់ ដែលក្នុងនោះមានស្ត្រី២៨នាក់ (៤០នាក់មានទឹកខ្មៅលើម្រាមដៃ និង៤០នាក់ទៀតមិនមានទឹកខ្មៅ) ដោយម្នាក់ៗត្រូវតម្រូវឲ្យសម្ភាសន៍ជនពិការ៤នាក់។ ក្នុងចំណោមអ្នកផ្តល់ចម្លើយទាំង៤០នាក់ មានមូលហេតុ៣សំខាន់ៗ ដែលជម្រុញឲ្យពួកគាត់ទៅបោះឆ្នោត។ ១៧នាក់ បានឆ្លើយថា ពួកគេមានឯកសារគ្រប់គ្រាន់ ហើយមន្ត្រីការិយាល័យបោះឆ្នោតបានបង្កភាពងាយស្រួលឲ្យគាត់បានបោះឆ្នោតមុន ដោយមិនចាំបាច់តម្រង់ជួរ។ ១៣ នាក់ បានឆ្លើយថា ពួកគាត់ទៅបោះឆ្នោតដើម្បីបំពេញសិទ្ធិ និងកាតព្វកិច្ចជាពលរដ្ឋ ខណៈពេលដែលជនពិការ១០នាក់ បានឆ្លើយថា គាត់ទៅបោះឆ្នោត ព្រោះវាមានសារៈសំខាន់ហើយគាត់ចង់ឃើញមានការផ្លាស់ប្តូរតាមរយៈការបោះឆ្នោត។ ជាក់ស្តែងលោកអ៊ុំស្រី ហុង ម៉ុម អាយុ៦៩ឆ្នាំ រស់នៅក្នុងសង្កាត់រកាធំ ក្រុងច្បារមន បានមានប្រសាសន៍ថា ខ្ញុំត្រូវបានមន្ត្រីការិយាល័យបោះឆ្នោតជួយសម្រួលឲ្យបានបោះមុនគេ ហើយខ្ញុំមកបោះឆ្នោតនេះ គឺខ្ញុំចង់បំពេញតួនាទីជាពលរដ្ឋខ្មែរ និងចង់ជ្រើសរើសមេដឹកនាំដែលខ្ញុំពេញចិត្ត។

**រូបភាពទី៩៖ ការចូលរួមរបស់ជនពិការក្នុងការបោះឆ្នោត**



## ១១.៥ ការចូលរួមរបស់ជនជាតិដើមភាគតិច

ខុមហ្វ្រែលបានធ្វើការសិក្សាមួយនៅតំបន់ឥសាន្តដែលមានជនជាតិដើមភាគតិចរស់នៅច្រើន ហើយនៅក្នុងនោះដែរ ខុមហ្វ្រែលសង្កេតឃើញថា ការចូលរួមរបស់ជនជាតិដើមភាគតិចនៅមានកំរិតតិចតួចនៅឡើយ ដូចជា មានតែជនជាតិដើមមួយរូបតែប៉ុណ្ណោះដែលបានជាប់ជាសមាជិកគណកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ដែលមានតួនាទីជាសមាជិកទទួលបន្ទុកការងារបណ្តុះបណ្តាល អប់រំសាធារណៈ និងព័ត៌មានសាធារណៈ នៅសង្កាត់រមនា ខេត្តមណ្ឌលគិរី។ ដោយឡែកនៅឃុំអូរជុំ ខេត្តរតនគិរី ជនជាតិដើមភាគតិចភាគច្រើនបានជាប់ជាសមាជិកគណកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត (គឃ/សប)។

ខុមហ្វ្រែលបានសហការជាមួយអង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (ICSO) ក្នុងការផលិតស្ពតអប់រំដើម្បីលើកទឹកចិត្តឲ្យជនជាតិដើមភាគតិចចូលរួមការបោះឆ្នោត២០១៣។

ចំពោះការជ្រើសរើសគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ខុមហ្វ្រែលបានសង្កេតឃើញថា នៅក្នុងសង្កាត់រមនា និងឃុំអូរជុំ មានអ្នកដាក់ពាក្យចូលបំរើការងារមិនបានគ្រប់ចំនួនតាមការកំណត់នោះទេសម្រាប់តំណែងនីមួយៗ នៃតំណែងទាំង ៥ (បើយោងតាមនីតិវិធី គឺត្រូវរើសយក ៣នាក់សម្រាប់ ១តំណែង)។ នៅក្នុងសង្កាត់រមនា អ្នកដែលបានដាក់ពាក្យបំរើការងារជាគឃ/សប មានតែចំនួន៧

នាក់ (ស្ត្រី ៦ នាក់) នៅក្នុងនោះ មានបេក្ខជនជាជនជាតិដើមភាគតិចចំនួន ១ នាក់ បានជាប់បម្រើការងារជាសមាជិក គឃ/សប មានតួនាទីជាសមាជិកទទួលបន្ទុកការងារបណ្តុះបណ្តាល អប់រំសាធារណៈ និងព័ត៌មានសាធារណៈ។ ដោយឡែកនៅក្នុងឃុំអូរជុំ ស្រុកអូរជុំ ខេត្តរតនគីរី អ្នកដែលបានដាក់ពាក្យ និងជាប់ជាសមាជិក គឃ/សប ភាគច្រើនជាជនជាតិដើមភាគតិច នៅក្នុងនោះមានជនជាតិដើមភាគតិចចំនួន ៤ នាក់ បានជាប់បម្រើការងារជាសមាជិក គឃ/សប ក្នុងចំណោមមុខដំណែងទាំង ៥។

រយៈពេលយុទ្ធនាការឃោសនាបោះឆ្នោត មានរយៈពេល ៣០ គឺចាប់ផ្តើមពីថ្ងៃទី២៧ ខែ មិថុនា ដល់ថ្ងៃទី២៦ខែកក្កដា ឆ្នាំ២០១៣។ ក្នុងដំណាក់កាលនេះ នៅសង្កាត់រមនា និងឃុំអូរជុំ ក្នុងខេត្តរតនគីរី មានគណបក្សនយោបាយចំនួន ២ បានធ្វើសកម្មភាពឃោសនារកសំឡេងឆ្នោតនៅទីនោះ គឺមានគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។ នៅក្នុងនោះដែ រក៏សង្កេតឃើញមានការចូលរួមសកម្មភាពឃោសនាជាច្រើនពីជនជាតិដើមភាគតិចផងដែរ ពីព្រោះនៅតំបន់នេះប្រជាពលរដ្ឋភាគច្រើនជាជនជាតិដើមភាគតិច។

ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ជាថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅក្នុងដំណាក់កាលនេះ ខុមហ្វ្រែលបានដាក់អ្នកសង្កេតការណ៍ចំនួន ២ ការិយាល័យ ដោយក្នុងនោះបានសង្កេតឃើញថា នៅក្នុងឃុំអូរជុំ សង្កេតឃើញមានជនជាតិដើមភាគតិចបានចេញទៅបោះឆ្នោតប្រហែល ៦០% នៃប្រជាពលរដ្ឋរស់នៅឃុំនេះ។ ចំណែកឯនៅសង្កាត់រមនា សង្កេតឃើញមានជនជាតិដើមភាគតិចចេញទៅបោះឆ្នោតប្រហែល ៦២% នៃប្រជាពលរដ្ឋរស់នៅសង្កាត់នេះ។

បើតាមការសម្ភាសន៍ជាមួយប្រជាពលរដ្ឋជាជនជាតិដើមភាគតិច ដែលបានទៅបោះឆ្នោត ពួកគាត់ភាគច្រើនបានឲ្យដឹងថា មូលហេតុដែលនាំអោយពួកគាត់ចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៣ គឺចង់មានអ្នកដឹកនាំល្អ មូលដ្ឋានមានការរីកចំរើន និងអភិវឌ្ឍន៍ និងបំពេញតួនាទីជាប្រជាពលរដ្ឋ។

យ៉ាងណាមិញ នៅថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ សម្រាប់ប្រជាពលរដ្ឋដែលចេញទៅបោះឆ្នោតនៅឃុំសង្កាត់ទាំងពីរនេះប្រមាណ៦០%។

បើពិនិត្យទៅលើចំនួនសន្លឹកឆ្នោតមិនបានការវិញឃើញថា មណ្ឌលដែលមានសន្លឹកឆ្នោតមិនបានការច្រើន គឺភាគច្រើននៅតំបន់ប៉ែកឥសាន្តដូចជាមណ្ឌលរតនគីរី មណ្ឌលមណ្ឌលគីរី មណ្ឌលស្ទឹងត្រែង និងមណ្ឌលកោះកុង ដែលភាគច្រើនជាមណ្ឌលដែលមានជនជាតិដើមភាគតិចរស់នៅច្រើន។

### ១១.៦ អ្នកចេញទៅបោះឆ្នោត និងការបាត់បង់សិទ្ធិ

តារាងទី៦៖ ការចូលរួមរបស់ប្រជាពលរដ្ឋពីឆ្នាំ១៩៩៣ ដល់ ២០១៣

| | 1993 | 1998 | 2002 | 2003 | 2007 | 2008 | 2012 | 2013 |
|---|---|---|---|---|---|---|---|---|
| **Eligible voters** | 4,654,000 | 5,488,029 | 6,251,832 | 6,749,876 | 7,291,084 | 7,828,161 | 8,894,219 | 9,509,732 |
| **Registered voters** | 4,764,430 | 5,395,595 | 5,190,307 | 6,341,834 | 7,799,371 | 8,125,529 | 9,203,493 | 9,675,453 |
| **Registered** | **102%** | **98%** | **83%** | **94%** | **107%** | **104%** | **104%** | **101%** |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| voters | | | | | | | | |
| Voter turnout | 4,267,192 | 5,057,830 | 4,543,974 | 5,277,494 | 5,293,327 | 6,100,884 | 5,993,992 | 6,735,244 |
| **Voter turnout** | **89.56%** | **93.74%** | **87.55%** | **83.22%** | **67.87%** | **75.08%** | **65.13%** | **69.61%** |

តារាងទី៦៖ បង្ហាញថា ចំនួននៃប្រជាពលរដ្ឋដែលបានចេញទៅបោះឆ្នោតបានកើនឡើងក្នុងឆ្នាំបោះឆ្នោតនីមួយៗ (លើកលែងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់)។ ទោះបីជាយ៉ាងណា ការចេញទៅបោះឆ្នោតរបស់ប្រជាពលរដ្ឋមានតែ៦៩% បើធៀបនឹងឆ្នាំ១៩៩៣មាន ៨៩%។ បញ្ហាបញ្ជីឈ្មោះ និងភាពមិនប្រក្រតីមួយចំនួនដែលកើតឡើងនៅថ្ងៃបោះឆ្នោតបានធ្វើឲ្យប្រជាពលរដ្ឋភាគច្រើនបាត់បង់នូវសិទ្ធិបោះឆ្នោតដូចជា ការលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីបោះឆ្នោត ការមិនទទួលបានប័ណ្ណព័ត៌មានបោះឆ្នោត និងឯកសារសម្រាប់ការបោះឆ្នោតផ្សេងទៀត។

ខុមហ្វ្រែលរកឃើញថា មាន៤៨,៣%នៃអ្នកអត់បោះឆ្នោត(អ្នកមិនមានទឹកខ្មៅលើចង្អុលដៃ) បានទៅដល់ការិយាល័យបោះឆ្នោត ប៉ុន្តែពួកគេមិនអាចបោះឆ្នោត ដោយសារជួបឧបសគ្គ និងបញ្ហាមួយចំនួនដូចជា ការរកឈ្មោះក្នុងបញ្ជីបោះឆ្នោតមិនឃើញ គ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត រកការិយាល័យមិនឃើញ គ្មានឯកសារបញ្ជាក់អត្តសញ្ញាណប្រើក្នុងការបោះឆ្នោត និងមានឯកសារគ្រប់គ្រាន់តែខុសទិន្នន័យ។ ៤១,៥%នៃអ្នកមិនបានបោះឆ្នោតបានលើកឡើងថា ចង់ទៅបោះឆ្នោត ប៉ុន្តែពួកគេមិនបានទៅ ដោយសាមិនបានចុះឈ្មោះបោះឆ្នោត មានជំងឺ ជាប់រវល់កិច្ចការងារផ្ទះ មិនបានទទួលព័ត៌មាន ចំណាយថវិកាច្រើនទៅបោះឆ្នោត ព្រមទាំងមិនបានទទួលប័ណ្ណព័ត៌មាន ហើយគិតថា គ្មានសិទ្ធិបោះឆ្នោត។ ចំណែកឯ១០,២% នៃម្ចាស់ឆ្នោតដែលមិនបានបោះឆ្នោតដែលពួកគាត់មិនចង់ទៅបោះឆ្នោត ដោយសារជាប់រវល់ ការបោះឆ្នោតមិនមានសារៈសំខាន់ មិនចូលចិត្តគណបក្ស និងបេក្ខជនដែលឈរឈ្មោះ និងមានគេប្រាប់មិនឲ្យទៅបោះឆ្នោត។

ក្រាហ្វិកទី៤៖ មូលហេតុដែលម្ចាស់ឆ្នោតមិនបានបោះឆ្នោត




នៅក្នុងការស្រាវជ្រាវនេះដែរ ស្ត្រីចំនួន២,០២៦នាក់ ស្មើនឹង ៥២,៤%នៃអ្នកសម្ភាសន៍សរុប ៤,១០៣នាក់។ ក្នុងចំណោមស្ត្រីដែលមិនបានបោះឆ្នោត(អ្នកដែលមិនមានទឹកខ្មៅនៅម្រាមដៃ) មាន៤៩%នៃ

ស្ត្រីមិនបានបោះឆ្នោតបានលើកឡើងថា ពួកគាត់បានទៅដល់ការិយាល័យដែរ ប៉ុន្តែមិនបានបោះឆ្នោត ដោយសារតែជួបឧបសគ្គដូចជា ការរកឈ្មោះក្នុងបញ្ជីបោះឆ្នោតមិនឃើញ គ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត រកការិយាល័យបោះឆ្នោតមិនឃើញ គ្មានឯកសារប្រើក្នុងការបោះឆ្នោត និងមានឯកសារគ្រប់គ្រាន់តែខុសទិន្នន័យ។ ៤១,៧%នៃស្ត្រីមិនបានបោះឆ្នោត បានលើកឡើងថា ពួកគេចង់ទៅបោះឆ្នោត ប៉ុន្តែមិនបានទៅ ដោយសារមិនបានចុះឈ្មោះបោះឆ្នោត ជាប់រវល់កិច្ចការផ្ទះ។ ៩%នៃស្ត្រីមិនបានបោះឆ្នោត បានលើកឡើងថា ពួកគេមិនចង់ទៅបោះឆ្នោត ដោយសារជាប់រវល់ ការបោះឆ្នោតមិនមានសារៈសំខាន់។

ចំណែកឯការមិនបានទៅបោះឆ្នោតរបស់យុវជនវិញ ក្នុងចំណោមយុវជន៥០,៦% ដែលបានផ្តល់បទសម្ភាសន៍ បានផ្តល់មូលហេតុដូចជា ៤៥,៥%នៃយុវជនដែលមិនបានបោះឆ្នោត បានលើកឡើងថា ពួកគេបានទៅដល់ការិយាល័យបោះឆ្នោត ប៉ុន្តែជួបឧបសគ្គមិនបានបោះឆ្នោត ដោយសារមូលហេតុមួយចំនួនដូចជា គ្មានឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត រកឈ្មោះបោះឆ្នោតមិនឃើញ(បាត់ឈ្មោះពីបញ្ជី) ខុសទិន្នន័យនៅក្នុងបញ្ជីបោះឆ្នោត មិនមានប័ណ្ណព័ត៌មានបោះឆ្នោត មន្ត្រីការិយាល័យមិនអនុញ្ញាតឲ្យបោះឆ្នោត និងការិយាល័យមានភាពច្របូកច្របល់។ ៤៥%នៃយុវជនមិនបានបោះឆ្នោត បានលើកឡើងថា មានបំណងចង់ទៅបោះឆ្នោត ប៉ុន្តែមិនបានទៅបោះឆ្នោត ដោយសារមិនបានទៅចុះឈ្មោះបោះឆ្នោត នៅឆ្ងាយពីទីតាំងដែលត្រូវបោះឆ្នោត ជាប់រវល់ការងារ ឬការសិក្សា ត្រូវចំណាយថវិកាច្រើនដើម្បីទៅបោះឆ្នោត រថយន្តឈ្នួលឡើងថ្លៃ មិនបានទទួលប័ណ្ណព័ត៌មានបោះឆ្នោតហើយគិតថា ខ្លួនគ្មានសិទ្ធិបោះឆ្នោត។ ៩,៥%នៃយុវជនមិនបានបោះឆ្នោត បានលើកឡើងថាពួកគេមិនចង់ទៅបោះឆ្នោត ដោយសារពួកគេគិតថាទៅបោះឆ្នោតដើម្បីអ្វី(មិនមានសារៈសំខាន់) មិនចូលចិត្តគណបក្ស និងបេក្ខជនដែលឈរឈ្មោះបោះឆ្នោត និងមានគេប្រាប់មិនឲ្យទៅបោះឆ្នោត។

តាមចម្លើយរបស់អ្នកផ្តល់បទសម្ភាសន៍ទាំង៤០នាក់ ដែលមិនបានទៅបោះឆ្នោតកាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៣ បានបង្ហាញឲ្យឃើញថា ១៦នាក់បានឆ្លើយថា ពួកគេមិនចេញទៅបោះឆ្នោតដោយសារចាស់ជរា និងមានជំងឺប្រចាំកាយមិនអាចទៅបោះឆ្នោតបាន)។ ជាក់ស្តែងដូចជាករណីលោកយាយ គាំ ឧន អាយុ៧៥ឆ្នាំ រស់នៅក្នុងសង្កាត់រកាធំ ជាជនពិការភ្នែកទាំងពីរ។ លោកយាយបានលើកឡើងថា លោកយាយមិនបានទៅបោះឆ្នោតលោកយាយចាស់ជរាដើរមិនរួច ហើយកូនគាត់រវល់ធ្វើការនៅឆ្ងាយ។ បន្ថែមពីនេះទៀត អ៊ុំស្រី ជា អាយុ៤៦ឆ្នាំ ជាជនពិការជើងខាងឆ្វេង បានមានប្រសាសន៍ថា គាត់មិនបានបោះឆ្នោតទេ ដោយសារតែគាត់មិនឃើញមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមិនបានទទួលបានប័ណ្ណព័ត៌មានអ្នកបោះឆ្នោតផងដែរ។ អ៊ុំស្រីឆ្ងល់ណាស់ថា ហេតុអ្វីបានជាគាត់មិនមានឈ្មោះបោះឆ្នោតហ្នឹងគេ បើគាត់ទើបតែបានបោះឆ្នោតរួចកាលពីឆ្នាំ២០១២។

ចំណែកជនជាតិដើមភាគតិចមិនបានបោះឆ្នោតចំនួន៥៣ នាក់ ដែលបានផ្តល់បទសម្ភាសន៍បានបង្ហាញថា មូលហេតុសំខាន់មិនបានបោះឆ្នោតដោយសារ ពួកគេមិនបានចុះឈ្មោះបោះឆ្នោត និងការរកឈ្មោះរបស់ពួកគេនៅក្នុងបញ្ជីឈ្មោះឆ្នោតមិនឃើញ។

ជាមួយគ្នានោះដែរខុមហ្វ្រែលក៏បានធ្វើការសម្ភាសន៍ជាមួយក្រុមជនបណ្តេញចេញ ចំនួន ៣៩ នាក់ (ស្រីចំនួន២១នាក់) ដែលមិនបានទៅបោះឆ្នោត នៅក្នុងនោះពួកគាត់បានឆ្លើយថា មានកត្តាសំខាន់ៗមួយ

ចំនួនដូជា ទី១.រកឈ្មោះមិនឃើញ ទី២.គ្មានឯកសារបញ្ជាក់អត្តសញ្ញាណ និងទី៣.ខុសទិន្នន័យ ហើយមន្ត្រីការិយាល័យមិនអនុញ្ញាតឲ្យបោះឆ្នោត។

ការសិក្សាស្រាវជ្រាវអ្នកមិនបានបោះឆ្នោតនេះ ខុមហ្វ្រែលបានធ្វើការសិក្សាស្រាវជ្រាវតាមលក្ខណបច្ចេកទេសកុំព្យូទ័រស្ថិតិតាមចំនួនការិយាល័យក្នុងមណ្ឌលនីមួយៗចំនួន១,៤៧០ការិយាល័យជាការិយាល័យសំណាកចេញពីការិយាល័យសរុបទូទាំងប្រទេស១៩,០០៩ការិយាល័យ។ ការិយាល័យសំណាកត្រូវបានកំណត់ចេញពីអ្នកបានចុះឈ្មោះបោះឆ្នោតសំណាកសរុប៦៨៧,០៧៩នាក់ ក្នុងចំណោមអ្នកបានចុះឈ្មោះបោះឆ្នោតសរុបចំនួន៩,៦៧៥,៤៥៣នាក់។ ការសិក្សាស្រាវជ្រាវនេះ អ្នកសង្កេតការណ៍ខុមហ្វ្រែលម្នាក់ត្រូវសម្ភាសន៍អ្នកដែលមិនបានទៅបោះឆ្នោត ឬអ្នកមិនមានទឹកខ្មៅនៅម្រាមដៃពី៤ទៅ៦នាក់នៅថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

យោងតាមការចុះផ្សាយកាលពីថ្ងៃទី០៦ ខែសីហា ឆ្នាំ ២០១៣ របស់កាសែតឌឹខេមបូឌាដេលី គណបក្សសង្គ្រោះជាតិបានទទួលពាក្យបណ្តឹងពាក់ព័ន្ធនឹងការបាត់សិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋកម្ពុជាចំនួន ១៨,៤០០ ពាក្យបណ្តឹង។ ក្នុងចំណោមពាក្យបណ្តឹងខាងលើ ខុមហ្វ្រែលបានយកពាក្យបណ្តឹងចំនួន ១០៦ ពាក្យបណ្តឹង មកធ្វើការសិក្សា នៅក្នុងនោះយើងសង្កេតឃើញថា មានបណ្តឹងចំនួន៦៧ទាក់ទងទៅនឹងការបាត់ឈ្មោះអ្នកបោះឆ្នោតពីបញ្ជីបោះឆ្នោត ៣បណ្តឹងទាក់ទងទៅនឹងមន្ត្រីការិយាល័យមិនអនុញ្ញាតឲ្យបោះឆ្នោតដោយសារមិនមានប័ណ្ណព័ត៌មាន និង៤បណ្តឹងទៀតទាក់ទងទៅនឹងឈ្មោះរបស់ពួកគេត្រូវបានអ្នកផ្សេងបោះជំនួស។

## ១២. ការចូលរួមរបស់គណបក្សនយោបាយ

### ១២.១ ការថយចុះចំនួនគណបក្សនយោបាយក្នុងការប្រកួតប្រជែង

បើយោងតាមតារាងខាងលើ ចាប់តាំងពីឆ្នាំ២០០៣មក ការចូលរួមរបស់គណបក្សនយោបាយក្នុងការប្រកួតប្រជែងសំរាប់ការបោះឆ្នោតកាន់តែមានការថយចុះ។ មានកត្តាជាច្រើនដែលនាំឲ្យមានការថយចុះចំនួនគណបក្សនយោបាយក្នុងការប្រកួតប្រជែងការបោះឆ្នោត។ សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ឆ្នាំ២០១៣នេះ មានគណបក្សនយោបាយចំនួន៨ប៉ុណ្ណោះបានចុះឈ្មោះសម្រាប់ការប្រកួតប្រជែងដែលក្នុងនោះមាន គណបក្សប្រជាជនកម្ពុជា គណបក្សសញ្ជាតិកម្ពុជា គណបក្សហ្វ៊ុនស៊ិនប៉ិច គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សសង្គ្រោះជាតិ គណបក្សខ្មែរឈប់ក្រ និងគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច។

ការវិវត្តន៍ចុងក្រោយនៃគណបក្សនយោបាយមួយចំនួន តាមរយៈការរួបរួមគ្នាបានធ្វើឲ្យគណបក្សសម រង្ស៊ី គណបក្សសិទ្ធិមនុស្ស និងគណបក្សជាតិនិយម (អតីតគណបក្សនរោត្តមរណឫទ្ធិ) នឹងមិនចូលរួមដាក់បេក្ខជនប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ខាងមុខនេះទេ ព្រោះថាពួកគេនឹងឈរឈ្មោះក្នុងបញ្ជីបេក្ខជនតំណាងរាស្ត្ររួមគ្នា ដូចជាគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សនឹងឈរឈ្មោះក្នុងបញ្ជីបេក្ខជនតំណាងរាស្ត្ររបស់គណបក្សសង្គ្រោះជាតិ។ ចំណែកឯគណបក្សជាតិនិយមវិញនឹងឈរឈ្មោះក្នុងបញ្ជីបេក្ខជនតំណាងរាស្ត្ររបស់គណបក្សហ្វ៊ុនស៊ិនប៉ិច។

មានការលើកឡើងរបស់គណបក្សនយោបាយមួយចំនួន ដែលធ្លាប់បានចុះឈ្មោះក្នុងការប្រកួតប្រជែងសម្រាប់ការបោះឆ្នោតមុនៗ ហើយមានការស្ទាក់ស្ទើរក្នុងការចូលរួមក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ឆ្នាំ២០១៣ ដោយសារតែមានបញ្ហាមួយចំនួនដែលគិតថា មិនទាន់មានយុត្តិធម៌ក្នុងដំណើរការបោះឆ្នោត ដូចជាប្រព័ន្ធផ្សព្វផ្សាយមិនស្មើភាព (ព្រោះការអនុវត្តកន្លងមកគណបក្សមាននិន្នាការមិនស្របគណបក្សកាន់អំណាច ជាពិសេសមិនអាចសុំបើកស្ថានីយវិទ្យុ ឬទូរទស្សន៍បាន) បញ្ហាគំរាមកំហែង/រើសអើង បញ្ហាភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត (អតីតទម្រង់១០១៨) បញ្ហាទិញទឹកចិត្តអ្នកបោះឆ្នោតតាមរយៈអំណោយ បញ្ហានៃការចំណាយធនធានថវិកាលើសលុបរបស់គណបក្សធំៗក្នុងកំឡុងពេលឃោសនាបោះឆ្នោត (ដោយសារកម្ពុជាមិនទាន់មានច្បាប់ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយ)។ ដោយឡែកបញ្ហារូបមន្តនៃការគណនាអាសនៈ ហាក់មិនមានភាពយុត្តិធម៌សម្រាប់គណបក្សតូចៗ ជាពិសេសមិនមានការលើកទឹកចិត្តពីរដ្ឋ និងអាជ្ញាធរគ្រប់លំដាក់ថ្នាក់ស្របតាមមាត្រា៤នៃច្បាប់ស្តីពីគណបក្សនយោបាយ។ ការដោះស្រាយបណ្តឹងមិនយុត្តិធម៌ ដែលគួរតែមានស្ថាប័នឯករាជ្យផ្សេងទៀតជាអ្នកដោះស្រាយ និងពិនិត្យការងាររបស់គ.ជ.ប និងការមិនទុកចិត្តក្នុងការយកធនធានរបស់រដ្ឋបំរើឲ្យគណបក្សកាន់អំណាច។

ចំណែកឯនីតិវិធីក្នុងការចុះបញ្ជីបេក្ខជនគណបក្សនយោបាយមានភាពស្មុគស្មាញ ដូចជារយៈពេលនៃការចុះបញ្ជីបេក្ខជន ព្រមទាំងការតម្រូវឲ្យតម្កល់ប្រាក់ជាមុនក្នុងរតនាគារជាតិចំនួនដប់ប្រាំលាន (១៥,០០០,០០០រៀល) ហើយប្រាក់តម្កល់នេះត្រូវបានបង្វិលជូនទៅសាមីគណបក្សនយោបាយវិញ ក្នុងករណីដែលគណបក្សនយោបាយនោះបានទទួលសន្លឹកឆ្នោតយ៉ាងតិចបីភាគរយ(៣%) នៃចំនួនសន្លឹកឆ្នោតបានការ ឬបានអាសនៈមួយក្នុងរដ្ឋសភា។

ឧបសគ្គទាំងអស់ខាងលើនេះ ដែលជំរុញឲ្យការចូលរួមរបស់គណបក្សដែលមិនមានអាសនៈក្នុងរដ្ឋសភាមួយចំនួនមិនចូលរួមប្រកួតប្រជែងសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ឆ្នាំ២០១៣ ដោយមានការថយចុះជាងការបោះឆ្នោតឆ្នាំមុនៗ

## ១២.២ ការកើនឡើងនៃចំនួនបេក្ខជនស្ត្រី

យោងតាមលទ្ធផលផ្លូវការនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះ និងបញ្ជីបេក្ខជនរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥នេះ បេក្ខជនស្ត្រីពេញសិទ្ធិមានចំនួន ១៦៨នាក់ (១៨,៩៦%) នៃចំនួនបេក្ខជនប្រុស ស្រីសរុប៨៨៦នាក់។ តួលេខនេះមានការកើន ៤,១៦% ពី១៤,៨០% (នីតិកាលទី៤ ឆ្នាំ២០០៨) ទៅ១៨,៩៦% (នីតិកាលទី៥ ឆ្នាំ២០១៣) ប៉ុន្តែវានៅតែជាចំនួនតិចតួចនៅឡើយដែលមិនទាន់បានសម្រេចដល់គោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា (CMDG) ដែលបានកំណត់ថានៅឆ្នាំ២០១៥ មន្ត្រីជាប់ឆ្នោតជាស្ត្រីនៅថ្នាក់ជាតិយ៉ាងតិច៣០%។

មុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រនីតិកាលទី៥ បើទោះបីជាមានការធ្វើយុទ្ធនាការតាមរយៈសិក្ខាសាលា កិច្ចពិភាក្សាតុមូល កិច្ចសន្ទនា និងចេញសេចក្ដីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិល[13] ដើម្បីបញ្ចុះបញ្ចូលគណបក្សនយោបាយ និងគ.ជ.ប ក្នុងការដាក់បេក្ខភាពស្ដ្រីឈរឈ្មោះបោះឆ្នោតនៅលេខរៀងខាងលើយ៉ាងយោច ៣០% ដើម្បីផ្ដល់ឱកាសដល់ស្ដ្រីមានលទ្ធភាពជាប់ឆ្នោត និងដាក់ប្រព័ន្ធកូតានៅក្នុងច្បាប់បោះឆ្នោត។

ជាសរុប តួលេខក្នុងការដាក់បេក្ខជនស្ដ្រីឈរឈ្មោះ បើទោះបីជាមានការកើនឡើង ប៉ុន្តែលទ្ធភាពដែលអាចឲ្យស្ដ្រីជាប់ឆ្នោតច្រើន នៅក្នុងកំរិតគួរឲ្យកត់សំគាល់ ដោយសារតែគណបក្សនយោបាយពីរដែលមានប្រជាប្រិយភាព ហើយសង្ឃឹមថា នឹងអាចទទួលបានអាសនៈនៅក្នុងរដ្ឋសភា ហាក់មិនលើកទឹកចិត្តក្នុងការដាក់បេក្ខជនស្ដ្រីនៅក្នុងបញ្ជីបេក្ខជនរបស់គណបក្ស។ នៅក្នុងការដាក់បេក្ខជនឈរឈ្មោះបោះឆ្នោតនេះដែរ គណបក្សនយោបាយចំនួនពីរគឺគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសង្គ្រោះជាតិបានដាក់បេក្ខជនស្ដ្រីឈរឈ្មោះតិចជាងគេប្រមាណ ១២នាក់ ស្មើនឹង៩,៧៥% ក្នុងចំណោម៨គណបក្សនយោបាយដែលបានចុះបញ្ជីចូលរួមប្រកួតប្រជែងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រនីតិកាលទី៥ឆ្នាំ២០១៣។ ប៉ុន្តែការដាក់បេក្ខជនស្ដ្រីឈរឈ្មោះនៅក្នុងការបោះឆ្នោតរបស់គណបក្សហ៊្វុនស៊ិនប៉ិចមានការកើនឡើង ២% បើធៀបទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រនីតិកាលទី៤ឆ្នាំ២០០៨ មានតែ៨%។ រីឯគណបក្សសង្គ្រោះជាតិដែលទើបបង្កើតថ្មីក្នុងការរួមបញ្ចូលរវាងគណបក្សពីរគឺគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សបានដាក់បេក្ខជនស្ដ្រីតិចតួចបំផុតតែ១២នាក់ ស្មើនឹង៩,៧៥% ដែលមានការថយចុះចំនួន១១នាក់បើប្រៀបធៀបនឹងនីតិកាលទី៤ ឆ្នាំ២០០៨ គណបក្សទាំងពីរនេះបូកបញ្ចូលគ្នាបេក្ខជនស្ដ្រីមានចំនួន២៣នាក់(គណបក្សសមរង្ស៊ី ១៧នាក់ ស្មើនឹង១៣,៨២% និងគណបក្សសិទ្ធិមនុស្ស៦នាក់ស្មើនឹង៤,៨៧%។ ចំណែកឯការដាក់បេក្ខជនស្ដ្រីរបស់គណបក្សប្រជាជនកម្ពុជាមិនមានអ្វីប្រែប្រួលទេគឺនៅប្រមាណ១៦% ដដែលសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រនីតិកាលទី៥ឆ្នាំ២០១៣ បើធៀបនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រនីតិកាលទី៤ឆ្នាំ២០០៨។

គណបក្សសញ្ជាតិកម្ពុជាបានដាក់បេក្ខជនស្ដ្រីពេញសិទ្ធិចំនួន២១នាក់ ស្មើនឹង១៧% ហើយគណបក្សសាធារណរដ្ឋប្រជាធិបតេយ្យបានដាក់បេក្ខជនស្ដ្រីពេញសិទ្ធិចំនួន៣៧នាក់ ស្មើនឹង៣៥% ចំណែកឯខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ចបានដាក់២០នាក់ ស្មើនឹង៤៤% (ក្នុងចំណោមបេក្ខជនពេញសិទ្ធិសរុបនៅក្នុងគណបក្សខ្លួន)។ រីឯគណបក្សខ្មែរឈប់ក្រដាក់ចំនួន៣១នាក់ ស្មើនឹង២៥% និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យបានដាក់បេក្ខជនស្ដ្រីពេញសិទ្ធិ១៥នាក់ ស្មើនឹង១២%។ បើតាមតួលេខនេះ គណបក្សតូចៗ ឬគណបក្សដែលពុំសូវមានប្រជាប្រិយភាពបានដាក់បេក្ខជនស្ដ្រីក្នុងបញ្ជីបេក្ខជនមានចំនួនច្រើនជាងគណបក្សដែលមានប្រជាប្រិយភាពដែលសង្ឃឹមថានឹងទទួលបានអាសនៈក្នុងរដ្ឋសភា។

ចំនួនបេក្ខជនស្ដ្រីដែលមានភាគរយច្រើនជាងគេនៅតាមបណ្ដាខេត្តចំនួន១០ ដូចជាខេត្តមណ្ឌលគិរី ៣៣,៣៣%, ខេត្តកណ្ដាល ២៩,៥៤%, ខេត្តកោះកុង ២៨,៥៧%, ខេត្តរតនគិរី ២៨,៥៧%, ខេត្តស្វាយរៀង

13

២៥,៧១%, រាជធានីភ្នំពេញ ២៥%, ខេត្តបាត់ដំបង ២៣,២១%, ខេត្តពោធិសាត់ ២១,៨៧%, ខេត្តកំពង់ឆ្នាំង ២១,៨៧%, និងខេត្តកំពង់ធំ ២០,៨៣%។

## ១៣. ការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការសង្កេតការណ៍បោះឆ្នោត

### ១៣.១ អ្នកសង្កេតការណ៍ជាតិ

តារាងទី៤៖ ចំនួនអ្នកសង្កេតការណ៍ជាតិ

| | 1993 | 1998 | 2002 | 2003 | 2007 | 2008 | 2012 | 2013 |
|---|---|---|---|---|---|---|---|---|
| អង្គការ | N/A | 18 | N/A | 102 | 33 | 72 | 24 | 35 |
| អ្នកសង្កេតការណ៍ | N/A | 83,665 | 39,948 | 29,637 | 19,121 | 31,262 | 14,778 | 40,287 |

សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ យោងតាមរបាយការណ៍របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានចេញកាតសង្កេតការណ៍សម្រាប់អ្នកសង្កេតការណ៍ជាតិប្រមាណ៤០,២៨៧នាក់ ដោយក្នុងនោះមានអ្នកសង្កេតការណ៍ចល័តប្រមាណ១៤៥នាក់ ដោយចេញពីអង្គការស្ថាប័នចំនួន៣៥។ ដោយឡែកគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សក៏បានដាក់អ្នកសង្កេតការណ៍ជាតិនៅក្នុងការបោះឆ្នោតនេះដែរ។

### ១៣.២ អ្នកសង្កេតការណ៍អន្តរជាតិ

បើធៀបទៅនឹងការបោះឆ្នោងអាណត្តិមុនៗ ចំនួនអ្នកសង្កេតការណ៍អន្តរជាតិមានការថយចុះយ៉ាងច្រើនមកត្រឹមតែ២៩២នាក់សម្រាប់ការបោះឆ្នោតក្នុងឆ្នាំ២០១៣នេះ ជាពិសេសសហភាពអឺរ៉ុបពុំបានបញ្ជូនអ្នកសង្កេតការណ៍មកសង្កេតក្នុងឆ្នាំបោះឆ្នោតនេះទេ នេះក៏ដោយសារតែអនុសាសន៍ដែលក្រុមអ្នកសង្កេតការណ៍របស់ខ្លួនបានធ្វើឡើងកាលពីឆ្នាំ២០០៨ មិនត្រូវបានទទួលយក។ ដូច្នេះហើយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក៏បានអញ្ជើញអ្នកសង្កេតការណ៍អន្តរជាតិមកត្រួតពិនិត្យសកម្មភាពបោះឆ្នោតដូចជាស្ថាប័នសន្និសីទអន្តរជាតិស្តីពីគណបក្សនយោបាយអាស៊ី (ICCAP) និងអង្គការទស្សននយោបាយអ្នកប្រជាធិបតេយ្យអាស៊ីប៉ាស៊ីហ្វិកអន្តរជាតិ (CAPDI) ដោយទទួលបានការរ៉ាប់រងផ្នែកចំណាយពីគណបក្សប្រជាជនកម្ពុជា[14]។

គួរឲ្យកត់សំគាល់ដែរថា នេះជាការអនុវត្តន៍ដែលពុំមានលក្ខណៈត្រឹមត្រូវតាមស្តង់ដាអន្តរជាតិដែលអ្នកសង្កេតការណ៍អន្តរជាតិដែលមានការអញ្ជើញពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប៉ុន្តែបែរជាគាំទ្រចំណាយដោយគណបក្សប្រជាជនកម្ពុជាទៅវិញ ដែលនេះបង្ហាញពីភាពមិនអព្យាក្រឹត្យភាពរបស់អ្នកសង្កេតការណ៍អន្តរជាតិក្នុងការសង្កេតដំណើរការបោះឆ្នោតទាំងមូលរួចទៅហើយ។

[14] កាសែតខេមបូខាឌេលីចេញថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៣

រូបភាពទី១០៖ អ្នកសង្កេតការណ៍អន្តរជាតិអញ្ជើញសង្កេតការណ៍បោះឆ្នោតដោយគ.ជ.ប
ប៉ុន្តែថវិការគាំទ្រដោយគណបក្សប្រជាជនកម្ពុជា







តារាងទី៧៖ ចំនួនអ្នកសង្កេតការណ៍អន្តរជាតិ

| 1993 | 1998 | 2002 | 2003 | 2007 | 2008 | 2012 | 2013 |
|---|---|---|---|---|---|---|---|
| N/A | 5,389 | 76,006 | 86,990 | 104,450 | 131,534 | 118,810 | 292 |

## ១៤. ទំនាស់ក្រោយពេលបោះឆ្នោត

ជម្លោះនៃការបោះឆ្នោតជាតិ ក្នុងខែកក្កដា ឆ្នាំ២០១៣ នៅកម្ពុជា បានវិវត្តន៍បន្តិចម្តងៗអាចទៅជាវិបត្តិនយោបាយ។ ទោះបីជាយ៉ាងនេះក្តី ជម្លោះ ឬ/និងវិបត្តិនយោបាយនៅក្នុងប្រទេសកម្ពុជា គឺមិនមែនជាលើកដំបូងឡើយព្រោះវាធ្លាប់កើតឡើងតាំងពីសម័យសង្គ្រាមត្រជាក់តាំងពីទសវត្សឆ្នាំ១៩៧០ កម្ពុជាមានវិបត្តិនយោបាយ ដោយភ្ជាប់ការតស៊ូដណ្តើមអំណាចនយោបាយដោយអាវុធ និងក្រោយមកទៀតបន្ទាប់ពីដំណើរការបោះឆ្នោតក្នុងឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ន កម្ពុជាជួបប្រឈមជម្លោះបោះឆ្នោត ហើយឈានទៅរកជម្លោះ ឬជាប់គាំងនយោបាយក្នុងរយៈពេលខ្លី។

ជម្លោះបោះឆ្នោតលើកនេះប្រាកដណាស់ថា បានចាប់ពន្លកតាំងពីការរៀបចំមុនពេលបោះឆ្នោត។ ជាការពិត ការចាត់ចែងការបោះឆ្នោតនៅកម្ពុជាក្នុងឆ្នាំ២០១៣ មិនទាន់មានភាពសេរី និងយុត្តិធម៌ ដោយសារខ្វះខាតការប្រកួតប្រជែងលើទីលានបោះឆ្នោតដ៏ត្រឹមត្រូវ។ គណបក្សមិនកាន់អំណាច ជាពិសេសគណបក្សសង្គ្រោះជាតិបានត្អូញត្អែរលើចំណុចសំខាន់ៗទាក់ទងនឹងសមាសភាពសមាជិករបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) និងបញ្ជីឈ្មោះអ្នកបោះឆ្នោត ព្រមទាំងការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត។ សមាជិក គ.ជ.ប ទាំង៩ ត្រូវបានជ្រើសរើសយ៉ាងសម្ងាត់ និង/ឬជ្រើសតាំងដោយរដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជា (រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គណៈរដ្ឋមន្ត្រី និងសមាជិករដ្ឋសភារបស់បក្សប្រជាជនកម្ពុជា)។ ទោះបីជាគណបក្សសង្គ្រោះជាតិបានស្នើដើម្បីពន្យារពេលបោះឆ្នោត ដើម្បីរៀបចំការចុះឈ្មោះបោះឆ្នោតឡើងវិញ ធានាគុណភាពនៃបញ្ជីឈ្មោះអ្នកបោះឆ្នោតថ្មីមួយ តែសំណើនេះមិនត្រូវបានយកចិត្តទុកដាក់ដោះស្រាយឡើយ។

រាប់ចាប់ពីការជ្រើសរើស និងការតែងតាំងសមាសភាពនៃ គ.ជ.ប និងមន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ក៏មិនត្រូវបានឆ្លើយតបនឹងអនុសាសន៍របស់អ្នកជំនាញការងារបោះឆ្នោតជាតិ អន្តរជាតិ និងការខកខានមិន

បានកំណែទម្រង់ស្ថាប័នអាជ្ញាកណ្តាលមួយនេះ ការលុបឈ្មោះមេដឹកនាំគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សជំទាស់រដ្ឋាភិបាលដ៏ធំមួយ និងជាគូប្រជែងស្មើកម្លាំងគ្នា គឺជាការយកប្រៀបខាងយុទ្ធសាស្ត្រដោយចេតនាមិនត្រឹមត្រូវដោយគ.ជ.ប ដែលជាស្ថាប័នទទួលស្គាល់ និងប្រកាសជោគជ័យរបស់គណបក្សកាន់អំណាច។ បន្ថែមទំនាស់នោះទៀត ការខ្វះខាតទំនុកចិត្ត និងទំនាស់បែបបុគ្គលរវាងមេដឹកនាំបានកើនឡើង។ គណបក្សកាន់អំណាចត្រូវបានគេជឿជាក់ថា បានគាំទ្រពីក្រោយខ្នងយុទ្ធនាការប្រឆាំងនឹងមេដឹកនាំគណបក្សសង្គ្រោះជាតិជាបន្តបន្ទាប់ ដូចជា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងនៅក្នុងពិធីបញ្ចុះខណ្ឌសីមានៅវត្តមង្គលវង្ស ក្នុងខេត្តកំពង់ចាម កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ថា នៅពេលលោក កឹម សុខា ត្រឡប់មកពីសហរដ្ឋអាមេរិកវិញ ប្រជាពលរដ្ឋនឹងធ្វើបាតុកម្មប្រឆាំងនឹងលោក ប្រសិនបើលោក កឹម សុខា មិនធ្វើការសុំទោសប្រជាពលរដ្ឋទាក់ទិននឹងការបកស្រាយអំពីគុកទួលស្លែង និងកងទ័ពវៀតណាម។ មិនយូរប៉ុន្មាន នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៣ លោក ជុំ ម៉ី ជាអតីតអ្នករងគ្រោះនៅក្នុងរបបខ្មែរក្រហម និងជាប្រធានសមាគមក្បៀមក្សាន្ត បានដឹកនាំបាតុកម្មក្នុងក្រុងភ្នំពេញដែលមានអ្នកចូលរួមរាប់ពាន់នាក់។ មានការផ្សាយផ្ទាល់ពីបាតុកម្ម និងការបរិហារតាមរយៈទូរទស្សន៍បាយ័នជាលើកដំបូង ដើម្បីប្រឆាំងនឹងលោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិ។ បាតុកម្មនេះត្រូវបានមន្ត្រីសំខាន់ៗរបស់គណបក្សប្រជាជនកម្ពុជា ដូចជា សមាជិកសភាគណបក្សប្រជាជនកម្ពុជា លោក ជាម យៀប លោក ឈាង វុន ... ក៏បានអះអាងថាចូលរួមបាតកម្មនេះដែរ។ ជាងនេះទៅទៀត ការបរិហារប្រឆាំងនឹងអនុប្រធានគណបក្សសង្គ្រោះជាតិ ក៏ត្រូវបានអុកឡុកដោយស្ត្រីម្នាក់ដែលអះអាងថា ស្ត្រីកំណាន់ជាច្រើនលើកក្នុងពេលដែលលោកចុះធ្វើវេទិកាផ្សេងៗជាមួយប្រជាពលរដ្ឋ។

ទោះបីជាយ៉ាងណា ស្ថានការណ៍មុនថ្ងៃបោះឆ្នោតហាក់បានធូរស្រាលបន្តិច ខណៈដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្នើទៅព្រះមហាក្សត្រដើម្បីព្រះរាជទានការលើកលែងទោសដល់ប្រធានគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។ ការនិវត្តន៍ចូលស្រុកវិញរបស់មេដឹកនាំគណបក្សសង្គ្រោះជាតិ ដែលមានអ្នកគាំទ្រគណបក្សសង្គ្រោះជាតិរាប់សិបម៉ឺននាក់បានចូលរួមអបអរ និងស្វាគមន៍ បានក្លាយជាសញ្ញាណវិវត្តន៍នៃដំណើរប្រជាធិបតេយ្យនៅកម្ពុជា ខណៈសង្គមស៊ីវិលក៏បានសម្តែងការសាទរចំពោះកិច្ចសម្របសម្រួលនយោបាយមួយនេះ។ យុវជនជាច្រើនម៉ឺននាក់ ចេញមុខដង្ហែតាមដងផ្លូវ និងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមហ្វេសប៊ុក ដើម្បីបញ្ជាក់ពីការគាំទ្រគណបក្សសង្គ្រោះជាតិ ក្រោមពាក្យឃោសនា «ដូរ ឬមិនដូរ» ដែលខុសពីការបោះឆ្នោតមុនៗ។

ការផ្លាស់ប្តូរដ៏ធំមួយបានស្តែងឡើងតាមរយៈការបោះឆ្នោតនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ដោយសារពលរដ្ឋម្ចាស់ឆ្នោតដែលធ្លាប់តែស្ងប់ស្ងាត់នឹងសន្តិភាព បានចេញមកការពារ និងតាមដានលទ្ធផលឆ្នោតរបស់ពួកគេ។ គណបក្សសង្គ្រោះជាតិបានរកឃើញថា ខ្លួនបានទទួលលទ្ធផលឈ្នះលើគណបក្សប្រជាជនកម្ពុជា ថា ៦៣អាសនៈ ទល់នឹង ៦០អាសនៈ។ តាមការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ (ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣) គ.ជ.ប និងគណបក្សប្រជាជនកម្ពុជា ប្រកាសថា គណបក្សសង្គ្រោះជាតិទទួលបាន ៥៥អាសនៈ ចំណែកគណបក្សប្រជាជនកម្ពុជាទទួលបាន ៦៨អាសនៈ។ គណបក្សសង្គ្រោះជាតិ ពិសេសអ្នកគាំទ្រ សកម្មជនរបស់គណបក្សនេះ មិនជឿ និងបដិសេធលទ្ធផលនេះទេ ពួកគេទាមទារឱ្យ គ.ជ.ប និងគណបក្សប្រជាជនកម្ពុជា ចូលរួមក្នុងការអង្កេតមួយ ដើម្បីផ្ទៀងផ្ទាត់លទ្ធ

ផលនេះ។ គ.ជ.ប និងគណបក្សប្រជាជនកម្ពុជា មិនសហការក្នុងការបង្កើតគណៈកម្មការឯករាជ្យដើម្បីធ្វើការស៊ើបអង្កេតលទ្ធផល និងភាពមិនប្រក្រតីបោះឆ្នោត។ ពាក្យបណ្តឹងអំពីភាពមិនប្រក្រតីបោះឆ្នោតត្រូវបានបដិសេធដោយ គ.ជ.ប រួមទាំង មិនលើកការផ្ទៀតផ្ទាត់លទ្ធផលបោះឆ្នោតពីការិយាល័យបោះឆ្នោត ពិសេសគឺទម្រង់ ១១០២ និង១១០៤។ មានភាពមិនប្រក្រតីមួយចំនួនដែលអាចប៉ះពាល់លទ្ធផលបោះឆ្នោត គោលការណ៍សុវត្ថិភាព អ្នកបោះឆ្នោតម្នាក់បោះបានតែមួយសន្លឹក មិនត្រូវបានធានាព្រោះថា ទឹកថ្នាំខ្មៅត្រូវបានលាងជ្រះ ខ្វះតម្លាភាពក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណ និងបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការដែលមិនមានគុណភាព មានឈ្មោះខុស និងឈ្មោះស្ទួន ។

គណបក្សប្រជាជនកម្ពុជា ចង់ប្រើប្រាស់ស្ថាប័នរដ្ឋដែលខ្លួនត្រួតត្រាដើម្បីដោះស្រាយបណ្តឹង និងភាពមិនប្រក្រតីនៃការបោះឆ្នោត តែគណបក្សសង្គ្រោះជាតិមិនមានជំនឿលើស្ថាប័នរដ្ឋ ដោយទាមទារយន្តការចម្រុះ ឬឯករាជ្យដែលមានការចូលរួមពីអង្គការសហប្រជាជាតិ និងសង្គមស៊ីវិល។ ទំនាស់បោះឆ្នោត វាបានជម្រុញឱ្យបង្កើនកំដៅជម្លោះនយោបាយ។ គណបក្សសង្គ្រោះជាតិបានរៀបចំធ្វើមហាបាតុកម្មច្រើនដង ដើម្បីទាមទារយុត្តិធម៌ក្នុងពេលបោះឆ្នោតដោយមានអ្នកចូលរួមរាប់ម៉ឺននាក់ ចំណែករដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជាបានចល័តទ័ពចូលក្នុងរាជធានីភ្នំពេញដើម្បីបង្ហាញសាច់ដុំរបស់ខ្លួនតាម រយៈកងកម្លាំងអាវុធ ព្រមគ្រឿងយុទ្ធភណ្ឌទ័ពយោធាដែលស្មគ្រការពារលោកនាយករដ្ឋមន្ត្រី គ្រួសារនិងគណបក្សកាន់អំណាច។ ទោះបីជាមជ្ឈដ្ឋានទូទៅយល់ថា កម្លាំងនេះគឺត្រៀមបង្ក្រាបបាតុកររបស់បក្សប្រឆាំង និងជាការបំភិតភ័យដល់ពលរដ្ឋ តែគណបក្សកាន់អំណាចបកស្រាយថា គ្រាន់ដើម្បីរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈប៉ុណ្ណោះ។ សម្រាប់ព្រឹត្តិការណ៍បាតុកម្មលើកទី១ ការបង្ក្រាបដោយរាជរដ្ឋាភិបាលទៅលើបាតុករ(អហិង្សា) បានក្លាយជាកំហុសមួយដ៏ធំរបស់រាជរដ្ឋាភិបាល ព្រោះបានបណ្តាលឱ្យមានពលរដ្ឋស្លូតត្រង់ស្លាប់ និងរងរបួសជាច្រើន ដោយសារការរារាំង និងឆែកឆេររបស់សមត្ថកិច្ច ពិសេសការបិទផ្លូវដោយប្រើលួសបន្លាជារបាំង។ ជាក់ស្តែង កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ មានព្រឹត្តិការណ៍ប៉ះទង្គិចហឹង្សាមួយកើតឡើងនៅស្ពានអាកាសក្បាលថ្នល់រវាងសមត្ថកិច្ចរាប់រយនាក់ប្រដាប់ដោយខែល ដំបង គ្រាប់បែកផ្សែង កាំភ្លើងគ្រាប់ពិតជាមួយនឹងក្រុមអ្នកតវ៉ាប្រមាណជិត ៣០នាក់ យ៉ាងហោចណាស់បានបណ្តាលឱ្យមនុស្សម្នាក់ស្លាប់ ១៥នាក់រងរបួស និងមនុស្ស ៦នាក់ ត្រូវសមត្ថកិច្ចចាប់ខ្លួន។ បុរសម្នាក់ឈ្មោះ ម៉ៅ សុខចន្ទ អាយុ ២៩ឆ្នាំ ត្រូវបានអះអាងថា ជាអ្នកដំណើរតាមផ្លូវ បានស្លាប់ភ្លាមៗនៅកន្លែងកើតហេតុដោយត្រូវគ្រាប់កាំភ្លើង (K59) បាញ់ចំក្បាល។

ដើមឡើយ គណបក្សប្រជាជនកម្ពុជាហាក់ដូចជាបានយល់ស្របដើម្បីបង្កើតគណៈកម្មការចម្រុះដើម្បីស៊ើបអង្កេតភាពមិនប្រក្រតីក្នុងពេលបោះឆ្នោតដែលស្នើដោយគណបក្សសង្គ្រោះជាតិ នេះបើយោងលើប្រសាសន៍របស់ លោក ហ៊ុន សែន បេក្ខជននាយករដ្ឋមន្ត្រីនៃគណបក្សប្រជាជនកម្ពុជា កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ក្នុងពេលចុះពិនិត្យការដ្ឋានសង់ស្ពានអាកាសស្ទឹងមានជ័យ។ ក្រោយជំនួបចរចាជាច្រើនលើកច្រើនសាររវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ គណបក្សប្រជាជនកម្ពុជាបែរជាបដិសេធយន្តការនៃគណៈកម្មការចម្រុះទៅវិញ។ ទោះយ៉ាងណាក្តី មានការចាប់ផ្តើមបើកជំនួបមេដឹកនាំកំពូលនៃគណបក្សទាំងពីរដោយការចែកលិខិតអញ្ជើញរបស់ព្រះមហាក្សត្រ។ មានកិច្ចប្រជុំពិភាក្សារវាងមេដឹកនាំកំពូលនៃគណបក្សទាំងពីរចំនួន ២លើក នៅថ្ងៃទី១៦ និង១៧ ខែកញ្ញា ឆ្នាំ២០១៣។ លទ្ធផលកិច្ចប្រជុំ

លើកទីមួយ បានស្រុះស្រួលគ្នាក្នុងការបង្កើតយន្តការ កំណែទម្រង់បោះឆ្នោត រួមគ្នាដោះស្រាយបញ្ហាជាតិ និងមិនប្រើអំពើហឹង្សាទៅលើគ្នាទៅវិញទៅមក។ ក្នុងនោះមានលទ្ធផលនៃកិច្ចប្រជុំទីពីរដែរ តែមិនទាន់ចុះហត្ថលេខាផ្លូវការ គឺបានស្រុះស្រួលគ្នាបន្ថែមថា គណបក្សទាំងពីរឈ្នះឆ្នោតដូចគ្នា និងយល់ព្រមអំពីការរៀបចំប្រព័ន្ធត្រួតពិនិត្យគ្នាទៅវិញទៅមក ការបែងចែកអំណាចដឹកនាំនៅសភា និងការធ្វើវិសោធនកម្មលើបទបញ្ជា និងលក្ខន្តិកៈរបស់សភា។

លទ្ធផលនៃកិច្ចប្រជុំទាំងនេះមិនបានបន្ថយកំដៅជម្លោះទេ ព្រោះគណបក្សទាំងពីរមិនទាន់ស្រុះស្រួលជាក់លាក់នៅឡើយ។ ដោយមិនរង់ចាំការស្រុះស្រួលនយោបាយ គណបក្សប្រជាជនកម្ពុជាឯកបក្សបានជម្រុញឱ្យមានការប្រកាសបង្កើតសភា និងរដ្ឋាភិបាល ដែលផ្តើមដោយការបើកសម័យប្រជុំសភាឯកបក្សនីតិកាលទី៥។ ក្នុងសម័យប្រជុំរដ្ឋសភាលើកដំបូងកាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ បានប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ នរោត្តម សីហមុនី ប្រកាសបើក និងស្វាគមន៍បេក្ខជនជាប់ឆ្នោតរបស់គណបក្សប្រជាជនកម្ពុជាទាំង ៦៨រូប ក្រោមសក្ខីភាពតំណាងទូតប្រចាំកម្ពុជាជាច្រើនរូប។ គណបក្សសង្គ្រោះជាតិបានស្នើឱ្យពន្យារពេលការប្រជុំដំបូងនេះ ហើយបេក្ខជនជាប់ឆ្នោតទាំង ៥៥រូប របស់គណបក្សសង្គ្រោះជាតិសម្រេចមិនចូលរួមប្រជុំទេ។ ចំពោះការបើកសម័យប្រជុំសភាលើកទីមួយ ស្ថានទូតសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុបប្រចាំកម្ពុជា បានបញ្ជាក់ពីជំហរចង់ឃើញការរួបរួមគ្នារបស់គណបក្សជាប់ឆ្នោតទាំងពីរ ហើយមិនទាន់បញ្ជាក់អំពីការគាំទ្រផ្លូវការលើលទ្ធផលបោះឆ្នោត ការបង្កើតសភា និងរដ្ឋាភិបាលដោយគណបក្សនយោបាយតែមួយឡើយ។ រាជ រដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជាធ្លាប់គ្រប់គ្រងប្រទេសកម្ពុជាតាំងពីឆ្នាំ ១៩៨១ ដល់ ឆ្នាំ១៩៨៥ ដោយខ្វះមូលដ្ឋាននីត្យានុកូលភាព និងក្រោយព្រឹត្តិការណ៍ខែកក្កដា ឆ្នាំ១៩៩៧ ទាំងពីរលើក មានទណ្ឌកម្មពីបរទេសទាំងពីរលើក មានការដាក់សម្ពាធផ្នែកសេដ្ឋកិច្ច អន្តរជាតិមិនទទួលស្គាល់។ គណបក្សប្រជាជនកម្ពុជារក្សាឥរិយាបថចាស់មិនទាន់កែ បើទោះបីជារាជរដ្ឋាភិបាលអាណត្តិថ្មីរបស់គណបក្សប្រជាជនកម្ពុជាបានប្រកាសថា នឹងធ្វើកំណែទម្រង់ស៊ីជម្រៅ បែរផ្សាភ្ជាប់មន្ត្រីរដ្ឋាភិបាលច្រើនលើសលប់ដដែល។ គណបក្សប្រជាជនកម្ពុជានឹងមិនព្រមបែងចែកអំណាចជាងការអនុវត្តទ្រឹស្តីអំណាចប្រមូលផ្តុំ ដែលអាចឈានដល់ការប្រកាសដំណើរការរដ្ឋសភាជាឯកបក្ស ខុសពីគោលការណ៍ប្រជាធិបតេយ្យ និងខ្វះនីត្យានុកូលភាព។

ការវិវត្តន៍ចុងក្រោយ គណបក្សប្រជាជនកម្ពុជាហាក់ដូចជាចង់អនុវត្តបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាទាំងមិនច្បាស់លាស់ថា ក្នុងន័យថាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អាចយកអាសនៈរបស់គណបក្សសង្គ្រោះជាតិមកបែងចែកឱ្យគណបក្សប្រជាជនកម្ពុជាទាំងអស់នៅពេលគណបក្សសង្គ្រោះជាតិមិនចូលសភា។ ការបែងចែកអំណាចគ្នានៅរដ្ឋសភាក៏ជាមូលហេតុនៃទំនាស់នយោបាយមួយ ខណៈដែលគណបក្សសង្គ្រោះជាតិប្រាថ្នាចង់បានប្រធានសភា(ប្រមុខនៃនីតិប្បញ្ញត្តិ) និងចំនួនសមាជិកគណៈកម្មការអចិន្ត្រៃយ៍របស់សភាស្មើគ្នានឹងគណបក្សប្រជាជនកម្ពុជា ដើម្បីធានាសមតុល្យនៃអំណាចរបស់រដ្ឋជាមួយគោលការណ៍គណបក្សទាំងពីរឈ្នះទាំងអស់គ្នា ខណៈដែលគណបក្សប្រជាជនកម្ពុជាដឹកនាំរដ្ឋាភិបាលជាមួយនាយករដ្ឋមន្ត្រី (នីតិប្រតិបត្តិ)។ កន្លងមកការអនុវត្តកំណែទម្រង់ដែលធ្វើឡើងដោយការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជាតែមួយគត់មិនអាចទៅរួចឡើយ។

គណបក្សសង្គ្រោះជាតិបានបើកយុទ្ធនាការបញ្ចុះបញ្ចូល និងតស៊ូមតិទៅសហគមន៍អន្តរជាតិ ដើម្បីកុំឱ្យទទួលស្គាល់លទ្ធផលបោះឆ្នោត រដ្ឋាភិបាល និងរដ្ឋសភារបស់គណបក្សប្រជាជនកម្ពុជា ខណៈដែលសហគមន៍ និងអ្នកសង្កេតការណ៍អន្តរជាតិបានដកឃ្លាចយតាំងពីចាប់ផ្តើមដំណើរការ។ អ្នកសង្កេតការណ៍អន្តរជាតិដូចជា សហគមន៍អឺរ៉ុប ស្ថានទូតអន្តរជាតិ ដែលធ្លាប់តែចូលរួមសង្កេតការណ៍ កន្លងមកបានដកខ្លួនពីការបោះឆ្នោតនៅកម្ពុជាក្នុងឆ្នាំ២០១៣ អាចដោយសារមិនចង់ផ្តល់ភាពស្របច្បាប់សម្រាប់ការបោះឆ្នោតមួយដែលលម្អៀងខ្លាំងជ្រុលទៅរកគណបក្សកាន់អំណាច ឬមិនមានភាពត្រឹមត្រូវ។ ចុងក្រោយ គណបក្សសង្គ្រោះជាតិបានព្រមានថា ម្ចាស់ជំនួយ ឬអ្នកធ្វើវិនិយោគទុន មិនត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងណាទាំងអស់ជាមួយនឹងរដ្ឋាភិបាលគណបក្សតែមួយ និងក៏បានស្នើឱ្យ អង្គការសហប្រជាជាតិទុកអាសនៈកម្ពុជាឱ្យនៅទំនេរ។

ជម្លោះរវាងគណបក្សធំទាំងពីរហាក់តឹងតែងមិនងាយនឹងឈានរកដំណោះស្រាយហើយកាន់តែរីកធំឡើង និងនៅឆ្ងាយគ្នាពីការប្រជុំចរចាស្ទើរតែទាំងអស់មិនបានសម្រេចលទ្ធផលនៅឡើយ។ ពលរដ្ឋម្ចាស់ឆ្នោតគាំទ្រគណបក្សសង្គ្រោះជាតិ ហាក់ចង់ឱ្យមានការផ្លាស់ប្តូរ រដ្ឋាភិបាល ជាពិសេសការផ្លាស់ប្តូរនាយករដ្ឋមន្ត្រី បើទោះបីជាមើលពីខាងក្រៅទៅភាគីទាំងសង្ខាង ទំនងហាក់ខិតជិតគ្នានឹងដំណោះស្រាយនយោបាយដោយគ្រាន់តែខ្វែងគំនិតគ្នាលើមុខតំណែងប្រធាន គណៈកម្មការសភា និងសមាជិកគណៈកម្មការអចិន្ត្រៃយ៍។

គណបក្សប្រជាជនកម្ពុជាក៏បានបញ្ជាក់ជំហរបន្ថែមដោយចេញសេចក្តីថ្លែងការណ៍អំពីក្របខណ្ឌកំណែទម្រង់បោះឆ្នោតលើ ៥ចំណុចសំខាន់ៗ ហើយក៏ចង់ឱ្យក្រសួងមហាផ្ទៃដឹកនាំកំណែទម្រង់ និងចាប់ផ្តើមរៀបចំធ្វើសិក្ខាសាលាដើម្បីប្រមូលអនុសាសន៍អំពីកំណែទម្រង់បោះឆ្នោត។ គណបក្សសង្គ្រោះជាតិមានប្រតិកម្មមិនគាំទ្រអំពីភាពចាំបាច់នៃតួនាទីរបស់ក្រសួងមហាផ្ទៃក្នុងការប្រមូលអនុសាសន៍។ គណបក្សសង្គ្រោះជាតិក៏មាន ១០ចំណុច ដែលស្រង់ចេញពីសមាជមហាជនរបស់គណបក្សនេះ ដើម្បីទាមទារឱ្យមានការព្រមព្រៀងក្នុងការចរចា។ ចំណុចសំខាន់ៗ រួមមាន ការអង្កេតស្វែងរកភាពមិនប្រក្រតី កំណែទម្រង់ការបោះឆ្នោត ពិសេសសមាសភាព គ.ជ.ប កំណែទម្រង់ដីធ្លី។

គណបក្សសង្គ្រោះជាតិក៏បង្កើនសម្ពាធបន្ថែមដោយប្រមូលស្នាមមេដៃរហូតដល់ ៣លាននាក់ ដើម្បីទាមទារសុំឲ្យពិនិត្យសើរើឡើងវិញអំពីភាពមិនប្រក្រតីនៃលទ្ធផលបោះឆ្នោត ។ គណបក្សប្រជាជនកម្ពុជាហាក់មានបំណងបំបែកមេដឹកនាំគណបក្សសង្គ្រោះជាតិជាមួយប្រជាពលរដ្ឋម្ចាស់ឆ្នោតគាំទ្រដោយការផ្សព្វផ្សាយថា ក្នុងកិច្ចប្រជុំពិភាក្សាគ្នា គណបក្សសង្គ្រោះជាតិបានទទួលស្គាល់លទ្ធផលបោះឆ្នោត ហើយបានពិភាក្សាទាមទារតំណែងក្នុងសភា ជាពិសេសប្រធានសភា។ គណបក្សប្រជាជនកម្ពុជា លោកនាយករដ្ឋមន្ត្រីក៏ព្រមានថា នឹងចាក់ផ្សាយសម្លេងសន្ទនានៃកិច្ចប្រជុំ។ រឿងនេះបានបន្តបន្ថែមបរិយាកាសទំនាស់ទៀតដោយឡែកការមិនទុកចិត្តអំពីការចរចារបស់គណបក្សទាំងពីរដោយគ្មានភាគីទីបី ដូចជាអាជ្ញាកណ្តាល អ្នកសម្របសម្រួល ឬអ្នកសង្កេតការណ៍ ព្រោះភាគីសាមីគណបក្សនយោបាយបានប្រើប្រាស់ការសន្ទនា ឬការចរចារនេះជាផលប្រយោជន៍នយោបាយ។ បក្សសង្គ្រោះជាតិក៏បានគាំទ្រការចាក់ផ្សាយសម្លេងកិច្ចប្រជុំទាំងមូល ហើយបន្ទាប់មកបានទាមទារល័ក្ខខ័ណ្ឌអំពីការប្រជុំទៅមុខទៀត ដោយបើកចំហ ហើយមានអ្នកសង្កេតការណ៍ចូលរួម។

ជាសរុប មានជម្លោះនយោបាយបន្ថែមលើទំនាស់បោះឆ្នោតដែលជម្លោះនេះមិនត្រឹមខុសគ្នាអំពីខ្លឹមសារ ប៉ុន្តែក៏មានការមិនទុកចិត្តគ្នាក្នុងការសន្ទនា។ ការវិវត្តន៍នៃជម្លោះនេះអាចចេញលទ្ធផលតាមរូបភាពផ្សេងៗដែលបន្តការចរចា និងបានសម្រេចការស្រុះស្រួលដោយបង្កើតបរិយាកាសជឿទុកចិត្តគ្នាវិញ និងមានកិច្ចព្រមព្រៀងច្បាស់លាស់។ នៅក្នុងករណីនេះមានការលំបាកជាខ្លាំងដែលស្ទើរមិនមានលទ្ធផលនៃដំណោះស្រាយនយោបាយ។ ម៉្យាងទៀត ជម្លោះទាំងនេះនឹងក្លាយទៅជាវិបត្តិនយោបាយធ្ងន់ធ្ងរ និងយូរអង្វែង ហើយមានរូបភាពក្នុងការទាមទារឱ្យបោះឆ្នោតឡើងវិញនៅក្នុងអាណត្តិ។ មានការកើនកំដៅខ្លាំងព្រោះថា ភាគីសាមីគណបក្សទាំងពីរខិតខំ រកកម្លាំងសម្ពាធដាក់ទៅលើគ្នាទៅវិញទៅមក។ កម្លាំងសម្ពាធនឹងមិនកើតមានដោយសន្តិវិធីទៀតឡើយ ប្រសិនបើនៅពេលដែលកម្លាំងដាក់សម្ពាធរបស់ម្ចាស់ឆ្នោតបែរត្រូវបានបង្ក្រាបយ៉ាងខ្លាំងក្លាដោយកងកម្លាំងប្រដាប់អាវុធ។ ករណីនេះនឹងអាចនាំមកនូវការបះបោរ និងអំពើហឹង្សា ហើយដែលពិបាកការប៉ាន់ប្រមាណ អំពីហានិភ័យអវិជ្ជមាន៕

## ១៥. ការផ្លាស់ប្តូរអំណាច: ការបង្កើតសភា និងរដ្ឋាភិបាល

### ១៥.១ ការបង្កើតរដ្ឋសភា

លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ បានបង្ហាញថា គណបក្សប្រជាជនកម្ពុជា គឺជាគណបក្សឈ្នះឆ្នោតដែលទទួលបានអាសនៈចំនួន៦៨នៃ១២៣អាសនៈនៃរដ្ឋសភា។ ចំណែកឯគណបក្សសង្គ្រោះជាតិទទួលបានតែចំនួន៥៥អាសនៈ នេះបើផ្អែកតាមការប្រកាសដោយ គ.ជ.ប កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣។ បើយោង រដ្ឋធម្មនុញ្ញ និងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មានការកំណត់ប្រភេទ ទី១ បេក្ខជនជាប់ឆ្នោត ទី២ តំណាងរាស្ត្រ និងទី៣ សមាជិកសភា។ រាល់ប្រភេទនីមួយៗមាន គឺមាននីតិវិធីផ្តល់សុពលភាព។

ទោះបីជាក្រុមអ្នកច្បាប់របស់គណបក្សប្រជាជនកម្ពុជា បានព្យាយាមបកស្រាយថា វត្តមានតំណាងរាស្ត្រមានចាប់តាំងពីពេលបោះឆ្នោត គ.ជ.ប អាចផ្តល់សុពលភាព ត្រឹមតែជា“បេក្ខជនជាប់ឆ្នោត” នេះពន្យល់បានថា បន្ទាប់ពី គ.ជ.បមិន អាចផ្តល់សុពលភាព «តំណាងរាស្ត្រ» បាននោះទេ។ ហេតុដូច្នេះដំបូង ត្រូវការការផ្តល់សុពលភាពពី «បេក្ខជនជាប់ឆ្នោត» ទៅ «សមាជិកតំណាងរាស្ត្រ» នៅពេលបង្កើតរដ្ឋសភានៃនីតិកាលថ្មី។

ក្នុងដំណើរការផ្តល់សុពលភាព មាននីតិវិធីខ្លះដែលកំពុងមានភាពចម្រូងចម្រាស់ក្នុងការបកស្រាយការបើកសម័យប្រជុំសភាដំបូងក្រោមព្រះរាជាធិបតីភាពព្រះមហាក្សត្រ ឬ/និងការបិទឈ្មោះអ្នកតំណាងរាស្ត្រនៅរដ្ឋសភា ឬ/និងការធ្វើសច្ចាប្រណិធានចូលកាន់ដំណែង។ ជាគោលការណ៍នៃប្រទេសប្រជាធិបតេយ្យ ការធ្វើសច្ចាប្រណិធានចូលកាន់ដំណែង គឺជាការផ្តល់សុពលភាពបេក្ខជនជាប់ឆ្នោតក្លាយជាតំណាងរាស្ត្រ ឬសមាជិកសភា ដែលនឹងអាចបំពេញមុខងារ និងតួនាទីនៅក្នុងគណៈកម្មការជំនាញ ធ្វើការពិភាក្សា ទទួលបានប្រាក់ខែ ឬប្រាក់បំណាច់របស់សភា និងមានអភ័យឯកសិទ្ធិសភា។ នៅកម្ពុជា អាណត្តិ សមាជិកសភាមិនត្រូវតែមានវិសមត្ថភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម ប៉ុន្តរួមជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត យោងតាមមាត្រា៧៩នៃរដ្ឋធម្មនុញ្ញ។

ផ្អែកលើកំណត់ហេតុជាផ្លូវការនៃការបកស្រាយបំភ្លឺរបស់ក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០០៣ ទាក់ទិននឹងបញ្ហាខាងលើនេះ ក្រុមប្រឹក្សាធម្មនុញ្ញបានបកស្រាយបំភ្លឺយ៉ាងច្បាស់ជា

លាយ លក្ខណ៍អក្សរលើខ្លឹមសារវាក្យខណ្ឌទី១ មាត្រា ៧៦ នៃច្បាប់ធម្មនុញ្ញ៖ «វាក្យខណ្ឌទី១ មាត្រា ៧៦ នៃច្បាប់រដ្ឋធម្មនុញ្ញចែងថា៖ រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រ យ៉ាងតិច ១២០ រូប។ ត្រង់នេះ មានន័យថា យ៉ាងតិចណាស់ត្រូវមាន**សមាជិកជាតំណាងរាស្ត្រចំនួន១២០រូប ទើបអាចបង្កើតរដ្ឋសភាក្នុងនីតិកាលនីមួយៗបាន**»។

តាមវាក្យខ័ណ្ឌទី១ មាត្រា ៨២ រដ្ឋសភាបើកកិច្ចប្រជុំដំបូង៦០ថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត ក្រោមការកោះប្រជុំរបស់ព្រះមហាក្សត្រ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានផ្តល់សុពលភាពដល់បេក្ខជនជាប់ឆ្នោតតែប៉ុណ្ណោះ ដូច្នេះបេក្ខជនទាំងនោះមិនទាន់ត្រូវបានក្លាយជាសមាជិកតំណាងរាស្ត្រនោះទេ។ ចំពោះវាក្យខ័ណ្ឌទី២ នៃមាត្រា ៨២ខាងលើ បានចែងថា មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ។ វាក្យខ័ណ្ឌនេះសំដៅទៅលើការប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិករដ្ឋសភា មិនមែនប្រកាសសុពលភាពរបស់តំណាងរាស្ត្រនោះទេ។

តាមវាក្យខ័ណ្ឌទី១មាត្រា ៧៦ និងតាមវាក្យខ័ណ្ឌទី១ មាត្រា ៨២ ខាងលើ ការបង្កើតរដ្ឋសភានីតិកាលថ្មី គឺតម្រូវឲ្យមានសមាជិកតំណាងរាស្ត្រយ៉ាងតិច១២០រូប និងមានបើកការប្រជុំដំបូងក្រោមព្រះរាជាធិបតីភាពព្រះមហាក្សត្រ។ ប៉ុន្តែមិនមានមាត្រាណាមួយចង្អុលបង្ហាញថា សមាជិកយ៉ាងតិច១២០រូបត្រូវតែមានវត្តមាន ក្នុងកិច្ចប្រជុំដំបូងនោះទេ។ នេះជាចំណុចដែលមានការមិនច្បាស់លាស់ថា តើកិច្ចប្រជុំដំបូងនេះជានីតិវិធីក្នុងការផ្តល់សុពលភាពបេក្ខជនជាប់ឆ្នោតទៅជាអ្នកតំណាងរាស្ត្រឬទេ?

ការអនុវត្តន៍កន្លងទៅ វត្តមានរបស់បេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រដែលមានចំនួនយ៉ាងតិច១២០រូបដូចដែលមានចែងក្នុងច្បាប់ គឺជាល័ក្ខខ័ណ្ឌចំបាច់ក្នុងការបើកនីតិកាលរបស់រដ្ឋសភាថ្មី។មានសំណួរលើកឡើងថា បើត្រូវការសមាជិកតំណាងរាស្ត្រយ៉ាងតិច១២០នាក់ក្នុងការយកសុពលភាព តើគេត្រូវដោះស្រាយដូចម្តេចនៅពេលបេក្ខជនជាប់ឆ្នោតត្រឹមតែ០៤នាក់មិនទទួលយកសុពលភាព។ ត្រង់នេះ គឺបណ្តាលឲ្យជាប់គាំងក្នុងការបង្កើតរដ្ឋសភា និងរដ្ឋភិបាល។ ប្រព័ន្ធនេះគឺអយុត្តិធម៌ចំពោះគណបក្សជាប់ឆ្នោតច្រើនជាងគេដោយសារតែបង្កើតរដ្ឋាភិបាលមិនបាន។

កន្លងមកមានការបកស្រាយដោយគណបក្សប្រជាជនកម្ពុជាថា មាត្រា១១៨ និង ១២០នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមានន័យថា ទោះបីមិនប្រកាសមិនយកសុពលភាព តែបើបេក្ខជនជាប់ឆ្នោតមិនយកសុពលភាព ក៏ គ.ជ.បយកអាសនៈទៅបែងចែកឲ្យគណបក្សដែលមានអាសនៈក្នុងរដ្ឋសភា។

ចំពោះស្ថានភាពក្រោយការបោះឆ្នោតឆ្នាំ២០០៨ និង២០១៣ គណបក្សប្រជាជនកម្ពុជា និង លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់បានព្រមានគណបក្សប្រឆាំងថា អាសនៈរបស់គណបក្សប្រឆាំង នឹងត្រូវយកទៅបែងចែកឲ្យគណបក្សដទៃទៀតដែលមានអាសនៈក្នុងរដ្ឋសភា ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប្រសិនបើគណបក្សប្រឆាំងនេះបោះបង់អាសនៈរបស់ខ្លួន បើយោងតាមមាត្រា១១៨ និងមាត្រា១២០នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយមិនយកសុពលភាពរបស់ខ្លួនក្នុងកិច្ចប្រជុំសភាដំបូង។

សម្រាប់ស្ថានភាពនយោបាយក្រោយពេលបោះឆ្នោតឆ្នាំ២០០៨ មានការព្រមានគណបក្សសិទ្ធិមនុស្ស និងគណបក្សសមរង្ស៊ី អាចនឹងប្រឈមនឹងការបាត់បង់អាសនៈក្នុងរដ្ឋសភា ដោយសារ គ.ជ.ប នឹងយកអាសនៈរបស់គណបក្សទាំងនោះទៅបែងចែកឲ្យគណបក្សផ្សេងទៀតដែលបានជាប់ឆ្នោត ប្រសិនបើគណបក្សនេះធ្វើពហិកាមិនចូលរួមប្រជុំសភាដំបូង។ អ្វីដែលខុសគ្នាចំពោះស្ថានភាពទាំងពីរនោះ គឺសម្រាប់

ការបោះឆ្នោតឆ្នាំ២០០៨ បើទោះបីជា គ.ជ.ប យកអាសនៈរបស់គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ទៅបែងចែកឲ្យគណបក្សដែលជាប់ឆ្នោត ក៏រដ្ឋសភានៅតែមានពហុបក្សដដែល ព្រោះគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សនរោត្តម រណឫទ្ធិ ក៏ជាប់ឆ្នោតក្នុងឆ្នាំ២០០៨ផងដែរ។ ដូចនេះក្នុងស្ថានភាពពេលនោះ ការបែងចែកអាសនៈរបស់គណបក្សទាំងពីរមិនធ្វើឲ្យរដ្ឋសភាក្លាយទៅជារដ្ឋសភាឯកបក្ស ដែលផ្ទុយពីគោលការណ៍សេរីពហុបក្សនោះទេ។ ដោយសារសម្ពាធដូចនេះហើយទើបគណបក្សសមរង្ស៊ី បានធ្វើការសម្រេចចូលរួមក្នុងសភានីតិកាលទី៤នៅដំណាក់ចុងក្រោយ។

ខុសពីស្ថានភាពក្រោយពេលបោះឆ្នោតឆ្នាំ២០០៨ បើ គ.ជ.ប យកអាសនៈរបស់គណបក្សសង្គ្រោះជាតិឲ្យគណបក្សជាប់ឆ្នោត នោះអាសនៈទាំង១២៣នឹងបានទៅគណបក្សប្រជាជនកម្ពុជា។ ក្នុងស្ថានការណ៍ថ្មីនេះ អ្នកច្បាប់ និងវាគ្មិនគាំទ្រគណបក្សប្រជាជនកម្ពុជាបានបកស្រាយពីការបង្កើតអាណត្តិសភាថ្មី ឬការផ្តល់សុពលភាពដល់អ្នកតំណាងរាស្ត្របានកើតឡើងតាំងពីពេលបោះឆ្នោតហើយបានពន្យល់ថា អ្នកតំណាង ១២៣នាក់ គឺគ្រាន់តែជាតម្រូវការកំណត់ចំនួននៅក្នុងច្បាប់បោះឆ្នោតទេ។

ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ គឺជាកាលបរិច្ឆេទនៃកិច្ចប្រជុំដំបូងនៃការបង្កើតរដ្ឋសភានីតិកាលទី៥។ វាក្យខណ្ឌទី០១ មាត្រា ៨២ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា រដ្ឋសភាបើកសម័យប្រជុំដំបូង ៦០ថ្ងៃយ៉ាងយូរ**«ក្រោយពេលបោះឆ្នោត»** តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។ ខុមហ្វ្រែលយល់ថា ជាបច្ចេកទេសនៅមានរយៈច្រើនក្នុងការអនុវត្តន៍មាត្រា៨២ខាងលើ ព្រោះថា «ក្រោយការបោះឆ្នោត» គឺនិយាយទៅដល់ពេលបញ្ចប់ការបោះឆ្នោត ឬពេលប្រកាសលទ្ធផលបោះឆ្នោតចុងក្រោយ។ ដូចនេះក្រោយពេលបោះឆ្នោតគឺ ចាប់តាំងពីក្រោយថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតនោះ។ ក្រោយពេលបោះឆ្នោតសំដៅទៅលើពេលដែលដំណើរនៃការបោះឆ្នោតទាំងមូលបានបញ្ចប់ មានន័យថា ក្រោយការបោះឆ្នោតទទួលបានលទ្ធផលផ្លូវការ មិនមែនសំដៅទៅលើក្រោយកាលបរិច្ឆេទណាមួយដែលបានកំណត់ក្នុងប្រតិទិនបោះឆ្នោត ដូចជាថ្ងៃបោះឆ្នោតជាដើមនោះទេ។ កិច្ចប្រជុំរដ្ឋសភាដំបូងដែលឆ្លើយតបតាមមាត្រា៨២ខាងលើ អាចត្រូវបានពន្យារពេលរហូតដល់ដើមខែវិច្ឆិកា។ ការពន្យារពេលនេះគឺទុកពេលវេលាឲ្យគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិមានពេលវេលាគ្រប់គ្រាន់ដើម្បីចរចាស្វែងរកដំណោះស្រាយជំលោះ ក្រោយការបោះឆ្នោត។

នៅក្នុងកិច្ចប្រជុំរដ្ឋសភាដំបូងកាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ មានតែបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រចំនួន៦៨រូបមកពីគណបក្សប្រជាជនកម្ពុជាទេ បានចូលរួមក្នុងកិច្ចប្រជុំដំបូងនោះ ដោយអវត្តមានបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រចំនួន ៥៥រូបរបស់គណបក្សសង្គ្រោះជាតិ។ ក្នុងដំណើរការនេះ បេក្ខជនជាប់ឆ្នោត ចំនួន៦៨រូបមកពីគណបក្សប្រជាជនកម្ពុជា បានក្លាយជាសមាជិកជាតំណាងរាស្ត្រខណៈពេលដែលបេក្ខជនជាប់ឆ្នោត ៥៥រូបរបស់គណបក្សសង្គ្រោះជាតិ មិនទាន់ក្លាយជាសមាជិកជាតំណាងរាស្ត្រនៅឡើយទេ។

បើយកនីតិវិធីនៃការផ្តល់សុពលភាព គឺនិយាយត្រឹមប្រកាសផ្សាយបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រតែប៉ុណ្ណោះ ដោយមិនមានវត្តមានបេក្ខជនជាប់ឆ្នោតអស់នោះទេ។ នេះបង្ហាញថា រដ្ឋសភាត្រូវបានបង្កើតដោយគ្មានការចូលរួមពីពហុបក្សក្នុងការឆ្លើយតបនឹងមាត្រា០១នៃរដ្ឋធម្មនុញ្ញដែលចែងថា ព្រះរាជាណាចក្រកម្ពុជាតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ម្យ៉ាងវិញទៀត ការបើកប្រជុំបង្កើតរដ្ឋសភាដំបូងក្រោមព្រះ

រាជាធិបតីភាពរបស់ព្រះមហាក្សត្រ ដែលមិនទាន់មានឯកភាពជាតិដូច្នេះ គឺពិតជាមិនបានអនុវត្តតាមមាត្រា ០៨នៃរដ្ឋធម្មនុញ្ញដែលបានចែងត្រង់វាក្យខ័ណ្ឌទី១ថា ព្រះមហាក្សត្រព្រះអង្គជានិមិត្តរូបនៃឯកភាពជាតិ។

ដំណើរការ និងនីតិវិធីនាពេលបច្ចុប្បន្ន គឺពឹងផ្អែកទាំងស្រុងទៅលើឆន្ទៈគណបក្សនយោបាយតែមួយគត់ ហើយក្នុងបរិបទនយោបាយប្រទេសកម្ពុជា គណបក្សនយោបាយមានអំណាច និងមានឥទ្ធិពលក្នុងការគ្រប់គ្រងបេក្ខជនជាប់ឆ្នោត ឬតំណាងរាស្ត្ររបស់គណបក្សខ្លួន។

## ១៥.២ ការតែងតាំងថ្នាក់ដឹកនាំរដ្ឋសភា និងរាជរដ្ឋាភិបាល

មាត្រា ៨២ថ្មី នៃរដ្ឋធម្មនុញ្ញ បានចែងថា រដ្ឋសភាត្រូវបោះឆ្នោតដាច់ដោយឡែកពីគ្នានូវប្រធាន និងអនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភាដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ចំណែកឯមាត្រា ១១៩ថ្មី ក៏បានចែងថា វរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សឈ្នះឆ្នោត ដែលត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ តាមសេចក្តីស្នើពីប្រធានដោយមានការឯកភាពពីអនុប្រធានរដ្ឋសភាទាំងពីរ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកតំណាងគណបក្សនៅក្នុងរដ្ឋសភាដែលផ្តល់ឲ្យកាន់ដំណែងផ្សេងៗ ក្នុងរាជរដ្ឋាភិបាលទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ យោងតាមវាក្យខ័ណ្ឌចុងក្រោយនៃមាត្រា ៩០ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ បានចែងថា រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ មាត្រានេះមានសារៈសំខាន់ណាស់ដើម្បីអនុវត្តប្រព័ន្ធសភានិយម។ អំណាចរដ្ឋសភាត្រូវខ្លាំងជាងអំណាចរាជរដ្ឋាភិបាល។ ហើយគេត្រូវធានាឲ្យមានការបែងចែកអំណាចឲ្យដាច់ពីគ្នារវាងរដ្ឋាភិបាល និងរដ្ឋសភា យោងតាមមាត្រា៥១ថ្មីនៃរដ្ឋធម្មនុញ្ញ។

ការបោះឆ្នោតជ្រើសតាំង ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការនានា និងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ នៃសភាជាតិ កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣វិញ ដំណើរការនៃការបោះឆ្នោតជ្រើសតាំងខាងលើមិនអនុវត្តតាមនីតិវិធីមាត្រា ៨២ថ្មី និងមាត្រា១១៩ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលបានអនុម័តនៅឆ្នាំ ១៩៩៣។ ដំណើរនីតិវិធីនៃការបោះឆ្នោតជ្រើសតាំង ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការនានា និងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ នៃសភាជាតិឆ្នាំ២០១៣ បានធ្វើឡើងតាមការបោះឆ្នោតជាកញ្ចប់ដោយយោងតាមមាត្រា០៤ នៃច្បាប់ធម្មនុញ្ញបន្ថែមដែលបានអនុម័តក្នុងឆ្នាំ២០០៤។ ប៉ុន្តែមាត្រា ៣ នៃច្បាប់ធម្មនុញ្ញបន្ថែមបានចែងយ៉ាងច្បាស់ថា គេអាចធ្វើការបោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុងពេលជាមួយគ្នានឹងការផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល ក្នុងករណីដែលឃើញថា នីតិវិធីនៃមាត្រា ៨២ និង ១១៩ ថ្មី នៃរដ្ឋធម្មនុញ្ញមិនអាចសម្រេចបាន។ ដូចនេះគណបក្សប្រជាជនកម្ពុជាមិនអនុវត្តមាត្រា ៨២ថ្មី និង ១១៩ថ្មី នៃរដ្ឋធម្មនុញ្ញ បើទោះបីគណបក្សនេះសន្មតថា ខ្លួនមានតំណាងរាស្ត្រគ្រប់ចំនួនក្តី។

ផ្អែកតាមលទ្ធផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលប្រកាសដោយ គ.ជ.ប កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣ គណបក្សប្រជាជនកម្ពុជាទទួលបានចំនួន ៦៨ នៃចំនួនអាសនៈសរុប ១២៣នៃរដ្ឋសភា។ លទ្ធផលនេះបានបង្ហាញយ៉ាងច្បាស់ថា គណបក្សប្រជាជនកម្ពុជាជាគណបក្សឈ្នះឆ្នោត ហើយទទួលបានអាសនៈលើសពីសម្លេងភាគច្រើនដាច់ខាតផងដែរ។ បន្ថែមលើសពីនេះទៀត ក្នុងកិច្ចប្រជុំបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្តខាងលើ គឺមានចំនួនកូរ៉ុមចំនួន៦៨លើ១២៣រូប ជាសម្លេងលើសមតិ

ភាគច្រើនដាច់ខាតដែលទាមទារឲ្យមានត្រឹមតែ៦៧រូបតែប៉ុណ្ណោះ។ ដូចនេះ ការបោះឆ្នោតជ្រើសតាំង ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការនានានៃសភាជាតិ និងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី ៥ នៃសភាជាតិ គឺត្រូវអនុវត្តតាមនីតិវិធីនៃមាត្រា ៨២ថ្មី មាត្រា១១៩ថ្មី និងមាត្រា ៩០ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ការធ្វើនីតិវិធីបោះឆ្នោតជាកញ្ចប់ ដោយយោងតាមមាត្រា០៤ នៃច្បាប់ធម្មនុញ្ញបន្ថែមនាពេលនេះ គឺធ្វើឲ្យរដ្ឋសភា និងរាជរដ្ឋាភិបាលខ្វះនីត្យានុកូលភាពក្នុងដំណើរការការងាររបស់ខ្លួន។

សរុបមក ការបង្កើតរដ្ឋសភា និងរាជរដ្ឋាភិបាលនីតិកាលទី៥ គឺមានបដិវាទពាក់ព័ន្ធការអនុវត្តន៍នីតិវិធី មាត្រា៧៦ មាត្រា ៨២ថ្មី មាត្រា១១៩ថ្មី និងមាត្រា ៩០ថ្មី(ពីរ)។ ការបង្កើតរដ្ឋសភាមិនគោរពតាមមាត្រា ៧៦ ដែលបានកំណត់ថា រដ្ឋសភាត្រូវមានសមាជិកតំណាងរាស្ត្រយ៉ាងតិច១២០រូប ព្រោះថាបេក្ខជនជាប់ឆ្នោត៥៥នាក់របស់គណបក្សសង្គ្រោះជាតិមិនទាន់ក្លាយជាអ្នកតំណាងរាស្ត្រ។ មិនមាននីតិវិធីច្បាស់លាស់មួយ ស្តីពីការផ្តល់សុពលភាពដើម្បីប្រែក្លាយបេក្ខជនជាប់ឆ្នោតទៅជាអ្នកតំណាងរាស្ត្រ។ បន្ថែមលើសពីនេះទៀត ការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាលមិនបានអនុវត្តតាមមាត្រា៨២ថ្មី និង ១១៩ថ្មី នៃរដ្ឋធម្មនុញ្ញដែលតម្រូវឲ្យមានការបោះឆ្នោតដាច់ដោយឡែកពីគ្នា។ ហើយការអនុវត្តន៍នេះមិនគោរពតាមស្មារតីនៃរដ្ឋធម្មនុញ្ញដែលផ្តោតសំខាន់លើការពង្រឹងឯកភាពជាតិកសាងប្រទេសឲ្យទៅរកការសន្តិភាពឡើងវិញផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ បដិវាទនៃការមិនអនុវត្តតាមរដ្ឋធម្មនុញ្ញ និងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របាននាំមកនូវការខ្វះនីត្យានុកូលភាព ឬខ្វះភាពត្រឹមត្រូវតាមច្បាប់ក្នុងកំរិតធ្ងន់ធ្ងរ។

## ១៦. អនុសាសន៍របស់ខុមហ្វ្រែល និងបន្ទប់ស្ថានការណ៍ស្តីពីយន្តការកំណែទម្រង់ការបោះឆ្នោត

យោងតាមកិច្ចព្រមព្រៀងរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិស្តីពីការបង្កើតយន្តការមួយដើម្បីកែទម្រង់ការបោះឆ្នោត ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងជំនួបកំពូលរវាងថ្នាក់ដឹកនាំគណបក្សទាំងពីរ។

ខាងក្រោមនេះ គឺជាការណែនាំអំពីការបង្កើតយន្តការកំណែទម្រង់បោះឆ្នោត តាមរយៈគណៈកម្មការពិសេសរដ្ឋសភា និងការបង្ហាញអនុសាសន៍សំខាន់ៗដែលយន្តការកំណែទម្រង់គួរយកទៅពិភាក្សា។ គណៈកម្មការនេះស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យរបស់គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។ អនុសាសន៍សម្រាប់កំណែទម្រង់បោះឆ្នោតផ្តោតយកចិត្តទុកដាក់លើបញ្ហាសំខាន់ៗដូចជាៈ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ក្រុមប្រឹក្សាធម្មនុញ្ញ ប្រព័ន្ធចុះឈ្មោះបោះឆ្នោត និងការបង្កើតបញ្ជីបោះឆ្នោត យន្តការដោះស្រាយទំនាស់បោះឆ្នោត ប្រព័ន្ធ និងពេលវេលានៃការបោះឆ្នោត តាំងពីបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដល់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាផ្សេងៗ និងបោះឆ្នោតជ្រើសរើសមេភូមិ ហិរញ្ញវត្ថុគណបក្សនយោបាយ តំណាងស្ត្រីជាប់ឆ្នោត កម្មវិធីអប់រំស្តីពីប្រជាធិបតេយ្យ និងការបោះឆ្នោត និងអាណត្តិនាយករដ្ឋមន្ត្រី...។ ជាមួយគ្នានេះក៏មានការបង្ហាញអំពីធាតុចេញ (output) ក្នុងអំឡុងឆ្នាំណាមួយ ដែលអនុសាសន៍កំណែទម្រង់បោះឆ្នោតនឹងត្រូវបានអនុវត្តដើម្បីឈានទៅរកការរៀបចំ ចាត់ចែងការបោះឆ្នោតនៅអាណត្តិខាងមុខដោយជោគជ័យ។

## ១៦.១. យន្តការកំណែទម្រង់បោះឆ្នោត

១.១ រដ្ឋសភា

យ៉ាងយូរចុងត្រីមាសទីមួយឆ្នាំ២០១៤ គណៈកម្មការពិសេសរបស់រដ្ឋសភាមួយនឹងត្រូវបានបង្កើត ដែលមានសមាសភាពស្មើគ្នា ជាសមាជិកសភាពីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។ គណៈកម្មការនេះធ្វើការសម្របសម្រួលយន្តការកំណែទម្រង់ ពិនិត្យរបាយការណ៍នានា និងដឹកនាំការអនុវត្តន៍អនុសាសន៍លំអិតទាំងឡាយ រួមទាំងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ច្បាប់ និងការផ្លាស់ប្តូរប្រព័ន្ធ និងការចាត់ចែងការបោះឆ្នោត។ គណៈកម្មការនេះត្រូវមានប្រធានប្តូរវេនរវាងគណបក្សទាំងពីរនៅរៀងរាល់ ៣ខែម្តង។ គណៈកម្មការនេះនឹងអញ្ជើញតំណាងរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ គ.ជ.ប និងអង្គការសង្គមស៊ីវិលមកចូលរួមប្រជុំ និងរាយការណ៍នានាទាក់ទងកំណែទម្រង់នេះ។ គណៈកម្មការពិសេសនឹងធ្វើនីតិវិធីដើម្បីដំណើរការការងារខ្លួន។

១.២ រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃមានតួនាទីគាំទ្រ និងអនុវត្តអនុសាសន៍ដែលសម្រេចដោយគណៈកម្មការពិសេសរបស់រដ្ឋសភា។

១.៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)

សហការក្នុងការអនុវត្តន៍អនុសាសន៍តាមការស្នើសុំរបស់គណៈកម្មការពិសេសរបស់រដ្ឋសភា និងផ្តល់យោបល់ និងកែលំអបទបញ្ញា និងនីតិវិធីបោះឆ្នោត។

១.៤ អង្គការសង្គមស៊ីវិល (បន្ទប់ស្ថានការណ៍នៃអង្គការ សមាគមក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ដូចជា NDI, IFES អង្គការដៃគូអភិវឌ្ឍន៍ និងអង្គការសិទ្ធិមនុស្សផ្សេងទៀត) បង្កើតសម្ព័ន្ធកំណែទម្រង់បោះឆ្នោត (ERA-Elections Reform Alliance in Cambodia) ដែលមានគណៈកម្មការ និងក្រុមការងារដូចខាងក្រោមៈ

**១.៤.១ គណៈកម្មការស្វែងរកការពិត (Truth Commission)**

យ៉ាងយូរដើមឆ្នាំ២០១៤ របាយការណ៍របស់គណៈកម្មការនេះនឹងត្រូវបានផ្សព្វផ្សាយ។

- ធ្វើសវនកម្មបញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់ ១១០២) តារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់១១០៨) និងសន្លឹកឆ្នោតពីក្នុងកញ្ចប់សុវត្ថិភាព «ក» និងគល់បញ្ជីលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត។
- ឬ/និងចងក្រងរបាយការណ៍នៃភាពមិនប្រក្រតីនៃការបោះឆ្នោត។

**១.៤.២ ក្រុមការងារ**

- ការពិគ្រោះយោបល់ តាមរយៈវេទិកា និងសិក្ខាសាលានៅគ្រប់រាជធានី ខេត្ត។
- យុទ្ធនាការដើម្បីឲ្យប្រជាពលរដ្ឋគាំទ្រ និងយល់ដឹង។

- ឥស្សរជនឯករាជ្យ អ្នកជំនាញច្បាប់ (ច្បាប់បោះឆ្នោត និងច្បាប់ពាក់ព័ន្ធ) ដើម្បីសិក្សា ផ្ដល់មតិ និងដាក់អនុសាសន៍លំអិត និងគម្រោងជាក់ស្ដែងទៅគណៈកម្មការពិសេស របស់រដ្ឋសភា។

## ១៦.២ អនុសាសន៍សំខាន់ៗសម្រាប់ការពិភាក្សា

1. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) គ្រប់លំដាប់ថ្នាក់ និងក្រុមប្រឹក្សាធម្មនុញ្ញ (រួមទាំងសមាសភាព រចនាសម្ព័ន្ធ និងតួនាទីភារកិច្ច) ត្រូវបានកែទម្រង់ ដោយមានការស្រុះស្រួលគ្នានៃគណបក្សក្នុងសភា៖

- វិសោធនកម្មរដ្ឋធម្មនុញ្ញដោយបន្ថែមមាត្រាខ្លះនៅក្នុងរដ្ឋធម្មនុញ្ញ ដើម្បីចែងអំពីការបង្កើតស្ថាប័នគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ជាស្ថាប័នកើតឡើងដោយច្បាប់រដ្ឋធម្មនុញ្ញ។
- ស្ថាប័ន គ.ជ.ប ត្រូវមានថវិកាស្វ័យយ័ត។
- ធ្វើវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយបង្កើតគណៈកម្មការជ្រើសរើសបេក្ខជនសម្រាប់សមាសភាពគ.ជ.ប ដោយជំនួសក្រសួងមហាផ្ទៃ និងគណៈរដ្ឋមន្ត្រី។
  - មានគណៈកម្មការជ្រើសរើសមួយ ដែលមានសមាសភាពពីក្រុមគណបក្សកាន់អំណាច និងក្រុមគណបក្សប្រឆាំងនៅក្នុងរដ្ឋសភា។
  - គណៈកម្មការនេះត្រូវមាននីតិវិធីជ្រើសរើសដោយបើកចំហ និងជាសាធារណៈដែលអនុញ្ញាតឲ្យបេក្ខជនដាក់ពាក្យឈរឈ្មោះជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ល័ក្ខខ័ណ្ឌចាំបាច់គឺ បេក្ខជនត្រូវលាឈប់ពីមន្ត្រីគណបក្សនយោបាយ បន្ទាប់ពីជាប់ជាសមាជិក គ.ជ.ប និងសន្យាថា មិនក្លាយជាមន្ត្រីគណបក្សនយោបាយរយៈពេល២ឆ្នាំ បន្ទាប់ពីចប់អាណត្តិរបស់ខ្លួន។ គណៈកម្មការជ្រើសរើសមានគោលការណ៍ដែលអនុញ្ញាតឲ្យក្រុមគណបក្សកាន់អំណាច និងក្រុមគណបក្សមិនកាន់អំណាច ចម្រាញ់ជ្រើសរើសបេក្ខជនចំនួន៤រូប យ៉ាងតិចស្ត្រី១រូប ស្មើៗគ្នា។
  - សម្រាប់បេក្ខជនប្រធាន គ.ជ.ប ត្រូវបានស្នើដោយព្រះមហាក្សត្រ។
  - រដ្ឋសភាផ្ដល់ការយល់ព្រមជាកញ្ចប់ដាក់សមាសភាពទាំង៩រូប តាមមតិពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។
- ការជ្រើសរើសសមាជិក និងមន្ត្រីសម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមរួមមាន៖ អគ្គលេខាធិការដ្ឋាន, នាយកដ្ឋាន, គណៈកម្មការខេត្ត រាជធានី, គណៈកម្មការឃុំសង្កាត់ និងការិយាល័យបោះឆ្នោតក៏ត្រូវបានអនុវត្ត តាមលក្ខណៈបើកចំហជាសាធារណៈ និងមានគណៈកម្មការជ្រើសរើសដោយមានសមាសភាពពីតំណាងគ.ជ.ប និងតំណាងគណបក្សមានអាសនៈក្នុងសភា។ ការសំរេចចិត្តចុងក្រោយក្នុងការតែងតាំង គឺគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។

2. សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែជាមនុស្សអព្យាក្រឹត្យ ដែលមិនមែនមន្ត្រីគណបក្សនយោបាយ ក្នុងនោះត្រូវលាលែងជាមន្ត្រីគណបក្សនយោបាយ មុនក្លាយជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ហើយមិនក្លាយជាមន្ត្រីគណបក្សនយោបាយរយៈពេលពីរឆ្នាំ បន្ទាប់ពីចប់អាណត្តិរបស់ខ្លួន។ តំណាងគណ

បក្សប្រឆាំងនៅក្នុងសភាគួរត្រូវបានឲ្យបញ្ជូនតំណាងមួយរបស់រដ្ឋសភាដើម្បីក្លាយជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។

3. កែលម្អប្រព័ន្ធផ្សព្វផ្សាយ ពិសេសទូរទស្សន៍ និងវិទ្យុ ដោយមានគោលនយោបាយ និងគោលការណ៍សមធម៌ តុល្យភាព និងសេរីសម្រាប់ការទទួលបានការប្រើប្រាស់ និងការផ្សព្វផ្សាយនៅអំឡុងពេលបោះឆ្នោត៖

បង្កើតក្រុមប្រឹក្សាភិបាលឯករាជ្យសម្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងពេលបោះឆ្នោត ដែលមានអំណាចគ្រប់គ្រងទូរទស្សន៍ជាតិ និងវិទ្យុជាតិ ព្រមទាំងត្រួតពិនិត្យការផ្សាយរបស់ទូរទស្សន៍ និងវិទ្យុឯកជនក្នុងអំឡុងពេលបោះឆ្នោត (អំឡុងពេលប្រតិទិននៃការបោះឆ្នោតរបស់ គ.ជ.ប)។ ក្រុមប្រឹក្សានេះមានសមាជិកចេញពីសមាគមអ្នកកាសែត១រូប, ពីសមាជិកគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភាក្រុមគណបក្សប្រឆាំង១រូប និងក្រុមគណបក្សកាន់អំណាច១រូប, គ.ជ.ប១រូប, អង្គការ សមាគមក្រៅរដ្ឋាភិបាលធ្វើការងារសង្កេតការណ៍បោះឆ្នោត១រូប។

4. ជាបន្ទាន់ រាជរដ្ឋាភិបាលត្រូវចេញអាជ្ញាប័ណ្ណបង្កើតប៉ុស្តិ៍ទូរទស្សន៍ និងវិទ្យុនៅតាមខេត្ត និងរាជធានីឲ្យទៅក្រុមហ៊ុន ឬអង្គការដែលមានការគាំទ្រដោយគណបក្សសង្គ្រោះជាតិ។

5. កំណែទម្រង់យន្តការដោះស្រាយទំនាស់វិវាទ និងបណ្តឹងបោះឆ្នោតឲ្យឯករាជ្យ រួមមានការបង្កើតយន្តការប្រសិទ្ធិភាពមួយសម្រាប់ការអង្កេតពីភាពមិនប្រក្រតី៖

វិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រ ដែលពង្រឹងសមត្ថកិច្ចក្រុមប្រឹក្សាធម្មនុញ្ញ និងបង្កើតនីតិវិធី បទបញ្ញា ទាក់ទងនឹងការដោះស្រាយគ្រប់ករណីនៃវិវាទបោះឆ្នោតដោយបន្ថែមយុត្តាធិការ ការដាក់បញ្ញាឲ្យមានការដាក់ពិន័យដល់សមាជិក និងមន្ត្រីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោគ្រប់លំដាប់ថ្នាក់។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ច និងតួនាទីដូចជាតុលាការកំពូលសម្រាប់ការដោះស្រាយវិវាទបោះឆ្នោត។

6. ធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដែលមានការបង្កើតគណៈកម្មការពិសេសនៅថ្នាក់ជាតិ និងរាជធានីខេត្ត សម្រាប់ដោះស្រាយវិវាទបោះឆ្នោត និងធ្វើការអង្កេតស្រាវជ្រាវភាពមិនប្រក្រតីបោះឆ្នោត។ គណៈកម្មការនេះមានសមាសភាពចម្រុះចេញមកពីតំណាងក្រុមប្រឹក្សាធម្មនុញ្ញ និង គជ.ប។.

7. បង្កើតច្បាប់មួយ ដើម្បីតម្លាភាពហិរញ្ញវត្ថុត្រួតពិនិត្យចំណូល និងកំណត់ការចំណាយរបស់គណបក្សនយោបាយ ជាពិសេសការផ្តល់មូលនិធិ ឬថវិកាជាតិដល់គណបក្សនយោបាយក្នុងដំណើរការឃោសនាបោះឆ្នោត៖

8. ផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះ និងការបង្កើតបញ្ជីឈ្មោះបោះឆ្នោតថ្មី ដែលអាចកំណត់បានអត្តសញ្ញាណអ្នកបោះឆ្នោតច្បាស់លាស់ និងមានប័ណ្ណបោះឆ្នោត។

- ការចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត គួរតែផ្លាស់ប្តូរទាំងស្រុងដើម្បីអោយការចុះឈ្មោះបោះឆ្នោតមានភាពងាយស្រួល និងសាមញ្ញ ហើយនិងធានាគុណ

ភាពនៃបញ្ជីឈ្មោះអ្នកបោះឆ្នោត ពិសេសកំណត់បានអត្តសញ្ញាណអ្នកបោះឆ្នោតច្បាស់លាស់ និងមានចេញប័ណ្ណបោះឆ្នោត។

- គួរធ្វើវិសោធនកម្មលើនីតិវិធីក្នុងការធ្វើអត្តសញ្ញាណបណ្ណសម្រាប់ប្រើបានអស់មួយជីវិត។ ប្រជាពលរដ្ឋត្រូវបានជំរុញអោយប្តូររូបថតរបស់ពួកគាត់ បន្ទាប់ពីបានប្រើប្រាស់អត្តសញ្ញាណ បណ្ណ ២០ឆ្នាំរួចមក។
- គ.ជ.ប ត្រូវចាត់ចែងការចុះឈ្មោះបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោត ជារៀងរាល់អំឡុងពេលបោះឆ្នោតធម្មតា និងមានចេញប័ណ្ណបោះឆ្នោត។
- គ.ជ.ប សហប្រតិបត្តិការជាមួយក្រសួង ឬស្ថាប័នរដ្ឋ អ្នកជំនាញ និងម្ចាស់ជំនួយកំពុងប្រឹងប្រែងក្នុងការផលិតកម្មវិធី ដើម្បីបង្កើតប្រពន្ធ័ចុះឈ្មោះបោះឆ្នោតដែលមានបញ្ចូលទិន្នន័យអត្តសញ្ញាណជីវសញ្ញា(មេដៃ) លេខអត្តសញ្ញាណប័ណ្ណអចិន្ត្រៃយ៍មួយ និងរូបថតផ្ទាល់ខ្លួន។
- ក្នុងករណីបន្ទាន់ ពិសេសការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ បន្ទាប់ពីរំលាយរដ្ឋសភាមុនអាណត្តិ គ.ជ.បត្រូវរៀបចំធ្វើបញ្ជីឈ្មោះអ្នកបោះឆ្នោតពិសេស ដាច់ដោយឡែកសំរាប់អ្នកមានសិទ្ធិបោះឆ្នោតថ្មីៗ ដោយប្រើទិន្នន័យអត្តសញ្ញាប័ណ្ណ និងអត្រានុកូលដ្ឋាន។ បញ្ជីឈ្មោះអ្នកបោះឆ្នោតដាច់ដោយឡែកត្រូវបានបិទ ហើយបើកឲ្យមានការប្តឹងតវ៉ា និងជំទាស់។

9. ពង្រឹងការអនុវត្តន៍ច្បាប់ឲ្យបានពេញលេញអំពីភាពអព្យាក្រឹត្យ មិនលម្អៀងដាច់ខាតសម្រាប់ទាំងស្ថាប័ន និងមន្ត្រីនៃកងយោធពលខេមរភូមិន្ទ នគរបាល និងមន្ត្រីតុលាការក្នុងការធ្វើសកម្មភាពគាំទ្រ និងប្រឆាំងគណបក្សណាមួយ។

បង្កើតគោលនយោបាយពិសេស ឬអនុក្រឹត្យមួយដើម្បីពង្រឹងអព្យាក្រឹត្យភាពរបស់កងយោធពលខេមរភូមិន្ទ មន្ត្រីតុលាការ និងកងកម្លាំងនគរបាលជាតិ និងការអនុវត្តន៍មាត្រា ១៥ នៃច្បាប់ស្តីពីគណបក្សនយោបាយ។ មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ អាចចូលរួមជាសមាជិកគណបក្សនយោបាយនានាបាន តែមិនមែនជាមន្ត្រីគណបក្សនយោបាយ ហើយក៏មិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ។ មន្ត្រីដូចបានរៀបរាប់ខាងលើ អាចចូលរួមស្តាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់បាន ប៉ុន្តែមិនត្រូវពាក់អាវ និងមួកនៃគណបក្សនយោបាយ ឬបេក្ខជននោះបានទេ។ ហើយកងយោធពលខេមរភូមិន្ទ នគរបាលមានតួនាទីសំខាន់ផ្ទាល់រក្សាសន្តិសុខក្នុងដំណើរការបោះឆ្នោត ហើយមន្ត្រីតុលាការក៏នឹងចូលរួមផ្ទាល់ក្នុងការងារបណ្តឹងទាក់ទិនការបោះឆ្នោត។

10. មានច្បាប់ ឬ គោលនយោបាយដើម្បីកំណត់កូតាស្ត្រីជាតំណាងជាប់ឆ្នោត។និង/

ធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដោយកំណត់ចំនួនកូតាស្ត្រី ឬបុរស៥0% ជាលក្ខខណ្ឌសំរាប់ចុះបញ្ជីឈ្មោះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ហើយដាក់ក្នុងបញ្ជីលេខរៀងឆ្លាស់គ្នារាប់ពីខាងលើ។ គណបក្សនយោបាយដែលមិនអនុវត្តកូតានេះនឹងទទួលការផាកពិន័យ។

11. ការបោះឆ្នោតជ្រើសរើសមេភូមិ

ការបោះឆ្នោតជ្រើសរើសមេភូមិដោយផ្ទាល់ពីប្រជាពលរដ្ឋក្នុងភូមិ ដោយមាននីតិវិធីសាមញ្ញមួយក្នុងការចាត់ចែងពីក្រុមប្រឹក្សាឃុំសង្កាត់ និងប្រជាពលរដ្ឋក្នុងភូមិ។

12. កែទម្រង់ប្រព័ន្ធ និងដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ប្រព័ន្ធការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាការបោះឆ្នោតជាសកល និងមានដំណើរការក្នុងអំឡុងពេលតែមួយនឹងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដោយគ្រាន់តែរៀបចំសន្លឹកឆ្នោត និងហិបឆ្នោតផ្សេងគ្នា (អាចត្រឹមពីរប្រភេទ)។

ប្រព័ន្ធបោះឆ្នោតសកលសម្រាប់ជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាប្រព័ន្ធចម្រុះ។ ប្រព័ន្ធនេះអនុញ្ញាតឲ្យបេក្ខជន ឬក្រុមបេក្ខជនឯករាជ្យឈរឈ្មោះប្រកួតជាមួយនឹងបញ្ជីគណបក្សនយោបាយ។

13. ដូរថ្ងៃបោះឆ្នោតៈ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ជ្រើសតាំងសមាជិកព្រឹទ្ធសភា និងក្រុមប្រឹក្សាផ្សេងទៀត ព្រមទាំងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅថ្ងៃអាទិត្យក្នុងខែមេសា ឬខែធ្នូ។
14. ធ្វើវិសោធនកម្មច្បាប់គណបក្សនយោបាយ ដើម្បីលើកស្ទួយសេរីភាពក្នុងការរួមបញ្ចូលគ្នារបស់គណបក្សនយោបាយ។ គណបក្សនយោបាយរួមបញ្ចូលគ្នាជាមួយគណបក្សនយោបាយផ្សេង បើទោះបីក្រសួងមហាផ្ទៃលុបឈ្មោះគណបក្សនយោបាយដែលប្រកាសបញ្ចូលគ្នា ក៏តំណាងជាប់ឆ្នោតរបស់គណបក្សនយោបាយទាំងនោះនឹងក្លាយជាតំណាងជាប់ឆ្នោតនៃគណបក្សបញ្ចូលគ្នាមួយនោះ។
15. បង្កើតកម្មវិធីអប់រំស្តីពីប្រជាធិបតេយ្យ និងការបោះឆ្នោត ដាក់បញ្ចូលក្នុងកម្មវិធីអប់រំរបស់ជាតិនៅតាមសាលារៀនចាប់ពីអនុវិទ្យាល័យឡើងទៅ។
16. នាយករដ្ឋមន្ត្រីម្នាក់អាចបន្តបានត្រឹមតែពីរអាណត្តិ ១០ឆ្នាំ។

## ឧបសម្ព័ន្ធទី១៖ សេចក្តីថ្លែងការណ៍របស់គណបក្សប្រជាជនកម្ពុជា

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

**សេចក្តីថ្លែងការណ៍**
**របស់គណបក្សប្រជាជនកម្ពុជា**

ជនរួមជាតិជាទីគោរពស្នេហា !

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៥ កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៣ កន្លងទៅនេះ បានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ប្រជាធិបតេយ្យ ។ នៅក្នុងបរិយាកាសនយោបាយប្រកបដោយសន្តិភាព សេរី និងតម្លាភាព ប្រជាជនកម្ពុជាដែលមានឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតយ៉ាងច្រើនកុះករបំផុតបានអនុវត្តនូវសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនក្នុងភាពជាម្ចាស់ ប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ និងការទទួលខុសត្រូវ ដើម្បីជ្រើសរើសគណបក្សនយោបាយ និងឥស្សរជនឆ្នើមឱ្យដឹកនាំប្រទេសសម្រាប់រយៈពេល ៥ឆ្នាំបន្តទៀតស្របទៅតាមឆន្ទៈរបស់ខ្លួន។ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិបានអបអរសាទរ និងធ្វើការវាយតម្លៃប្រកបដោយភាពវិជ្ជមានក្រៃលែងចំពោះការបោះឆ្នោតនេះ ហើយបានធ្វើការកត់សម្គាល់ថា ទោះបីជាមានបញ្ហាខ្វះខាតតិចតួចក្តី ក៏ពុំបានធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតឡើយ ។ នេះជាសមិទ្ធផលជាប្រវត្តិសាស្ត្រថ្មីមួយទៀតរបស់ជាតិយើង ដែលបានឆ្លុះបញ្ចាំងឱ្យឃើញនូវភាពចាស់ទុំនៃប្រជាធិបតេយ្យនៅកម្ពុជា និងបំណងប្រាថ្នារបស់ប្រជាជន ដើម្បីបន្តស្ថាបនាសង្គមជាតិរបស់ខ្លួនប្រកបដោយសន្តិភាព សេរីភាព សមភាព យុត្តិធម៌ និងវឌ្ឍនភាព ដែលរួចចាកផុតពីភាពក្រីក្រ ។

នៅក្នុងឱកាសនេះ គណបក្សប្រជាជនកម្ពុជា សូមប្រកាសជាឧឡារិក**ទទួលយកលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៥** ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាសនាថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៣ នេះ ហើយប្តេជ្ញាការពារលទ្ធផលនៃការបោះឆ្នោតនេះ ដែលបានកើតចេញពីឆន្ទៈរបស់ប្រជាជនពិតប្រាកដ ។

គណបក្សប្រជាជនកម្ពុជាសូមសម្តែងនូវការគោរព និងដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះជនរួមជាតិនៅគ្រប់ទិសទី ដែលបានផ្តល់យុត្តិធម៌ចំពោះការដឹកនាំរបស់គណបក្សរយៈពេលជិត ៣៥ឆ្នាំមកនេះ ហើយបានបន្តបោះឆ្នោតគាំទ្រឱ្យគណបក្សទទួលបានជ័យជម្នះជាថ្មីទៀត ។ ប្រការនេះបានបង្ហាញយ៉ាងច្បាស់ថា ប្រជាជនកម្ពុជានៅតែមានជំនឿទុកចិត្តយ៉ាងមុតមាំមកលើគណបក្សប្រជាជនកម្ពុជា ក្នុងការដឹកនាំ កសាង និងការពារមាតុភូមិតទៅមុខទៀត ទោះបីជាមានមជ្ឈដ្ឋានអគតិខ្លះបានខិតខំរកគ្រប់វិធី ដើម្បីបំបែកបំបាក់ចំណងទាក់ទងដ៏ស្អិតរមួត រវាងគណបក្ស និងប្រជាជនយ៉ាងណាក្តី ។

គណបក្សប្រជាជនកម្ពុជា សូមវាយតម្លៃខ្ពស់ចំពោះការខិតខំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានជំនះរាល់ការលំបាកស្មុគស្មាញនានាក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ធានាឱ្យដំណើរការរៀបចំការបោះឆ្នោតទាំងមូលបានប្រព្រឹត្តទៅយ៉ាងល្អប្រសើរ និងទៀងទាត់តាមប្រតិទិនការងារ ដោយប្រកាន់ខ្ជាប់នូវជំហរ

ឯករាជ្យ អព្យាក្រឹត និងតម្លាភាព លើមូលដ្ឋានអនុវត្តយ៉ាងត្រឹមត្រូវ តាមច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត។ ព្រមជាមួយនេះ សូមវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាល គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលបានយកអស់លទ្ធភាពជួយគាំទ្រដល់កិច្ចដំណើរការរៀបចំការបោះឆ្នោត និងការពារស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈបានល្អប្រសើរ ទាំងក្នុងពេលយុទ្ធនាការឃោសនា ពេលបោះឆ្នោត ក៏ដូចក្រោយពេលបោះឆ្នោត។

ទន្ទឹមនេះក្នុងនាមប្រជាជនកម្ពុជា សូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបណ្តាប្រទេសជាមិត្ត សហគមន៍អន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ និងមជ្ឈដ្ឋាននានាក្នុងសង្គម ដែលបានចូលរួមសង្កេតការណ៍ និងសម្តែងការអបអរសាទរចំពោះជោគជ័យនៃដំណើរការបោះឆ្នោតនៅកម្ពុជា។ វិភាគទានដ៏ថ្លៃថ្លានេះ ជាកត្តាលើកទឹកចិត្តដ៏សំខាន់ចំពោះដំណើរការនៃប្រជាធិបតេយ្យនៅកម្ពុជាទាំងក្នុងពេលបច្ចុប្បន្ន ក៏ដូចតទៅមុខទៀត ។

ជនរួមជាតិជាទីគោរពស្នេហា ដើម្បីឆ្លើយតបទៅនឹងការជឿទុកចិត្តរបស់ជនរួមជាតិ គណបក្សប្រជាជនកម្ពុជា សូមសន្យាថា នឹងប្រមូលផ្តុំគ្រប់កម្លាំង និងលទ្ធភាពទាំងអស់របស់ខ្លួន ដើម្បីអនុវត្តនូវកម្មវិធីនយោបាយដែលបានប្រកាសជូនជនរួមជាតិរួចមកហើយ សំដៅសម្រេចនូវគោលដៅធំៗទាំងឡាយគឺ ការការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីនៃមាតុភូមិ ការថែរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការបន្តអនុវត្តកំណែទម្រង់រដ្ឋដ៏ស៊ីជម្រៅ និងដាច់ខាត ការលប់បំបាត់នូវបាតុភាពអសកម្មទាំងឡាយដែលធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ប្រទេសជាតិ និងប្រជាពលរដ្ឋ ការបន្តអភិវឌ្ឍសេដ្ឋកិច្ច សង្គមឱ្យកាន់តែរីកចម្រើនខ្លាំងឡើង ការបន្តជំរុញដំឡើងប្រាក់បៀវត្សរបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ក៏ដូចកម្មករ និយោជិត និងការលើកកម្ពស់ឥតឈប់ឈរនូវកម្រិតជីវភាព និងសុខុមាលភាពរបស់ប្រជាជនគ្រប់ៗរូប ជាពិសេសប្រជាជនក្រីក្រដែលកំពុងមានជីវភាពលំបាកលំបិន ។

ដើម្បីសម្រេចនូវរាល់គោលដៅខាងលើនេះ គណបក្សប្រជាជនកម្ពុជា នឹងរៀបចំរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៥ ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលដែលបម្រើនូវឆន្ទៈ និងផលប្រយោជន៍របស់ប្រជាជនទាំងស្រុង ប្រកបដោយតម្លាភាព និងមានសមត្ថភាពពេញលេញក្នុងការដឹកនាំប្រទេសជាតិ។

**គណបក្សប្រជាជនកម្ពុជា** សូមអំពាវនាវជនរួមជាតិទាំងអស់ ទោះបីបានបោះឆ្នោតគាំទ្រគណបក្សនយោបាយណាក្តី សូមរួមសាមគ្គីគ្នាជាធ្លុងមួយក្រោមដំបូលរដ្ឋធម្មនុញ្ញ និងក្រោមម្លប់ដ៏ត្រជាក់នៃ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៃយើង និងសាមគ្គីជុំវិញរាជរដ្ឋាភិបាល ដើម្បីថែរក្សារាល់សមិទ្ធផលរបស់ជាតិ បន្តការពារ និងកសាងមាតុភូមិកម្ពុជាឆ្ពោះទៅរកអនាគតដ៏រុងរឿង។ ព្រមជាមួយនេះ សូមអំពាវនាវដល់គណបក្សដែលទទួលបានអាសនៈក្នុងរដ្ឋសភា នីតិកាលទី ៥ សូមតម្កល់នូវឧត្តមប្រយោជន៍របស់ប្រទេសជាតិ និងប្រជាជនជាធំលើសអ្វីៗទាំងអស់ ហើយធ្វើការរួមគ្នា ដោយឈរលើមូលដ្ឋានរដ្ឋធម្មនុញ្ញ ច្បាប់ និងគោលការណ៍នៃប្រជាធិបតេយ្យ និងស្មារតីបង្រួបបង្រួមជាតិ ដើម្បីធានាឱ្យរដ្ឋសភានីតិកាលទី ៥ បានចាប់ផ្តើមការងាររបស់ខ្លួនយ៉ាងល្អប្រសើរ ស្របតាមរដ្ឋធម្មនុញ្ញ និងបំណងប្រាថ្នារបស់ប្រជាជនយើង។

ជាទីបញ្ចប់សូមប្រសិទ្ធពរជូនជនរួមជាតិ សូមបានប្រកបពុទ្ធពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៣

**គណបក្សប្រជាជនកម្ពុជា**

២

## ឧបសម្ព័ន្ធទី២៖ សេចក្តីថ្លែងការណ៍របស់គណបក្សសង្គ្រោះជាតិ

គណបក្សសង្គ្រោះជាតិ

CAMBODIA NATIONAL RESCUE PARTY

សង្គ្រោះ បម្រើ ការពារ

### សេចក្តីថ្លែងការណ៍

**គណបក្សសង្គ្រោះជាតិ** គាំទ្រញត្តិដែលសម្រេចអនុម័តដោយប្រជាពលរដ្ឋខ្មែរ ចូលរួមក្នុងមហាបាតុកម្មអហិង្សា កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ ។

**គណបក្សសង្គ្រោះជាតិ** គាំទ្រសេចក្តីអំពាវនាវបន្ទាន់របស់បន្ទប់ស្ថានការណ៍ ដែលបានដាក់ជូនគណបក្សសង្គ្រោះជាតិ ក្នុងអំឡុងពេលធ្វើមហាបាតុកម្មអហិង្សា កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ ។

**គណបក្សសង្គ្រោះជាតិ** សូមថ្លែងអំណរគុណសាជាថ្មីម្តងទៀតដល់បងប្អូនប្រជាពលរដ្ឋខ្មែរ ដែលបានបោះឆ្នោតគាំទ្រដល់បេក្ខជនតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ដែលលទ្ធផលនៃការបោះឆ្នោតនេះ សល់ពីការបំភិតបំភ័យ និងលួចបន្លំសន្លឹកឆ្នោតនៅទូទាំងប្រទេស ។

**គណបក្សសង្គ្រោះជាតិ** ជំទាស់នូវលទ្ធផលនៃការបោះឆ្នោត ដែលបានប្រកាសដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣ និងនៅតែបន្តទាមទារឲ្យមានការបង្កើតគណៈកម្មការចម្រុះឯករាជ្យមួយដើម្បីស៊ើបអង្កេត និងដោះស្រាយភាពមិនប្រក្រតីនៃការបោះឆ្នោតជាតិអាណត្តិទី៥ ។ ក្នុងករណីដែលមិនមានដំណោះស្រាយសមស្របណាមួយដើម្បីរកយុត្តិធម៌ជូនម្ចាស់ឆ្នោត គណបក្សសង្គ្រោះជាតិនឹងបន្តរៀបចំមហាបាតុកម្មអហិង្សាដើម្បីសម្តែងពីឆន្ទៈរបស់មហាជនខ្មែរ ចាប់ពីថ្ងៃទី១៥ ១៦ និង១៧ ខែកញ្ញា ឆ្នាំ២០១៣ នេះតទៅ រហូតដល់មានដំណោះស្រាយប្រកបដោយយុត្តិធម៌ជូនប្រជាពលរដ្ឋខ្មែរដែលជាម្ចាស់ឆ្នោត ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣

គណបក្សសង្គ្រោះជាតិ

CAMBODIA NATIONAL RESCUE PARTY

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង*

*ទូរស័ព្ទលេខ ៖ 012 788 999*

ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Headquarters : House #576, National Road Nº2, Sangkat Chakangres Leu, Khan Mean Chey Phnom Penh, Kingdom of Cambodia

Tel : 012 90 57 75 / 092 92 51 71

## ឧបសម្ព័ន្ធទី៣៖ សេចក្តីប្រកាសរួមនៃជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិ

### សេចក្តីប្រកាសរួមនៃជំនួបកំពូល
### រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ
### ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៣

នាព្រឹកថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៣ គណៈប្រតិភូគណបក្សប្រជាជនកម្ពុជា ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងគណៈប្រតិភូគណបក្សសង្គ្រោះជាតិ ដឹកនាំដោយ **ឯកឧត្តម សម រង្ស៊ី** បានជួបប្រជុំដើម្បីពិភាក្សាគ្នា និងរកដំណោះស្រាយចំពោះបញ្ហាប្រទេសជាតិ តបតាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់ របស់ **ព្រះករុណា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** កាលពីប្រជុំកំពូលថ្ងៃទី ១៤ ខែកញ្ញា កន្លងទៅ ដោយទទួលបានលទ្ធផលដូចខាងក្រោម:

១- ភាគីទាំងពីរ បានឯកភាពគ្នាគោរព និងអនុវត្តដោយហ្មត់ចត់តាមព្រះរាជសាររបស់ **ព្រះករុណា ព្រះមហាក្សត្រ** ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៣ អំពាវនាវចំពោះជនរួមជាតិទាំងមូល ដែលជាក្រុមបាតុករ និងក្រុមសមត្ថកិច្ច សូមបញ្ឈប់ការប្រើអំពើហិង្សាតាមរូបភាពណាក៏ដោយ ដូចជាការគប់ដុំថ្ម និងការប្រើប្រាស់អាវុធ ដែលបណ្តាលអោយបងប្អូនទាំងអស់គ្នាទទួលរងរបួស ឬបាត់បង់ជីវិត និងបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សង្គមជាតិទាំងមូល ហើយងាកមកប្រកាន់យកប្រពៃណីអហិង្សា ខិតខំយោគយល់គ្នា រាប់អានគ្នាជាខ្មែរដូចគ្នា និងអត់ធ្មត់ជាអតិបរមា ដើម្បីបញ្ចៀសអស្ថិរភាពនៃជាតិយើង ព្រមទាំងរក្សាភាពថ្លៃថ្នូរ និងភាពស្ងាត់ស្ងៀម ដើម្បីទុកឱកាសរកដំណោះស្រាយបញ្ហាជាតិយើងទាំងអស់គ្នា ។

២- ភាគីទាំងពីរព្រមព្រៀងគ្នា នឹងបង្កើតយន្តការមួយដើម្បីកែទម្រង់ការបោះឆ្នោតនាពេលខាងមុខ ។

៣- ភាគីទាំងពីរនឹងបន្តជួបចរចាគ្នាតទៅទៀតតាមគ្រប់កម្រិតដើម្បីដោះស្រាយបញ្ហារបស់ជាតិ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៣

| **តំណាងគណបក្សប្រជាជនកម្ពុជា** | **តំណាងគណបក្សសង្គ្រោះជាតិ** |
|---|---|
| **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** | **ឯកឧត្តម សម រង្ស៊ី** |
| **ឯកឧត្តម សាយ ឈុំ** **ឯកឧត្តម ស ខេង** | **ឯកឧត្តម កឹម សុខា** **ឯកឧត្តម ប៉ុល ហំម** |

## ឧបសម្ព័ន្ធទី៥៖ ការឆ្លើយតបរបស់ខុមហ្វ្រែលទាក់ទងទៅនឹងសៀវភៅសរបស់គ.ជ.ប

### ❖ បញ្ជីបោះឆ្នោត

យោងតាមសៀវភៅស ស្តីពីការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥នៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលចេញនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣ បានលើកឡើងពីការស្ទាបស្ទង់មតិពីរដោយឡែកពីគ្នាដែលធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ បានបង្ហាញឲ្យឃើញនូវភាពខុសគ្នាយ៉ាងច្រើន។ ការស្ទាបស្ទង់មតិមួយបង្ហាញថា អ្នកផ្តល់ព័ត៌មានចំនួន៩៧,៧% បានអះអាងថា បានចុះឈ្មោះបោះឆ្នោត ខណៈដែលតួលេខប្រៀបធៀបនៅក្នុងការស្ទង់មតិមួយផ្សេងទៀតគឺមានតែ៨២,៩%ប៉ុណ្ណោះ។

ខុមហ្វ្រែលបានធ្វើការស្រាវជ្រាវទៅលើបញ្ជីឈ្មោះបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត និងសវនកម្មបញ្ជីឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ២០១៣ ដែលក្នុងនោះបានជ្រើសរើសការិយាល័យសំណាក២២៣ នៅក្នុង២៤ខេត្ត/ក្រុង ជាមួយនឹងការជ្រើសរើសដោយចៃដន្យអ្នកមានសិទ្ធិបោះឆ្នោត២៦០០នាក់។ ការសិក្សាស្រាវជ្រាវក៏បានរកឃើញថា ៩៧,៧%នៃអ្នកផ្តល់បទសម្ភាសន៍បានឆ្លើយថាពួកគេបានចុះឈ្មោះបោះឆ្នោត ខុមហ្វ្រែលបានធ្វើការស្រាវជ្រាវអ្នកដែលឆ្លើយថា បានចុះឈ្មោះបោះឆ្នោតផ្ទៀងផ្ទាត់ជាមួយបញ្ជីឈ្មោះផ្លូវការរបស់គ.ជ.ប ដែលចេញនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ បានរកឃើញថា ១៣,៥% មិនមានទិន្នន័យនៅក្នុងបញ្ជីបោះឆ្នោត បើទោះបីជាពួកគាត់ធ្លាប់បានបោះឆ្នោត និងចុះឈ្មោះកន្លងមកក៏ដោយ។ ដូច្នេះបើគិតអំពីតួលេខរបស់ខុមហ្វ្រែល និងអង្គការNDI ឃើញថា មិនសូវខុសប្លែកគ្នាប៉ុន្មានទេ ពីព្រោះថា NDI បានបង្ហាញអំពីចំនួនអ្នកដែលមានឈ្មោះនៅក្នុងបញ្ជីពិតប្រាកដ ៨២,៩% រីឯខុមហ្វ្រែលបានបង្ហាញពីអ្នកបានចុះឈ្មោះ ប៉ុន្តែឈ្មោះពួកគេខ្លះត្រូវបានរកពុំឃើញ នេះមិនន័យថា តួលេខរបស់អង្គការទាំងពីរនេះមិនខុសគ្នាខ្លាំងនោះទេ។

### ❖ ការប្រកាសលទ្ធផលឆ្នោតលឿនរបស់ខុមហ្វ្រែល

ទាក់ទងទៅនឹងការលើកឡើងនៅក្នុងសៀវភៅសស្តីពីការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥នៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានបង្ហាញពីការគណនាលទ្ធផលនៃការបោះឆ្នោតរបស់ខុមហ្វ្រែល។ សូមបញ្ជាក់ថា ខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍នៅប្រមាណ១,៤៧០ការិយាល័យសំណាកទូទាំងប្រទេសដើម្បីប្រមូលលទ្ធផលបោះឆ្នោត។ ការប្រមូលលទ្ធផលបោះឆ្នោតលឿននេះ អ្នកសង្កេតការណ៍របស់ខុមហ្វ្រែលគ្រាន់តែធ្វើការប្រមូលដោយពុំទាន់គិតពីភាពមិនប្រក្រតីដែលកើតឡើងក្នុងកំឡុងពេលបោះ និងរាប់សន្លឹកឆ្នោតនោះទេ។ ដូច្នេះលទ្ធផលមិនផ្លូវការដែលខុមហ្វ្រែលបង្ហាញពុំបញ្ជាក់ពីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ឡើយ។

### ❖ ទឹកខ្មៅលុបលាងមិនជ្រះ

ទឹកថ្នាំសម្រាប់ការបោះឆ្នោត គឺជាទឹកថ្នាំដែលមិនហើរពណ៌ ហើយត្រូវបានប្រើទៅលើចង្អុលដៃរបស់អ្នកបោះឆ្នោតក្នុងថ្ងៃបោះឆ្នោតដើម្បីបង្ការការក្លែងបន្លំការបោះឆ្នោត ដូចជាការបោះឆ្នោតពីរដង។ វាជាធម្មតាត្រូវបានប្រើនៅលើស្បែកជុំវិញគល់ក្រចក និងក្រចកនៃចង្អុលដៃ ដែលជាកន្លែងពិបាកនឹងលាង ឬជូតសម្អា

ត។ ទឹកថ្នាំនេះជាធម្មតាមានពណ៌ស្វាយនៅមុនពេលដែលសារធាតុប៉ះពន្លឺមិនបានមានប្រតិកម្មទៅជាពណ៌ខ្មៅ ឬត្នោតវិញ។ ប្រទេសឥណ្ឌាមានជំនាញក្នុងការផលិត និងផ្គត់ផ្គង់ទឹកថ្នាំលុបលាងមិនជ្រះនេះ[15]។

ទឹកថ្នាំសម្រាប់ការបោះឆ្នោតសម្រាប់សម្គាល់ស្នាមប្រឡាក់ ជាធម្មតាមានផ្ទុកសារធាតុពណ៌សម្រាប់ការកត់សម្គាល់ភ្លាមៗ ហើយសារធាតុនីត្រាតពណ៌ប្រាក់ (silver nitrate solution) ដែលប្រឡាក់នៅលើស្បែកនៅពេលត្រូវពន្លឺព្រះអាទិត្យ វានឹងបន្សល់ទុកនូវស្នាមដែលមិនអាចលាងជ្រះភ្លាមៗនោះទេ។ ស្តង់ដារឧស្សាហកម្មនៃទឹកថ្នាំបោះឆ្នោតនេះគឺមានចំនួន ១០%, ១៤% ឬ ១៨% នៃសារធាតុនីត្រាតពណ៌ប្រាក់[16]។

ទឹកខ្មៅលុបលាងមិនជ្រះ គឺជាសម្ភារៈសំខាន់មួយក្នុងចំណោមសម្ភារៈផ្សេងទៀតដូចជាសន្លឹកឆ្នោត បញ្ជីបោះឆ្នោត និងហិបឆ្នោតជាដើម ដែលសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត។ ទឹកខ្មៅលុបលាងមិនជ្រះគឺជានិមិត្តសញ្ញានៃសុចរិតភាព និងតម្លាភាពក្នុងដំណើរការបោះឆ្នោត ហើយវាជាសញ្ញាសម្រាប់មន្ត្រីការិយាល័យបោះឆ្នោតការពារមិនឲ្យមានអ្នកបោះឆ្នោតបានលើសពីមួយដង[17]។

ការបង្ហាញទឹកខ្មៅលុបលាងមិនជ្រះនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣ និងការអនុញ្ញាតឲ្យតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានអាចធ្វើការសាកល្បងជ្រលក់ទឹកខ្មៅនេះ គឺដើម្បីចង់បង្ហាញអំពីគុណភាពនៃទឹកខ្មៅលុបលាងមិនជ្រះនេះ[18]។

កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំពិធីប្រគល់ និងទទួលអំណោយទឹកខ្មៅលុបលាងមិនជ្រះចំនួន ៤០,០០០ដប ពីសាធារណរដ្ឋឥណ្ឌា។ លុះនៅរសៀលថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ២០១៣ គ.ជ.ប បានរៀបចំកិច្ចប្រជុំមួយស្តីពីព្រឹត្តិការណ៍ទូទៅនៃការឃោសនាបោះឆ្នោត ការបង្ហាញសម្ភារៈបោះឆ្នោត និងទឹកខ្មៅលុបលាងមិនជ្រះដល់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មាន ក្រោមអធិបតីភាព ឯកឧត្តម ហាវ៉ាណ ស៊ីរីល័យ សមាជិក គ.ជ.ប។ ក្នុងកិច្ចប្រជុំនោះដែរ គ.ជ.ប បានអនុញ្ញាតឲ្យតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានធ្វើការសាកល្បងជ្រលក់ទឹកខ្មៅនេះ ដើម្បីចង់បង្ហាញអំពីគុណភាពនៃទឹកខ្មៅលុបលាងមិនជ្រះនោះ។ លោក ហ៊ី រ៉ុង ប្រធាននាយកដ្ឋានប្រតិបត្តិការរបស់ គ.ជ.ប ទទួលភារកិច្ចរៀបចំ និងដឹកនាំការជ្រលក់សាកល្បងទឹកខ្មៅនាពេលនោះ ដោយមានតំណាងគណបក្សនយោបាយមួយចំនួន អ្នកសង្កេតការណ៍បោះឆ្នោត និងរួមទាំងអ្នកចូលរួមផ្សេងទៀតបានធ្វើការសាកល្បង។ ក្នុងការសាកល្បងនោះបុគ្គលិករបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានចូលរួមជ្រលក់សាកល្បងទឹកខ្មៅនោះផងដែរ។ ពិធីនោះបានធ្វើឡើងជាសាធារណៈនៅចំពោះមុខមន្ត្រី គ.ជ.ប តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ។ នៅបន្ទាប់ពីការជ្រលក់សាកល្បងបានធ្វើត្រឹមត្រូវតាមនីតិវិធី គ.ជ.ប លោក ហ៊ី រ៉ុង ដែលជាអ្នកអនុវត្តការងារនោះដោយផ្ទាល់បាន

[15] http://www.rayuduchemlabs.com/voter-marking-ink/voter-marking-ink.html

[16] http://www.rayuduchemlabs.com/electoral-marking-stain/electoral-marking-stain.html

[17] ប្រសាសន៍ឯកឧត្តម អ៊ឹម សួស្តី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ថ្លែងក្នុងពិធីទទួលដបទឹកខ្មៅលុបលាងមិនជ្រះពីរដ្ឋាភិបាលឥណ្ឌាកាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ នៅទីស្តីការ គ.ជ.ប។

[18] សេចក្តីប្រកាសព័ត៌មានរបស់ គ.ជ.ប លេខ ០៧.០៨៣/១៣ គ.ជ.ប.អគ្គ.ពស ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៣។

បញ្ជាក់ឲ្យអ្នកដែលចូលរួមសាកល្បងធ្វើការលុបលាងទឹកខ្មៅពីម្រាមដៃ និងឆ្លើយតបទៅ គ.ជ.ប វិញអំពីលទ្ធផលនៃការលុបលាងនោះ។

នៅរយៈពេលជិតបីម៉ោងនៅក្រោយពិធីនោះ បុគ្គលិកខុមហ្វ្រែលទាំងពីរនាក់នោះបានធ្វើការសាកល្បងលាងសម្អាតទឹកខ្មៅចេញពីម្រាមដៃនៅស្នាក់ការកណ្តាលខុមហ្វ្រែល ដោយប្រើប្រាស់ផលិតផលមួយចំនួនដូចជាៈ សាំងក្រអូប ទឹកថ្នាំអ៊ុតសក់ និងទឹកលាងក្រចក ហើយជាលទ្ធផលការលាងសម្អាតនោះបានជ្រះទាំងស្រុង។ ភ្លាមនោះតំណាងខុមហ្វ្រែល ក៏បានទំនាក់ទំនងទៅតំណាង គ.ជ.ប ដើម្បីជម្រាបអំពីដំណឹងនេះ ហើយតំណាង គ.ជ.ប ក៏បានអញ្ជើញបុគ្គលិកខុមហ្វ្រែលទាំងពីរនាក់នោះទៅទីស្តីការ គ.ជ.ប នៅវេលាម៉ោងប្រមាណ ៨និង៣០នាទីយប់ ដើម្បីពិនិត្យដោយផ្ទាល់ភ្នែក។ ការពិនិត្យនោះឃើញមានវត្តមានលោក ហ៊ឹ រ៉ុង ប្រធាននាយកដ្ឋានប្រតិបត្តិការ និងរួមទាំងមន្ត្រី គ.ជ.ប ចំនួនពីរនាក់ផ្សេងទៀត។ មន្ត្រី គ.ជ.ប ទាំងនោះបានពិនិត្យមើលម្រាមដៃដែលលាងជ្រះនោះយ៉ាងយកចិត្តទុកដាក់បំផុត និងពិនិត្យឃើញថា ជ្រះពិតប្រាកដមែន ហើយនៅពេលនោះ មន្ត្រី គ.ជ.ប និងបុគ្គលិកខុមហ្វ្រែលបានពិភាក្សាគ្នា និងបានព្រមព្រៀងគ្នាឲ្យមន្ត្រីគ.ជ.ប និងបុគ្គលិកខុមហ្វ្រែលផ្សេងទៀតជ្រលក់ទឹកខ្មៅក្នុងគោលបំណងមកសាកល្បងលុបលាងនៅព្រឹកថ្ងៃបន្ទាប់ នៅស្នាក់ការខុមហ្វ្រែល។ ប៉ុន្តែមន្ត្រី គ.ជ.ប នោះមិនបានអញ្ជើញមកស្នាក់ការខុមហ្វ្រែលតាមការព្រមព្រៀងនោះទេ។

ក្នុងនាមជាអង្គការ សមាគមសង្កេតការណ៍បោះឆ្នោត ហើយបានរកឃើញនូវភាពមិនប្រក្រតីទាក់ទងទឹកខ្មៅនេះ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៣ បន្ទប់ស្ថានការណ៍នៃអង្គការ សមាគមមិនមែនរដ្ឋាភិបាល ចេញសេចក្តីថ្លែងការណ៍រួមស្តីពីការព្រួយបារម្ភអំពីទឹកខ្មៅជ្រលក់ម្រាមដៃ និងបញ្ជីបោះឆ្នោត និងបានធ្វើសន្និសីទសារព័ត៌មានមួយ ដើម្បីជំរាបជូនសាធារណជនអំពីការលុបលាងទឹកខ្មៅជ្រះនេះ និងព្រមទាំងអំពាវនាវដល់ គ.ជ.ប ធ្វើការពិភាក្សាជាមួយគណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងការបោះឆ្នោតអំពីវិធានការដោះស្រាយបញ្ហានេះ។

នៅរសៀលថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៣នេះ គ.ជ.ប ក៏បានរៀបចំសន្និសីទសារព័ត៌មានមួយស្តីអំពីការត្រៀមរៀបចំការបោះឆ្នោតរបស់ គ.ជ.ប។ ហើយជុំវិញបញ្ហាទឹកខ្មៅនោះ ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប បានសង្កត់ធ្ងន់ឲ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍សង្កេតតាមដាន និងកត់ត្រា ហើយរាយការណ៍ពីបញ្ហានានាដែលពាក់ព័ន្ធនឹងករណីនេះ។ រីឯឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានគូសបញ្ជាក់ដែរថា ទឹកខ្មៅគឺជារបាយគីមី គេលាយបាន គេក៏អាចលាងវិញបានដែរ ហើយវាមិនមែនជារឿងអ្វីថ្មី និងប្លែកនោះទេ។ ឯកឧត្តមក៏បានលើកឡើងដែរថា បើទោះជាទឹកខ្មៅអាចលុបលាងជ្រះ ក៏មិនមែនជាបញ្ហាអ្វីគួរឲ្យបារម្ភនោះទេ ព្រោះនៅមានលក្ខខណ្ឌផ្សេងទៀតដើម្បីការពារកុំឲ្យអ្នកបោះឆ្នោតអាចបោះឆ្នោតច្រើនដង ហើយទឹកខ្មៅគឺគ្រាន់តែជាចំណែកមួយដើម្បីធ្វើឲ្យមានតម្លាភាព និងជឿទុកចិត្ត។ បើទោះជាមិនមានទឹកខ្មៅក៏អាចបោះឆ្នោតបានដែរ ហើយការបោះឆ្នោតរបស់ប្រទេសមួយចំនួនគេមិនមានប្រើទឹកខ្មៅនេះទេ។

សូមបញ្ជាក់នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៣ គណៈកម្មាធិការខុមហ្វ្រែលបានផ្ញើលិខិតមួយទៅប្រធាន គ.ជ.ប ស្នើសុំ គ.ជ.ប រៀបចំពិធីសាកល្បងការប្រើប្រាស់ទឹកខ្មៅលុបលាងមិនជ្រះ និងបង្ហាញអំពី

សារធាតុផ្សំនៃការបង្កើតទឹកខ្មៅលុបលាងមិនជ្រះនេះ និងរបៀបនៃការលាយមុនការប្រើប្រាស់ និងព្រមទាំងសម្របសម្រួលឲ្យតំណាង ខុមហ្វ្រែលធ្វើការសាកល្បងនៅតាមការិយាល័យមួយចំនួន។ ទោះជាយ៉ាងណាមិនមានការឆ្លើយតបពី គ.ជ.ប អំពីសំណើនេះទេ លុះមកដល់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ទើប គ.ជ.ប បើឲ្យមានការសាកល្បងដូចបានជំរាបជូនអំពីដំណើរការខាងលើ។

**សកម្មភាពបុគ្គលិកខុមហ្វ្រែលសាកល្បងទឹកខ្មៅ និងបង្ហាញទឹកខ្មៅលុបលាងជ្រះ នៅទីស្តីការ គ.ជ.ប នៅវេលាម៉ោងប្រមាណ ៤ និង៥០នាទីល្ងាច និង០៨ និង៣០នាទីយប់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣**










## ឧបសម្ព័ន្ធទី៦៖ កាលប្បវត្តព្រឹត្តការណ៍សំខាន់ៗ នៃការបោះឆ្នោតឆ្នាំ២០១៣
## (បច្ចុប្បន្នភាពពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ រហូតដល់ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៣)

- **ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១** ៖ ឈ្មោះ សម រង្ស៊ី ត្រូវបាត់បង់សមាជិកភាពជាសមាជិករដ្ឋសភានីតិកាលទី៤ តាមរយៈសេចក្តីប្រកាសលេខ០៤៥រស របស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកតាមសាលដីកាផ្តន្ទាទោសរបស់តុលាការ នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១១ និងកថាខណ្ឌទី៣ មាត្រា១៤ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ចែងថា តំណាងរាស្ត្រដែលមានសាលក្រមស្ថាពរ ឬសាលដីកាស្ថាពរ សម្រេចថា ជាទណ្ឌិតជាប់ពន្ធនាគារ ត្រូវបាត់បង់ទាំងស្រុងនូវសិទ្ធិ បុព្វសិទ្ធិ និងសមាជិកភាពជាសមាជិករដ្ឋសភា។
- **ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១** ៖ គណៈកម្មការកំណត់អាសនៈរដ្ឋសភានីតិកាលទី៥ រាជរដ្ឋាភិបាល និងរដ្ឋសភា បានសម្រេចមិនធ្វើការកែប្រែ និងបង្កើនចំនួនអាសនៈរដ្ឋសភា ដោយរក្សា ត្រឹម ១២៣ អាសនៈដដែល ក្រោមហេតុផលថា វិបត្តិសេដ្ឋកិច្ច ហិរញ្ញវត្ថុសកល និងផលប៉ះពាល់ពីគ្រោះទឹកជំនន់កន្លងមក។
- **ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១** ៖ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានសម្តែងការសោកស្តាយ ចំពោះគណៈកម្មការកំណត់អាសនៈរដ្ឋសភានីតិកាលទី៥ រាជរដ្ឋាភិបាល និងរដ្ឋសភា ដែលបានសម្រេចមិនធ្វើការកែប្រែ និងបង្កើនចំនួនអាសនៈ ដើម្បីឱ្យស្របតាមការអភិវឌ្ឍន៍នៃប្រទេស។ ខុមហ្វ្រែល បានផ្តល់អនុសាសន៍ថា គួរតែកែប្រែចំនួនអាសនៈសម្រាប់ រដ្ឋសភានីតិកាលថ្មី (ឆ្នាំ២០១៣-២០១៨) ដោយការ បន្ថែម ៤អាសនៈ ទៀតទៅលើ ខេត្តកណ្តាល ខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តបាត់ដំបង ខណៈអាសនៈរដ្ឋសភាបច្ចុប្បន្ន ១២៣អាសនៈ ដើម្បីធានាភាពស្របច្បាប់ ផ្អែកលើស្ថានភាពប្រជាពលរដ្ឋ ស្របនឹងហេតុផល កំណើនសេដ្ឋកិច្ច និងកំណើនប្រជាពលរដ្ឋក្នុងមណ្ឌល។
- **ថ្ងៃទី១០ សីហា ឆ្នាំ២០១២** ៖ លិខិតមួយដែលមានព្រះហស្តលេខារបស់ព្រះប្រធានគណបក្ស នរោត្តម រណឫទ្ធិ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ពីប្រទេសបារាំង មានខ្លឹមសារខ្លីថា ព្រះអង្គឈប់ធ្វើនយោបាយ និងសេចក្តីសម្រេចផ្សេងៗរបស់គណបក្សនេះទៀតហើយ។ ការប្រកាសឈប់ប្រឡូកនយោបាយរបស់សម្តេចក្រុមព្រះនេះ គឺមិនមែនជាលើកទី១ទេ។ ការប្រកាសលាលែងនេះ ធ្វើឡើងបន្ទាប់ពី លោក សៅ រ៉ានី អគ្គលេខាធិការគណបក្ស បានប្តឹង សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ទៅសាលាដំបូងរាជធានីភ្នំពេញ។ មន្ត្រីមួយចំនួនដែលស្និទ្ធនឹងសម្តេចក្រុមព្រះ រួមមានប្រធានស្តីទីគណបក្ស លោក ឈឹម សៀកឡេង និងមន្ត្រីអ្នកនាំពាក្យ លោក ប៉ែន សង្ហា ក៏បានប្រកាសលាឈប់ពីគណបក្សនេះ និងឈប់ធ្វើនយោបាយតាមព្រះអង្គដែរ។
- **ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១២** ៖ សមាជិកសំខាន់ៗនៃគណបក្ស នរោត្តម រណឫទ្ធិ ចំនួនជាង៤០០នាក់ មកពីគ្រប់ខេត្តក្រុង នៅប្រទេសកម្ពុជា បានមកចូលរួមក្នុងសមាជវិសាមញ្ញ ដើម្បីផ្លាស់ប្តូរឈ្មោះគណបក្ស និងរចនាសម្ព័ន្ធថ្នាក់ដឹកនាំនៅមុនការច្របាច់បញ្ចូលជាមួយគណបក្សហ្វ៊ុនស៊ិនប៉ិច។ ប្រធានស្តីទីគណបក្ស នរោត្តម រណឫទ្ធិ លោក សៅ រ៉ានី នៅថ្ងៃដដែល បានប្រកាសប្តូរឈ្មោះគណបក្ស នរោត្តម រ

ណប្ញទ្ធិ មកជាគណបក្សជាតិនិយម វិញ ហើយគណបក្សនេះត្រៀមចូលរួមធ្វើសមាជវិសាមញ្ញប្រញាប់ បញ្ចូលជាមួយ គណបក្សហ៊្វុនស៊ិនប៉ិច នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១២។

- **ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២** ៖ គ.ជ.ប. សម្រេចជាគោលការណ៍ឲ្យលេខាធិការដ្ឋានរាជធានី-ខេត្តរៀបចំការបោះឆ្នោត បង្កើតមជ្ឈមណ្ឌលស្វែងរកឈ្មោះអ្នកបោះឆ្នោត ក្នុងបញ្ជីបោះឆ្នោតតាមប្រព័ន្ធអ៊ីនធឺណិត តាមគេហទំព័រ voterlist.org.kh ដើម្បីផ្តល់ព័ត៌មានជូនអ្នកបោះឆ្នោត។
- **ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២** ៖ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ និងមន្ត្រីជាន់ខ្ពស់មកពីគណបក្ស សម រង្ស៊ី និងគណបក្ស សិទ្ធិមនុស្ស បានជួបចរចារយៈពេល ២ម៉ោង នៅក្រសួងមហាផ្ទៃ ផ្តោតលើការកែទម្រង់នៃសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នៅមុនពេលការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ខាងមុខនេះ។ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ បានបដិសេធសំណើរួមគ្នារបស់គណបក្ស សម រង្ស៊ី និងគណបក្ស សិទ្ធិមនុស្ស ដែលបានស្នើសុំឲ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង កែទម្រង់សមាសភាពរបស់ គ.ជ.ប ដោយសំអាងថា គឺជាសំណើដដែលដូចពេលមុនៗដែរ និងជាការមិនចាំបាច់ឡើយ។
- **ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២** ៖ លោក សម រង្ស៊ី ប្រកាសលាលែងចេញពីតំណែងប្រធានគណបក្ស សម រង្ស៊ី ដើម្បីទៅកាន់តំណែងជាប្រធានគណបក្សសង្គ្រោះជាតិវិញ។ ការប្រកាសនេះ គឺបន្ទាប់ពីក្រសួងមហាផ្ទៃ បានអនុញ្ញាតយល់ព្រមចំពោះការបង្កើតគណបក្សសង្គ្រោះជាតិ ដែលមានលោក សម រង្ស៊ី ធ្វើជាប្រធាន កាលពីថ្ងៃទី២៨ ខែកញ្ញា កន្លងទៅ។
- **ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១២** ៖ នៅក្នុងអង្គសមាជវិសាមញ្ញរបស់គណបក្ស សម រង្ស៊ី មានសមាជិកជាច្រើនសម្រេចលើកដៃគាំទ្រលោក គង់ គាំ ជាប្រធានគណបក្សស្តីទី ឲ្យឡើងធ្វើជាប្រធានគណបក្ស សម រង្ស៊ី ថ្មីចាប់ពីពេលនេះតទៅ ហើយគាំទ្រអ្នកស្រី ជូរ ឡុងស៊ូម្ហ៊ា ជាអនុប្រធានគណបក្ស។
- **ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១២** ៖ សវនាការរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសម្រេចលុបឈ្មោះ លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ ចេញពីបញ្ជីចុះឈ្មោះបោះឆ្នោត។ អង្គជំនុំជម្រះសម្រេចក្តីដោយផ្អែកលើការកាត់ក្តីរបស់ ក្រុមប្រឹក្សាសង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១២ សម្រេចលុបឈ្មោះលោក សម រង្ស៊ី ចេញពីបញ្ជីឈ្មោះបោះឆ្នោត។ ការសម្រេចសេចក្តីរបស់ក្រុមប្រឹក្សាសង្កាត់បឹងរាំង គឺយោងតាមមាត្រាទី៥០ នៃច្បាប់បោះឆ្នោត ដែលចែងពីលក្ខខណ្ឌមួយចំនួនដែលពលរដ្ឋត្រូវបំពេញដើម្បីទទួលសិទ្ធិ បោះឆ្នោត។ អង្គការខុមហ្វ្រែល ថ្លែងថា ការអនុវត្តបែបនេះ គឺផ្ទុយពីគតិយុត្តិ ដែលគ្មានច្បាប់សម្អាងអំពីនីតិវិធីលុបឈ្មោះទណ្ឌិត។
- **ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១២** ៖ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសម្ពោធដំណើរការសាងសង់អគារថ្មី កម្ពស់ ១៦ជាន់ នៅលើផ្ទៃដីទំហំមួយហិកតារ ក្នុងខណ្ឌដូនពេញ។ គម្រោងសាងសង់អគារ គ.ជ.ប ថ្មីនេះ ដែលឧបត្ថម្ភថវិកាដោយក្រុមហ៊ុនកាស៊ីណូណាហ្គា (NagaCorp) ចំនួន ១២ លានដុល្លារអាមេរិក នឹងគ្រោងបញ្ចប់សាងសង់ក្នុងរយៈពេលជាង ២ឆ្នាំ។
- **ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២** ៖ ក្រុមប្រឹក្សាធម្មនុញ្ញ បានប្រកាសបិទផ្លូវតវ៉ាដល់លោក សម រង្ស៊ី ហើយគាំទ្រការសម្រេចរបស់ គ.ជ.ប ដែលបានលុបឈ្មោះលោក សម រង្ស៊ី ពីបញ្ជីបោះឆ្នោតឆ្នាំ២០១២ ព្រមបាន

បញ្ហាឲ្យស្ថាប័នពាក់ព័ន្ធអនុវត្ត និងធ្វើការផ្សព្វផ្សាយជាសាធារណៈទៀតផង។ មេធាវីរបស់លោក សម រង្ស៊ី អះអាងថា ក្រុមប្រឹក្សាធម្មនុញ្ញបន្តគាំទ្រការប្រើច្បាប់បោះឆ្នោតខុស មាត្រារបស់អ្នករៀបចំការបោះឆ្នោត ដែលធ្វើឲ្យគាត់មិនអស់ចិត្តនឹងការកាត់សេចក្តីនោះ។ ក្រុមប្រឹក្សាសង្កាត់បឹងរាំង រាជធានីភ្នំពេញ បានលុបឈ្មោះលោក សម រង្ស៊ី ពីបញ្ជីឈ្មោះបោះឆ្នោតបច្ចុប្បន្នភាពឆ្នាំ២០១២ កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១២ ដោយសំអាងលើសាលដីការបស់តុលាការកំពូលលេខ៣២ ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០១១ ដែលសម្រេចឲ្យលោក សម រង្ស៊ី ជាប់ពន្ធនាគារ។ បន្ទាប់មក គ.ជ.ប គាំទ្រក្រុមប្រឹក្សាសង្កាត់បឹងរាំង ដែលបានលុបឈ្មោះលោក សម រង្ស៊ី ហើយបានចេញសេចក្តីសម្រេចលេខ០០៨/១២ គ.ជ.ប សសរ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១២។

- **ថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ២០១២** ៖ ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ បានទទួលពាក្យបណ្តឹងរបស់ប្រធានក្រុមយុវជននៃគណបក្ស សម រង្ស៊ី លោក សួង សុភ័ណ្ឌ ដែលបានប្តឹងចោទលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ពីបទឃាតកម្មគិតទុកជាមុន ពាក់ព័ន្ធករណីជាន់គ្នាស្លាប់ និងរបួសនៅលើស្ពានកោះពេជ្រ នាថ្ងៃបញ្ចប់នៃព្រះរាជពិធីបុណ្យអុំទូក កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១០ ទៅដាក់នៅសាលាដំបូងរាជធានីភ្នំពេញ។ ការដាក់ពាក្យប្តឹងនេះ ត្រូវបានអ្នកនាំពាក្យរដ្ឋាភិបាល អះអាងថា មិនមែនជាការដាក់ពាក្យប្តឹងទេ តែគឺជាការវាយប្រហារលើប្រមុខដឹកនាំរដ្ឋាភិបាល។
- **ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១២** ៖ ថ្លែងនៅក្នុងពិធីចែកប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ នៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គំរាមប្តឹងបកទៅបណ្តឹងរបស់ប្រធានយុវជនគណបក្ស សម រង្ស៊ី ដែលប្តឹងរូបលោកពីបទមនុស្សឃាតគិតទុកជាមុន ក្នុងករណីមនុស្សជាន់គ្នាស្លាប់លើស្ពានកោះពេជ្រ កាលពីឆ្នាំ២០១០។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសង្កត់ធ្ងន់ថា លោកនឹងប្រើសិទ្ធិជាពលរដ្ឋខ្មែរមួយរូបដើម្បីប្តឹងបកទៅសកម្មជន គណបក្ស សម រង្ស៊ី វិញ ដើម្បីការពារកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់លោកផ្ទាល់ផង និងការពារកិត្តិយសសេចក្តីថ្លៃថ្នូររបស់រដ្ឋាភិបាលផង។
- **ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២** ៖ ក្នុងសន្និសីទកាសែត លោក សុន ឆ័យ ថ្លែងថា គណៈកម្មការទី២ រដ្ឋសភារំលោភបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ដោយធ្វើតាមតែការសម្រេចរបស់រដ្ឋាភិបាល។ មន្ត្រីជាន់ខ្ពស់គណបក្ស សម រង្ស៊ី រូបនេះ បានដាក់ងារឲ្យរដ្ឋសភាកម្ពុជា ថាជា «ស្ថាប័នប្រថាប់ត្រា» បន្ទាប់ពីគណៈកម្មការទី២ រដ្ឋសភា បដិសេធសំណើររបស់តំណាងរាស្ត្រសុំពិភាក្សាដើម្បីធ្វើវិសោធនកម្ម សេចក្តីព្រាងច្បាប់ថវិកាជាតិឆ្នាំ២០១៣។
- **ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១២** ៖ ប្រធានគណៈកម្មាធិការប្រតិបត្តិនៃចលនាយុវជនគណបក្ស សម រង្ស៊ី នៅទូទាំងប្រទេសកម្ពុជា លោក សួង សុភ័ណ្ឌ បានប្រកាសថា លោកលុបចោលនូវផែនការប្តឹងប្រមុខរដ្ឋាភិបាលកម្ពុជា លោក ហ៊ុន សែន ក្រោមបទអំពើឃាតកម្មគិតទុកជាមុនទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (អាយ.ស៊ី.ស៊ី = ICC = International Criminal Court) នោះហើយ។ ប្រធានក្រុមចលនាយុវជននៃគណបក្ស សម រង្ស៊ី ដែលជាដើមបណ្តឹង បានបញ្ជាក់ថា ការលុបចោលបណ្តឹងនេះ គឺដើម្បីចង់រក្សាការផ្សះផ្សាជាតិ និងបង្រួបបង្រួមជាតិ។
- **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២** ៖ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) បានប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១២ និងផ្តល់សុពលភាព លើឈ្មោះអ្នកបោះឆ្នោតប្រមាណ ៩៦៧៥៤៥៣ នាក់

ក្នុងចំណោម ពលរដ្ឋសរុបប៉ាន់ប្រមាណប្រហែល ១៤៤៥៦១០៤នាក់ (យុវជនចាប់ពី ១៨ឆ្នាំឡើង មានប្រមាណ ៩៥០៩៧៣២នាក់)។ ក្នុងបញ្ជីនេះ គ្មានឈ្មោះលោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិឡើយ។

- **ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៣** ៖ ព្រះមហាក្សត្រ នរោត្តម សីហមុនី ទ្រង់ចេញព្រះរាជសារ អំពាវនាវម្ចាស់ឆ្នោត ប្រើសិទ្ធិរបស់ខ្លួន ដើម្បីបោះឆ្នោតតាមសតិសម្បជញ្ញៈរបស់ខ្លួន ដោយកុំបីព្រួយបារម្ភពីការគាបសង្កត់ ការគំរាម កំហែង ឬសម្លុតពី ជនណាមួយ បក្សណាមួយឱ្យសោះ។
- **ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣** ៖ សហភាពអន្តរសភា បានចេញសេចក្តីសម្រេចចិត្តមួយ សម្តែងការសោកស្តាយ ចំពោះករណីលោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ ដែលមិនទាន់មានឱកាសត្រឡប់ទៅប្រទេសកម្ពុជាវិញ ហើយបានស្នើឱ្យរដ្ឋាភិបាល និងគណបក្ស សម រង្ស៊ី ស្វែងរកវិធីគ្រប់យ៉ាងរួមគ្នា ដើម្បីអនុញ្ញាតឱ្យលោក សម រង្ស៊ី អាចចូលរួមបោះឆ្នោតឆ្នាំ២០១៣។
- **ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៣** ៖ លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស បានប្រកាសលាលែងពី តួនាទីប្រធានបក្ស ក្នុងសមាជរបស់ខ្លួន ដើម្បីបើកផ្លូវ បំពេញតួនាទីជា អនុប្រធានគណបក្សសង្គ្រោះជាតិ។ ក្នុងសមាជតែមួយ លោក សឺន ស៊ូប៊ែរ្ត៍ អតីតប្រធានគណៈកម្មាធិការនាយក ត្រូវបានតែងតាំងជា ប្រធានគណបក្សសិទ្ធិមនុស្ស បន្តវេន ក្រោមសម្លេងលើកដៃគាំទ្រពីសមាជិកប្រមាណ ២ពាន់នាក់ មកពី បណ្តាខេត្តចំនួន ១៥។
- **ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣** ៖ គ.ជ.ប បើកការចុះបញ្ជីគណបក្ស និងបេក្ខជនសម្រាប់ការបោះឆ្នោតសភាអាណត្តិទី៥ (ចាប់ផ្តើមពីថ្ងៃទី២៩ ខែមេសា ដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៣)។ គ្រប់គណបក្សនយោបាយដែលមានបំណងចូលរួមប្រកួតត្រូវ ចុះបញ្ជីគណបក្ស និងបេក្ខជននៅទីស្តីការ គ.ជ.ប។ គណបក្សប្រជាជនកម្ពុជា បានចុះឈ្មោះនៅ គ.ជ.ប វេលាម៉ោង ៩ព្រឹក (ថ្ងៃច័ន្ទ ទី២៩ ខែមេសា) ដោយមានបេក្ខជនបេក្ខនារី ដាក់ទាំង ២៤រាជធានីខេត្ត (បេក្ខជនសរុបចំនួន ២៦៨នាក់ ពេញសិទ្ធិ ១២៣នាក់ និងបម្រុងចំនួន ១៤៥នាក់ ក្នុងនោះមានស្ត្រីចំនួន ៤៨នាក់)។ ចំណែក គណបក្សហ៊្វុនស៊ិនប៉ិច ក៏បានទៅចុះបញ្ជីបក្ស និងបេក្ខជន នៅវេលាម៉ោង ២ រសៀលថ្ងៃដដែល។ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៥ តម្រូវឲ្យគណបក្សនីមួយៗ ត្រូវបង់ប្រាក់តម្កល់ចំនួន ១៥លានរៀល។ ប្រាក់តម្កល់នេះត្រូវបង់ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងគណនីប្រាក់តម្កល់របស់ គ.ជ.ប ហើយប្រាក់តម្កល់នេះ នឹងបង្វិលជូនទៅសាមីគណបក្សវិញ ក្នុងករណីដែលគណបក្សនយោបាយនោះបានទទួលសន្លឹកឆ្នោតយ៉ាងតិច ៣ភាគរយនៃចំនួនសន្លឹកឆ្នោតបានការ ឬបានអាសនៈមួយកៅអីក្នុងរដ្ឋសភា។
- **ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣** ៖ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ បានដាក់លិខិតជាផ្លូវការទៅសម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ (សម្តេចម៉ែ) កាលពីថ្ងៃទី២៩ ខែឧសភា ដើម្បីទូលថ្វាយសុំលាលែងពីតួនាទីជាព្រះរាជលេខាផ្ទាល់របស់សម្តេចម៉ែ។ សំណើសុំឈប់នេះត្រូវបានព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ពន្យល់ពីមូលហេតុក្នុងលិខិតថា ដោយសារតែព្រះអង្គបានចូលក្នុងឆាកនយោបាយ និងមិនចង់ឲ្យពាក់ព័ន្ធក្នុងស្ថាប័នព្រះមហាក្សត្រ ហើយកុំឲ្យប៉ះពាល់កិត្តិយស ព្រះកិត្តិនាមព្រះមហាក្សត្រ និងសម្តេចម៉ែ ទើបព្រះអង្គសុំលាលែងពីតួនាទីជាព្រះរាជលេខាផ្ទាល់។ អតីតលេខាផ្ទាល់ព្រះបរមរតនកោដ្ឋ សម្តេច

ឪ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ត្រូវបានព្រះមហាក្សត្រប្រោសព្រះរាជទានតែងតាំងជាព្រះរាជលេខាផ្ទាល់សម្តេចម៉ែ កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣ បន្ទាប់ពីសម្តេចឪបានសោយទិវង្គត។ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ធម្មិកោ ក៏បានឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ មណ្ឌលព្រះសីហនុ សម្រាប់ការបោះឆ្នោតជាតិនៅខែកក្កដា ឆ្នាំ២០១៣។

○ **ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣** ៖ គណបក្សសង្គ្រោះជាតិបានជំរុញឲ្យរដ្ឋាភិបាល និងគណបក្សកាន់អំណាច ស្នើច្បាប់មួយទប់ស្កាត់ការវិលមកវិញនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ច្បាប់ថ្មីដែលបក្សប្រឆាំងស្នើឡើងនេះ គឺមិនអនុញ្ញាតឲ្យអតីតមេដឹកនាំក្នុងរបបខ្មែរក្រហម មានតួនាទីសំខាន់ក្នុងស្ថាប័នកំពូលរបស់រដ្ឋាភិបាល។ សំណើធ្វើច្បាប់ទប់ស្កាត់របបប្រល័យពូជសាសន៍ខ្មែរក្រហមរបស់មេដឹកនាំបក្សប្រឆាំងដូចនេះ កើតឡើងក្រោយពេលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចោទថា បើបក្សប្រឆាំងឈ្នះការបោះឆ្នោតឆ្នាំ២០១៣ នោះរបបខ្មែរក្រហមអាចនឹងវិលមកជាថ្មី។

○ **ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣** ៖ លោក ហ៊ុន សែន បានថ្លែងនៅក្នុងពិធីបញ្ចុះខណ្ឌសីមានៅវត្តមង្គលវង្ស ក្នុងខេត្តកំពង់ចាម ថា នៅពេលលោក កឹម សុខា ត្រឡប់មកពីសហរដ្ឋអាមេរិក វិញនោះ ប្រជាពលរដ្ឋនឹងធ្វើបាតុកម្មប្រឆាំងនឹងលោក ប្រសិនបើលោក កឹម សុខា មិនធ្វើការសុំទោសប្រជាពលរដ្ឋទេនោះ។ លោក ហ៊ុន សែន អះអាងថា ការធ្វើបាតុកម្មនេះនឹងផ្ទុះឡើងនៅពេលមានការបើកភ្លៀងខៀវពីលោក ជុំ ម៉ី ជាអតីតអ្នករងគ្រោះនៅក្នុងរបបខ្មែរក្រហម និងជាប្រធានសមាគមក្បៀមក្សាន្ត។ លោក កឹម សុខា បានអះអាងថា លោកមិនបាននិយាយថា គ្មានការសម្លាប់មនុស្សនៅគុកទួលស្លែង នៅក្នុងរបបខ្មែរក្រហម ឬគុកទួលស្លែង ជាគុកសិប្បនិម្មិតនោះទេ។ អនុប្រធានសមាគមក្បៀមក្សាន្ត លោក ប៊ូ ម៉េង បានអះអាងថា លោកមិនបានឮដោយផ្ទាល់ ដែលថា លោក កឹម សុខា មានប្រសាសន៍ថា គ្មានការកាប់សម្លាប់នៅគុកទួលស្លែងនោះទេ។ អនុប្រធានសមាគមក្បៀមក្សាន្ត បានចាត់ទុកបញ្ហានេះ ជារឿងនយោបាយ ប្រសិនបើលោក ជុំ ម៉ី ចង់ធ្វើបាតុកម្មប្រឆាំងនឹងលោក កឹម សុខា ក្នុងនាមសមាគមក្បៀមក្សាន្ត លុះត្រាតែមានការសម្រេចពីគណៈកម្មការសមាគមជាមុនសិន។

○ **ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៣** ៖ គជប ប្រកាសចែកចាយប័ណ្ណព័ត៌មានអ្នកបោះឆ្នោតឲ្យដល់ដៃអ្នកបោះឆ្នោតទៅតាមការគ្រោងទុករបស់ខ្លួនចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២៥ មិថុនា។ សន្លឹកប័ណ្ណព័ត៌មាន និងអ្នកបោះឆ្នោតមានចំនួនជាង ៩លានសន្លឹក ក្នុងឆ្នាំ២០១៣ (ឆ្នាំ២០០៨ មានត្រឹមតែជិត ៧លានសន្លឹក)។ អ្នកផ្តល់ប័ណ្ណនេះ ជាមន្ត្រីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមានប្រធានភូមិ ក្នុងឃុំ សង្កាត់នីមួយៗនោះជាជំនួយការ។ មន្ត្រី គ.ជ.ប និយាយថា ប័ណ្ណព័ត៌មានសម្រាប់ឆ្នាំ២០១៣ នេះ ពុំមានការប្រែប្រួលជាដុំកំភួនច្រើននោះឡើយ គ្រាន់តែកែប្រែផ្នែកខាងខ្នងពណ៌ផ្ទៃមេឃស្រាល និងអក្សរពណ៌ផ្ទៃមេឃដិត។ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត មានផ្តល់ព័ត៌មានទាក់ទងនឹង ទីតាំងការិយាល័យបោះឆ្នោត ...។

○ **ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៣** ៖ លោក ជុំ ម៉ី ជាអតីតអ្នករងគ្រោះនៅក្នុងរបបខ្មែរក្រហម និងជាប្រធានសមាគមក្បៀមក្សាន្ត បានដឹកនាំបាតុកម្មក្នុងក្រុងភ្នំពេញដែលមានអ្នកចូលរួមរាប់ពាន់នាក់ ហើយការផ្សាយផ្ទាល់ពីបាតុកម្មតាមរយៈទូរទស្សន៍បាយ័នជាលើកដំបូង ដើម្បីប្រឆាំងនឹងលោក កឹម សុខា អនុ

ប្រធានគណបក្សសង្គ្រោះជាតិ។ បាតុកម្មបានបញ្ចប់នៅពេលដែលលោក ជុំ មុី បានយកញត្តិទៅដាក់នៅទីស្នាក់ការគណបក្សសង្គ្រោះជាតិ ដើម្បីទាមទារឱ្យលោក កឹម សុខា ធ្វើការសុំទោសចំពោះជនរងគ្រោះក្នុងរបបខ្មែរក្រហម។

○ **ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣** ៖ លោក ជុំ មុី ជាដើមបណ្តឹងព្រហ្មទណ្ឌពីបទបរិហារកេរ្តិ៍ ត្រូវតុលាការសាលាដំបូងរាជធានីភ្នំពេញកោះហៅទៅសាកសួរ។ លោក ជុំ មុី ប្តឹងប្រធានស្តីទីគណបក្សសង្គ្រោះជាតិ លោក កឹម សុខា ដែលបាននិយាយថា គុកទួលស្លែងជាគុកសិប្បនិម្មិត្ត ហើយប្តឹងទាមទារ សំណងជាប្រាក់១ពាន់ដុល្លារ (ប្រមាណ៤លានរៀល) ដើម្បីធ្វើបុណ្យបង្សុកូលដល់ជនរងគ្រោះក្នុងគុកទួលស្លែង។ តុលាការសាលាដំបូងក្រុងភ្នំពេញ នឹងកោះហៅលោក កឹម សុខា ឱ្យចូលខ្លួនមកបំភ្លឺនៅថ្ងៃទី២៧ មិថុនា ឆ្នាំ២០១៣។ ឆ្លើយតបនឹងអ្នកសារព័ត៌មាន មុនពេលដល់ថ្ងៃចូលតុលាការ លោក កឹម សុខា បានបកស្រាយការពារខ្លួនថា ភស្តុតាងដាក់បន្ទុកជាសំឡេងរបស់គាត់ត្រូវបានគេកាត់ត ហើយលោកចោទថា ការប្តឹងរបស់លោក ជុំ មុី មានគណបក្សប្រជាជនកម្ពុជានៅពីក្រោយខ្នង។

○ **ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣** ៖ ក្រសួងព័ត៌មាន បានចេញសេចក្តីណែនាំមួយ ជូនដល់ ប្រធានស្ថានីយវិទ្យុ FM ក្នុងស្រុកទាំងអស់ ត្រូវផ្អាកការផ្សាយបន្តពី វិទ្យុបរទេស ដែលផ្សាយជាខេមរភាសាទាំងអស់ ក្នុងរយៈពេលបើកការឃោសនា ៣១ថ្ងៃ មុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត។ សេចក្តីណែនាំ បានពន្យល់ត្រឹមពីតួនាទីរបស់ស្ថានីយវិទ្យុ ត្រូវមានអព្យាក្រិតក្នុងការរាយការណ៍ព័ត៌មាន ពាក់ព័ន្ធនឹងការបោះឆ្នោតជូនអ្នកបោះឆ្នោត និងលើកយកបទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ដែលហាមជនបរទេស ដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជាធ្វើសកម្មភាពឃោសនាបោះឆ្នោតដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ តែមិនបានពន្យល់ច្បាស់លាស់ពី មូលហេតុជាក់លាក់ដែលត្រូវផ្អាកការផ្សាយបន្តពីវិទ្យុបរទេស ដែលផ្សាយជាខេមរភាសា រួមរាប់ វិទ្យុអាស៊ីសេរី វិទ្យុវីអូអេ វិទ្យុអេប៊ីស៊ីអូស្ត្រាលី វិទ្យុបារាំងអែរអែហ្វអុី។ សេចក្តីណែនាំ ដែលមានចុះហត្ថលេខា លោក អ៊ុក ប្រាថ្នា បានព្រមាន ដល់ស្ថានីយវិទ្យុ FM ណាមិនគោរពតាមសេចក្តីណែនាំ របស់ក្រសួងព័ត៌មាន នឹងត្រូវរងវិធានការតាមច្បាប់របស់ក្រសួងជាធរមាន។ ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ តាមប្រតិទិនរបស់ គជប នឹងចាប់ផ្តើមពីថ្ងៃទី២៧ ខែមិថុនា ដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣។

○ **ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៣** ៖ ក្រសួងព័ត៌មាន បានប្រកាស តាមរយៈស្ថានីយទូរទស្សន៍ជាតិកម្ពុជា (ទ.ទ.ក) អនុញ្ញាតអោយវិទ្យុ អេហ្វអឹម (FM) ក្នុងស្រុកទាំងអស់ អាចធ្វើការចាក់ផ្សាយបន្តកម្មវិធីផ្សាយរបស់វិទ្យុបរទេសផ្សាយជាភាសាខ្មែរឡើងវិញ។ សេចក្តីប្រកាសនេះធ្វើឡើងក្រោយការរិះគន់យ៉ាងចាស់ដៃពីអង្គការសង្គមស៊ីវិលជាតិ សហគមន៍អន្តរជាតិ និងតំណាងគណបក្សនយោបាយដែលចូលរួមប្រកួតថាជាទង្វើមួយដើរផ្ទុយពីច្បាប់ និងជាដំណើរដើរថយក្រោយនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ គណបក្សនយោបាយចំនួន៦ ដែលចូលរួមប្រកួតប្រជែង រួមមាន គណបក្សសញ្ជាតិកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ គណបក្សខ្មែរឈប់ក្រ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សសង្គ្រោះជាតិ ដែលបានរិះគន់សេចក្តីណែនាំរបស់ក្រសួងព័ត៌មាន ដែលមិនអនុញ្ញាតឲ្យវិទ្យុអែហ្វអឹម (FM) ក្នុងស្រុកផ្សាយបន្តកម្មវិធីព័ត៌មានរបស់វិទ្យុបរទេសផ្សាយជាខេមរភាសា ក្នុងអំឡុងពេល

ឃោសនាបោះឆ្នោត និងពេលបោះឆ្នោត ចំណែក គណបក្សប្រជាជនកម្ពុជា និងគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច បែរជាគាំទ្រចំណាត់ការរបស់ក្រសួង ក្រោមហេតុផល ស្ថាប័នផ្សព្វផ្សាយមួយចំនួនមិនផ្តល់ផលប្រយោជន៍សម្រាប់ជាតិខ្មែរ និងមិនមានអព្យាក្រឹត។

- **ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៣** ៖ ព្រះមហាក្សត្រ នរោត្តម សីហមុនី ទ្រង់ចេញព្រះរាជក្រឹត្យមួយ ត្រាស់បង្គាប់ លើកលែងទោសឱ្យទណ្ឌិតឈ្មោះ សម រង្ស៊ី ភេទប្រុស អាយុ ៦២ឆ្នាំ ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ តាមអំណាចសាលដីកាស្ថាពរលេខ ៣២ ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០១១ របស់តុលាការកំពូល និងសាលដីកាស្ថាពរលេខ ៨៤ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍។ ព្រះរាជក្រឹត្យរបស់ ព្រះមហាក្សត្រ បានធ្វើឡើងក្រោយ លិខិតស្នើលើកលែងទោសរបស់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន តំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៣។ នៅក្នុងថ្ងៃដដែល ប្រធានគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី បានផ្ញើលិខិតចូលរួមមរណទុក្ខ សម្តែងការសោកស្តាយ និងរំលែកទុក្ខ ជាមួយនឹង លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចំពោះមរណភាពរបស់ អ្នកឧកញ៉ាមហាភក្តីសប្បុរសភោគាធិបតី ហ៊ុន នាង ត្រូវជា បិតា បានទទួលអនិច្ចកម្មកាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៣ ក្នុងជន្មាយុ ៩០ឆ្នាំ ដោយ ជរាពាធ។
- **ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣** ៖ គ.ជ.ប បានចេញសេចក្តីបំភ្លឺមួយ ស្តីពី ការផ្អាកវិទ្យុមិនឱ្យផ្សាយបន្ត និងការហាមផ្សព្វផ្សាយការងារ និងលទ្ធផលនៃការបោះឆ្នោត ថា គ.ជ.ប មិនបាន ផ្អាកវិទ្យុមិនឱ្យផ្សាយបន្តក្នុងអំឡុងពេលបោះឆ្នោត។ គ.ជ.ប បន្តបកស្រាយថា ចំពោះការហាមផ្សព្វផ្សាយ ក្នុងរយៈពេល ៥ថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ដែលបានចែងក្នុងបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ជំពូក៧ ចំណុច ៧.២.៥ គឺ សំដៅតែលើ ការហាមធ្វើ និងហាមផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិ ទាក់ទងនឹងដំណើរការបោះឆ្នោតតែប៉ុណ្ណោះ។ ចំណែកការផ្សព្វផ្សាយលទ្ធផលនៃការបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ មានសិទ្ធិធ្វើការផ្សព្វផ្សាយលទ្ធផលដែលខ្លួនទទួលបាន។
- **ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣** ៖ មេដឹកនាំគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី ដែលបាននិរទេសខ្លួនឯង បានវិលមកដល់កម្ពុជាវិញ ក្រោយព្រះមហាក្សត្រព្រះរាជទានការលើកលែងទោស។ រាប់ចាប់ពីព្រលានយន្តហោះភ្នំពេញ រហូតដល់ ទីលានសេរីភាព (ចម្ងាយប្រមាណ ១៣គីឡូម៉ែត្រ) អ្នកគាំទ្រ និងអ្នកដំណើរ រាប់សែននាក់ អមសង្ខាងផ្លូវ និងស្វាគមន៍មេដឹកនាំគណបក្សប្រឆាំងចូលស្រុកវិញ។
- **ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣ ៖** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) លោក អ៊ឹម សួស្តី បានស្នើដល់ រដ្ឋមន្ត្រីក្រសួងព័ត៌មាន ចាត់វិធានការជាបន្ទាន់ ដើម្បីផ្អាកការផ្សាយរបស់ វិទ្យុ អេប៊ីស៊ី FM 107.5 MHz រហូតដល់ក្រោយការបោះឆ្នោត ដោយហេតុផលថា វិទ្យុនេះ បានផ្សព្វផ្សាយដោយប្រើភាសា និងពាក្យពេចន៍ញុះញង់ បំភិតបំភ័យអ្នកបោះឆ្នោត ដែលរំលោភទៅនឹងច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។ គ.ជ.ប បានបញ្ជាក់ថា ស្ថានីយវិទ្យុ អេប៊ីស៊ី FM 107.5 MHz នៅតែបន្តផ្សព្វផ្សាយបទសម្ភាសន៍របស់ម្ចាស់ស្ថានីយតាមទូរស័ព្ទពីទល់ដែនខ្មែរ ថៃ ដដែល បើទោះបីជា គ.ជ.ប ធ្លាប់បានចេញលិខិតព្រមានដោយផ្ទាល់រួចហើយក្តីកាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣។

- **ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣** ៖ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលថ្មី បានចាប់ផ្តើមដំណើរការចាប់ពីម៉ោង ៧ព្រឹក រហូតដល់ ម៉ោង ៣រសៀល។ ក្នុងថ្ងៃបោះឆ្នោត បន្ទប់ស្ថានការណ៍ថ្ងៃបោះឆ្នោតបានទទួលសេចក្តីរាយការណ៍ជាច្រើនថា ពលរដ្ឋជាច្រើនបានបាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោត មានបាតុភាពមិនប្រក្រតីជាច្រើនកើតនៅរាជធានីភ្នំពេញ...។
- **ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣** ៖ មានអំពើហិង្សាមួយកើតឡើងនៅការិយាសាលាបឋមសិក្សាស្ទឹងមានជ័យ ស្ថិតក្នុងទីស្នាក់ការ គណៈកម្មការរៀបចំការបោះឆ្នោត សង្កាត់ស្ទឹងមានជ័យ ផ្តើមចេញពីការបាត់ឈ្មោះអ្នកបោះឆ្នោត តែមន្ត្រីបោះឆ្នោតមិនរវល់ដោះស្រាយ។ អន្តរាគមន៍របស់ប៉ូលីស ដោយមិនខ្វល់ពីកំហឹងម្ចាស់ឆ្នោតបានបណ្តាលឱ្យការវាយបំផ្លាញ និងដុតឡានប៉ូលីសអស់២គ្រឿង។
- **ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣** ៖ មន្ត្រីរៀបចំការបោះឆ្នោតប្រចាំឃុំល្វាក្រាំង នៃស្រុកវ៉ារិន្ទ ខេត្តសៀមរាប រួមទាំងអ្នកសង្កេតការណ៍របស់គណបក្សនយោបាយខ្លះទៀត បានឱ្យដឹងថា គេបានប្រទះឃើញលិខិតអនាមិកមួយសន្លឹកនៅក្នុងហិបឆ្នោតនៃការិយាល័យលេខ ១១១៥។ លិខិតនោះបានសុំឱ្យប្រមុខរដ្ឋាភិបាលជួយអន្តរាគមន៍បង្ក្រាបទៅលើអំពើពុករលួយក្នុងអង្គភាពយោធា ដែលមេបញ្ជាការមួយចំនួនកំពុងប្រព្រឹត្ត។ នៅការិយាល័យបោះឆ្នោតលេខ ១១១៥ នោះ ក្នុងចំណោមទាហាន ៦៩២នាក់ ដែលគេបានបញ្ជូនពីព្រំដែនកម្ពុជា-ថៃ ឱ្យមកបោះឆ្នោតនៅស្រុកវ៉ារិន គឺចំនួនជាង ២០សំឡេងបានបោះគាំទ្រគណបក្សសង្គ្រោះជាតិ ហើយគេសង្ស័យថា ប្រហែលជាទាហានណាម្នាក់ក្នុងចំណោមអ្នកជាង ២០នាក់នោះដែលបានប្លងលិខិតទៅក្នុងហិបឆ្នោត។
- **ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៣** ៖ គណបក្សហ្វ៊ុនស៊ិនប៉ិច បានចេញសេចក្តីថ្លែងការណ៍មួយ ទាមទារឲ្យបង្កើតគណៈកម្មការឯករាជ្យមួយ ដើម្បីត្រួតពិនិត្យភាពមិនប្រក្រតីដែលកើតមាននៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ កាលពីថ្ងៃទី២៨ កក្កដា ហើយបន្ថែមថា គណបក្សហ្វ៊ុនស៊ិនប៉ិច សូមប្រកាសនូវជំហរម៉ឺងម៉ាត់របស់ខ្លួនក្នុងការទាមទារនេះ ដើម្បីឲ្យសមស្របទៅតាមការទាមទារ និងឆន្ទៈរបស់ប្រជារាស្ត្រម្ចាស់ឆ្នោត។
- **ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣** ៖ ថ្លែងនៅក្នុងទស្សនកិច្ចពិនិត្យការដ្ឋានសង់ស្ពានអាកាសស្ទឹងមានជ័យ ជាទីដែលម្ចាស់ឆ្នោត និងប៉ូលីសប៉ះទង្គិចគ្នា ហើយមានការដុតឡានប៉ូលីសអស់ ២គ្រឿង លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបង្ហាញជំហរគាំទ្រការបង្កើតគណៈកម្មការចម្រុះ ដើម្បីធ្វើការស៊ើបអង្កេតលើភាពមិនប្រក្រតីក្នុងថ្ងៃបោះឆ្នោត ដោយបានមានប្រសាសន៍ថា *«បើសិនជាគណៈកម្មការជាតិរៀបចំការបោះឆ្នោត យល់ឃើញថា មានការចាំបាច់ឱ្យគណបក្សនយោបាយចូលរួម សង្គមស៊ីវិលចូលរួម សម្រាប់ខាងរាជរដ្ឋាភិបាល និងគណបក្សប្រជាជន សូមស្វាគមន៍នូវការបើកទូលាយបែបនេះ ដើម្បីបង្ហាញពីតម្លាភាព និងដំណោះស្រាយដែលអាចទទួលយកបានទាំងអស់គ្នា[19]»*។
- **ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣** ៖ អ្នកបាត់បង់សិទ្ធិបោះឆ្នោតរាប់ពាន់នាក់ បានមកជួបជុំគ្នានៅទីស្នាក់ការកណ្តាលគណបក្សសង្គ្រោះជាតិ ស្ថិតនៅខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីដាក់ពាក្យបណ្តឹងលើ

[19] យោងព័ត៌មាន វិទ្យុអាស៊ីសេរី ផ្សាយថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ មានចំណងជើងថា លោក ហ៊ុន សែន ស្វាគមន៍ការបង្កើតគណៈកម្មការស៊ើបអង្កេតរឿងបោះឆ្នោត http://www.rfa.org/khmer/news/politics/pm-appears-after-election-07312013043811.html

ករណីបាត់ឈ្មោះពីបញ្ជីបោះឆ្នោត តាមការប្រកាសអញ្ជើញរបស់គណបក្សសង្គ្រោះជាតិ។ បណ្ដឹងដែលគណបក្សសង្គ្រោះជាតិ ទទួល រាប់បញ្ចូល បណ្ដឹងបាត់ឈ្មោះអ្នកបោះឆ្នោត បណ្ដឹងមន្ត្រីការិយាល័យបដិសេធមិនឱ្យបោះឆ្នោត បណ្ដឹងមានអ្នកបោះឆ្នោតជំនួស បណ្ដឹងមនុស្សចល័តបោះឆ្នោតច្រើនដង និងបណ្ដឹងប្ដឹងជនបរទេសមកបោះឆ្នោត។

- **ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣** ៖ ព្រះរាជសាររបស់ ព្រះបាទព្រះបរមនាថ នរោត្តម សីហមុនី បានអំពាវនាវដល់គណបក្សនយោបាយទាំងពីរដែលប្រជាពលរដ្ឋបានបោះឆ្នោតគាំទ្រឲ្យមានអាសនៈក្នុងរដ្ឋសភាអាណត្តិថ្មី "ឲ្យបន្តពិភាក្សាគ្នារកដំណោះស្រាយដោយសន្តិវិធី ចំពោះវិវាទ ឬបញ្ហាទាំងឡាយ ដែលនៅសេសសល់"។ ព្រះមហាក្សត្រក៏បានអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ឲ្យបន្តប្រកបរបរចិញ្ចឹមជីវិតដោយភាពសុខសាន្ត ព្រមទាំងរក្សាឯកភាព និងសាមគ្គីជាតិ ដែលព្រះអង្គចាត់ទុកថា ជាកម្លាំងរបស់ជាតិក្នុងការជំនះរាល់ការលំបាកធំៗទាំងឡាយកន្លងទៅ។
- **ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៣** ៖ តាមការប្រកាសលទ្ធផលបណ្ដោះអាសន្ន របស់ គជប កូនប្រុសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺលោក ហ៊ុន ម៉ានី ឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រនៅខេត្តកំពង់ស្ពឺ នៅលេខរៀងទី៤ មិនបានទទួលអាសនៈទេ ដោយសារក្នុងមណ្ឌលខេត្តកំពង់ស្ពឺ គណបក្សប្រជាជនកម្ពុជាអាចទទួលបានត្រឹម ៣អាសនៈ ក្នុងចំណោម អាសនៈ សរុបចំនួន ៦ ។ ទន្ទឹមនឹងនោះ លោក ស សុខា វ័យ ៣៤ឆ្នាំ ស្នងការរងប៉ូលីសក្រុងភ្នំពេញ ជាកូនប្រុសរបស់លោកឧបនាយករដ្ឋមន្ត្រី ស ខេង ដែលបានឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រលេខរៀងទី៦ ប្រចាំខេត្តព្រៃវែង ក៏មិនបានឈ្នះអាសនៈផងដែរ ដោយសារគណបក្សប្រជាជនកម្ពុជាទទួលបានត្រឹម ៥អាសនៈ ក្នុងចំណោមអាសនៈសរុប ១១ ក្នុងខេត្តព្រៃវែង ។
- **ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ ៖** ព្រះមហាក្សត្រ សម្ដេច ព្រះមរមនាថ នរោត្តម សីហមុនី អមព្រះរាជដំណើរដោយព្រះមាតា សម្ដេចព្រះមហាក្សត្រីយ៍ នរោត្តម មុនីនាថ សីហនុ បានយាងចាកចេញពីប្រទេសកម្ពុជាក្នុងព្រះរាជដំណើរទៅកាន់ប្រទេសចិន។ ជូនព្រះរាជដំណើរព្រះមហាក្សត្រដល់ព្រលានយន្តហោះអន្តរជាតិភ្នំពេញ មានវត្តមានលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រធានរដ្ឋសភា លោក ហេង សំរិន ព្រមទាំងមន្ត្រីជាន់ខ្ពស់ និងក្រុមគ្រួសាររាជវង្សជាច្រើនទៀត។ អវត្តមានពីប្រទេសរបស់ព្រះមហាក្សត្រដែលកើតឡើងចំពេលដែលវិបត្តិនយោបាយក្រោយការបោះឆ្នោតនៅមិនទាន់អាចដោះស្រាយចេញបានធ្វើឲ្យមានការព្រួយបារម្ភថា កម្ដៅនយោបាយអាចកើនឡើងថែមទៀត។ ការយាងចាកចេញពីប្រទេសរបស់ព្រះមហាក្សត្រនៅពេលនេះ បានធ្វើឡើងចំថ្ងៃដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រកាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត បន្ទាប់ពីគណបក្សជាប់ឆ្នោតទាំងពីរបានជួបនឹងបរាជ័យក្នុងការបង្កើតគណៈកម្មការចម្រុះដើម្បីដោះស្រាយភាពមិនប្រក្រតីនៃការបោះឆ្នោត។
- **ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣** ៖ ព្រះមហាក្សត្រ នរោត្តម សីហមុនី ដែលកំពុងគង់ប្រថាប់នៅឯទីក្រុងប៉េកាំង ប្រទេសចិន បានចេញព្រះរាជសារមួយជំរុញឲ្យគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ដែលជាជម្លោះនឹងគ្នា គោរពរដ្ឋធម្មនុញ្ញ និងច្បាប់នានារបស់ជាតិក្នុងនាមជារដ្ឋអធិបតេយ្យមួយ។
- **ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៣ ៖** បាតុកររបស់គណបក្សសង្គ្រោះជាតិ រាប់រយនាក់ បានហាត់សមពីរបៀបធ្វើបាតុកម្មដោយសន្តិវិធី នៅទីលានប្រជាធិបតេយ្យ ជាមួយឧបករណ៍ ផ្កាឈូក ទៀន ធូប បដា និងបូចង

ក្បាល។ ចំណែកកម្លាំងសមត្ថកិច្ច រយនាក់ ក៏បានហាត់បំប៉នជំនាញការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ នៅកោះពេជ្រ ប្រដាប់ដោយ ខែងការពារ ដំបងឆក់ មួកសុវត្ថិភាព គ្រាប់បែកផ្សែង ឡានទឹក។

- **ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២១០១៣** ៖ គជប បានប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ (ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣) និងផ្តល់សុពលភាព ជូនតំណាងរាស្ត្រជាប់ឆ្នោតសរុប ១២៣រូប។ តាមលទ្ធផលនេះ មានត្រឹមគណបក្សនយោបាយ ពីរប៉ុណ្ណោះដែលទទួលបានអាសនៈ ក្នុងនោះ គណបក្សប្រជាជនកម្ពុជាទទួលបាន ៦៨អាសនៈ និងគណបក្សសង្គ្រោះជាតិ ទទួលបាន ៥៥ អាសនៈ។
- **ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣** ៖ ព្រះមហាក្សត្រព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី យាងត្រឡប់មកដល់ប្រទេសកម្ពុជា នៅវេលាម៉ោង ៤រសៀល បន្ទាប់ពីព្រះអង្គបានយាងចេញពីប្រទេសទៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ ដើម្បីទៅពិនិត្យព្រះរាជសុខភាពព្រះអង្គ តាមការកំណត់រៀងរាល់ ៦ខែម្តង។ ថ្នាក់ដឹកនាំនៃគណបក្សជាប់ឆ្នោតនៅសភា រួមទាំងមន្ត្រី និងញាតិវង្សច្រើនរូប បានចាំទទួលស្វាគមន៍ធ្វើបដិសណ្ឋារកិច្ចព្រះអង្គទាំងពីរយាងចុះពីព្រះទីនាំង នៅឯព្រលានយន្តហោះភ្នំពេញអន្តរជាតិ។ មេដឹកនាំគណបក្សនយោបាយធំទាំងពីរ គឺលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក សម រង្ស៊ី មិនបានជួបស្វាគមន៍ ឬពិភាក្សាគ្នាអ្វីបន្តិចទេ នៅក្នុងឱកាសនោះ។
- **ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣** ៖ ជំនួបថ្នាក់ដឹកនាំគណបក្សនយោបាយជាប់ឆ្នោតនៅព្រះបរមរាជវាំង ក្រោមព្រះរាជាធិបតីនៃព្រះមហាក្សត្រដែលប្រើពេលប្រមាណ ២០នាទី ភាគីទាំងពីរនៅពុំទាន់បានឯកភាពលើគោលការណ៍រួម ដើម្បីទម្លាយភាពជាប់គាំងនយោបាយបាននៅឡើយ។ ព្រះមហាក្សត្រព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះអង្គរំពឹងថា ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ នឹងបើកផ្លូវក្នុងការចូលរួមប្រជុំសភាដូចការគ្រោងទុកនៅថ្ងៃទី២៣ កញ្ញា ខាងមុខ តាមព្រះរាជតម្រិះរបស់ព្រះអង្គ។
- **ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣** ៖ គណបក្សសង្គ្រោះជាតិ បានដឹកនាំមហាបាតុកម្មអហឹង្សាចំនួនបីថ្ងៃ ១៥) ខែកញ្ញា ១៧ដល់ ) នាទីលានប្រជាធិបតេយ្យ ដោយមានអ្នកចូលរួម រាប់ម៉ឺននាក់ ទាមទារយុត្តិធម៌ ហើយមានការចងតង់ស្នាក់ពេលយប់ផងដែរ។
- **ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣** ៖ ព្រឹត្តិការណ៍ប៉ះទង្គិចហឹង្សាកើតឡើងនៅស្ពានអាកាសក្បាលថ្នល់ រវាងសមត្ថកិច្ចរាប់រយនាក់ ប្រដាប់ដោយ ខែល ដំបង គ្រាប់បែកផ្សែង កាំភ្លើងគ្រាប់ពិត ជាមួយនឹងក្រុមអ្នកតវ៉ា ប្រមាណជិត ៣០នាក់ យ៉ាងហោចណាស់ បានបណ្តាលឱ្យ មនុស្សម្នាក់ស្លាប់ ១៥នាក់រងរបួស និងមនុស្ស ៦នាក់ ត្រូវសមត្ថកិច្ចចាប់ខ្លួន។ បុរសម្នាក់ឈ្មោះ ម៉ៅ សុខចន្ទ អាយុ ២៩ឆ្នាំ ត្រូវបានអះអាងថា ជាអ្នកដំណើរតាមផ្លូវ បានស្លាប់ភ្លាមៗនៅកន្លែងកើតហេតុ ដោយត្រូវគ្រាប់ (K59) ចំក្បាល។ មន្ត្រីអង្គការសង្គមស៊ីវិល រិះគន់ថា ការវាយបន្ទាលួស និងបិទរបាំងផ្លូវ មិនឲ្យអ្នកដំណើរឆ្លងកាត់ ជាមូលហេតុនៃហឹង្សារវាងពលរដ្ឋ និងកម្លាំងប្រដាប់អាវុធ។

- **ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ ៖** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះបាទ នរោត្តម សីហមុនី បានចេញព្រះរាជសារ ចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារនៃពលរដ្ឋខ្មែរដែលបានបាត់បង់ជីវិត និងរងរបួស ក្នុងគ្រាមានការប៉ះទង្គិចគ្នាយ៉ាងខ្លាំងរវាង ក្រុមសមត្ថកិច្ច និងក្រុមបាតុករ រួមទាំងអ្នកដំណើរតាមផ្លូវ ។ ព្រះមហាក្សត្រទ្រង់បានអំពាវនាវ ដល់ជនរួមជាតិ រក្សាភាពស្ងៀមស្ងាត់ និងសេចក្តីថ្លៃថ្នូរ ក្នុងការរកដំណោះស្រាយបញ្ហាជាតិ។
- **ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ ៖** ក្រុមមេដឹកនាំកំពូលៗរបស់គណបក្សជាប់ឆ្នោតនៅរដ្ឋសភានីតិកាលថ្មីមានសមាសភាព លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លោក ស ខេង លោក សាយ ឈុំ មកពីគណបក្សប្រជាជនកម្ពុជា និងលោក សម រង្ស៊ី លោក កឹម សុខា លោក បានជួបជជែកគ្នារកដំណោះស្រាយលើកដំបូងក្រោយការបោះឆ្នោតដ៏ចម្រូងចម្រាស នៅវិមានរដ្ឋសភា។ ក្រោយជំនួបរយៈពេលជិត ៥ម៉ោង លោក សម រង្ស៊ី បានប្រកាសនៅចំពោះមុខបាតុករដែលមានចំនួនកើនឡើងជាច្រើនម៉ឺននាក់ នៅលើទីលានប្រជាធិបតេយ្យ នាថ្ងៃរសៀលថា លោកបានទាមទារពីលោកនាយករដ្ឋមន្ត្រី ធ្វើយ៉ាងណាមិនឱ្យអាជ្ញាធរប្រើប្រាស់ហឹង្សាដាក់ក្រុមបាតុករ ហើយលោកនឹងបន្តស្វែងរកយុត្តិធម៌ជូនម្ចាស់ឆ្នោតបន្តទៀត។
- **ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣** ៖ ភិក្ខុសង្ឃនាម សេក ឌីណា ព្រះជន្ម ៣៥ វស្សា បានទាញយកដបសាំងដែលលាក់ក្នុងស្បង់មកស្រោចប៉ុនប៉ងដុតព្រះកាយលើវេទិកា មហាបាតុកម្មរបស់គណបក្សសង្គ្រោះជាតិ បន្ទាប់ពីសម្តែងការឈឺចាប់ទៅលើការដឹកនាំរបស់លោកនាយករដ្ឋ មន្ត្រី ហ៊ុន សែន ថា ពោរពេញទៅដោយភាពអយុត្តិធម៌។ ព្រះអង្គ បានមានសង្ឃដីកាថ្កោលទោសរដ្ឋាភិបាលរបស់លោក ហ៊ុន សែន ដែលបានកាន់អំណាចជាង ៣០ ឆ្នាំថា នាយករដ្ឋមន្ត្រីរូបនេះ បានធ្វើបាប និងសម្លាប់ប្រជាជនខ្មែរ ដោយបញ្ជូនពួកគេទៅក-៥ ហើយបានបំផ្លាញធនធានជាតិ បានផ្តល់ដីសម្បទានទៅក្រុមហ៊ុនបរទេស រហូតដល់ ៩៩ ឆ្នាំ។
- **ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣** ៖ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះបាទ នរោត្តម សីហមុនី ទ្រង់ផ្ញើព្រះរាជសារមួយ ជូនបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រនៃគណបក្សសង្គ្រោះជាតិទាំង ៥៥រូប ដែលបានប្រកាសធ្វើពហិការចូលរួមបើកសម័យប្រជុំដំបូងនៃរដ្ឋសភា នីតិកាលទី៥ អញ្ជើញចូលរួមក្នុងសម័យប្រជុំដំបូងនៃរដ្ឋសភា ដែលបានកំណត់ទុកនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ដើម្បីបង្ហាញនូវការរួបរួម និងឯកភាពជាតិ។ ព្រះរាជសារបានលើកយកមាត្រា ៨២ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលបានប្រទានព្រះរាជសិទ្ធិដល់ ព្រះមហាក្សត្រ យាងជា ព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងសម័យប្រជុំដំបូងនៃរដ្ឋសភា នីតិកាលថ្មី។
- **ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ ៖** ព្រះមហាក្សត្របានផ្ញើព្រះរាជសារមួយជូនសមាជិក សមាជិកា រដ្ឋសភារបស់គណបក្សសង្គ្រោះជាតិ ចំនួន ៥៥រូប បញ្ជាក់ថា យោងតាមមាត្រា ៨២ថ្មី នៃរដ្ឋធម្មនុញ្ញ ព្រះអង្គនឹងយាងជាព្រះរាជាធិបតីនៅក្នុងសម័យប្រជុំដំបូងនៃរដ្ឋសភានីតិកាលទី៥ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣។ ព្រះរាជសារបានបន្ថែមថា ព្រះអង្គសូមឯកឧត្តម និងលោកជំទាវ សមាជិកគណបក្សសង្គ្រោះជាតិ មេត្តាអញ្ជើញចូលរួមក្នុងសម័យប្រជុំសភាដំបូង ដើម្បីបង្ហាញនូវការរួបរួមជាតិនិងឯកភាពជាតិ។
- **ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣ ៖** បេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិទាំងអស់ បានដាក់លិខិតថ្វាយព្រះករុណាសម្តេចព្រះ នរោត្តម សីហមុនី ដោយបញ្ជាក់ថា បេក្ខជនជាប់ឆ្នោតទាំង

៥៥រូប របស់គណបក្សសង្គ្រោះជាតិ នឹងមិនទៅចូលរួមប្រជុំទៅតាមការកោះអញ្ជើញរបស់ព្រះមហាក្សត្រទេនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ទេ។ មូលហេតុចម្បងដែលគណបក្សសង្គ្រោះជាតិ មិនទៅចូលរួមប្រជុំសភានោះ ត្រូវបានបកស្រាយថា បេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិគោរពតាមឆន្ទៈរបស់ប្រជាពលរដ្ឋដែលទាមទារឲ្យរដ្ឋាភិបាលបង្កើតគណៈកម្មការស៊ើបអង្កេតលទ្ធផលបោះឆ្នោតជាមុនសិន។

- **ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៣** ៖ តំណាងសង្គមស៊ីវិល៤នាក់ត្រូវបានអនុញ្ញាតឱ្យនាំយកញត្តិទៅថ្វាយព្រះមហាក្សត្រ តាមរយៈមន្ត្រីព្រះបរមរាជវាំង។ ញត្តិដែលសរសេររួមគ្នាដោយអង្គការសង្គមស៊ីវិលចំនួន១០ដែល ស្នើឱ្យព្រះមហាក្សត្រពន្យារការប្រជុំសភាដំបូងនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣។ ញត្តិដដែលសរសេរថា គណបក្សទាំងពីរគួរតែមានពេលវេលាច្រើនជាងនេះដើម្បីអាចពិភាក្សា ដោះស្រាយបញ្ហាជាតិដោយសន្តិវិធី។
- **ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣** ៖ សម័យប្រជុំរដ្ឋសភាលើកដំបូង នីតិកាលទី៥ បានប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ នរោត្តម សីហមុនី បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ របស់គណបក្សប្រជាជនកម្ពុជា ទាំង ៦៨ រូប ចូលរួម។
- **ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣** ៖ មេដឹកនាំជាន់ខ្ពស់គណបក្សសង្គ្រោះជាតិ បានប្រកាសថ្កោលទោសរដ្ឋាភិបាលថ្មីដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា នៅក្នុងសន្និសីទសារព័ត៌មាននៅទីស្នាក់ការកណ្តាលគណបក្សសង្គ្រោះជាតិ នាសង្កាត់ចាក់អង្រែលើ ថាជារដ្ឋាភិបាលខុសច្បាប់ ដោយសារបង្កើតឡើងនោះមិនគោរពតាមរដ្ឋធម្មនុញ្ញកម្ពុជា។
- **ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣** ៖ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់បានឡាយព្រះហត្ថលេខា លើព្រះរាជក្រឹត្យមួយ តែងតាំង (សរុប៥៥រូប) ទីប្រឹក្សាផ្ទាល់ចំនួន ២១រូប និងជំនួយការ ចំនួន ៣៤រូប របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា។
- **ថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៣** ៖ ដូចការគ្រោងទុកជាមុន សមាជមហាជនរបស់គណបក្សសង្គ្រោះជាតិបានចាប់ផ្តើមនៅរសៀលថ្ងៃអាទិត្យ ក្រោមការដឹកនាំរបស់លោក សម រង្ស៊ី ប្រធានគណបក្ស និងលោក កឹម សុខា អនុប្រធានគណបក្ស។ មានប្រជាពលរដ្ឋចូលរួមប្រមាណជាង១ម៉ឺននាក់ ដោយមានការជួបជុំថ្លែងសារនយោបាយ និងលើកឡើងពីកង្វល់ផ្សេងរបស់តំណាងអ្នកចូលរួម នៅក្រោមតំណក់ភ្លៀងបន្តិចបន្តួច ។ អង្គសមាជបានសម្រេចទៅលើចំណុចមួយចំនួន ក្នុងនោះ បានប្រកាសថា នឹងធ្វើមហាបាតុកម្មនៅទូទាំងប្រទេសនៅថ្ងៃ២៣ ខែតុលា ឆ្នាំ២០១៣ ម្តងទៀត។
- **ថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៣** ៖ លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ ត្រូវបានអមដំណើរដោយមន្ត្រីជាន់ខ្ពស់ និងអង្គរក្សរបស់លោក ឆ្ពោះទៅការិយាល័យចុះឈ្មោះបោះឆ្នោត នៅភូមិព្រែកតាគង់ទី១ សង្កាត់ចាក់អង្រែលើ ជាសង្កាត់ដែលមានទីលំនៅអចិន្ត្រៃយ៍របស់លោកសព្វថ្ងៃ ដើម្បីចុះឈ្មោះបោះឆ្នោតឡើងវិញ។ ប្រធានគណបក្សសង្គ្រោះជាតិ ត្រូវបានមន្ត្រីបោះឆ្នោតក្នុងសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ ចុះឈ្មោះរបស់លោកចូលក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅរសៀលថ្ងៃចន្ទនោះ។ លោក សម រង្ស៊ី មិនបានបោះឆ្នោត និងមិនអាចចុះឈ្មោះជាបេក្ខជនតំណាងរាស្ត្របានសម្រាប់ការបោះឆ្នោតនីតិកាលទី៥ នេះ ដោយសារ គ.ជ.ប បានលុបឈ្មោះរបស់លោកចោល ក្រោយពីលោកត្រូវបានតុលាការកាត់ទោស

ក្នុងសំណុំរឿងព្រំដែន។ ការចុះឈ្មោះបោះឆ្នោតលើកនេះ គឺជាជំហានមួយដែលអនុញ្ញាតអោយលោក សម រង្ស៊ី ឈានជើងចូលក្នុងបញ្ជីឈ្មោះអ្នកតំណាងរាស្ត្រ តាមរយៈការអនុវត្តន៍នីតិវិធីមួយចំនួន។

- **ថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៣** ៖ ប្រធានគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី បានធ្វើដំណើរចាកចេញពីប្រទេសកម្ពុជា ទៅកាន់ប្រទេសមួយចំនួននៅទ្វីបអឺរ៉ុប និងអាមេរិក ក្នុងគោលបំណងស្វែងរកការគាំទ្រពីសហគមន៍អន្តរជាតិ ដើម្បីដាក់សម្ពាធដល់រដ្ឋាភិបាលដែលទើបបង្កើតនៅក្រោយការបោះឆ្នោតកន្លងទៅថ្មីៗនេះ ដែលបក្សប្រឆាំងមិនទទួលស្គាល់ និងចូលរួមធ្វើការងារជាមួយក្នុងរដ្ឋាភិបាល។
- **ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៣** ៖ សាលារាជធានីភ្នំពេញ បានចេញលិខិតជាផ្លូវការប្រឆាំងនឹងគណបក្សសង្គ្រោះជាតិ ដែលកំពុងធ្វើសកម្មភាពប្រមូលស្នាមមេដៃពលរដ្ឋឲ្យបានយ៉ាងហោចណាស់ ៣លាននាក់ ក្នុងគោលបំណងយកទៅដាក់ជូនអង្គការសហប្រជាជាតិ ដើម្បីស្នើព្យួរសមាជិកភាពកម្ពុជា នៅអង្គការសហប្រជាជាតិ ដោយចោទថា មិនបានសុំការអនុញ្ញាតជាមុន។
- **ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣** ៖ រដ្ឋសភាក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា បានបើកសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ ដើម្បីបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មការជំនាញទាំង៩ នៃរដ្ឋសភា។ ការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មការទាំង៩ របស់បក្សកាន់អំណាច ប្រកបដោយជោគជ័យ ដោយទទួលបានសំឡេងគាំទ្រ ៦៥ លើ ៦៥ នៃចំនួនសមាជិកបានចូលរួម។ លោក ហ៊ុន សែន លោក សុខ អាន និង លោក ហោ ណាំហុង មិនបានចូលរួមក្នុងសម័យប្រជុំនេះទេ ដោយលោកទាំងបីជាប់រវល់បំពេញការងារនៅក្រៅប្រទេស។
- **ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៣** ៖ លោក ជាម យៀប[20] សមាជិករដ្ឋសភាតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា បានដាក់ទំនាយមេបក្សជំទាស់ឲ្យជួបគ្រោះមហន្តរាយ ឲ្យជួបគ្រោះថ្នាក់ដល់អាយុជីវិតក្នុងពេលធ្វើដំណើរតាមយន្តហោះទៅក្រៅប្រទេស កុំឲ្យបានជោគជ័យក្នុងដំណើរកៀរគររកការគាំទ្ររបស់អន្តរជាតិ ចំពោះវិបត្តិបោះឆ្នោតនៅកម្ពុជា។
- **ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៣** ៖ ខុទ្ទកាល័យឯកឧត្តម ស ខេង សមាជិកគណៈ អចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលនៃគណបក្សប្រជាជនកម្ពុជា បានចេញសេចក្តីប្រកាសព័ត៌មានមួយ ដោយបានអះអាងថា ថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិ មានជំហរខុសគ្នាអំពីការទាមទារចង់បានតំណែងប្រធានរដ្ឋសភា។ ទោះបីជាយ៉ាងណា អនុប្រធានបក្សសង្គ្រោះជាតិ លោក កឹម សុខា និងអ្នកនាំពាក្យគណបក្សសង្គ្រោះជាតិ លោក យឹម សុវណ្ណ បានបញ្ជាក់ថា គណបក្សសង្គ្រោះជាតិ នៅតែរក្សាជំហរទាមទារតំណែងប្រធានរដ្ឋសភាដដែល។
- **ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៣** ៖ ខណៈដែលសមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា កំពុងរៀបចំបាតុកម្មអហិង្សានៅទីលានសេរីភាព អបអរទិវាគ្រូបង្រៀនអន្តរជាតិ ស្រាប់តែមនុស្សម្នាក់មានកាំភ្លើងជាប់ខ្លួន និងមានពាក់ស្លាកអ្នកសារព័ត៌មាន គេហទំព័រ មង្គល រិទ្ធិ បានបន្លំចូលក្នុងការជួបជុំរបស់ក្រុមគ្រូបង្រៀន។ ជនសង្ស័យត្រូវបានអ្នកចូលរួមចាប់ខ្លួន វាយរហូតដល់ សន្លប់ និងដកហូតអាវុធ ហើយប្រគល់ជូនអាជ្ញាធ

[20] វិទ្យុអាស៊ីសេរី ៖ តំណាងរាស្ត្របក្សប្រជាជនដាក់ទំនាយមេបក្សជំទាស់ http://www.rfa.org/khmer/news/politics/Ruling-Party-MP-Chiem-Yeap-Curses-CNRP-President-Sam-Rainsy-to-meet-a-plane-crash-10112013001128.html

រដើម្បីស្រាវជ្រាវ និងកាត់ទោស។ បណ្តាញព័ត៌មានក្នុងស្រុកបានផ្សាយថា ជនល្មើសទំនងជាមានបំណងបាញ់លោកស្រី មួរ សុខហួរ និងលោក រ៉ុង ឈុន។

○ **ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣** ៖ លោក កឹម សុខា ប្រធានស្តីទីគណបក្សសង្គ្រោះជាតិ បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយថា អាជ្ញាធរ មិនអនុញ្ញាតឲ្យគណបក្សសង្គ្រោះជាតិ ចូលគោរពព្រះវិញ្ញាណក្ខន្ធរបស់ព្រះអង្គនៅវិមានព្រះបរមរូប សម្តេចព្រះ នរោត្តម សីហនុ លើសួនច្បារ ខាងកើតវិមានឯករាជ្យ ទេ លុះត្រាតែពិធីផ្លូវការ នៃការគោរពព្រះវិញ្ញាណក្ខន្ធរបស់ព្រះករុណា ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៣ រួចរាល់ ទើបគេអនុញ្ញាតឲ្យគណបក្សប្រឆាំង ទៅគោរពព្រះវិញ្ញាណក្ខន្ធព្រះអង្គ នៅទីតម្កល់ព្រះបរមរូប។

## ឧបសម្ព័ន្ធទី៧៖ សេចក្តីថ្លែងការណ៍រួមរបស់បន្ទប់ស្ថានការណ៍

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

---

## សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## ការវាយតម្លៃស្ថានភាពមុនថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣

ភ្នំពេញ,ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣

អង្គការសង្គមស៊ីវិលដែលតាមដាន និងសង្កេតការណ៍ដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ បានសង្កេតឃើញស្ថានភាពវិជ្ជមាន ភាពមិនប្រក្រតី និងភាពមិនស្មើគ្នា ព្រមទាំងបានផ្តល់អនុសាសន៍មុនថ្ងៃបោះឆ្នោតដូចខាងក្រោម៖

**I .ភាពវិជ្ជមាន**

-ស្ថា នភាពមានភាពធូរស្រាលដោយសារតែអំពើហឹង្សាមានការថយចុះច្រើន និងព្រះមហាក្សត្របានលើកលែងទោសឲ្យលោក សម រង្ស៊ី ដោយយោងតាមលិខិតស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រី ព្រមទាំងពុំមានការរំខានរាំងដល់ដំណើរការឃោសនារបស់គាត់។

- ប្រជាពលរដ្ឋកម្ពុជាបានចូលរួមសកម្ម (ជាពិសេសយុវជន)ភាពយុទ្ធនាការឃោសនាបោះឆ្នោតយ៉ាងច្រើន ដែលខុសពីអាណត្តិមុនៗ។

- ប្រជាពលរដ្ឋកម្ពុជាហ៊ានបញ្ចេញមតិនយោបាយរបស់ខ្លួននៅតាមទីសាធារណៈនានាដោយពុំមានការភ័យខ្លាច។

- ប្រជាពលរដ្ឋមានការយល់ដឹងអំពីសិទ្ធិក្នុងសង្គមប្រជាធិបតេយ្យមានការរីកចំរើន ជាពិសេសប្រជាជនជាច្រើនមិនជឿងប់ងល់លើគណបក្សណាមួយឡើយ។ ប្រជាពលរដ្ឋនឹងតាមដានសកម្មភាពគណបក្សដែលគេគាំទ្រ ប្រសិនបើមិនគោរពតាមការសន្យារបស់ខ្លួន ប្រជាពលរដ្ឋនឹងមិនបន្តគាំទ្រគណបក្សនោះទៀតទេ។

- ប្រព័ន្ធផ្សព្វផ្សាយសង្គម) Facebook, Twitter, Youtube... (មានការរីកចំរើនក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោត និងគោលនយោបាយរបស់គណបក្សនយោបាយទៅដល់ប្រជាពលរដ្ឋ។

- អំពើហឹង្សាធ្ងន់ធ្ងរនយោបាយបានធ្លាក់ចុះយ៉ាងច្រើនបើធៀបនឹងអាណត្តិមុនៗ។

---

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

**II. ភាពមិនប្រក្រតី**

- បញ្ជីឈ្មោះអ្នកបោះឆ្នោតមានភាពប៉ោងចំនួននៃអ្នកបោះឆ្នោតលើសពី១០០ដែលធ្វើឲ្យមានមន្ទិល % ថាអាចនឹងមានការបន្លំសន្លឹកឆ្នោត។ មានអ្នកមានសិទ្ធិបោះឆ្នោត និងអ្នកដែលបានបោះឆ្នោតពីមុនកន្លងមកមួយចំនួនមិនមានឈ្មោះ និងបាត់ឈ្មោះពីក្នុងបញ្ជីបោះឆ្នោត។

- ការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ឲ្យការបោះឆ្នោតដ៏ច្រើនលើសលុប ដែលចំនួនខ្លះពុំមានភាពត្រឹមត្រូវ និងតម្លាភាព ក្នុងនោះ ១ សន្លឹក៨៩៣,០៩៨,បានចេញក្នុងការបោះឆ្នោតមុនៗ និងក្នុងការបោះឆ្នោតលើកនេះមានចំនួនជាង៧០០សន្លឹក០០០,[1]បន្ថែមទៀត។

- មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋាភិបាលបានធ្វើសកម្មភាព និងដឹកនាំការឃោសនាបោះឆ្នោត ព្រមទាំងប្រើប្រាស់ធនធានរដ្ឋថែមទៀតផង។

- អាជ្ញាធរខេត្តមួយចំនួនបានហាមឃាត់ទីកន្លែងសាធារណៈមួយចំនួនមិនឲ្យធ្វើការហែក្បួន ឬជួបប្រជុំធ្វើសកម្មភាពឃោសនាបោះឆ្នោត ដែលធ្វើឲ្យប៉ះពាល់ដល់ភាពសេរី និងយុត្តិធម៌នៃដំណើរការបោះឆ្នោត។

- មានការរំខាន[2] និងប្រើហឹង្សាខ្លះៗក្នុងពេលយុទ្ធនាការឃោសនា ជាពិសេសពេលមានក្បួនដង្ហែប៉ះគ្នា។

- មានការប្រើរចនាសម្ព័ន្ធរដ្ឋ និងឯកជនគំរាមកំហែង និងគាបសង្កត់ទៅលើអ្នកបោះឆ្នោតឲ្យបោះឆ្នោតគាំទ្រគណបក្សណាមួយ។

**III. ភាពមិនស្មើគ្នា**

- គណបក្សកាន់អំណាចគ្រប់គ្រងពេញ៣០ថ្ងៃនៅទីកន្លែងសាធារណៈមួយចំនួនផ្ដាច់មុខក្នុងយុទ្ធនាការឃោសនារបស់ខ្លួន។

- គណបក្សដែលមានធនធានច្រើនបានប្រើប្រាស់ច្រើនលើសលប់លើគណបក្សដែលមានធនធានតិចតួចនូវស្លាកសញ្ញាឃោសនានៅតាមដងផ្លូវ និងតាមទីសាធារណៈនានាដោយពុំស្មើភាពគ្នា។

- ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកមានភាពលំអៀងច្រើនលើសលប់ទៅ(...វិទ្យុ និងទូរទស្សន៍) លើគណបក្សកាន់អំណាច។

**IV. អនុសាសន៍**

***១ប.ជ.ចំពោះគ.***

- អនុញ្ញាតឲ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតអាចត្រួតពិនិត្យទឹកខ្មៅជ្រលក់ដៃនៅតាមការិយាល័យបោះឆ្នោតនីមួយៗ។

---

[1] យោងតាមរបាយការណ៍របស់គ.ជ.ប

[2] របាយការណ៍លំអិតក្នុងឧបសម្ព័ន្ធរបស់ខុមហ្វ្រែល និងនិកហ្វិក

- មិនត្រូវអនុញ្ញាតឲ្យប្រើលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោតណាដែលមិនគ្រប់លក្ខណៈ(គ្មានរូបថត ឬគ្មានត្រា ឬគ្មានស្នាមមេដៃ...)ដើម្បីបោះឆ្នោតនោះទេ។
- ផ្តល់តារាងលទ្ធផល(ទំរង់១១០៤) ដល់អ្នកសង្កេតការណ៍នៅតាមការិយាល័យបោះឆ្នោត នីមួយៗ។

***២សំរាប់ភ្នាក់ងារគណបក្ស .នយោបាយ***

-ត្រូវហ៊ានតវ៉ាដល់មន្ត្រីការិយាល័យបោះឆ្នោត ដើម្បីចូលឲ្យជិតការរាប់សន្លឹកឆ្នោត ប្រសិនបើមើលមិនឃើញច្បាស់គំនូសសន្លឹកឆ្នោតនោះទេ។

- ត្រូវនៅរហូតដល់រាប់សន្លឹកឆ្នោតចប់ និងយកឲ្យបានតារាងលទ្ធផលផ្លូវការ១១០៤ទំរង់))ពីប្រធានការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ។

***៣សំរាប់អ្នកដឹកនាំនយោបាយ .***

- សូមមេត្តាមានការអត់ធ្មត់ ដោយខិតខំរិះរកដំណោះស្រាយលើបញ្ហានានាដោយសន្តិវិធី ជាពិសេសនៅក្រោយថ្ងៃបោះឆ្នោត

***៤ .សំរាប់សហគមន៍អន្តរជាតិ***

- សូមចូលរួមតាមដានយ៉ាងជិតដិត និងជួយធ្វើអន្តរាគមន៍ទាន់ពេលវេលានៅពេលមានបញ្ហាធំៗកើតឡើង

***៥សំរាប់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ .***

- សូមប្រកាន់នូវជំហរអព្យាក្រឹត្យក្នុងនាមជាកងកម្លាំងរបស់ជាតិដោយមិនចូលអន្តរាគមន៍ ឬពាក់ព័ន្ធ ដោយប្រើអាវុធនៅក្នុងជំលោះនយោបាយ ជាពិសេសត្រូវចេញសេចក្តីថ្លែងការណ៍បញ្ជាក់ពីជំហរអព្យាក្រិត្យនេះជាសាធារណៈជាបន្ទាន់។

***៦សំរាប់ក្រុមប្រឹក្សាធម្មនុញ្ញ .***

- សូមពិនិត្យបណ្តឹងតវ៉ាករណីលោក សម រង្ស៊ី ដើម្បីដាក់ឈ្មោះក្នុងបញ្ជីបេក្ខជនតំណាងរាស្ត្រដល់គាត់វិញ ពីព្រោះមេដឹកនាំគណបក្សប្រឆាំងធំជាងគេមិនអាចបាត់លទ្ធភាពឈរជាបេក្ខជនតំណាងរាស្ត្រនោះទេ ប្រការនេះអាចធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់គោលការណ៍សេរី និងយុត្តិធម៌នៃការបោះឆ្នោត និងការប៉ះពាល់តម្លៃនៃការលើកលែងទោសពីព្រះមហាក្សត្រ ព្រមទាំងសំណើបង្រួបបង្រួមជាតិរបស់សម្តេចនាយករដ្ឋមន្ត្រី។

*សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង*


| | | |
|---|---|---|
| ១. លោក ធន សារាយ | ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល | ទូរស័ព្ទលេខ ០១៦ ៤៤ ០០ ៤៤ |
| ២. លោក សុក សំអឿន | អនុប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល | ទូរស័ព្ទលេខ ០១២ ៩០ ១១ ៩៩ |
| ៣. លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការខុមហ្វ្រែល | ទូរស័ព្ទលេខៈ ០១២ ៩៤២ ០១៧ |
| ៤. លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិក | ទូរស័ព្ទលេខៈ ០១២ ៩៥៩ ៦៦៦ |


COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

## សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## ការព្រួយបារម្ភអំពីទឹកខ្មៅជ្រលក់ម្រាមដៃ និងបញ្ជីឈ្មោះអ្នកបោះឆ្នោត

ភ្នំពេញ, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៣

សម្ព័ន្ធអង្គការសង្គមស៊ីវិលដែលតាមដាន និងសង្កេតការណ៍ដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ មានការព្រួយបារម្ភអំពីទឹកខ្មៅជ្រលក់ម្រាមដៃ ព្រមទាំងបញ្ជីឈ្មោះបោះឆ្នោតដែលនឹងប្រើប្រាស់សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ខាងមុខនេះ។

ក្រោយពីខុមហ្វ្រែលបានសាកល្បងលុបជម្រះទឹកខ្មៅជ្រលក់ម្រាមដៃ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) នឹងយកទៅសម្រាប់ប្រើប្រាស់ជ្រលក់ម្រាមដៃអ្នកបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដ៏ខ្លីខាងមុខនេះ យើងសង្កេតឃើញថា ទឹកខ្មៅជ្រលក់ម្រាមដៃដែលជ្រលក់នៅទីស្នាក់ការ គ.ជ.ប អាចលុបចេញបានទាំងស្រុង។ ខុមហ្វ្រែលបានសាកល្បងធ្វើការលុបដោយចំណាយពេលតែ២ទៅ៣នាទីប៉ុណ្ណោះ ក៏បានជម្រះទឹកខ្មៅនោះបានទាំងស្រុង ដែលបន្ទាប់ពីការជ្រលក់ប្រហែល២ឬ៣ម៉ោង។

បន្ថែមពីនេះ ការប្រកាសរបស់គ.ជ.ប នៅក្នុងសន្និសីទសារព័ត៌មាននៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣ ដោយបានលើកឡើងថាបញ្ជីឈ្មោះបោះឆ្នោតនឹងមិនត្រូវបានអនុញ្ញាតឲ្យអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយធ្វើការផ្ទៀងផ្ទាត់នៅតាមបរិវេណ និងការិយាល័យបោះឆ្នោតបានឡើយ។ ការណ៍នេះស្របពេលដែលស្ថាប័នខ្លះ និងគណបក្សនយោបាយមានបំណងធ្វើការផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោត។

បន្ថែមជាមួយជម្រះទឹកខ្មៅការហាមរបស់គ.ជ.បទៅលើការផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោតខ្វះតម្លាភាពបែបនេះ អាចធ្វើឲ្យមានការមន្ទិលសង្ស័យដែលងាយស្រួលអាចមានការបន្លំសម្រាប់ការបោះឆ្នោតនាពេលខាងមុខនេះ។

បន្ទប់ស្ថានការណ៍នៃសម្ព័ន្ធអង្កេតការសង្គមស៊ីវិលសូមអំពាវនាវដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ធ្វើយ៉ាងណាពិភាក្សាជាមួយគណបក្សនយោបាយដែលចូលរួមការប្រកួតប្រជែងអំពីវិធានការណ៍ដោះស្រាយចំពោះបញ្ហា ដែលបានលើកឡើងដូចខាងលើ។ ម្យ៉ាងវិញទៀត គ.ជ.ប ត្រូវតែបើកចំហរឲ្យស្ថាប័ន

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

មួយចំនួន ជាពិសេសភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចយកបញ្ជីបោះឆ្នោតទៅផ្ទៀងផ្ទាត់នៅបរិវេណ ឬខាងក្នុងការិយាល័យបោះឆ្នោតបាន ហើយថែមទាំងផ្តល់បញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានប្រើប្រាស់នៅការិយាល័យបោះឆ្នោតដោយមន្ត្រីការិយាល័យបោះឆ្នោត បើកចំហរនៅក្រោយថ្ងៃបោះឆ្នោតដើម្បីបង្ហាញពីតម្លាភាព។ មិនតែប៉ុណ្ណោះ ទឹកខ្មៅជ្រលក់ម្រាមដៃគួរតែត្រូវបានធ្វើការសាកល្បងនៅការិយាល័យបោះឆ្នោត ដើម្បីប្រាកដអំពីគុណភាពនៃទឹកខ្មៅជ្រលក់ម្រាមដៃ។

*សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង*

១. លោក ធន សារាយ ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល ០១៦ ៨៤ ០០ ៨៤

២. លោក សុក សំអឿន ប្រធានសម្របសម្រួលនៃគណៈកម្មាធិការប្រព្រឹត្តកម្ម(CHRAC)០១២ ៩០ ១១ ៩៩

៣. លោក គល់ បញ្ញា នាយកប្រតិបត្តិអង្គការខុមហ្វ្រែល ០១២ ៩៤២ ០១៧

៤. លោក ហង្ស ពុទ្ធា នាយកប្រតិបត្តិអង្គការនិកហ្វិច ០១២ ៩៥៩ ៦៦៦

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

---

## សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## លទ្ធផលបឋមនៃការសង្កេតនៅថ្ងៃស និងថ្ងៃបោះឆ្នោត រាប់សន្លឹកឆ្នោត

ភ្នំពេញ, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣

នៅថ្ងៃបោះឆ្នោតនេះ បន្ទប់ស្ថានការណ៍បោះឆ្នោត យល់ឃើញថា ដំណើរការបោះឆ្នោតនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣នេះ បានប្រព្រឹត្តទៅស្របតាមប្រតិទិន ដែលបានគ្រោងទុករបស់គ.ជ.ប បើទោះបីជាមានអំពើហឹង្សាតិចតួច និងភាពមិនប្រក្រតីខ្លះបានកើតឡើងក្នុងកំឡុងពេលថ្ងៃបោះឆ្នោតនេះ។

យ៉ាងណាមិញ សំរាប់ការបោះឆ្នោតនីតិកាលទី៥នេះ ប្រជាពលរដ្ឋមានការចូលរួមយ៉ាងសកម្មក្នុងការបោះឆ្នោត។

បន្ទប់ស្ថានការណ៍រកឃើញជាបឋមនូវភាពមិនប្រក្រតីប្រមាណចំនួន ២០០ករណី (ក្នុងខេត្តមួយចំនួនដូចជា កំពង់ចាម ភ្នំពេញ ព្រៃវែង សៀមរាប ស្វាយរៀង និងខេត្តផ្សេងៗទៀត) ដែលក្នុងនោះទាក់ទងទៅនឹងការបាត់ឈ្មោះ និងរកឈ្មោះមិនឃើញ ព្រមទាំងអាជ្ញាធរមានវត្តមាននៅតាមការិយាល័យបោះឆ្នោត។

បន្ទប់ស្ថានការណ៍សូមអំពាវនាវឲ្យប្រជាពលរដ្ឋ និងអាជ្ញាធរ គ្រប់គណបក្សនយោបាយ កងកម្លាំងប្រដាប់អាវុធ រក្សានូវភាពស្ងៀមស្ងាត់ ដើម្បីរង់ចាំការប្រកាសលទ្ធផលរបស់គ.ជ.ប។


*សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង*

១. លោក ធន សារាយ ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល ០១៦ ៤៤ ០០ ៤៤

២. លោក សុក សំអឿន ប្រធានសម្របសម្រួលនៃគណៈកម្មាធិការប្រព្រឹត្តកម្ម(CHRAC)០១២ ៩០ ១១ ៩៩

៣. លោក គល់ បញ្ញា នាយកប្រតិបត្តិអង្គការខុមហ្វ្រែល ០១២ ៩៤២ ០១៧

៤. លោក ហង្ស ពុទ្ធា នាយកប្រតិបត្តិអង្គការនិកហ្វិច ០១២ ៩៥៩ ៦៦៦


---

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣

# Situation Room on Cambodia Election Day 2013

---

## សេចក្តីថ្លែងការណ៍រួម

## ស្តីពី

## ការបន្តការអង្កេតស្រាវជ្រាវទៅលើភាពមិនប្រក្រតីក្នុងការបោះឆ្នោតឆ្នាំ២០១៣

ភ្នំពេញ,ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៣

បន្ទប់ស្ថានការណ៍ថ្ងៃបោះឆ្នោត សូមធ្វើការកត់សំគាល់ថាខុមហ្វ្រែលបានបញ្ជាក់រួចហើយថាលទ្ធផលបោះឆ្នោតបឋមចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៣គឺមិនមែនជាលទ្ធផលផ្លូវការទេ។ បន្ទប់ស្ថានការណ៍កំពុងធ្វើការអង្កេតភាពមិនប្រក្រតីមួយចំនួនទាក់ទិននឹងលទ្ធផលបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោត ដើម្បីការពារសិទ្ធិអ្នកបោះឆ្នោត និងសុច្ចរិតភាពនៃការបោះឆ្នោត។

បន្ទប់ស្ថានការណ៍សូមស្នើដល់គ.ជ.ប បង្កើនតម្លាភាពបន្ថែមក្នុងការបើកចំហរផ្នែកឯកសារៈ

- បើកកញ្ចប់សុវត្ថិភាព "ក" ដោយផ្តល់កំណត់ហេតុរាប់សន្លឹកឆ្នោតទំរង់១១០២ ដើម្បីធ្វើការផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោតតាមការិយាល័យនីមួយៗ។
- ផ្តល់បញ្ជីឈ្មោះអ្នកដែលបានបោះឆ្នោតហើយ(បញ្ជីឈ្មោះដែលបានប្រើប្រាស់នៅតាមការិយាល័យបោះឆ្នោត)។
- អនុញ្ញាតឲ្យថតចំលងគល់បញ្ជីនៃលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោតនៅខេត្តមួយចំនួន។

បន្ទប់ស្ថានការណ៍ សូមអំពាវនាវដល់ថ្នាក់ដឹកនាំគណបក្សនយោបាយ សូមដោះស្រាយបញ្ហាបោះឆ្នោតដោយសន្តិវិធីដោយផ្អែកលើភស្តុតាង ហើយក៏សូមអំពាវនាវដល់សាធារណជន និងអ្នកពាក់ព័ន្ធសូមរក្សាភាពស្ងៀមស្ងាត់រង់ចាំដំណោះស្រាយ។

***ព័ត៌មានបន្ថែមសូមទាក់ទងៈ***


| | | |
|---|---|---|
| ១. លោក ធន សារាយ | ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល | ទូរស័ព្ទលេខ ០១៦ ៤៤ ០០ ៤៤ |
| ២. លោក សុក សំអឿន | អនុប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល | ទូរស័ព្ទលេខ ០១២ ៩០ ១១ ៩៩ |
| ៣. លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការខុមហ្វ្រែល | ទូរស័ព្ទលេខ: ០១២ ៩៤២ ០១៧ |
| ៤. លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិក | ទូរស័ព្ទលេខ: ០១២ ៩៥៩ ៦៦៦ |


COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GAD/C, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣

# Situation Room on Cambodia Election Day 2013

## សេចក្តីថ្លែងការណ៍
## ស្តីពី
## ការធានាតម្លាភាពក្នុងការស៊ើបអង្កេត
## របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ភ្នំពេញ, ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៣

បន្ទប់ស្ថានការណ៍នៃអង្គការ សមាគមមិនមែនរដ្ឋាភិបាល មានការខកចិត្តជាខ្លាំងចំពោះជំហរ និងការសំរេចមិនច្បាស់លាស់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដើម្បីធានាតម្លាភាពក្នុងការដោះស្រាយភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោត ពិសេសកិច្ចស៊ើបអង្កេតដ៏ត្រឹមត្រូវមួយ។

ចំណុចដំបូងជាមូលដ្ឋាននៃការស៊ើបអង្កេត និងការស្រាវជ្រាវភាពមិនប្រក្រតីនៃការបោះឆ្នោតគឺត្រូវបើកចំហឯកសារសំខាន់ៗមួយចំនួន ក្នុងនោះរួមមាន៖

១, បញ្ជីបោះឆ្នោតដែលបានប្រើប្រាស់ក្នុងការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត

២. កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់១១០២)

៣. គល់បញ្ជីលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ដោយការថតចម្លង ឬ/និង ថតរូប)។ គ.ជ.បមិនទាន់បានអនុវត្តចំណុចដំបូងជាមូលដ្ឋាននៃការស៊ើបអង្កេត និងការស្រាវជ្រាវនៅឡើយ។

តាំងពីតំណាងអង្គការ សមាគមក្រៅរដ្ឋាភិបាលបានជួបជាមួយមន្ត្រី គ.ជ.ប នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣ និងការដាក់លិខិតស្នើសុំដើម្បីថតចម្លងឯកសារទាំងនោះ គ.ជ.ប បានឆ្លើយតបពេលខ្លះថានឹងសហការណ៍ផ្តល់ឯកសារទាំងនោះ ពេលខ្លះមន្ត្រី គ.ជ.ប និយាយជាមួយអ្នកសារព័ត៌មានថា មិនអាចឱ្យចម្លងឯកសារទាំងនោះបានទេ ក្រោមហេតុផល«ការពារសិទ្ធិឯកជនរបស់បុគ្គល»។ ប៉ុន្តែមកដល់ថ្ងៃនេះ គ.ជ.ប មិនបានធ្វើការសម្រេចឱ្យជាក់ច្បាស់ថាតើគ.ជ.ប សហការផ្តល់ឱ្យចម្លងឯកសារទាំងនោះ ដែរឬទេ?

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

ជាការពិត គោលការណ៍របស់គ.ជ.ប ក៏បានបញ្ជាក់អំពីសារៈសំខាន់នៃតម្លាភាពហើយ ហើយបទបញ្ជា និង នីតិវិធីរបស់ គ.ជ.ប សុទ្ធតែបានចង្អុលបង្ហាញថា បើមានភាពមិនប្រក្រតី គ.ជ.ប ត្រូវបើកចំហរព័ត៌មាន និងឯកសារ នានា រួមទាំងកញ្ចប់សុវត្ថិភាព ក ឬ ខ ។ល។ និង។ល។

បន្ទប់ស្ថានការណ៍នៃអង្គការ សមាគមមិនមែនរដ្ឋាភិបាល មានការព្រួយបារម្ភអំពីស្ថានការណ៍នៃភាពចម្រូង ចម្រាស់អំពីការខុសគ្នានៃលទ្ធផលបោះឆ្នោត និងភាពមិនប្រក្រតីបោះឆ្នោតដែលធ្វើអោយមានស្ថានការណ៍ នយោបាយតានតឹង។ គ.ជ.ប គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ មិនទាន់ឈានទៅរកភាពស្រុះ ស្រួលគ្នាអំពីការបង្កើតគណៈកម្មការចម្រុះពិសេស ដើម្បីស៊ើបអង្កេតភាពមិនប្រក្រតីនៃការបោះឆ្នោត។ ម្យ៉ាងទៀត គ.ជ.ប មិនមានយន្តការ ឬសកម្មភាពជាក់លាក់ឆ្លើយតបនឹងការទាមទាបើកកិច្ចស៊ើបអង្កេតទេ ប៉ុន្តែ គ.ជ.ប ហាក់ មានបំណងឱ្យដំណើរការដោះស្រាយទំនាស់ ឬបណ្ដឹងបោះឆ្នោតទៅតាមទំលាប់ និងប្រតិទិនរបស់ខ្លួនដោយមិន បានពិចារណាអំពីទំហំនៃភាពមិនប្រក្រតី ដែលអាចប៉ះពាល់ដល់លទ្ធផលបោះឆ្នោត និងសិទ្ធិអ្នកបោះឆ្នោត។

គ.ជ.ប គួរខិតខំកែលម្អរបៀបធ្វើការឱ្យមានតម្លាភាព និងទទួលយកការចូលរួមដោយពេញលេញនៃអ្នក ជំនាញការឯករាជ្យក្នុងការអង្កេតភាពមិនប្រក្រតីទាំងនេះ ដើម្បីឆ្លើយតបកង្វល់របស់ម្ចាស់ឆ្នោតជាច្រើន និងអនុ សាសន៍របស់សហគមន៍អន្តរជាតិជាច្រើនដែលចង់ឃើញការអង្កេតមួយប្រកបដោយតម្លាភាព និងយុត្តិធម៌ត្រឹម ត្រូវ។

គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិត្រូវបន្តខិតខំកច្រកចេញ ឬ/និងពិភាក្សាជាមួយ គ.ជ.បអំពីការបង្កើត ការកំណត់នៃទំហំការងារ និងដំណើរការនៃគណៈកម្មការអង្កេតចម្រុះនេះ។

***ព័ត៌មានបន្ថែមសូមទាក់ទង៖***

| | | |
|---|---|---|
| ១. លោក ធន សារាយ | ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល | ០១៦ ៤៤ ០០ ៤៤ |
| ២. លោក សុក សំអឿន | ប្រធានសម្របសម្រួលនៃCHRAC | ០១២ ៩០ ១១ ៩៩ |
| ៣. លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការខុមហ្វ្រែល | ០១២ ៩៤ ២០ ១៧ |
| ៤. លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិច | ០១២ ៩៥ ៩៦ ៦៦ |
| ៥. លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការCLEC | ០១២ ៨០ ១២ ៣៥ |
| ៦. លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិCCIM | ០៦០ ៤០ ៩៩ ៩៩ |
| ៧. លោក សាម អ៊ីន | នាយកប្រតិបត្តិអង្គការជីវិតថ្ងៃថ្មី | ០១២ ៥៥ ១៨ ៨៦ |
| ៨. លោក យ៉ង់ គិមអេង | អនុប្រធានCISA | ០១៦ ៨២៨ ២១១ |
| ៩. លោក អ៊ូ វីរៈ | ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | ០១២ ៤០ ៤០ ៥១ |

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

---

## សេចក្តីថ្លែងការណ៍
## ស្តីពី
## អាជ្ញាធរមូលដ្ឋានបង្ខំម្ចាស់ឆ្នោតអោយផ្តិតមេដៃគាំទ្រលទ្ធផលបោះឆ្នោត ដែលនៅមានភាពចម្រូងចម្រាស់នៅឡើយ

ភ្នំពេញ, ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

យើងទាំងអស់គ្នាជាសមាជិកនៃបន្ទប់ស្ថានការណ៍នៃអង្គការសមាគមន៍មិនមែនរដ្ឋាភិបាល មានការខកចិត្តជាខ្លាំង និងសូមថ្កោលទោសចំពោះទង្វើរបស់អាជ្ញាធរដែនដីនៅក្នុងរាជធានីភ្នំពេញដែលបង្ខំម្ចាស់ឆ្នោតអោយផ្តិតមេដៃលើញត្តិគាំទ្រលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន ដែលនៅមានវិវាទនៅឡើយ។

មានការរាយការណ៍ពីសំណាក់ម្ចាស់ឆ្នោតថា បច្ចុប្បន្នមានការគំរាមកំហែង នៅក្នុងតំបន់មួយចំនួនដូចជាសង្កាត់អូរឬស្សី សង្កាត់ស្រះចក សង្កាត់ពងទឹក សង្កាត់បឹងប៉ាយ៉ាប សង្កាត់ទួលស្វាយព្រៃ១ សង្កាត់បឹងកេងកង ២ និងសង្កាត់ចាក់អង្រែលើ។

ទង្វើនេះគឺជាការបំភិតបំភ័យធ្ងន់ធ្ងរថ្មីមួយទៀត ក្រោយថ្ងៃបោះឆ្នោតជាការរំលោភច្បាប់ និង ជាការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើសេរីភាពបញ្ចេញមតិរបស់ម្ចាស់ឆ្នោតនៅកម្ពុជា។ លើសពីនេះទៅទៀត ទង្វើនេះបានគំរាមកំហែងដល់សិទ្ធិរក្សាការសម្ងាត់របស់ម្ចាស់ឆ្នោត និងបង្កើននូវភាពតានតឹង និងការភ័យខ្លាចដែលកំពុងកើតមាន។

ញត្តិទាំងឡាយណាដែលធ្វើឡើងក្រោមរូបភាពបង្ខិតបង្ខំ នឹងពុំជួយអ្វីដល់ភាពទទួលយកបាននៃលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនោះទេ។ ទង្វើរបស់អាជ្ញាធរដែនដីបែបនេះ វាកាន់តែធ្វើអោយខូចដល់សុច្ចរិតភាពនៃកិច្ចដំណើរការបោះឆ្នោត។ មានតែការស៊ើបអង្កេតដោយតម្លាភាព និងឯករាជ្យនូវភាពមិនប្រក្រតីទាំងឡាយនោះទេ ដែលនឹងស្តារអោយមានសុច្ចរិតភាព។

បន្ទប់ស្ថានការណ៍នៃអង្គការសមាគមមិនមែនរដ្ឋាភិបាល សូមអំពាវនាវឲ្យរដ្ឋាភិបាលបច្ចុប្បន្នចាត់វិធានការណ៍ដើម្បីបញ្ឈប់ទង្វើទាំងអស់នេះ និងភាពមិនប្រក្រតីផ្សេងទៀតដែលប្រព្រឹត្តដោយអាជ្ញាធរមូលដ្ឋាន។

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

**ព័ត៌មានបន្ថែមសូមទាក់ទង៖**

| | | |
|---|---|---|
| ១. លោក ធន សារាយ | ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល | ទូរស័ព្ទលេខ ០១៦ ៤៤ ០០ ៤៤ |
| ២. លោក សុក សំអឿន | ប្រធានសម្របសម្រួលនៃCHRAC | ទូរស័ព្ទលេខ ០១២ ៩០ ១១ ៩៩ |
| ៣. លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការខុមហ្វ្រែល | ទូរស័ព្ទលេខ: ០១២ ៩៤២ ០១៧ |
| ៤. លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិក | ទូរស័ព្ទលេខ: ០១២ ៩៥៩ ៦៦៦ |
| ៥. លោក ព្រាប កុល | នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា | ទូរស័ព្ទលេខ: ០១២៨៧៧៨៣៣ |
| ៦. លោក ហឹម យន់ | អ្នកសម្របសម្រួលអង្គការ CISA | ទូរស័ព្ទលេខ: ០១២៩៤៧០២២ |
| ៧. លោកស្រី រស់ សុភាព | នាយកប្រតិបត្តិអង្គការ GADC | ទូរស័ព្ទលេខ: ០១២ ៦២៧៨៥៧ |
| ៨. លោក ឈឹត សំអាត | នាយកប្រតិបត្តិ វេទិការនៃអង្គការមិនមែនរដ្ឋាភិបាល | ទូរស័ព្ទលេខ: ០១២ ៩២៨៥៨៥ |
| ៩. លោកស្រី ណាលី ពីឡូច | នាយិការ អង្គការលីកាដូ | ទូរស័ព្ទលេខ: ០១២ ៨០៣ ៦៥០ |
| ១០. លោក យ៉េង វីរៈ | នាយកប្រតិបត្តិមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ | ទូរស័ព្ទលេខ: ០៦៦៧៧៧០០០ |
| ១១. លោក សួន ប៊ុនស័ក្តិ | លេខាធិការប្រតិបត្តិ CHRAC | ទូរស័ព្ទលេខ: ០៩២ ៣៤៤ ៣៥៧ |

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

---

## សេចក្តីថ្លែងការណ៍
## ស្តីពី
## អាជ្ញាធរមូលដ្ឋានបង្ខំម្ចាស់ឆ្នោតអោយផ្តិតមេដៃគាំទ្រលទ្ធផលបោះឆ្នោត ដែលនៅមានភាពចម្រូងចម្រាស់នៅឡើយ

ភ្នំពេញ, ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣

យើងទាំងអស់គ្នាជាសមាជិកនៃបន្ទប់ស្ថានការណ៍នៃអង្គការសមាគមន៍មិនមែនរដ្ឋាភិបាល មានការខកចិត្តជាខ្លាំង និងសូមថ្កោលទោសចំពោះទង្វើរបស់អាជ្ញាធរដែនដីនៅក្នុងរាជធានីភ្នំពេញដែលបង្ខំម្ចាស់ឆ្នោតអោយផ្តិតមេដៃលើញត្តិគាំទ្រលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន ដែលនៅមានវិវាទនៅឡើយ។

មានការរាយការណ៍ពីសំណាក់ម្ចាស់ឆ្នោតថា បច្ចុប្បន្នមានការគំរាមកំហែង នៅក្នុងតំបន់មួយចំនួនដូចជាសង្កាត់អូរឬស្សី សង្កាត់ស្រះចក សង្កាត់ពងទឹក សង្កាត់បឹងប៉ាយ៉ាប សង្កាត់ទួលស្វាយព្រៃ១ សង្កាត់បឹងកេងកង ២ និងសង្កាត់ចាក់អង្រែលើ។

ទង្វើនេះគឺជាការបំភិតបំភ័យធ្ងន់ធ្ងរថ្មីមួយទៀត ក្រោយថ្ងៃបោះឆ្នោតជាការរំលោភច្បាប់ និង ជាការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើសេរីភាពបញ្ចេញមតិរបស់ម្ចាស់ឆ្នោតនៅកម្ពុជា។ លើសពីនេះទៅទៀត ទង្វើនេះបានគំរាមកំហែងដល់សិទ្ធិរក្សាការសម្ងាត់របស់ម្ចាស់ឆ្នោត និងបង្កើននូវភាពតានតឹង និងការភ័យខ្លាចដែលកំពុងកើតមាន។

ញត្តិទាំងឡាយណាដែលធ្វើឡើងក្រោមរូបភាពបង្ខិតបង្ខំ នឹងពុំជួយអ្វីដល់ភាពទទួលយកបាននៃលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនោះទេ។ ទង្វើរបស់អាជ្ញាធរដែនដីបែបនេះ វាកាន់តែធ្វើអោយខូចដល់សុច្ចរិតភាពនៃកិច្ចដំណើរការបោះឆ្នោត។ មានតែការស៊ើបអង្កេតដោយតម្លាភាព និងឯករាជ្យនូវភាពមិនប្រក្រតីទាំងឡាយនោះទេ ដែលនឹងស្តារអោយមានសុច្ចរិតភាព។

បន្ទប់ស្ថានការណ៍នៃអង្គការសមាគមមិនមែនរដ្ឋាភិបាល សូមអំពាវនាវឲ្យរដ្ឋាភិបាលបច្ចុប្បន្នចាត់វិធានការណ៍ដើម្បីបញ្ឈប់ទង្វើទាំងអស់នេះ និងភាពមិនប្រក្រតីផ្សេងទៀតដែលប្រព្រឹត្តដោយអាជ្ញាធរមូលដ្ឋាន។

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

**ព័ត៌មានបន្ថែមសូមទាក់ទង៖**

| | | |
|---|---|---|
| ១. លោក ធន សារាយ | ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល | ទូរស័ព្ទលេខ ០១៦ ៤៤ ០០ ៤៤ |
| ២. លោក សុក សំអឿន | ប្រធានសម្របសម្រួលនៃCHRAC | ទូរស័ព្ទលេខ ០១២ ៩០ ១១ ៩៩ |
| ៣. លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការខុមហ្វ្រែល | ទូរស័ព្ទលេខៈ ០១២ ៩៤២ ០១៧ |
| ៤. លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិក | ទូរស័ព្ទលេខៈ ០១២ ៩៥៩ ៦៦៦ |
| ៥. លោក ព្រាប កុល | នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា | ទូរស័ព្ទលេខៈ ០១២៨៧៧៨៣៣ |
| ៦. លោក ហឹម យន់ | អ្នកសម្របសម្រួលអង្គការ CISA | ទូរស័ព្ទលេខៈ ០១២៩៤៧០២២ |
| ៧. លោកស្រី រស់ សុភាព | នាយកប្រតិបត្តិអង្គការ GAD/C | ទូរស័ព្ទលេខៈ ០១២ ៦២៧៨៥៧ |
| ៨. លោក ឈឹត សំអាត | នាយកប្រតិបត្តិ វេទិការនៃអង្គការមិនមែនរដ្ឋាភិបាល | ទូរស័ព្ទលេខៈ ០១២ ៩២៨៥៨៥ |
| ៩. លោកស្រី ណាលី ពីឡូច | នាយិការ អង្គការលីកាដូ | ទូរស័ព្ទលេខៈ ០១២ ៨០៣ ៦៥០ |
| ១០. លោក យ៉េង វីរៈ | នាយកប្រតិបត្តិមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ | ទូរស័ព្ទលេខៈ ០៦៦៧៧៧០០០ |
| ១១. លោក សួន ប៊ុនស័ក្តិ | លេខាធិការប្រតិបត្តិ CHRAC | ទូរស័ព្ទលេខៈ ០៩២ ៣៤៤ ៣៥៧ |

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

## សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## ការវាយតម្លៃលើលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន

*ភ្នំពេញ, ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៣*

បន្ទប់ស្ថានការណ៍នៃអង្គការ សមាគមមិនមែនរដ្ឋាភិបាលវាយតម្លៃថា លទ្ធផលបោះឆ្នោតបណ្តោះអាសន្ន ជាលទ្ធផលជាមួយផលវិបាកចេញមកពីភាពមិនប្រក្រតីជាច្រើននៅក្នុងកំឡុងពេលបោះឆ្នោត ដែលបណ្តាលឲ្យមានការបាត់បង់សិទ្ធិអ្នកបោះឆ្នោតជាច្រើន និងកង្វះនូវភាពយុត្តិធម៌ក្នុងការចាត់ចែងការបោះឆ្នោតជាដើម។ តាមការសង្កេតការណ៍របស់ ខុមហ្វ្រែល និចហ្វិច និងសមាជិកអង្គការបន្ទប់ស្ថានការណ៍ផ្សេងទៀតបានរកឃើញថា មានភាពមិនប្រក្រតី ច្រើនជាងមួយម៉ឺនមួយពាន់ និងតាមការសិក្សាស្រាវជ្រាវរបស់ខុមហ្វ្រែលទៅលើអ្នកមានសិទ្ធិបោះឆ្នោតដែលគ្មានស្នាមទឹកខ្មៅនៅលើចង្អុលដៃបង្ហាញថា៤៨% បានទៅដល់ការិយាល័យបោះឆ្នោត ប៉ុន្តែពួកគាត់មិនបានបោះឆ្នោត ដោយសាររកឈ្មោះ ឬរកការិយាល័យបោះឆ្នោតមិនឃើញ គ្មានឯកសារបញ្ជាក់អត្តសញ្ញាណប្រើប្រាស់ក្នុងការបោះឆ្នោត និងខុសទិន្នន័យក្នុងបញ្ជីបោះឆ្នោតជាដើម។ ចំណែកការសង្កេតរបស់អង្គការតម្លាភាពកម្ពុជា និងសម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម បានរកឃើញថា ៦០%នៃការិយាល័យបោះឆ្នោតប្រជាពលរដ្ឋមានឯកសារបញ្ជាក់អត្តសញ្ញាណត្រឹមត្រូវប៉ុន្តែមិនអាចរកឈ្មោះឃើញក្នុងបញ្ជីបោះឆ្នោត។

បន្ថែមទៅលើនោះទៀត យើងឃើញមានភាពមិនប្រក្រតីនៅថ្ងៃបោះឆ្នោតដែលងាយនឹងប៉ះពាល់ដល់លទ្ធផលបោះឆ្នោតគឺអាចកើតមាននៅក្នុងខេត្តកណ្តាល ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប ព្រោះថាសន្លឹកឆ្នោតខុសគ្នារវាងគណបក្សមួយ ទៅគណបក្សមួយផ្សេងទៀត ដើម្បីទទួលបានអាសនៈនៅសល់ចុងក្រោយគឺមានចំនួនតិចតួចត្រឹមរយទៅពាន់សម្លេងឆ្នោត ជាពិសេសករណីនៅខេត្តកណ្តាលគឺត្រឹមតែ ១៦៨សន្លឹកឆ្នោត ឬ ០.៣% នៃចំនួនសន្លឹកឆ្នោតមធ្យមភាគចុងក្រោយ ដែលអាចប្រែប្រួលអាសនៈមួយនៅសល់ចុងក្រោយ។ កំរិតភាពមិនប្រក្រតីនៅខេត្តកណ្តាលក៏មានច្រើនគួរឲ្យចាប់អារម្មណ៍ផងដែរ ជាពិសេស គេឃើញមានការិយាល័យបោះឆ្នោតលេខ ១២០៤ នៅឃុំស្អាងភ្នំ ស្រុកស្អាងត្រូវបិទមុនពេលកំណត់។ និងម៉្យាងទៀតភាពមិនប្រក្រតីដោយ

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

គ្មានរបាយការណ៍លទ្ធផលបោះឆ្នោតទម្រង់១១០៨នៅ៨ការិយាល័យបោះឆ្នោតក្នុងសង្កាត់តាខ្មៅ ក្រុងតាខ្មៅ និងការប្រែប្រួលចំនួនសន្លឹកឆ្នោតមិនបានការ និងសម្លេងឆ្នោតគណបក្ស។

បន្ទប់ស្ថានការណ៍នៃអង្គការ សមាគមមិនមែនរដ្ឋាភិបាល មានការព្រួយបារម្ភយ៉ាងខ្លាំងអំពីការបន្តបំភិតបំភ័យ និងការគំរាមកំហែងធ្ងន់ធ្ងរដោយមានការជ្រៀតជ្រែកពីរដ្ឋាភិបាល និងកងកម្លាំងប្រដាប់អាវុធក្នុងអំឡុងពេលដោះស្រាយទំនាស់បោះឆ្នោត និងមានការខកចិត្តអំពីការខ្វះភាពយុត្តិធម៌ក្នុងការចាត់ចែង និងការដោះស្រាយបណ្តឹងទៅលើភាពមិនប្រក្រតីនៃការបោះឆ្នោត ព្រោះគ្មានការអង្កេតដោយតម្លាភាព។

ដូចនេះបន្ទប់ស្ថានការណ៍នៃអង្គការ សមាគមមិនមែនរដ្ឋាភិបាលៈ

- ស្នើឲ្យក្រុមប្រឹក្សាធម្មនុញ្ញ និងគ.ជ.ប ពិនិត្យការបោះឆ្នោតឡើងវិញនៅការិយាល័យ ១២០៤ និងរាប់សន្លឹកឆ្នោតឡើងវិញនៅសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ស្នើឲ្យក្រុមប្រឹក្សាធម្មនុញ្ញ និងគណបក្សនយោបាយសំខាន់ៗយកចិត្តទុកដាក់ក្នុងការដោះស្រាយវិវាទបោះឆ្នោតតាមរយៈការសិក្សាស្រាវជ្រាវ ការអង្កេត ដោយមានការស្រុះស្រួលគ្នាប្រកបដោយតម្លាភាព។
- ស្នើឲ្យរាជរដ្ឋាភិបាលដកកងកម្លាំងប្រដាប់អាវុធ និងគ្រឿងយុទ្ធភណ្ឌយោធាដែលរដ្ឋាភិបាលបានដាក់ពង្រាយ បណ្តាលឲ្យមានការបំភិតបំភ័យ ដល់ប្រជាពលរដ្ឋ ទៅកន្លែងដើមវិញ ព្រោះថា គ.ជ.ប និងគណៈកម្មការសន្តិសុខជាតិទទួលបន្ទុកការបោះឆ្នោតជាស្ថាប័នមានសមត្ថកិច្ចរក្សាសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលបោះឆ្នោត។ ម្យ៉ាងទៀតតុលាការ និងរដ្ឋាភិបាលត្រូវដកការចោទប្រកាន់ទៅលើយុវជន និងយុវតីបួននាក់ទាក់ទិននឹងការជួនផ្កាដល់កងកំលាំងប្រដាប់អាវុធជាបន្ទាន់។
- សំណូមពរកុំឲ្យមានការបំភិតបំភ័យ ដល់ប្រជាពលរដ្ឋ ដូចជាការចោទប្រកាន់តាមផ្លូវតុលាការដល់យុវជនទាក់ទិននឹងការជូនផ្កាដល់កងកម្លាំងប្រដាប់អាវុធ និង ការបង្ខំប្រជាពលរដ្ឋពីសំណាក់អជ្ញាធរមូលដ្ឋានឲ្យចុះហត្ថលេខាក្នុងគាំទ្រទៅលើលទ្ធផលបោះឆ្នោតដែលគ.ជ.បបានចេញផ្សាយនៅថ្ងៃទី១២ សីហា ឆ្នាំ២០១៣ ការមិនចូលរួមមហាបាតុកម្ម និងពេញចិត្តចំពោះថៃរក្សាសណ្តាប់ធ្នាប់ ស្ថេរភាពរបស់រដ្ឋាភិបាល។


**<u>ព័ត៌មានបន្ថែមសូមទាក់ទងៈ</u>**

| | | |
|---|---|---|
| ១. លោក សុក សំអឿន | ប្រធានសម្របសម្រួលនៃ CHRAC | ០១២ ៩០ ១១ ៩៩ |
| ២. លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការខុមហ្វ្រែល | ០១២ ៩៤ ២០ ១៧ |
| ៣. លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិច | ០១២ ៩៥ ៩៦ ៦៦ |
| ៤. លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | ០១២ ៨០ ១២ ៣៥ |
| ៥. លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិ CCIM | ០៦០ ៤០ ៩៩ ៩៩ |
| ៦. លោក អ៊ូ វីរៈ | ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | ០១២ ៤០ ៤០ ៥១ |


COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

| | | |
|---|---|---|
| ៧. លោក យ៉ង់ គិមអេង | អនុប្រធាន CISA | ០១៦ ៨២ ៨២ ១១ |
| ៨. លោក ព្រាប កុល | នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា | ០១២ ៨៧៧ ៨៣៣ |
| ៩. លោកស្រី ធីតា យឺះ | នាយិកាអង្គការសីលការ | ០១២ ៨៣ ៨៤ ៦៤ |
| ១០. លោក សុខ ពិទូរ្យ | នាយកប្រតិបត្តិក្រុមប្រឹក្សាយុវជនកម្ពុជា | ០១៧ ២៧ ៣៣ ០៣ |
| ១១. លោក ម៉ាក់ ចំរើន | ប្រធានសមាគមយុវជនខ្មែរ | ០១៧ ៧៨ ៨៩ ៥៥ |
| ១២. លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| ១៣. លោក នី ចរិយា | ប្រធានផ្នែកអង្កេតADHOC | ០១១ ២៧ ៤៩ ៥៩ |

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

## សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## អនុសាសន៍របស់សង្គមស៊ីវិលក្នុងការដោះស្រាយវិវាទនៃការបោះឆ្នោត

*ភ្នំពេញ, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣*

បន្ទប់ស្ថានការណ៍សូមស្វាគមន៍ដល់ដំណើរការដោះស្រាយបណ្តឹងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានសម្រេចឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បើកកញ្ចប់សុវត្ថិភាព "ក"។ បន្ទប់ស្ថានការណ៍សង្កេតឃើញថា កញ្ចប់សុវត្ថិភាព "ក" នេះមានភាពមិនប្រក្រតីជាច្រើននៅមណ្ឌលខេត្តក្រចេះ បាត់ដំបង និងសៀមរាប ភាគច្រើនគឺការមិនបិទកញ្ចប់ត្រឹមត្រូវតាមនីតិវិធី ការកែទិន្នន័យដូចជា ចំនួនសន្លឹកឆ្នោតបានការ និងការខុសទិន្នន័យគ្នាក្នុងទម្រង់១១០៤ ទម្រង់១១០៨ និងទម្រង់១១០២ ការមិនកត់ត្រាសម្លេងឆ្នោតរបស់គណបក្សនយោបាយ។ ម្យ៉ាងទៀត មានការបដិសេធបណ្តឹងរបស់គណបក្សនយោបាយដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) និងក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការសម្រេចជ្រើសរើសក្នុងការស្រាវជ្រាវកញ្ចប់សុវត្ថិភាព"ក" ខ្វះតម្លាភាពពីចំនួនការិយាល័យតិចតួចក្នុងចំណោមពាក្យបណ្តឹងរាប់រយការិយាល័យ មិនតែប៉ុណ្ណោះការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញដោយតម្កល់សេចក្តីសម្រេចរបស់ គ.ជ.ប បដិសេធបណ្តឹងតវ៉ាលទ្ធផលបោះឆ្នោតបណ្តោះអាសន្នសម្រាប់មណ្ឌលខេត្តក្រចេះ ហើយដាក់ពិន័យមន្ត្រីការិយាល័យបោះឆ្នោត។ ហេតុផលទាំងនេះដែលធ្វើឲ្យគណបក្សនយោបាយមួយចំនួន និងប្រជាពលរដ្ឋបន្តមិនមានជំនឿទុកចិត្តទៅលើយន្តការ និងដំណើរវិវឌ្ឍន៍នៃការដោះស្រាយភាពមិនប្រក្រតី និងលទ្ធផលនៃការបោះឆ្នោត។

ដោយសង្កេតឃើញថា ក្រោយពីឯកភាពគ្នារវាងគណបក្សនយោបាយទាំងពីរក្នុងការបង្កើតគណៈកម្មការចម្រុះក្នុងការស៊ើបអង្កេតលើភាពមិនប្រក្រតីនៃដំណើរការបោះឆ្នោតនាថ្ងៃ២៨ កក្កដា ២០១៣ នេះ និងការឆ្លងឆ្លើយលិខិតនៃមេដឹកនាំគណបក្សទាំងពីរអំពីការបន្តការចរចារ ប៉ុន្តែមិនមានការវិវត្តន៍រីកចម្រើនទៅមុខ ដែលបង្កឲ្យមានវិវាទបោះឆ្នោតកាន់តែមានភាពស្មុគស្មាញឡើង និង តានតឹង ដែលអាចឈានទៅដល់ការប្រទូសរាយក្នុងសង្គមដ៏ធ្ងន់ធ្ងរពេលខាងមុខ។ បន្ទប់ស្ថានការណ៍នៃអង្គការ សមាគមមិនមែនរដ្ឋាភិបាល សូមផ្តល់នូវសំណើរជាក់លាក់ថា បើទោះ មិនទាន់មានការជួបកំពូលនៃអ្នកដឹកនាំ ក្នុងខណៈនេះគណបក្សនយោបាយទាំងពីរគួរបញ្ជូនប្រតិភូជាន់ខ្ពស់ដើម្បីជជែកគ្នាអំពីការបង្កើតគណកម្មការស៊ើបអង្កេតចម្រុះជាបន្ទាន់នេះ ដើម្បីអង្កេតទៅលើ

---

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

ភាពមិនប្រក្រតីដែលអាចធ្វើឲ្យប៉ះពាល់ដល់លទ្ធផលបោះឆ្នោត និងបន្ថែមផែនការណ៍ កំណែទម្រង់សំខាន់ៗទៅអនាគត។

ដូច្នេះបន្ទប់ស្ថានការណ៍នៃអង្គការ សមាគមមិនមែនរដ្ឋាភិបាល ដែលមានការគោរពទៅលើគោលការណ៍តម្លាភាព យុត្តិធម៌ និងអហិង្សា សូមស្នើឲ្យមានគណកម្មការស៊ើបអង្កេតចម្រុះដែលមានសមាសភាពចូលរួមពី៖

- តំណាងគណបក្សប្រជាជនកម្ពុជា
- តំណាងគណបក្សសង្គ្រោះជាតិ
- អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិជាអ្នកសង្កេតការណ៍ និងក៏អាចផ្តល់បច្ចេកទេស
- អង្គការសង្គមស៊ីវិល ជាអ្នកស៊ើបអង្កេត(ផ្តល់របាយការណ៍ពីលទ្ធផលស្រាវជ្រាវ និងអនុសាសន៍)
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាអ្នកសម្របសម្រួលការប្រជុំ និងអ្នកគាំទ្រផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធចាំបាច់ក្នុងការអង្កេតស្រាវជ្រាវ

*កំណត់សំគាល់៖ គណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជាជាប្រធានផ្លាស់វេននៃគណកម្មការនេះ ដែលជាអ្នកសម្រេចទំហំនៃការអង្កេតស្រាវជ្រាវ ហើយជាអ្នកសម្រេចយកអនុសាសន៍ពីការអង្កេតស្រាវជ្រាវទៅឲ្យគ.ជ.ប អនុវត្តន៍។*

អានុសាសន៍បន្ទាន់គួរមានការអង្កេតស្រាវជ្រាវ ពិសេសលើភាពមិនប្រក្រតីដែលអាចនាំមកការបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យខ្លះនៅមណ្ឌលខេត្តកណ្តាល និងសៀមរាប។ ដោយឡែកគណបក្សនយោបាយទាំងពីរអាចពិភាក្សាការអង្កេតស្រាវជ្រាវបន្ថែមទៅលើខេត្តមួយចំនួនទៀតដូចជា កំពង់ចាម បាត់ដំបង ភ្នំពេញ សៀមរាប កណ្តាល ក្រចេះ និងព្រៃវែង ដែលយកចិត្តទុកដាក់ការផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោតចាប់សំណាកដោយចៃដន្យលទ្ធផលបោះឆ្នោត និងភាពមិនប្រក្រតី(ទម្រង់១១០២ និង១១០៨) នៅក្នុងកញ្ចប់សុវត្ថិភាព"ក" ជាមួយលទ្ធផលបោះឆ្នោតទម្រង់១១០៤។

បន្ទប់ស្ថានការណ៍យល់ឃើញថា របៀបដោះស្រាយនេះគឺជាមធ្យោបាយដ៏ប្រសើរជាងគេបំផុតដែលអាចបញ្ចៀសការជាប់គាំងនយោបាយ និងទប់ស្កាត់ការប្រេទូស្តរាយគ្នាក្នុងសង្គមនាពេលអនាគតខាងមុខ។

បន្ទប់ស្ថានការណ៍សូមអំពាវនាវដល់មេដឹកនាំគណបក្សនយោបាយមេត្តាអត់ធ្មត់ បន្ថយវោហាសព្ទនយោបាយដែលងាយបង្កឲ្យមានអំពើហិង្សា និងកាត់បន្ថយការបង្ហាញនូវចលនាចល័តទ័ព និងអាវុធដែលធ្វើឲ្យប្រជាពលរដ្ឋមានការភ័យខ្លាច។ យើងក៏សូមអំពាវនាវផងដែរ សូមឲ្យមេដឹកនាំគណបក្សនយោបាយប្រកាន់យកនូវមធ្យោបាយចរចារគ្នាដោះស្រាយបញ្ហាដោយសន្តិវិធីឲ្យបានជាអតិប្បរមាដែលអាចធ្វើទៅបាន ហើយនិងតំកល់ទុកប្រយោជន៍ជាតិឲ្យខ្ពស់ជាងប្រយោជន៍របស់គណបក្សខ្លួន។

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

**ព័ត៌មានបន្ថែមសូមទាក់ទង៖**

| | | |
|---|---|---|
| ១. លោក ធន សារាយ | ប្រធាននៃសមាគមអាដហុក | ០១៦ ៨៤ ០០ ៨៤ |
| ២. លោកស្រី ធីតា ឃឹះ | នាយិកាអង្គការសីលការ | ០១២ ៨៣ ៨៤ ៦៤ |
| ៣. លោកស្រី រស់ សុភាព | នាយិកាអង្គការGADC | ០១២ ៦២ ៧៨ ៥៧ |
| ៤. លោក សុក សំអឿន | ប្រធានសម្របសម្រួលនៃCHRAC | ០១២ ៩០ ១១ ៩៩ |
| ៥. លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិច | ០១២ ៩៥ ៩៦ ៦៦ |
| ៦. លោកស្រី ណាលី ពីឡូច | នាយិកាអង្គការលីកាដូ | ០១២ ៨០ ៣៦ ៥០ |
| ៧. លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | ០១២ ៨០ ១២ ៣៥ |
| ៨. លោក ឈិត សំអាត | នាយកប្រតិបត្តិ NGO Forum | ០១២ ៨២ ៨៥ ៨៥ |
| ៩. លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិ CCIM | ០៦០ ៤០ ៩៩ ៩៩ |
| ១០. លោក អ៊ូ វីរៈ | ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | ០១២ ៤០ ៤០ ៥១ |
| ១១. លោក យ៉ង់ គិមអេង | អនុប្រធាន CISA | ០១៦ ៨២ ៨២ ១១ |
| ១២. លោក ព្រាប កុល | នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា | ០១២ ៨៧ ៧៨ ៣៣ |
| ១៣. លោក ម៉ាក់ ចំរើន | ប្រធានសមាគមយុវជនខ្មែរ | ០១៧ ៧៨ ៨៩ ៥៥ |
| ១៤. លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| ១៥. លោក សុខ ពិទូរ្យ | នាយកប្រតិបត្តិក្រុមប្រឹក្សាយុវជនកម្ពុជា | ០១៧ ២៧ ៣៣ ០៣ |
| ១៦. លោក សឿង សារឿន | នាយកប្រតិបត្តិអង្គការCCC | ០១៦ ៩០ ០៥ ០៣ |
| ១៧. លោក សួន ប៊ុនស័ក្តិ | អគ្គលេខាធិការCHRAC | ០១២ ៣៤ ៤៣ ៥៧ |
| ១៨. លោក គាន ពន្លក | នាយកប្រតិបត្តិរងនៃDHRAC | ០១២ ៥៥ ១៤ ៦៦ |
| ១៩. លោក សាម អ៊ីន | នាយកប្រតិបត្តិនៃLWD | ០១២ ៥៥ ១៨ ៨៦ |
| ២០. លោក ហឹម យន់ | អ្នកសម្របសម្រួលអង្គការCISA | ០១២ ៩៤ ៧០ ២២ |
| ២១. លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការខុមហ្វ្រែល | ០១២ ៩៤ ២០ ១៧ |

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

## សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## ការវាយតម្លៃអំពីដំណើរការទាំងមូលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣
## «ត្រូវការសុចរិតភាព និងយុត្តិធម៌ក្នុងការបោះឆ្នោត»

*ភ្នំពេញ, ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣*

បន្ទប់ស្ថានការណ៍នៃសម្ព័ន្ធអង្គការសង្គមស៊ីវិលសូមវាយតម្លៃអំពីដំណើរការ និងការចាត់ចែងការបោះឆ្នោតទាំងមូល (ក្នុងកំឡុងពេល និងក្រោយពេលបោះឆ្នោត) នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ថា «មិនទាន់សេរី និងយុត្តិធម៌ទេ» បើទោះបីជាមានការថយចុះករណីហិង្សាធ្ងន់ធ្ងរ និងគ្មានការសម្លាប់សកម្មជន អ្នកនយោបាយ និងការចូលរួមយ៉ាងសកម្មរបស់យុវជនក្នុងយុទ្ធនាការបោះឆ្នោតក៏ដោយ។

យុត្តិធម៌ និងសុចរិតភាពក្នុងការបោះឆ្នោតលើកនេះ បានធ្លាក់ចុះ បើធៀបជាមួយការបោះឆ្នោតមុនៗ ចាត់ចែងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ដែលស្ថិតនៅក្រោមស្តង់ដាអន្តរជាតិ ការបោះឆ្នោតសេរី និងយុត្តិធម៌រួចទៅហើយ។ មានបញ្ហាសំខាន់ៗមិនត្រូវបានកែលម្អដែលប៉ះពាល់ដល់ដំណើរការ និងការចាត់ចែងរួមមាន ៖

ក) គ្មានភាពស្មើគ្នាក្នុងការផ្សព្វផ្សាយ និងការប្រើប្រាស់ ប្រព័ន្ធផ្សព្វផ្សាយរួមមាន ទូរទស្សន៍ និងវិទ្យុ ជាច្រើនលើសលុបបានផ្សាយលំអៀង យ៉ាងខ្លាំងទៅរកគណបក្សកាន់អំណាច ហើយផ្សព្វផ្សាយប្រឆាំងទៅនឹងគណបក្សដទៃទៀត។

ខ) បរិយាកាសខ្វះអព្យាក្រឹត្យ និងការជ្រៀតជ្រែករបស់រដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ កងនគរបាល និងមន្ត្រីតុលាការ ដែលបានធ្វើសកម្មភាព ឃោសនាបោះឆ្នោត និងគាំទ្រគណបក្សកាន់អំណាច ព្រមទាំងរារាំងប្រឆាំងនឹងគណបក្សនយោបាយផ្សេងទៀត។

គ) បញ្ហាបញ្ជីឈ្មោះអ្នកបោះឆ្នោត ឈ្មោះស្ទួនប្រមាណជាង សាមសិបម៉ឺនឈ្មោះ ជាពិសេសការចេញលិខិតបញ្ជាក់អត្តសញ្ញាណសំរាប់បំរើឲ្យការបោះឆ្នោតនេះមានរហូតដល់ជាងមួយលានលិខិត ក្នុងនោះមានភាព

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

មិនប្រក្រតីជាច្រើន រួមទាំង ការលុបលាងបានភ្លាមៗនូវទឹកខ្មៅលើម្រាមដៃ ដែលនាំឲ្យមិនអាចធានាមនុស្សម្នាក់បោះឆ្នោតបានតែម្តង។

ឃ) បញ្ហាបញ្ជីឈ្មោះបោះឆ្នោត អ្នកបោះឆ្នោតបាត់ឈ្មោះ (ដូរ ខុសឈ្មោះ ឬលុបឈ្មោះ ឬ...) អ្នកបោះឆ្នោតជាច្រើនបានបាត់បង់សិទ្ធិបោះឆ្នោត បើទោះបីពួកគេមានឆន្ទៈ និងបានចេញទៅដល់ការិយាល័យបោះឆ្នោត ប៉ុន្តែមិនបានបោះឆ្នោតមាន ៤៨%[1] នៃអ្នកមិនបានបោះឆ្នោត (អ្នកមិនមានទឹកខ្មៅលើម្រាមដៃ) និងភាពមិនប្រក្រតីប្រមាណជាង មួយម៉ឺនករណី នៅថ្ងៃបោះឆ្នោត រួមទាំងការដឹកជញ្ជូនអ្នកបោះឆ្នោត[2]ពីខេត្តមួយឲ្យបោះទៅខេត្តមួយផ្សេងទៀត។

ង) ការបាត់សិទ្ធិឈរឈ្មោះរបស់មេដឹកនាំគណបក្សប្រឆាំងលោក សម រង្ស៊ី ជាបេក្ខជនឲ្យគេបោះឆ្នោតបាន។

ច) ការលម្អៀង និងមិនឯករាជ្យរបស់ស្ថាប័នរៀបចំការបោះឆ្នោត និងការដោះស្រាយវិវាទបោះឆ្នោត (គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ) ដោយ ការខ្វះតម្លាភាព និង ការ ខ្វះយុត្តិធម៌ ក្នុងការបំពេញភារកិច្ច និងតួនាទីរបស់ខ្លួន។ ស្ថាប័នទាំងនេះ ជានិច្ចជាកាលព្រងើយកន្តើយ ការអនុវត្តអនុសាសន៍ក្នុងការកែលម្អការបោះឆ្នោត ឬបដិសេធចោលស្ទើតែទាំងស្រុងទៅនឹងបណ្តឹងតវ៉ា និង ជំទាស់ របស់គណបក្សនយោបាយផ្សេងដែលមិនមែនជាគណបក្សកាន់អំណាច ដែលក្នុងនោះមាន យ៉ាងតិចចំនួនប្រហែល៧០០បណ្តឹងក្នុងកំឡុងពេលបោះឆ្នោត។

ឆ) ការកើនឡើងនៃការប្រើប្រាស់ធនធានរដ្ឋមិនបានត្រឹមត្រូវ និងការយកទីធ្លាសាធារណៈយ៉ាងច្រើនសន្ធឹកសន្ធាប់មកប្រើប្រាស់ពីសំណាក់គណបក្សកាន់អំណាច ។

ជ) ការកើនឡើងនៃការទិញសន្លឹកឆ្នោតដោយគណបក្សកាន់អំណាច ជាពិសេសកំឡុងពេលមុនឃោសនាបោះឆ្នោត មានគម្លាតគ្នាយ៉ាងខ្លាំងក្នុងការចំណាយថវិកាឃោសនាបោះឆ្នោតរវាងគណបក្សកាន់អំណាច និងគណបក្សប្រកួតប្រជែងផ្សេងៗ។

មានបរិយាកាស ការបំភិតបំភ័យ ការគំរាមកំហែង ដល់ម្ចាស់ឆ្នោត និងសកម្មជនគណបក្សនយោបាយប្រកួតប្រជែង ចាប់ពីកំឡុងពេលបោះឆ្នោតរហូតដល់ក្រោយពេលបោះឆ្នោត។ តាំងពីមន្ត្រីរដ្ឋាភិបាល អាជ្ញាធររហូតដល់ប្រព័ន្ធផ្សព្វផ្សាយ គាំទ្រគណបក្សកាន់អំណាចបានលើកឡើងជាញឹកញាប់លើការព្រមានអំពីលទ្ធភាពសង្គ្រាម ឬយោធាយកអំណាចវិញបើមានការផ្លាស់ប្តូររដ្ឋាភិបាល និងរហូតដល់មានសកម្មភាពជាក់ស្តែង ដូចជាការដាក់ពង្រាយកងទ័ពប្រដាប់អាវុធ យុទ្ធភ័ណ្ឌ យោធានៅក្នុងកំឡុងពេលដោះស្រាយវិវាទបោះឆ្នោត (ក្រោយពេលបោះឆ្នោត)។ បរិយាកាសបំភិតបំភ័យ គំរាមកំហែង និងដំណើរការ និងការចាត់ចែងបោះឆ្នោត ខ្វះយុត្តិធម៌ និងខ្វះសុចរិតភាពធ្ងន់ធ្ងរដែលប៉ះពាល់ដល់លទ្ធផលបោះឆ្នោតនាំឲ្យគណបក្សកាន់អំណាចមានប្រៀប ព្រមទាំង

[1] ការសិក្សាស្រាវជ្រាវរបស់ខុមហ្វ្រែលក្រោយពេលបោះឆ្នោត

[2] ករណីសិក្សារបស់លីកាដូ អាដហុក និចហ្វិច និងVOD/CCIM

មិនឆ្លុះបញ្ចាំង ឆន្ទៈ ដោយសេរីរបស់អ្នកបោះឆ្នោតពេញលេញ និងមានការថយចុះចំនួនបេក្ខជនជាស្ត្រីជាប់ឆ្នោត។

ច្បាប់ នីតិវិធី គោលនយោបាយ និងយន្តការទាក់ទិននឹងការបោះឆ្នោត គួរត្រូវបង្កើតឡើង ផ្លាស់ប្តូរ ឬ/និងកែលម្អបន្ថែមទៀត ខណៈដែលការអនុវត្តកំណែទម្រង់បោះឆ្នោតសំខាន់ៗត្រូវតែធ្វើឡើងដោយខានពុំបានសម្រាប់ការចាត់ចែងការបោះឆ្នោតនៅពេលខាងមុខ រួមមាន ៖

១. កំណែទម្រង់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) គ្រប់លំដាប់ថ្នាក់ និងក្រុមប្រឹក្សាធម្មនុញ្ញ (រួមទាំង សមាសភាព រចនាសម្ព័ន្ធ និងតួនាទីភារកិច្ច) ដោយមានការស្រុះស្រួលគ្នានៃគណបក្សក្នុងសភា។

២. កែលម្អប្រព័ន្ធផ្សព្វផ្សាយពិសេសទូរទស្សន៍ និងវិទ្យុ ដោយមានគោលនយោបាយ និងគោលការណ៍សមធម៌ តុល្យភាព និងសេរីសម្រាប់ការទទួលបានការប្រើប្រាស់ និងការផ្សព្វផ្សាយ។

៣. កំណែទម្រង់យន្តការដោះស្រាយទំនាស់វិវាទ និងបណ្តឹងបោះឆ្នោតឲ្យឯករាជ្យ រួមមាន ការបង្កើតយន្តការប្រសិទ្ធិភាពមួយសម្រាប់ការអង្កេតពីភាពមិនប្រក្រតី។

៤. មាន ច្បាប់ ដើម្បីតម្លាភាពហិរញ្ញវត្ថុ និងកំណត់ការចំណាយរបស់គណបក្សនយោបាយក្នុងដំណើរការឃោសនាបោះឆ្នោត។

៥. ផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះ និងការបង្កើតបញ្ជីឈ្មោះបោះឆ្នោតថ្មី ដែលអាចកំណត់បានអត្តសញ្ញាណអ្នកបោះឆ្នោតច្បាស់លាស់ និងមានប័ណ្ណបោះឆ្នោត។

៦. ពង្រឹងការអនុវត្តច្បាប់ឲ្យបានពេញលេញអំពីភាពអព្យាក្រិត្យ មិនលម្អៀងដាច់ខាតសម្រាប់ទាំងស្ថាប័ន និងមន្ត្រីនៃកងយុទ្ធពលខេមរភូមិន្ទ នគរបាល និង មន្ត្រីតុលាការក្នុងការធ្វើសកម្មភាពគាំទ្រ និងប្រឆាំងគណបក្សណាមួយ។

៧. មានច្បាប់ ឬ/និងគោលនយោបាយដើម្បីកំណត់កូតាស្ត្រីជាតំណាងជាប់ឆ្នោត

**<u>ព័ត៌មានបន្ថែមសូមទាក់ទង៖</u>**

| | | |
|---|---|---|
| ១. លោក ធន សារាយ | ប្រធាននៃសមាគមអាដហុក&ខុមហ្វ្រែល | ០១៦ ៤៤ ០០ ៤៤ |
| ២. លោកស្រី ធីតា ឃឹះ | នាយិកាអង្គការសីលការ | ០១២ ៨៣ ៨៤ ៦៤ |
| ៣. លោកស្រី រស់ សុភាព | នាយិកាអង្គការGADC | ០១២ ៦២ ៧៨ ៥៧ |
| ៤. លោក សុក សំអឿន | ប្រធានសម្របសម្រួលនៃCHRAC | ០១២ ៩០ ១១ ៩៩ |
| ៥. លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិច | ០១២ ៩៥ ៩៦ ៦៦ |
| ៦. លោកស្រី ណាលី ពីឡូច | នាយិកាអង្គការលីកាដូ | ០១២ ៨០ ៣៦ ៥០ |
| ៧. លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | ០១២ ៨០ ១២ ៣៥ |

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

| | | |
|---|---|---|
| ៨. លោក ឈិត សំអាត | នាយកប្រតិបត្តិ NGO Forum | ០១២ ៨២ ៨៥ ៨៥ |
| ៩. លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិ CCIM | ០៦០ ៤០ ៩៩ ៩៩ |
| ១០. លោក អ៊ូ វីរៈ | ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | ០១២ ៤០ ៤០ ៥១ |
| ១១. លោក យង់ គិមអេង | ប្រធាន PDP-Center | ០១៦ ៨២ ៨២ ១១ |
| ១២. លោក ព្រាប កុល | នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា | ០១២ ៨៧ ៧៨ ៣៣ |
| ១៣. លោក ម៉ាក់ ចំរើន | ប្រធានសមាគមយុវជនខ្មែរ | ០១៧ ៧៨ ៨៩ ៥៥ |
| ១៤. លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| ១៥. លោក សុខ ពិទូរ្យ | នាយកប្រតិបត្តិក្រុមប្រឹក្សាយុវជនកម្ពុជា | ០១៧ ២៧ ៣៣ ០៣ |
| ១៦. លោក សឿង សារឿន | នាយកប្រតិបត្តិអង្គការCCC | ០១៦ ៩០ ០៥ ០៣ |
| ១៧. លោក សួន ប៊ុនស័ក្តិ | អគ្គលេខាធិការCHRAC | ០១២ ៣៤ ៤៣ ៥៧ |
| ១៨. លោក គាន ពន្លក | នាយកប្រតិបត្តិរងនៃDHRAC | ០១២ ៥៥ ១៤ ៦៦ |
| ១៩. លោក សាម អ៊ីន | នាយកប្រតិបត្តិនៃLWD | ០១២ ៥៥ ១៨ ៨៦ |
| ២០. លោក ហឹម យន់ | អ្នកសម្របសម្រួលអង្គការCISA | ០១២ ៩៤ ៧០ ២២ |
| ២១. លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការCOMFREL | ០១២ ៩៤ ២០ ១៧ |

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

## សេចក្តីអំពាវនាវបន្ទាន់
## ស្តីពី
## ជំនួបកំពូលឲ្យមានដំណោះស្រាយនយោបាយទាក់ទងនឹងវិវាទបោះឆ្នោត

*ភ្នំពេញ, ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៣*

ដោយសង្កេតឃើញថា ក្របខណ្ឌច្បាប់ដែលបានអនុវត្តកន្លងមករបស់ស្ថាប័នរៀបចំការបោះឆ្នោត (គ.ជ.ប) និងស្ថាប័នដោះស្រាយវិវាទបោះឆ្នោត(ក្រុមប្រឹក្សាធម្មនុញ្ញ) បរាជ័យក្នុងការស្វែងរកយុត្តិធម៌ជូនម្ចាស់ឆ្នោតឲ្យបានត្រឹមត្រូវ និងស្ងប់ចិត្ត។ បន្ទប់ស្ថានការណ៍យល់ឃើញថា មានតែការដោះស្រាយតាមផ្លូវនយោបាយទេ ដែលអាចឈានទៅរកការដោះស្រាយភាពមិនប្រក្រតី និងជំលោះនៃការបោះឆ្នោតនេះបាន។

អាស្រ័យហេតុនេះ យើងស្នើសុំដោយទទូចឲ្យមេដឹកនាំកំពូលនៃគណបក្សនយោបាយទាំងពីរជួបគ្នាជាបន្ទាន់ដើម្បីដោះស្រាយបញ្ហាជំលោះខាងលើនេះ។

ដោយសង្កេតឃើញថា គណបក្សសង្គ្រោះជាតិបានលើកសំណើជាផ្លូវការឲ្យមានជំនួបកំពូលជាច្រើនដងមកហើយនោះ ដូច្នេះគណបក្សប្រជាជនកម្ពុជាគួរតែផ្តល់ចម្លើយជាវិជ្ជមាននៅពេលឆាប់ៗខាងមុខនេះ។

បន្ទប់ស្ថានការណ៍មានកង្វល់ និងព្រួយបារម្ភជាខ្លាំងថាការខកខាន និងភាពបរាជ័យដែលមិនបានដោះស្រាយបញ្ហាវិវាទតាមផ្លូវនយោបាយពីជំនួបកំពូលនេះនឹងអាចបង្កឲ្យមានភាពប្រទុស្តរាយក្នុងសង្គម វិបត្តិនយោបាយ និងសេដ្ឋកិច្ចសង្គមធ្ងន់ធ្ងរ ដែលធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅសុខសាន្តរបស់ប្រជាពលរដ្ឋ ការអភិវឌ្ឍន៍សង្គម កេរ្តិ៍ឈ្មោះ និងសេចក្តីថ្លៃថ្នូរបស់ប្រទេសជាតិ។

ជំនួបមេដឹកនាំនយោបាយកំពូល ព្រមទាំងការដោះស្រាយបញ្ហាខាងលើដោយសន្តិវិធី និងជោគជ័យក្នុងការឆ្លើយតបទៅនឹងការទទួចចង់បានរបស់ប្រជាពលរដ្ឋ គឺជាគំរូល្អ និងត្រូវចារទុកជាប្រវត្តិសាស្ត្រសម្រាប់កូនខ្មែរជំនាន់ក្រោយ។

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

**ព័ត៌មានបន្ថែមសូមទាក់ទង៖**

| | | |
|---|---|---|
| ១. លោក ធន សារាយ | ប្រធាននៃសមាគមអាដហុក&ខុមហ្វ្រែល | ០១៦ ៨៤ ០០ ៨៤ |
| ២. លោកស្រី ធីតា ឃឹះ | នាយិកាអង្គការសីលការ | ០១២ ៨៣ ៨៤ ៦៤ |
| ៣. លោកស្រី រស់ សុភាព | នាយិកាអង្គការGADC | ០១២ ៦២ ៧៨ ៥៧ |
| ៤. លោក សុក សំអឿន | ប្រធានសម្របសម្រួលនៃCHRAC | ០១២ ៩០ ១១ ៩៩ |
| ៥. លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិច | ០១២ ៩៥ ៩៦ ៦៦ |
| ៦. លោកស្រី ណាលី ពីឡូច | នាយិកាអង្គការលីកាដូ | ០១២ ៨០ ៣៦ ៥០ |
| ៧. លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | ០១២ ៨០ ១២ ៣៥ |
| ៨. លោក ឈិត សំអាត | នាយកប្រតិបត្តិ NGO Forum | ០១២ ៩២ ៨៥ ៨៥ |
| ៩. លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិ CCIM | ០៦០ ៤០ ៩៩ ៩៩ |
| ១០. លោក អ៊ូ វីរៈ | ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | ០១២ ៤០ ៤០ ៥១ |
| ១១. លោក យង់ គិមអេង | ប្រធាន PDP-Center | ០១៦ ៨២ ៨២ ១១ |
| ១២. លោក ព្រាប កុល | នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា | ០១២ ៨៧ ៧៨ ៣៣ |
| ១៣. លោក ម៉ាក់ ចំរើន | ប្រធានសមាគមយុវជនខ្មែរ | ០១៧ ៧៨ ៨៩ ៥៥ |
| ១៤. លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| ១៥. លោក សុខ ពិទូរ្យ | នាយកប្រតិបត្តិក្រុមប្រឹក្សាយុវជនកម្ពុជា | ០១៧ ២៧ ៣៣ ០៣ |
| ១៦. លោក សឿង សារឿន | នាយកប្រតិបត្តិអង្គការCCC | ០១៦ ៩០ ០៥ ០៣ |
| ១៧. លោក សួន ប៊ុនស័ក្តិ | អគ្គលេខាធិការCHRAC | ០១២ ៣៤ ៤៣ ៥៧ |
| ១៨. លោក គាន ពន្លក | នាយកប្រតិបត្តិរងនៃDHRAC | ០១២ ៥៥ ១៤ ៦៦ |
| ១៩. លោក សាម អ៊ីន | នាយកប្រតិបត្តិនៃLWD | ០១២ ៥៥ ១៨ ៨៦ |
| ២០. លោក ហឹម យន់ | អ្នកសម្របសម្រួលអង្គការCISA | ០១២ ៩៤ ៧០ ២២ |
| ២១. លោក ណែប ស៊ិនថៃ | នាយកAPI | ០១២ ៥២ ៧០ ០៤ |
| ២២. លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការCOMFREL | ០១២ ៩៤ ២០ ១៧ |

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

## សេចក្តីប្រកាសព័ត៌មាន
## ស្តីអំពី
## តួនាទីរបស់អង្គការសមាគមមិនមែនរដ្ឋាភិបាល
## ក្នុងការរួមចំណែកអភិវឌ្ឍន៍សង្គមកម្ពុជា

*ភ្នំពេញ, ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៣*

អង្គការសង្គមស៊ីវិល សមាគមមិនមែនរដ្ឋាភិបាល ដែលបាន នឹងកំពុងចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សង្គមកម្ពុជាលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច កសិកម្ម សុខាភិបាល អភិវឌ្ឍន៍ធនធានមនុស្ស លទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត ច្បាប់ ការលើកស្ទួយសិទ្ធិមនុស្ស ជាពិសេសជួយអ្នកក្រីក្រ និងអ្នកទន់ខ្សោយ...។ល។

សមាជិកបន្ទប់ស្ថានការណ៍នៃអង្គការសមាគមមិនមែនរដ្ឋាភិបាល ដែលយកចិត្តទុកដាក់លើបញ្ហាសិទ្ធិមនុស្ស ការបោះឆ្នោត កសាងសន្តិភាព និងប្រជាធិបតេយ្យនៅកម្ពុជា បានរួមគ្នារៀបចំក្រុមការងារទាំងថ្នាក់រាជធានី និងខេត្ត ដើម្បីចូលរួមសង្កេតឃ្លាំមើល ជួយអន្តរាគមន៍ចំពោះបញ្ហារំលោភសិទ្ធិមនុស្ស និងសង្គ្រោះបឋមដល់ដល់ប្រជាពលរដ្ឋទូទៅដែលទទួលរងគ្រោះ ក្នុងកំឡុងពេលបាតុកម្មណាមួយដែលអាចនឹងកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទាំងនេះគឺជាបេសសកកម្មស្នូលរបស់អង្គការសង្គមស៊ីវិលក្នុងការពង្រឹងនូវលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមូលដ្ឋានរបស់ប្រជាពលរដ្ឋ។

- ដោយឡែក ដោយដឹងថាមានបាតុកម្មអហិង្សាលើកទី២ របស់គណបក្សសង្គ្រោះជាតិ ដែលគ្រោងនឹងធ្វើឡើងនៅថ្ងៃទី ១៥ ដល់ ១៧ ខែកញ្ញា ឆ្នាំ២០១៣ ខាងមុខនេះ អង្គការ សមាគមមិនមែនរដ្ឋាភិបាល បានត្រៀម និងពង្រាយក្រុមសង្គ្រោះបឋមប្រមាណ៨០០នាក់ និងក្រុមសង្កេតឃ្លាំមើលប្រមាណ ៨០០នាក់ ដើម្បីប្រតិបត្តិការងារមនុស្សធម៌ និងសង្កេតការណ៍។ ក្នុងនោះផងដែរក៏មានក្រុមសម្របសម្រួលដើម្បីផ្តល់នូវព័ត៌មានទៅលើការវាយតម្លៃដំណើរវិវត្តន៍នៃមហាបាតុកម្មនេះនៅលើគេហទំព័រសម្លេងម្ចាស់ឆ្នោតកម្ពុជា (CVV: www.cambodianvotervoice.org)។

សកម្មភាពមនុស្សធម៌ និងសង្កេតការណ៍បែបនេះ មិនមែនគ្រាន់តែជាលើកទីមួយទេ ក្រុមការងាររបស់អង្គការសង្គមស៊ីវិល ធ្លាប់បានអនុវត្តជាច្រើនលើកច្រើនសារមកហើយ ជាពិសេសក្រុមអង្គការសង្គមស៊ីវិលក៏បានផ្តល់សេវាសង្គ្រោះបឋម ដែលមានអ្នកស្ម័គ្រចិត្តទទួលការបណ្តុះបណ្តាល ។

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

***សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង***


| | | |
|---|---|---|
| លោក សឿង សារឿន | នាយកប្រតិបត្តិអង្គការCCC | ០១៦ ៩០ ០៥ ០៣ |
| លោក ឈិត សំអាត | នាយកប្រតិបត្តិ NGO Forum | ០១២ ៩២ ៨៥ ៨៥ |
| លោក នី ចរិយា | ប្រធានផ្នែកអង្កេតADHOC | ០១១ ២៧ ៤៩ ៥៩ |


COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣

# Situation Room on Cambodia Election Day 2013

## សេចក្ដីអំពាវនាវ

ភ្នំពេញ, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលនៅកម្ពុជា សូមកោតសរសើរចំពោះដំណើរការបាតុកម្មរយៈពេលមួយថ្ងៃនេះ (១៥ ខែកញ្ញា ឆ្នាំ២០១៣) ទាំងបាតុករ និងអាជ្ញាធរមានការអត់ធ្មត់ អហឹង្សា រក្សាបាននូវសណ្ដាប់ធ្នាប់របៀបរៀបរយ ក្នុងការលើកកម្ពស់ការអនុវត្តសិទ្ធិរបស់ប្រជាពលរដ្ឋ។

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលនៅកម្ពុជា សូមអំពាវនាវ៖

- អាជ្ញាធរមានសមត្ថកិច្ច ត្រូវបន្តការអត់ធ្មត់ និងការពារសន្តិសុខជូនបាតុករឲ្យបានកាន់តែប្រសើរថែមទៀត ទាំងពេលថ្ងៃ និងពេលយប់។
- បាតុករ សូមមេត្តារក្សានៅភាពអត់ធ្មត់ និងអហឹង្សាជាបន្តទៀត។

បន្ទប់ស្ថានការណ៍នឹងបន្តការតាមដានយ៉ាងយកចិត្តទុកដាក់បំផុត នូវដំណើរការនៃបាតុកម្មនេះ។

**<u>ព័ត៌មានបន្ថែមសូមទាក់ទង៖</u>**

| | | |
|---|---|---|
| ១.លោក គល់ បញ្ញា | នាយកប្រតិបត្តិ comfrel | 012 942 017 |
| ២.លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | 066 777 000 |
| ៣.លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិ CCIM | 060 409 999 |
| ៤.លោក ម៉ាក ចំរើន | ប្រធានKYA | 017 789 955 |
| ៥.លោក យ៉ង់ គិមអេង | នាយកប្រតិបត្តិ PDPCenter | 016 828 211 |

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

## សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## ជំនួបកំពូលរបស់ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិ

ភ្នំពេញ, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលនៅកម្ពុជា សាទរចំពោះលទ្ធផលនៃជំនួបកំពូលរបស់ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិក្នុងការគោរពតាមព្រះរាជសាររបស់ព្រះមហាក្សត្រអំពាវនាវឲ្យបញ្ឈប់កុំឲ្យមានការប្រើអំពើហិង្សា ការព្រមព្រៀងរបស់គណបក្សទាំងពីរស្តីពីការបង្កើតយន្តការមួយដើម្បីកែទម្រង់ប្រព័ន្ធបោះឆ្នោត និងព្រមទាំងបន្តជួបពិភាក្សាដើម្បីស្វែងរកដំណោះស្រាយបញ្ហាជាតិធំៗនៅក្រោយការបោះឆ្នោត។

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលនៅកម្ពុជា ទទូចឲ្យគណបក្សទាំងពីរបន្តការពិភាក្សាឲ្យមានការកែទម្រង់ស៊ីជំរៅ គ្រប់ជ្រុងជ្រោយទៅលើចំណុចមួយចំនួនដូចជា កំណែទម្រង់ប្រព័ន្ធបោះឆ្នោត កំណែទម្រង់ស្ថាប័នជាតិសំខាន់ៗ ពង្រឹងប្រព័ន្ធត្រួតពិនិត្យអំណាច និងការបង្កើតយន្តការត្រួតពិនិត្យការអនុវត្តន៍កំណែទម្រង់។ គណបក្សទាំងពីរអាចត្រូវការពេលវេលាសម្រាប់ការពិភាក្សាលើកម្មវិធីកំណែទម្រង់ខាងលើ ដូច្នេះការប្រជុំរដ្ឋសភាដំបូងគួរត្រូវបានធ្វើឡើងបន្ទាប់ពីគណបក្សទាំងពីរឈានទៅដល់ការព្រមព្រៀងគ្នា និងឯកភាពជាតិ។


**<u>ព័ត៌មានបន្ថែមសូមទាក់ទង៖</u>**

| | | |
|---|---|---|
| ១.លោក ធន សារាយ | ប្រធាននៃសមាគមអាដហុក ADHOC | ០១៦ ៨៤ ០០ ៨៤ |
| ២.លោកស្រី រស់ សុភាព | នាយិកាអង្គការ GADC | ០១២ ៦២ ៧៨ ៥៧ |
| ៣.លោក សុក សំអឿន | ប្រធានសម្របសម្រួលនៃ CHRAC | ០១២ ៩០ ១១ ៩៩ |
| ៤.លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិច | ០១២ ៩៥ ៩៦ ៦៦ |
| ៥.លោក ឈិត សំអាត | នាយកប្រតិបត្តិ NGO Forum | ០១២ ៩២ ៨៥ ៨៥ |
| ៦.លោក សៀង សារឿន | នាយកប្រតិបត្តិអង្គការ CCC | ០១៦ ៩០ ០៥ ០៣ |


COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

| | | |
|---|---|---|
| ៧.លោក សួន ប៊ុនស័ក្តិ | អគ្គលេខាធិការនៃ CHRAC | ០៩២ ៣៤ ៤៣ ៥៧ |
| ៨.លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | ០១២ ៨០ ១២ ៣៥ |
| ៩.លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិ CCIM | ០៦០ ៤០ ៩៩ ៩៩ |
| ១០.លោក អ៊ូ វីរៈ | ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | ០១២ ៤០ ៤០ ៥១ |
| ១១.លោក យ៉ង់ គិមអេង | នាយកប្រតិបត្តិ PDP-Center | ០១៦ ៨២ ៨២ ១១ |
| ១២.លោក ព្រាប កុល | នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា | ០១២ ៨៧៧ ៨៣៣ |
| ១៣.លោកស្រី ធីតា យ៉ឹះ | នាយិកាអង្គការសីលការ | ០១២ ៨៣ ៨៤ ៦៤ |
| ១៤.លោក ម៉ាក់ ចំរើន | ប្រធានសមាគមយុវជនខ្មែរ | ០១៧ ៧៨ ៨៩ ៥៥ |
| ១៥.លោក ម៉ម សម្បត្តិ | នាយកប្រតិបត្តិ DPA | ០១២ ៧៧ ៩៧ ៣៤ |
| ១៦.លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| ១៧.លោក សាម អ៊ីន | នាយកប្រតិបត្តិ LWD | ០១២ ៥៥ ១៨ ៨៦ |
| ១៨.លោក ណែប ស៊ិនថៃ | នាយក API | ០១២ ៥២ ៧០ ០៤ |
| ១៩.លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការខុមហ្វ្រែល | ០១២ ៩៤ ២០ ១៧ |

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM ON CAMBODIA, API, CCC, CDP, CLEC, CPWP, PDP-CENTER, DHRAC, GADC, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.

# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

បច្ចុប្បន្នភាព

## អនុសាសន៍សំរាប់កញ្ចប់ ដំណោះស្រាយនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ

*ភ្នំពេញ, ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣*

បន្ទប់ស្ថានការណ៍ផ្តល់ជូនអនុសាសន៍សម្រាប់កញ្ចប់ដំណោះស្រាយនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិដូចខាងក្រោម។ អនុសាសន៍នោះរួមមាន កិច្ចសន្យានយោបាយ (ការស្វែងរកការពិតនៃភាពមិនប្រក្រតីបោះឆ្នោត កំណែទម្រង់បោះឆ្នោត និងកំណែទម្រង់ស្ថាប័ន) ការពង្រឹងអំណាចតួនាទីពិនិត្យគ្នាទៅវិញទៅមក និងយន្តការដឹកនាំ និងត្រួតពិនិត្យអំពីការអនុវត្តន៍កិច្ចសន្យានយោបាយអំពីកំណែទម្រង់។ បន្ទប់ស្ថានការណ៍ សង្ឃឹមថា ការដោះស្រាយនយោបាយ និងការអនុវត្តន៍អនុសាសន៍ទាំងនេះជោគជ័យនឹងនាំមកការជឿទុកចិត្តខាងនយោបាយ ស្ថេរភាពនយោបាយដែលមេដឹកនាំនយោបាយ និងគណបក្សនយោបាយទាំងនេះនឹងក្លាយជាគំរូល្អ និងត្រូវចារទុកជាប្រវត្តិសាស្ត្រសម្រាប់កូនខ្មែរជំនាន់ក្រោយ។

### I. កិច្ចសន្យានយោបាយ

#### ក. ការស្វែងរកឃើញការពិតនៃភាពមិនប្រក្រតីបោះឆ្នោត

១. បង្កើតគណៈកម្មការស្វែងរកការពិតដែលមានសមាសភាពចូលរួមពី៖ តំណាងគណបក្សប្រជាជនកម្ពុជា, តំណាងគណបក្សសង្គ្រោះជាតិ, អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិជាអ្នកសង្កេតការណ៍ និងក៏អាចផ្តល់បច្ចេកទេស, អង្គការសង្គមស៊ីវិល ជាអ្នកស៊ើបអង្កេត(ផ្តល់របាយការណ៍ពីលទ្ធផលស្រាវជ្រាវ និងអនុសាសន៍) និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)ជាអ្នកគាំទ្រផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធចាំបាច់ក្នុងការអង្កេតស្រាវជ្រាវ។

*កំណត់សំគាល់៖ គណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជាជាប្រធានផ្លាស់វេននៃគណៈកម្មការនេះ ដែលជាអ្នកសម្រេចទំហំនៃការអង្កេតស្រាវជ្រាវ ហើយជាអ្នកសម្រេចយកអនុសាសន៍ពីការអង្កេតស្រាវជ្រាវទៅឲ្យគ.ជ.ប អនុវត្ត។ ក្នុងករណីគណបក្សណាមួយមិនគាំទ្រ ឬមិនចូលរួមការបង្កើតគណៈកម្មការនេះ យ៉ាងហោចណាស់គណបក្សនយោបាយទាំងពីរគាំទ្រការអនុវត្តន៍គោលការណ៍តម្លាភាពរបស់ គ.ជ.ប ហើយលើកទឹកចិត្តឲ្យ គ.ជ.ប ចូលរួមសហការណ៍ផ្តល់ព័ត៌មាន និង*

*ឯកសារ ដើម្បីស្វែងរកការពិត។ គណៈកម្មការនេះ និងអាច ត្រូវបង្កើត និងចាត់ចែងដោយអង្គការសង្គមស៊ីវិលជាអ្នកស៊ើបអង្កេតផ្ទាល់ដែរ។ ព្រោះថាការស្វែងរកការពិតនេះអាចធ្វើឲ្យម្ចាស់ឆ្នោតស្ងប់ចិត្ត និងមានទំនុកចិត្តលើការបោះឆ្នោត និងធ្វើឲ្យគណបក្សឈ្នះឆ្នោតទទួលបានកិត្តិយស។ លទ្ធផលបានមកពីការស្វែងរកការពិតនេះនឹងត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់កំណែទម្រង់ប្រព័ន្ធបោះឆ្នោត។*

- គណៈកម្មការនឹងធ្វើការសិក្សាស្រាវជ្រាវអង្កេត និងសវនកម្មដោយសំណាកចៃដន្យ ក្នុងនោះ គ.ជ.ប ត្រូវបើកកញ្ចប់សុវត្ថិភាព "ក" ដោយផ្តល់កំណត់ហេតុរាប់សន្លឹកឆ្នោតទំរង់១១០២, ១១០៨ និងឯកសារផ្សេងទៀត ដើម្បីធ្វើការផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោតតាមការិយាល័យនីមួយៗ។ ផ្តល់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត (បញ្ជីបោះឆ្នោតដែលបានប្រើនៅតាមការិយាល័យបោះឆ្នោត)។ អនុញ្ញាតឲ្យថតចំលងគល់បញ្ជីនៃលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោតនៅខេត្តមួយចំនួន។

**ខ.កំណែទម្រង់: កំណែទម្រង់បោះឆ្នោត**

២. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) គ្រប់លំដាប់ថ្នាក់ និងក្រុមប្រឹក្សាធម្មនុញ្ញ (រួមទាំងសមាសភាព រចនាសម្ព័ន្ធ និងតួនាទីភារកិច្ច) *ត្រូវបានកំណែទម្រង់* ដោយមានការស្រុះស្រួលគ្នានៃគណបក្សក្នុងសភា៖

- វិសោធនកម្មរដ្ឋធម្មនុញ្ញដោយបន្ថែមមាត្រាខ្លះនៅក្នុងរដ្ឋធម្មនុញ្ញ ដើម្បីចែងអំពីការបង្កើតស្ថាប័នគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ជាស្ថាប័នកើតឡើងដោយច្បាប់រដ្ឋធម្មនុញ្ញ។
- ស្ថាប័ន គ.ជ.ប ត្រូវមានថវិកាស្វ័យយ័ត។
- ធ្វើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយបង្កើតគណៈកម្មការជ្រើសរើសបេក្ខជនសម្រាប់សមាសភាព គ.ជ.ប ដោយជំនួសក្រសួងមហាផ្ទៃ និងគណៈរដ្ឋមន្ត្រី។
    - មានគណៈកម្មការជ្រើសរើសមួយ ដែលមានសមាសភាពពីក្រុមគណបក្សកាន់អំណាច និងក្រុមគណបក្សប្រឆាំងនៅក្នុងរដ្ឋសភា។
    - គណៈកម្មការនេះត្រូវមាននីតិវិធីជ្រើសរើសដោយបើកចំហ និងជាសាធារណៈដែលអនុញ្ញាតឲ្យបេក្ខជនដាក់ពាក្យឈរឈ្មោះជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ល័ក្ខខ័ណ្ឌចាំបាច់គឺ បេក្ខជនត្រូវលាឈប់ពីមន្ត្រីគណបក្សនយោបាយ បន្ទាប់ពីជាប់ជាសមាជិក គ.ជ.ប និងសន្យាថា មិនក្លាយជាមន្ត្រីគណបក្សនយោបាយរយៈពេល២ឆ្នាំ បន្ទាប់ពីចប់អាណត្តិរបស់ខ្លួន។ គណៈកម្មការជ្រើសរើសមានគោលការណ៍ដែលអនុញ្ញាតឲ្យក្រុមគណបក្សកាន់អំណាច និងក្រុមគណបក្សមិនកាន់អំណាច ចម្រាញ់ជ្រើសរើសបេក្ខជនចំនួន៤រូប យ៉ាងតិចស្ត្រី១រូប ស្មើៗគ្នា។
    - សម្រាប់បេក្ខជនប្រធាន គ.ជ.ប ត្រូវបានស្នើដោយព្រះមហាក្សត្រ

- រដ្ឋសភាផ្តល់ការយល់ព្រមជាកញ្ចប់ដាក់សមាសភាពទាំង៩រូប តាមមតិពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។

- ការជ្រើសរើសសមាជិក និងមន្ត្រីសម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមរួមមាន៖ អគ្គលេខាធិការដ្ឋាន, នាយកដ្ឋាន, គណៈកម្មការខេត្ត រាជធានី, គណៈកម្មការឃុំសង្កាត់ និងការិយាល័យបោះឆ្នោតក៏ត្រូវបានអនុវត្ត តាមលក្ខណៈបើកចំហជាសាធារណៈ និងមានគណៈកម្មការជ្រើសរើសដោយមានសមាសភាពពីតំណាងគ.ជ.ប និងតំណាងគណបក្សមានអាសនៈក្នុងសភា។ ការសំរេចចិត្តចុងក្រោយក្នុងការតែងតាំង គឺគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។

៣. សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែជាមនុស្សអព្យាក្រឹត្យ ដែលមិនមែនមន្ត្រីគណបក្សនយោបាយ ក្នុងនោះត្រូវលាលែងជាមន្ត្រីគណបក្សនយោបាយ មុនក្លាយជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ហើយមិនក្លាយជាមន្ត្រីគណបក្សនយោបាយរយៈពេលពីរឆ្នាំបន្ទាប់ពីចប់អាណត្តិរបស់ខ្លួន។ តំណាងគណបក្សប្រឆាំងនៅក្នុងសភាគួរត្រូវបានឲ្យបញ្ជូនតំណាងមួយរបស់រដ្ឋសភាដើម្បីក្លាយជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។

៤. កែលម្អប្រព័ន្ធផ្សព្វផ្សាយ ពិសេសទូរទស្សន៍ និងវិទ្យុ ដោយមានគោលនយោបាយ និងគោលការណ៍សមធម៌ តុល្យភាព និងសេរីសម្រាប់ការទទួលបានការប្រើប្រាស់ និងការផ្សព្វផ្សាយ៖

បង្កើតក្រុមប្រឹក្សាភិបាលឯករាជ្យ ដែលមានអំណាចចេញអាជ្ញាប័ណ្ណសំរាប់ទូរទស្សន៍ និងវិទ្យុ និងគ្រប់គ្រងទូរទស្សន៍ជាតិ និងវិទ្យុជាតិ ព្រមទាំងត្រួតពិនិត្យការផ្សាយរបស់ទូរទស្សន៍ និងវិទ្យុឯកជន។ ក្រុមប្រឹក្សានេះមានសមាជិកចេញពីព្រះមហាក្សត្រ១រូប, សមាគមអ្នកកាសែត១រូប, ពីសមាជិកគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភាក្រុមគណបក្សប្រឆាំង១រូប និងក្រុមគណបក្សកាន់អំណាច១រូប, រាជរដ្ឋាភិបាល១រូប, សមាគមមេធាវី១រូប និងសភាពាណិជ្ជកម្ម១រូប។ នីតិវិធីនៃការចេញអជ្ញាប័ណ្ណ គឺមានលក្ខណៈតម្លាភាព និង មានការដេញដោយចំហ។

៥. ជាបន្ទាន់រាជរដ្ឋាភិបាលត្រូវចេញអាជ្ញាប័ណ្ណបង្កើតប៉ុស្តិ៍ទូរទស្សន៍ និងវិទ្យុនៅតាមខេត្ត និងរាជធានីឲ្យទៅក្រុមហ៊ុន ឬអង្គការដែលមានការគាំទ្រដោយគណបក្សសង្គ្រោះជាតិ។

៦. កំណែទម្រង់យន្តការដោះស្រាយទំនាស់វិវាទ និងបណ្តឹងបោះឆ្នោតឲ្យឯករាជ្យ រួមមាន ការបង្កើតយន្តការប្រសិទ្ធិភាពមួយសម្រាប់ការអង្កេតពីភាពមិនប្រក្រតី៖

វិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រ ដែលពង្រឹងសមត្ថកិច្ចក្រុមប្រឹក្សាធម្មនុញ្ញ និងបង្កើតនីតិវិធី បទបញ្ជា ទាក់ទងនឹងការដោះស្រាយគ្រប់ករណីនៃវិវាទបោះឆ្នោតដោយបន្ថែមយុត្តាធិការ ការដាក់បញ្ជាឲ្យមានការដាក់ដល់ពិន័យសមាជិក និងមន្ត្រីគណៈកម្មាធិការរៀបចំការបោះឆ្នោគ្រប់លំដាប់ថ្នាក់។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ច និងតួនាទីដូចជាតុលាការកំពូលសម្រាប់ការដោះស្រាយវិវាទបោះឆ្នោត។

៧. ធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដែលមានការបង្កើតគណៈកម្មការពិសេសនៅថ្នាក់ជាតិ និងរាជធានីខេត្ត សម្រាប់ដោះស្រាយវិវាទបោះឆ្នោត និងធ្វើការអង្កេតស្រាវជ្រាវដើម្បីធានាអោយមាននូវភាពយុត្តិធម៌

3

ដល់ភាគីវិវាទ។ គណៈកម្មការនេះមានសមាសពភាពចម្រុះចេញមកពីតំណាងក្រុមប្រឹក្សាធម្មនុញ្ញ និង គ.ជ.ប។

៨. បង្កើតច្បាប់មួយ ដើម្បីតម្លាភាពហិរញ្ញវត្ថុត្រួតពិនិត្យចំណូល និងកំណត់ការចំណាយរបស់គណបក្សនយោបាយ ជាពិសេសការផ្តល់មូលនិធិរបស់រដ្ឋដល់គណបក្សនយោបាយក្នុងដំណើរការឃោសនាបោះឆ្នោត៖

៩. ផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះ និងការបង្កើតបញ្ជីឈ្មោះបោះឆ្នោតថ្មី ដែលអាចកំណត់បានអត្តសញ្ញាណអ្នកបោះឆ្នោតច្បាស់លាស់ និងមានប័ណ្ណបោះឆ្នោត។

- ការចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត គួរតែផ្លាស់ប្តូរទាំងស្រុង ដើម្បីអោយការចុះឈ្មោះបោះឆ្នោតមានភាពងាយស្រួល និងសាមញ្ញ ហើយនឹងធានាគុណភាពនៃបញ្ជីឈ្មោះអ្នកបោះឆ្នោត ពិសេសកំណត់បានអត្តសញ្ញាណអ្នកបោះឆ្នោតច្បាស់លាស់ និងមានចេញប័ណ្ណបោះឆ្នោត។
- គួរធ្វើវិសោធនកម្មលើនីតិវិធីក្នុងការធ្វើអត្តសញ្ញាណបណ្ណសម្រាប់ប្រើបានអស់មួយជីវិត។ ប្រជាពលរដ្ឋត្រូវបានជំរុញអោយប្តូររូបថតរបស់ពួកគាត់ បន្ទាប់ពីបានប្រើប្រាស់អត្តសញ្ញាណបណ្ណ២០ឆ្នាំរួចមក។
- គ.ជ.ប ត្រូវចាត់ចែងការចុះឈ្មោះបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោត ជារៀងរាល់អំឡុងពេលបោះឆ្នោតធម្មតា និងមានចេញប័ណ្ណបោះឆ្នោត។
- គ.ជ.ប សហប្រតិបត្តិការជាមួយក្រសួង ឬស្ថាប័នរដ្ឋ អ្នកជំនាញ និងម្ចាស់ជំនួយកំពុងប្រឹងប្រែងក្នុងការផលិតកម្មវិធី ដើម្បីបង្កើតប្រពន្ធ័ចុះឈ្មោះបោះឆ្នោតដែលមានបញ្ចូលទិន្នន័យអត្តសញ្ញាណជីវសញ្ញា(មេដៃ) លេខអត្តសញ្ញាណប័ណ្ណអចិន្ត្រៃយ៍មួយ និងរូបថតផ្ទាល់ខ្លួន។
- ក្នុងករណីបន្ទាន់ ពិសេសការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ បន្ទាប់ពីរំលាយរដ្ឋសភាមុនអាណត្តិ គ.ជ.បត្រូវរៀបចំធ្វើបញ្ជីឈ្មោះអ្នកបោះឆ្នោតពិសេស ដាច់ដោយឡែកសំរាប់អ្នកមានសិទ្ធិបោះឆ្នោតថ្មីៗ ដោយប្រើទិន្នន័យអត្តសញ្ញាប័ណ្ណ និងអត្រានុកូលដ្ឋាន។ បញ្ជីឈ្មោះអ្នកបោះឆ្នោតដាច់ដោយឡែកត្រូវបានបិទ ហើយបើកឲ្យមានការប្តឹងតវ៉ា និងជំទាស់។

១០. ពង្រឹងការអនុវត្តន៍ច្បាប់ឲ្យបានពេញលេញអំពីភាពអព្យាក្រិត្យ មិនលម្អៀងដាច់ខាតសម្រាប់ទាំងស្ថាប័ន និងមន្ត្រីនៃកងយុទ្ធពលខេមរភូមិន្ទ នគរបាល និងមន្ត្រីតុលាការក្នុងការធ្វើសកម្មភាពគាំទ្រ និងប្រឆាំងគណបក្សណាមួយ។

បង្កើតគោលនយោបាយពិសេស ឬអនុក្រឹត្យមួយដើម្បីពង្រឹងអព្យាក្រឹត្យភាពរបស់កងយោធពលខេមរភូមិន្ទ មន្ត្រីតុលាការ និងកងកម្លាំងនគរបាលជាតិ និងការអនុវត្តន៍មាត្រា ១៥ នៃច្បាប់ស្តីពីគណបក្សនយោបាយ។ មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិអាចចូលរួមជាសមាជិកគណបក្សនយោបាយនានាបាន តែមិនមែនជាមន្ត្រីគណបក្សនយោបាយហើយក៏

មិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ។ មន្ត្រីដូចបានរៀបរាប់ខាងលើអាចចូលរួមស្តាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់បាន ប៉ុន្តែមិនត្រូវពាក់អាវ និងមួកនៃគណបក្សនយោបាយ ឬបេក្ខជននោះបានទេ។ ហើយកងយោធពលខេមរភូមិន្ទ នគរបាលមានតួនាទីសំខាន់ផ្ទាល់រក្សាសន្តិសុខក្នុងដំណើរការបោះឆ្នោត ហើយមន្ត្រីតុលាការក៏នឹងចូលរួមផ្ទាល់ក្នុងការងារបណ្តឹងទាក់ទិនការបោះឆ្នោត។

១១. មានច្បាប់ ឬ/និងគោលនយោបាយដើម្បីកំណត់កូតាស្ត្រីជាតំណាងជាប់ឆ្នោត។

ធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដោយកំណត់ចំនួនកូតាស្ត្រី ឬបុរស៥០% ជាលក្ខខណ្ឌសំរាប់ចុះបញ្ជីឈ្មោះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ហើយដាក់ក្នុងបញ្ជីលេខរៀងឆ្លាស់គ្នារាប់ពីខាងលើ។

១២. បោះឆ្នោតជ្រើសរើសមេភូមិ

ការបោះឆ្នោតផ្ទាល់ជ្រើសរើសមេភូមិដោយប្រជាពលរដ្ឋក្នុងភូមិ ដោយមាននីតិវិធីសាមញ្ញមួយក្នុងការចាត់ចែងពីក្រុមប្រឹក្សាឃុំសង្កាត់ និងប្រជាពលរដ្ឋក្នុងភូមិ។

១៣. កែទម្រង់ប្រព័ន្ធ និងដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងក្រុមប្រឹក្សារាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ

ប្រព័ន្ធការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាការបោះឆ្នោតជាសកល និងមានដំណើរការក្នុងអំឡុងពេលតែមួយនឹងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដោយគ្រាន់តែរៀបចំសន្លឹកឆ្នោតផ្សេងគ្នា។

១៤. ប្រព័ន្ធបោះឆ្នោតសកលសម្រាប់ជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាប្រព័ន្ធចម្រុះ។ ប្រព័ន្ធនេះអនុញ្ញាតឲ្យបេក្ខជន ឬក្រុមបេក្ខជនឯករាជ្យ ជាមួយនឹងបញ្ជីគណបក្សនយោបាយ។

## គ. កំណែទម្រង់ស្ថាប័ន

១៥. តុលាការ មានច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់តុលាការ, ច្បាប់ស្តីពីលក្ខន្តិកៈនៃអង្គចៅក្រម និងព្រះរាជអាជ្ញា និងវិសោធនកម្មច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានអង្គចៅក្រមដែលធានាអំពីឯករាជ្យ និងអព្យាក្រឹត្យពីគណបក្សនយោបាយ និងរាជរដ្ឋាភិបាល។

១៦. ធ្វើវិសោធនកម្មច្បាប់ប្រឆាំងអំពើពុករលួយ ដែលកែលំអសមាសភាពគណៈកម្មាធិការជាតិប្រឆាំងអំពើពុករលួយឲ្យឯករាជ្យពីរាជរដ្ឋាភិបាល ដែលមានការព្រមព្រៀងគ្នាគណបក្សនយោបាយដែលមានអាសន្នក្នុងរដ្ឋសភា។

- គណៈកម្មាធិការនេះត្រូវតែជាស្ថាប័នរដ្ឋធម្មនុញ្ញ។
- បើកចំហជាសាធារណៈអំពីការប្រកាសទ្រព្យសម្បត្តិរបស់សមាជិករាជរដ្ឋាភិបាល។
- កំណត់ចំនួនទឹកប្រាក់ចំណាយដល់សមាជិករាជរដ្ឋាភិបាល។

5

- ត្រូវតែកំណត់ឲ្យមាន វិធានទាំងឡាយក្នុងច្បាប់ដើម្បីការពារសាក្សី និងអ្នករាយការណ៍អំពីអំពើពុករលួយ។
- ប្រធានអង្គភាពប្រឆាំងអំពើពុករលួយត្រូវប្រកាសជ្រើសរើសជាសាធារណៈដោយគណៈកម្មាធិការជាតិប្រឆាំងអំពើពុករលួយ។

១៧. បង្កើតគណៈកម្មាធិការសិទ្ធិមនុស្សឯករាជ្យ ស្របតាមគោលការណ៍ទីក្រុងប៉ារីស។

១៨. សមាសភាពសវនកម្មជាតិអព្យាក្រឹត និងឯករាជ្យដោយត្រូវសុំការយល់ព្រមពីរដ្ឋសភា។

១៩. ពង្រឹងការអនុវត្តន៍ច្បាប់ឧត្តមក្រុមប្រឹក្សាការពារជាតិ ពិសេសការតែងតាំងអគ្គមេបញ្ជាការ (កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ) ត្រូវសុំការយល់ព្រមពីរដ្ឋសភា ។

## II. **ពង្រឹងការត្រួតពិនិត្យអំណាចគ្នារវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំងក្នុងសភា និងរវាងរាជរដ្ឋាភិបាល និងសភា**

២០. មាននីតិវិធីដូចជម្រើសខាងក្រោមក្នុងការបែងចែកការដឹកនាំគណៈកម្មការជំនាញសភាទាំង៩ ដែលក្នុងនោះមានជំរើសពីរសំរាប់ក្រុមគណបក្សកាន់អំណាច(បច្ចុប្បន្នគឺគណបក្សប្រជាជនកម្ពុជា) និងក្រុមគណបក្សមិនកាន់អំណាច(បច្ចុប្បន្នគឺគណបក្សសង្គ្រោះជាតិ)។

ជំរើសទី១៖ គណបក្សសង្គ្រោះជាតិត្រូវធ្វើជាប្រធានរដ្ឋសភា, អនុប្រធានរដ្ឋសភាទាំងពីរត្រូវធ្វើដោយគណបក្សប្រជាជនកម្ពុជា ចំណែកគណបក្សសង្គ្រោះជាតិត្រូវគ្រប់គ្រង/ជាប្រធានទាំង៤គណៈកម្មការជំនាញ រីឯគណបក្សប្រជាជនកម្ពុជាគ្រប់គ្រង/ជាប្រធានទាំង៥គណៈកម្មាការជំនាញ។ ផ្ទុយមកវិញ

ជំរើសទី២៖ គណបក្សប្រជាជនកម្ពុជាត្រូវធ្វើជាប្រធានរដ្ឋសភា, អនុប្រធានរដ្ឋសភាទាំងពីរត្រូវធ្វើដោយគណបក្សសង្គ្រោះជាតិ ចំណែកគណបក្សប្រជាជនកម្ពុជាត្រូវគ្រប់គ្រង/ជាប្រធានចំនួន៤គណៈកម្មាការជំនាញ រីឯគណបក្សសង្គ្រោះជាតិត្រូវគ្រប់គ្រង/ជាប្រធានទាំង៥គណៈកម្មាការជំនាញ។

២១. ការបង្កើតក្រុមឡើងបញ្ចេញមតិក្នុងសម័យប្រជុំពេញអង្គ៖ ធ្វើវិសោធនកម្មប្រការ៤៨ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ដោយអនុញ្ញាតឲ្យគណបក្សដែលទទួលបានអាសនៈតិចជាង១០ អាចបង្កើតក្រុមបញ្ចេញមតិរបស់ខ្លួនបាន១ក្រុម។

២២. តម្លាភាព និងការចូលរួមពីម្ចាស់ឆ្នោតនៅក្នុងគណៈកម្មការជំនាញរដ្ឋសភា៖ រដ្ឋសភាត្រូវបើកទូលាយឲ្យមានការចូលរួមសង្កេតការរាល់ការពិភាក្សាសេចក្តីព្រាងច្បាប់/ស្នើច្បាប់នៅក្នុងគណៈកម្មការជំនាញរដ្ឋសភា ដើម្បីបង្កើនការចូលរួមរបស់ម្ចាស់ឆ្នោតទៅលើសេចក្តីព្រាងច្បាប់ និងតម្លាភាពក្នុងការពិភាក្សា។

២៣. ក្នុងនីតិកាលទី៥ នៃរដ្ឋសភា នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលនឹងត្រូវមកឆ្លើយឆ្លងយ៉ាងសកម្មជាមួយតំណាងរាស្ត្រ ស្របតាមបទបញ្ញត្តិ ដូចមានចែងនៅក្នុងមាត្រាទី៩៦ ជំពូកទី៧ មាត្រាទី១២១ថ្មី ជំពូកទី១០ នៃរដ្ឋធម្មនុញ្ញ និងមាត្រាទី១ ទី២ និងទី៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។ ការមិនគោរព និងមិនអនុវត្តតាមមាត្រាខាងលើ សមាជិកសភានឹងធ្វើញ្ញត្តិស្តី

បន្ទោស។ បើលើសបីដង សមាជិកសភានឹងធ្វើញត្តិដកការទុកចិត្តលើនាយករដ្ឋមន្ត្រី ឬសមាជិករាជរដ្ឋាភិបាល។ ហើយបើនៅបន្តមិនគោរព និងមិនអនុវត្តលើសពីប្រាំដង សមាជិកសភានឹងធ្វើញត្តិដកការទុកចិត្តទៅលើរាជរដ្ឋាភិបាល ឬគណៈរដ្ឋមន្ត្រី។

**III. យន្តការដឹកនាំ និងត្រួតពិនិត្យអំពីការអនុវត្តន៍កិច្ចសន្យានយោបាយអំពីកំណែទម្រង់**

២៤. បង្កើតគណៈកម្មការសភាចំរុះ ឬក្រុមប្រឹក្សាមួយ ស្ដីពីកំណែទម្រង់ដែលមានសមាសភាពមកពីសមាជិកសភាគណបក្សប្រជាជនកម្ពុជា៩រូប និងគណបក្សសង្គ្រោះជាតិ៩រូប (ក្នុងនោះសមាជិកសភាម្នាក់របស់គណបក្សមកពីគណៈកម្មការបច្ចេកទេសរដ្ឋសភាមួយ) ដើម្បីដឹកនាំ និងត្រួតពិនិត្យមើលការអនុវត្តកំណែទម្រង់ (កិច្ចព្រមព្រៀងនយោបាយ)។ មានប្រធានផ្លាស់វេន(មួយត្រីមាសម្ដងរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ)។

គណៈកម្មការសភាចំរុះ ឬក្រុមប្រឹក្សាស្ដីពីកំណែទម្រង់មានសិទ្ធិសម្រេចលើយុត្តិសាស្ត្រ និងអំពីផែនការកំណែទម្រង់ ព្រមទាំងរៀបចំកិច្ចប្រជុំសាធារណៈដែលកោះហៅរាជរដ្ឋាភិបាលរៀងរាល់មួយខែម្ដងដើម្បីរាយការណ៍អំពីការអនុវត្តនៃកំណែទម្រង់។ អ្នកជំនាញការ និងតំណាងអង្គការសង្គមស៊ីវិលត្រូវបានអញ្ជើញដើម្បីចូលរួមសង្កេតការណ៍ និងផ្ដល់របាយការណ៍ឯករាជ្យនៃការវាយតម្លៃលើការអនុវត្តន៍កំណែទម្រង់ផងដែរ។

**<u>ព័ត៌មានបន្ថែមសូមទាក់ទង៖</u>**

| | | |
|---|---|---|
| ១. លោក ធន សារាយ | ប្រធាននៃសមាគមអាដហុក&ខុមហ្វ្រែល | ០១៦ ៤៤ ០០ ៤៤ |
| ២. លោកស្រី ធីតា យ៉ឺះ | នាយិកាអង្គការសីលការ | ០១២ ៨៣ ៨៤ ៦៤ |
| ៣. លោកស្រី រស់ សុភាព | នាយិកាអង្គការGADC | ០១២ ៦២ ៧៨ ៥៧ |
| ៤. លោក សុក សំអឿន | ប្រធានសម្របសម្រួលនៃCHRAC | ០១២ ៩០ ១១ ៩៩ |
| ៥. លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិច | ០១២ ៩៥ ៩៦ ៦៦ |
| ៦. លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | ០១២ ៨០ ១២ ៣៥ |
| ៧. លោក ឈិត សំអាត | នាយកប្រតិបត្តិ NGO Forum | ០១២ ៩២ ៨៥ ៨៥ |
| ៨. លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិ CCIM | ០៦០ ៤០ ៩៩ ៩៩ |
| ៩. លោក អ៊ូ វីរៈ | ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | ០១២ ៤០ ៤០ ៥១ |
| ១០. លោក យង់ គិមអេង | ប្រធាន PDP-Center | ០១៦ ៨២ ៨២ ១១ |
| ១១. លោក ព្រាប កុល | នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា | ០១២ ៨៧ ៧៨ ៣៣ |
| ១២. លោក ម៉ាក់ ចំរើន | ប្រធានសមាគមយុវជនខ្មែរ | ០១៧ ៧៨ ៨៩ ៥៥ |
| ១៣. លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| ១៤. លោក សុខ ពិទូរ្យ | នាយកប្រតិបត្តិក្រុមប្រឹក្សាយុវជនកម្ពុជា | ០១៧ ២៧ ៣៣ ០៣ |
| ១៥. លោក សឿង សារឿន | នាយកប្រតិបត្តិអង្គការCCC | ០១៦ ៩០ ០៥ ០៣ |
| ១៦. លោក សួន ប៊ុនស័ក្តិ | អគ្គលេខាធិការCHRAC | ០១២ ៣៤ ៤៣ ៥៧ |

| | | |
|---|---|---|
| ១៧. លោក គាន ពន្លក | នាយកប្រតិបត្តិរងនៃDHRAC | ០១២ ៥៥ ១៤ ៦៦ |
| ១៨. លោក សាម អ៊ីន | នាយកប្រតិបត្តិនៃLWD | ០១២ ៥៥ ១៨ ៨៦ |
| ១៩. លោក ហ៊ឹម យន់ | អ្នកសម្របសម្រួលអង្គការCISA | ០១២ ៩៤ ៧០ ២២ |
| ២០. លោក ណែប ស៊ិនថៃ | នាយកAPI | ០១២ ៥២ ៧០ ០៤ |
| ២១. លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការCOMFREL | ០១២ ៩៤ ២០ ១៧ |

8

# ឧបត្ថម្ភដោយ

forum syd

NORWEGIAN PEOPLE'S AID

Oxfam Novib

OPEN SOCIETY FOUNDATIONS

សេចក្តីអធិប្បាយនៅក្នុងរបាយការណ៍នេះ ជាការទទួលខុសត្រូវទាំងស្រុងរបស់អង្គការខុមហ្វ្រែល ហើយមិនអាចយកទៅប្រើប្រាស់ក្នុងរូបភាពណាមួយ ដើម្បីឆ្លុះបញ្ជាំងពីទស្សនៈរបស់ម្ចាស់ជំនួយឡើយ ។


ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា**

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ ទឹកល្អក់១ ទួលគោក ភ្នំពេញ ប្រអប់សំបុត្រលេខ ១១៤៥

ទូរស័ព្ទ ០២៣ ៨៨៤ ១៥០ ទូរសារ ០២៣ ៨៨៥ ៧៤៥

អ៊ីម៉ែល: comfrel@comfrel.org, comfrel@online.com.kh

គេហទំព័រ: www.comfrel.org